# គោលព្រះវិន័យ

## ព្រះអភិធម្ម និងគោលធម៌ផ្សេងៗ

សម្រាប់សមណសិស្សថ្នាក់មត្តេយ្យ ទី១ ទី២ ទី៣ ឆ្នាំ២០១៦

**កម្មវិធីសិក្សារបស់សាលាពុទ្ធិកបឋមសិក្សាវត្តស្វាយដង្គំ ខេត្តបាត់ដំបង**




រៀបរៀងដោយ

លោកម្ចាស់គ្រូ

បិយវិនយោ ស៊ាក់ ស៊ីន




# អារម្ភកថា

បុព្វហេតុដែលនាំឱ្យខ្ញុំព្រះករុណារៀបចំសៀវភៅនេះឡើងគឺក្នុងគោលបំណងដើម្បីជួយសម្រួលដល់ព្រះសង្ឃឬសមណសិស្ស ជាអ្នកប្រាថ្នានូវការសិក្សាព្រះវិន័យដើម្បីងាយស្រួលដល់ការចង់ចាំ និងការរំលឹកនូវអ្វីដែលបានសិក្សារួចហើយ សៀវភៅគោលព្រះវិន័យនេះមានគោលសំខាន់ៗ ជាច្រើនដែលសិក្សាហើយ អាចយកទៅប្រតិបត្តិ ក្នុងការប្រព្រឹត្តនូវព្រហ្មចរិយធម៌ប្រចាំថ្ងៃ មានជាកងៗសម្រាប់សូត្រ តាមកម្រិតអ្នកសិក្សា។

មួយវិញទៀតដោយគិតឃើញថាសៀវភៅនេះនឹងបានជាប្រយោជន៍ដ៏ច្រើន ដល់សមណសិស្សដែលសិក្សានៅសាលាពុទ្ធិកៈ ក៏ដូចជាព្រះសង្ឃទូទៅ ដែលបួសក្នុងសាសនាព្រះដ៏មានព្រះភាគ ជំនួយដល់ការស្រាយជ្រាវ និងការចងចាំមិនងាយភ្លេច ដើម្បីឱ្យអ្នកបួសមានការយល់ដឹង ពីកិច្ចបដិបត្តិ និងសម្រេចបាននូវចរិយាសម្បត្តិនិងមារយាទដ៏ថ្លៃថ្នូរ ដឹងតួនាទីហើយប្រព្រឹត្តខ្លួនឱ្យសមជាសមណៈល្អ វៀរចាកនូវទង្វើរអាក្រក់ខុសឆ្គាំឆ្គង ដែលជាហេតុនាំឱ្យសប្បុរសទាំងឡាយតិះដៀល ដើម្បីរក្សានូវព្រះពុទ្ធសាសនាឱ្យឋិតថេរបានយូរអង្វែង សមដូចព្រះពុទ្ធដីកាបានត្រាស់ថា **វិនយោ សាសនស្ស មូលំ** វិន័យជាឫសគល់របស់ព្រះពុទ្ធសានា **វិនយោ នាម សាសនស្ស អាយុ** វិន័យជាអាយុរបស់ព្រះពុទ្ធសាសនា។

ជាចុងក្រោយនេះខ្ញុំព្រះករុណាសូមរំលឹកដឹងគុណដល់អ្នកមានគុណទាំងឡាយមានអ្នកមានគុណទាំងពីរ ជាពិសេសញោមស្រីដែលចិញ្ចឹមបីបាច់ថែរក្សាអាត្មាភាពតាំងតូចមក ទោះបីញោមប្រុសស្លាប់តាំងពីកូនអាយុ៥ឆ្នាំក្តីក៏ម៉ែបានមើលថែរក្សាបានយ៉ាងល្អ ប្រកបដោយភាពកក់ក្តៅបំផុតរហូតបាន

ផ្តល់ឱកាសឱ្យកូនបានបួសក្នុងព្រះពុទ្ធសាសនា។សូមរំលឹកគុណដល់លោកគ្រូអ្នកគ្រូទាំងឡាយ មានលោកម្ចាស់គ្រូ**វិរិមុនីវង្សា ពៅ មុនី** ជាដើម ដែលបានចំណាយកម្លាំងកាយចិត្ត ជាច្រើនឆ្នាំក្នុងការបង្ហាត់បង្រៀន ដោយគ្មានខ្លាចនឿយហត់ ហើយតែងតែអប់រំទូន្មានក្រើនរំលឹកប្រដៅណែនាំ ប្រាប់នូវទោសកំហុសទាំងឡាយ លើកលែងអនុគ្រោះ និងគាំទ្រលើកទឹកចិត្តមិនថាកាលៈទេសៈណាក៏ដោយ។ សូមអរគុណដល់សមណមិត្តមិត្តទាំងឡាយដែល តែងតែស្រឡាញ់រាប់អានជួយគាំទ្រ លើកទឹកចិត្តក្រើនរំលឹកកន្លងមក។

ដោយអំណាចនាំមហាកុលសនេះសូមកុំឱ្យខ្ញុំភ្លាត់ធ្វើនូវអនន្តរិយកម្ម៥ សូមបានជួបតែសប្បុរសកណ្យាណមិត្តជាសម្មាទិដ្ឋ និងប្រគេនជូនដល់អ្នកមានគុណទាំងឡាយ មានមាតាបិតាលោកគ្រូអ្នកគ្រូ និងមិត្តទាំងឡាយ សូមត្រេកអររីករាយនូវកុសលធម៌នេះ និងសូមឱ្យបានជាឧបនិស្ស័យ ជាបច្ច័យនៃការរួចទុក្ខ កុំបីក្លាជាបការៈដទៃឡើយ។

វត្តស្វាយដង្គំ ខេត្តបាត់ដំបង
ថ្ងៃទី៥ឧសភា ឆ្នាំ២០១៦



**ស៊ាក់ ស៊ីន**

# សៀវភៅព្រះវិន័យ

## បោះពុម្ពលើកទី៧ សម្រាប់ជាធម្មទាន



ដោយអំណាចមហាកុសលនេះ សូមបានជាបច្ច័យនៃការរួចចាកទុក្ខទាំងពួង សូមអនុមោទនាបុណ្យ!

## មាតិកា


អារម្ភកថា.............................................. 2

មាតិកា.............................................. 5

បួសរៀនទើបមានតម្លៃ .............................................. 9

ព្រះវិន័យសូត្រថ្នាក់មត្តេយ្យ

សិក្ខាបទ ១០ .............................................. 10

ទណ្ឌកម្ម១០.............................................. 12

នាសនង្គ:១០.............................................. 13

អង្គនៃសិក្ខាបទ១០ .............................................. 14

ព្រះអង្គបញ្ញត្តិទណ្ឌកម្ម១០ ដល់សាមណេរ.............................................. 18

ព្រះអង្គបញ្ញត្តិ នាសនង្គ: ១០ ដល់សាមណេរ.............................................. 18

សិក្ខាបទ ១០ របស់សាមណេរ.............................................. 19

វិន័យថ្នាក់មូលដ្ឋាន

សិក្ខា .............................................. 28

សិក្ខាបទះ .............................................. 28

អនុញ្ញាត .............................................. 28

អតិសមាចារ.............................................. 28

អាបត្តិមាន៧កង .............................................. 28

អាបត្តិ.............................................. 28

បារាជិក .............................................. 28

សង្ឃាទិសេសះ.............................................. 28

ថុល្លច្ច័យះ .............................................. 29

បាចិត្តិយះ .............................................. 29

ទុក្កដ.............................................. 29

ទុព្ភាសិត .............................................. 29

អនុសាសនៈ................................................. 29
និស្ស័យ ៤ ................................................. 29
អករណីយកិច្ច ៤ ................................................. 29
ត្រៃសិក្ខា ................................................. 30
ចរិយាវត្ត ................................................. 30
សមណៈ ប្រែថា អ្នកមានព្យាយាមដុតកម្តៅបាប ................................................. 30
លក្ខណៈរបស់សមណៈក្នុងការបដិបត្តិមាន៤យ៉ាងគឺ ................................................. 31
ទិសដៅរបស់សមណៈមាន៥ ................................................. 31
ធម៌ជាមន្ទិល ៩ យ៉ាង................................................. 32
ព្រះពុទ្ធទ្រង់ត្រាស់ថា................................................. 32
អ្នកបួសត្រូវមានធម៌៥យ៉ាងគឺ................................................. 32
ជំនួញខុស ៥ យ៉ាងដែលមិនគួរប្រព្រឹត្តិ................................................. 32

លោកវជ្ជសិក្ខាបទ៤៩ /34

សង្ឃាទិសេស១៣ /50

ព្រះសូត្រមាន ៥គម្ពីរគឺ(ទី.ម.សំ.អំ.ខុ.) ................................................. 79
ព្រះអភិធម្មមាន ៧ គម្ពីរគឺ................................................. 80
បរិក្ខារ ៨ យ៉ាងរបស់ភិក្ខុ ................................................. 80
ចីវរ ២យ៉ាង................................................. 80
ពណ៌ពិន្ទុចីវរ៣យ៉ាង ................................................. 81
នាសនង្គៈ ៣យ៉ាង................................................. 81
បាលី អធិដ្ឋានត្រៃចីវរ ................................................. 81
បាលី ដកអធិដ្ឋាន ................................................. 81
អន្តេវាសិករបស់អាចារ្យ៥យ៉ាង................................................. 81
សង្ឃ មាន៥ពួក................................................. 82
អបលោកនកម្ម មានស្ថាន៥យ៉ាង ................................................. 82
ញត្តិកម្ម មានស្ថាន៩យ៉ាង ................................................. 83
ញត្តិទុតិយកម្ម មានស្ថាន៧យ៉ាង................................................. 83

ញត្តិចតុត្ថកម្ម  មានស្ថាន៧យ៉ាង ........................................ 83
រតនជាអនាមាស  មាន១០យ៉ាង ........................................ 84
វត្ថុនិស្សគ្គិយមាន៤យ៉ាង ........................................ 84
វត្ថុជានិស្សគ្គិយ  ក្នុងខណៈអរុណរះឡើងមាន៧យ៉ាង........................ 85
អាបត្តិចែកដោយកិរិយាមាន៥យ៉ាង ........................................ 85
បទេសប្បញ្ញត្តិ  មាន៤យ៉ាង ........................................ 86
បញ្ញត្តិ  មាន៩យ៉ាង ........................................ 86
អន្តេវាសិករបស់អាចារ្យ៥យ៉ាង........................................ 86
ភិក្ខុជាសិស្សត្រូវគោរពអាចារ្យ៥យ៉ាង ........................................ 87
បុព្វករណរបស់ឧបោសថមាន៤យ៉ាង........................................ 87
បុព្វកិច្ច របស់ឧបោសថមាន៥យ៉ាង ........................................ 87
បត្តកល្លៈរបស់ឧបោសថមាន៤យ៉ាង ........................................ 87
សីមាមាន២យ៉ាង ........................................ 88
ពទ្ធសីមា មាន៣យ៉ាង ........................................ 88
អពទ្ធសីមា មាន៣យ៉ាង ........................................ 88
និមិត្តសីមា  មាន៨យ៉ាង........................................ 88
សីមាសម្បត្តិ  មាន៣យ៉ាង........................................ 89
សីមាវិបត្តិ  មាន១១យ៉ាង ........................................ 89
ភិក្ខុមិនត្រូវអាស្រ័យនៅនឹងភិក្ខុ ដែលប្រកបដោយអង្គ៣យ៉ាង ........................ 90
បុព្វករណៈ  របស់កឋិនមាន៧យ៉ាង........................................ 90
កឋិនដោះដោយមាតិកា៨យ៉ាង........................................ 90
សេនាសនៈ៥យ៉ាង ........................................ 91
គ្រែមាន៤យ៉ាង........................................ 91
កៅអី  ៤ យ៉ាង ........................................ 91
សុរា៥យ៉ាង ........................................ 92
មេរ័យ៥យ៉ាង ........................................ 92
បញ្ចអាទីនវាកុលូបកេ ភិក្ខុអ្នកទៅកាន់ត្រកូលតែងមានទោស៥យ៉ាង ........................ 92

អនតិរិត្តភោជន ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្មដោយអាការៈ៧យ៉ាង................ 93
ប្រធាននៃសមុដ្ឋាន អាបត្តិមាន១៣យ៉ាង ........................................................ 93
ភិក្ខុជាមហាចោរដោយអាការ: ៥យ៉ាង............................................................. 94
៣.ទស្សបនាយកិក្ខុនក:....................................................................... 96

## ប្រជុំកងធម៌

បកិណ្ណកៈ ពួកធម៌រាយរង.......................................................... 131
គោលព្រះធម៌ផ្សេងៗ ............................................................ 140
ព្រះអភិធម្ម..................................................................... 164
ចេតសិក ៥២ ដួង............................................................. 164
ចេតសិកបរមត្ថ................................................................. 176
និព្វានបរមត្ថ.................................................................. 180
ឯកទត្ថបាលីប្រែ .............................................................. 181

## ផ្នែកធម៌បទ សម្រាប់ស្មូត្រ

អាសាឡ្ហបូជា(ប្រារព្ធហេតុ៥យ៉ាង) ...................................... 200
គោតមប្របទត្តិ(បុរាណ).................................................... 204
ខ្ញុំនឹកព្រះណាស់ ............................................................ 205
ទ្រង់ដាក់អាយុសង្ខារ-បរិនិព្វាន ............................................ 208
សម្រស់ទេវឡុង់ន មហាវិហារ................................................ 210
ឋានត្រៃរតនៈ.................................................................. 211
បារមី ៣០ ..................................................................... 212
ពុទ្ធកិច្ច ៥ យ៉ាង ............................................................. 226
រក្សាព្រះត្រៃបិដក............................................................ 227
សុខាភិយាចនគាថា........................................................... 231

# បួសរៀនទើបមានតម្លៃ

*និពន្ធដោយ: លោកគ្រូបិយវិនយោ ស៊ាក់ ស៊ីន*
*វត្តស្វាយដង្គុំខេត្តបាត់ដំបង ៣០/០៤/២០២១*

- បួសហើយមិនរៀនបួសខ្ជិលសិក្សា បួសយូរយ៉ាងណាក៏នៅតែល្ងង់
  បើផ្លូវជាបួសកុំឲ្យលិចលង់ ព្រោះតែក្តីល្ងង់នាំលង់លុះក្ស័យ។
- បួសហើយមិនរៀននាំខូចសាសនា បួសឥតបានការឥតមានតម្លៃ
  បួសមិនបដិបត្តិនាំឲ្យចង្រៃ ទោះបួសលុះក្ស័យក៏ឥតប្រយោជន៍។
- ទោះក្មេងឬចាស់បួសប្រឹងរៀនទៅ បួសដឹងខុសត្រូវទើបមានប្រយោជន៍
  បួសហើយខ្លាចបាបឈ្មោះមិនអាសោច មិនត្រូវបួសខូចក្បត់ពុទ្ធដីកា។
- បួសហើយមិនរៀននាំខូចសាសនា ប្រព្រឹត្តធម៌អាទិ៍ខុសវាចាព្រះ
  បើបានបួសយូរកុំឡើងមានះ ទន់ខ្លួនសំពះគ្រូបាអាចារ្យ។
- បួសវ័យនៅក្មេងពិតជាល្អណាស់ បួសយល់ឱ្យច្បាស់ព្រោះបានសិក្សា
  កុំក្មេងតែវ័យតែខ្ជិលសិក្ខា កុំនាំអាត្មាទៅកាន់អបាយ។
- បួសហើយភ្លេចខ្លួនព្រោះចង់បានសុខ ចង់បានស្រណុកមិនខ្លាចអន្តរាយ
  រឿងធម៌វិន័យបំពានសប្បាយ ដេកស៊ីលូយឆាយឥតមានខ្លាចបាប។
- បួសហើយមិនរៀនធ្វើខុសមិនដឹង ល្ងង់ហើយរឹងត្អឹងខឹងមិនខ្លាចបាប
  ចិត្តនៅលោភលន់ជាគ្រឿងឆ្អេះឆ្អាប បួសគួរខ្លាចបាបគួរប្រឹងសិក្សា។
- បព្វជិតទាំងឡាយបួសហើយគួរគិត គួរប្រឹងប្រព្រឹត្តខ្វល់នឹងសិក្ខា
  វិន័យទាំងឡាយដែលព្រះទេសនា ដែលជាកិច្ចរបស់អ្នកបួស។
- បួសរៀនចេះដឹងទើបបដិបត្តិត្រូវ ត្រូវនាំខ្លួនទៅឱ្យឆ្ងាយពីជ្រោះ
  ឱ្យផុតពីបាបជាកិច្ចអ្នកបួស ចេះដឹងសង្គ្រោះបរិស័ទទាំងឡាយ។
- នរកស៊ីភ្លើងធ្វើជាអាហារ ជនគ្រប់រូបាគួរតែនឿយណាយ
  គួរសាងកុសលលាងបាបទាំងឡាយ ឱ្យផុតអបាយសប្បាយនឹងធម៌។
- បព្វជិតទាំងឡាយគួរខ្វល់ខ្វាយគិត ដឹងការប្រព្រឹត្តអ្វីគួរមិនគួរ
  ធ្វើចិត្តឱ្យមាំកុំឱ្យញាប់ញ័រ ពាល់ត្រូវលោកធម៌កុំខឹងនាំខុស។
- ត្រូវប្រឹងធ្វើខ្លួនឱ្យល្អត្រឹមត្រូវ គួរឈប់ខ្លះទៅរឿងចាប់កំហុស
  ទោះយើងឬគេសុទ្ធតែធ្លាប់ខុស បើឃើញគេខុសគួរមានមេត្តា។
- សរុបមកវិញបួសហើយត្រូវរៀន អប់រំទូន្មានបួសត្រូវឧស្សាហ៍
  កុំយូរតែបួសតែអស់ខ្លឹមសារ ល្ងង់គ្មានបញ្ញាព្រោះបួសមិនរៀន។

# ព្រះវិន័យសូត្រថ្នាក់មត្តេយ្យ

## សិក្ខាបទ ១០

*(បិដកលេខ ៦ ទំព័រទី២៧៧)*

*អដ្ឋកថាពន្យល់ សារត្ថទីបនីសារត្ថទីបនី សាមន្តប្បាសាទិកា ភាគ ៥ ទំព័រ ១៥៧*

**១.បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វ មាន ឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ។

**២.អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុ ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា។

**៣.អព្រហ្មចរិយា វេរមណី** ចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តនូវធម៌ មិនប្រសើរ គឺសេពនូវមេថុនធម្ម។

**៤.មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលពាក្យកុហក។

**៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** ចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានឹងមេរ័យ

**៦.វិកាលភោជនា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា បរិភោគនូវភោជនាហារ ក្នុងកាលខុស។

**៧.នច្ចគីតវាទិតវិសូកទស្សនា វេរមណី**ចេតនាជាហេតុវៀរចាកកិរិយា រាំច្រៀងប្រគំនិងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌

**៨.មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានាវេរមណី** ចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ប្រដាប់និងការតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ។

**៩.ឧច្ចាសយនមហាសយនាវេរមណី** ចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ។

**១០.ជាតរូបរជតប្បដិគ្គហណា ទោរមណី** ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យទទួលកាន់យក ឬត្រេកអរចំពោះមាស និងប្រាក់នោះ។

**សុភាសិត**

រៀនហើយមិនរំឭកស្មើនឹងទទេ
អ្នករៀនយើងគេត្រូវតែឧស្សាហ៍
កុំខ្ជិលរៀនសូត្រគេចពីសាលា
បើខ្វះបញ្ញាបញ្ហាឥតស្រាក៕

## ទណ្ឌកម្ម១០

(បិដកលេខ៦ ទំព័រទី២៧៨)

អដ្ឋកថាពន្យល់ សាមន្តប្បាសាទិកា ភាគ៥ ទំព័រទី១៥៧

**១.វិកាលភោជី ហោតិ** សាមណេរបរិភោគនូវភោជនាហារក្នុងកាលខុស

**២.នច្ចាទិវិសូកទស្សនោ ហោតិ** សាមណេររាំច្រៀងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌

**៣.មាលាទិធារណាទិកោ ហោតិ** សាមណេរទ្រទ្រង់ប្រដាប់ និងតាក់តែង ទ្រទ្រង់រាងកាយដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ

**៤.ឧច្ចាសយនាទិកោ ហោតិ** សាមណេរដេកឬអង្គុយ លើទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ

**៥.ជាតរូបរជតប្បដិគ្គណ្ហកោ ហោតិ** សាមណេរទទួលកាន់ យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យទទួលកាន់យក ឬត្រេកអរចំពោះមាស និងប្រាក់នោះ

**៦.ភិក្ខូនំ អលាភាយ បរិសក្កតិ** សាមណេរព្យាយាម ដើម្បីនឹងឱ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ

**៧.ភិក្ខូនំ អនត្ថាយ បរិសក្កតិ** សាមណេរព្យាយាម ដើម្បីមិនឱ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ

**៨.ភិក្ខូនំ អនាវាសាយ បរិសក្កតិ** សាមណេរព្យាយាម ដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយ បាននូវទីលំនៅ

**៩ភិក្ខូ អក្កោសតិ បរិភាសតិ** សាមណេរជេរប្រទេចនូវភិក្ខុទាំងឡាយ។

**១០.ភិក្ខូ ភិក្ខូហិ ភេទេតិ**សាមណេរញ៉ាំងភិក្ខុទាំងឡាយឱ្យបែកចាកភិក្ខុទាំងឡាយ

**នាសនង្គៈ**

(បិដកលេខ៦ ទំព័រទី២៨២)

អដ្ឋកថាពន្យល់ សាមន្តប្បាសាទិកា ភាគ៥ ទំព័រទី១៦១

១.**បាណាតិបាតី ហោតិ** សាមណេរធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

២.**អទិន្នាទាយី ហោតិ** សាមណេរកាន់យកនូវវត្ថុដែលគេ មិនបានឱ្យ ដោយកាយ ឬដោយវាចា។

៣.**អព្រហ្មចារី ហោតិ**សាមណេរប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

៤.**មុសាវាទី ហោតិ** សាមណេរពោលនូវពាក្យកុហក។

៥.**មជ្ជបាយី ហោតិ** សាមណេរផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ

៦.**ពុទ្ធស្ស អវណ្ណំ ភាសតិ**សាមណេរពោលតិះដៀលនូវព្រះសម្មាសម្ពុទ្ធ។

៧.**ធម្មស្ស អវណ្ណំ ភាសតិ** សាមណេរពោលតិះដៀលនូវព្រះធម៌

៨.**សង្ឃស្ស អវណ្ណំ ភាសតិ** សាមណេរពោលតិះដៀលនូវព្រះសង្ឃ។

៩.**មិច្ឆាទិដ្ឋិកោ ហោតិ** សាមណេរមានទិដ្ឋិខុស។

១០.**ភិក្ខុនីទូសកោ ហោតិ** សាមណេរប្រទូស្តនឹងនាងភិក្ខុនី។

## អង្គនៃសិក្ខាបទ១០

### បាណាតិបាតៈ មានអង្គ៥

១.បាណោ សត្វមានជីវិត

២.បាណសញ្ញិតា សេចក្តីដឹងថា សត្វមានជីវិត

៣.វធកចិត្តំ គិតនឹងសម្លាប់

៤.ឧបក្កមោ ព្យាយាមនឹងសម្លាប់។

៥. តេនមរណំ សត្វស្លាប់ដោយព្យាយាមនោះ។

### អទិន្នាទានៈ មានអង្គ៥

១.បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់គេហួងហែងថែរក្សា

២.បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់គេហួងហែងរក្សា

៣.ថេយ្យចិត្តំ គិតនឹងលួច

៤.ឧបក្កមោ ព្យាយាមនឹងលួច

៥.តេន ហរណំ លួចបានមកដោយព្យាយាមនោះ។

### អព្រហ្មចរិយៈ មានអង្គ៤

១.តេធនវត្ថុ វត្ថុជាទីទម្លាយនូវសីល  គឺក្នុងទ្វារទាំង៣០ទ្វារណាមួយ

២.សេវនចិត្តំ គិតនឹងសេព

៣.តជ្ជោវាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤.មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា។

### មុសាវាទៈ មានអង្គ៤

១.អតថវត្ថុ វត្ថុមិនពិត

២.វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស

៣.**តជ្ជោវាយាមោ** ព្យាយាមនឹងពោលឱ្យខុសនោះ
៤.**បរស្ស តទត្ថវិជាននំ** ញុាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ

**សុរាមេរយៈ មានអង្គ៤**

១.**មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹងគឺសុរា និងមេរ័យ
២.**បាតុកម្យតាចិត្តំ** ចិត្តប្រាថ្នាដើម្បីនឹងផឹក
៣.**តជ្ជោវាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ
៤.**តស្ស បានំ** បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ។

**វិកាលភោជនៈ មានអង្គ៣**

១.**វិកាលោ** កាលខុសគឺព្រះអាទិត្យជ្រេទៅហើយដរាបទល់នឹងអរុណរះ
២.**យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើង ដល់ថ្ងៃត្រង់
៣.**អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក។

**នច្ចគីតៈ មានអង្គ៣**

១.**នច្ចគីតាទិ** ការល្បែងមានរាំ និងច្រៀងជាដើម
២.**ទដ្ឋុកម្យតាចិត្តំ** ចិត្តប្រាថ្នាដើម្បីនឹងធ្វើ
៣.**សុតទស្សនត្ថាយ គមនំ** ទៅដើម្បីនឹងស្តាប់ ឬមើល ហើយបានស្តាប់ឬមើល។

**មាលា មានអង្គ៣**

១.**មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម
២.**ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង
៣.**តស្សធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រង ជាដើមនោះ។

**ឧច្ចាសយនៈ មានអង្គ៣**

**១.ឧច្ចាសយនមហាសយនា** ទីដេកទីអង្គុយដ៏ខ្ពស់ដ៏ប្រសើរហួសប្រមាណ

**២.បរិភោគចិត្តំ** គិតនឹងដេក ឬអង្គុយ

**៣.បរិភោគករណំ** បានដេក ឬអង្គុយ

**ជាតរូបៈ មានអង្គ៣**

**១.ជាតរូបរជតំ** មាសឬប្រាក់ ជាអកប្បិយភណ្ឌ

**២.អត្តុទ្ទិសតា** ចំពោះជារបស់ខ្លួន

**៣.បដិគ្គណ្ហាតិ** បានទទួលកាន់យកដោយខ្លួនឯង ឬប្រើគេឱ្យទទួលកាន់យកទុកដាក់ឱ្យ ឬត្រេកអរចំពោះមាសឬប្រាក់នោះដោយឧបាយឯណានីមួយ។

**ទ្រង់បញ្ញត្តិសិក្ខាបទ១០ដល់សាមណេរ**

**បិដកលេខ ៦ ទំព័រទី ២៧៦**

(១១៩)សម័យនោះឯងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្រដ៏មានអាយុ បញ្ជូនទារកទៅក្នុងសំណាក់ព្រះសារីបុត្រដ៏មានអាយុហើយនិយាយថាសូមព្រះថេរៈបំបួសទារកនេះឱ្យទាន។

គ្រានោះព្រះសារីបុត្រដ៏មានអាយុត្រិះរិះគិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តិថា ភិក្ខុមួយរូបមិនត្រូវឱ្យសាមណេរពីររូប បម្រើខ្លួនឥឡូវរាហុលសាមណេរនេះ ជាសាមណេរ របស់អញ តើអញនឹងត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ព្រះសារីបុត្រក៏ក្រាបទូលសេចក្ដីនោះ ចំពោះព្រះដ៏មានព្រះភាគ។

ព្រះអង្គទ្រង់អនុញ្ញាតថាម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុមួយរូបដែលឆ្លាសប្រតិពល ឱ្យសាមណេរពីររូបបម្រើបាន ម្យ៉ាង វិញ

ទៀត បើភិក្ខុនោះអាចទូន្មានប្រៀនប្រដៅ សាមណេរប៉ុន្មានរូប បានឱ្យសាមណេរមានទាំងប៉ុណ្ណោះបម្រើក៏បានដែរ។

(១២០)គ្រាតពីនោះមកសាមណេរទាំងឡាយ បានត្រិះរិះសេចក្តីនេះនិងគ្នាថា សិក្ខាបទរបស់យើងទាំងឡាយមានប៉ុន្មានហ្នឹងម៉្យាងទៀតយើងទាំងឡាយគួរសិក្សាក្នុងវិន័យដូចម្តេចខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់អនុញ្ញាតថាម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទ ទាំងឡាយ១០ ដល់សាមណេរទាំងឡាយម៉្យាងទៀតអនុញ្ញាតឱ្យសាមណេរ ទាំងឡាយសិក្សាក្នុងសិក្ខាបទទាំងឡាយ ១០នេះគឺ (សិក្ខាបទ១០មាននូវ ខាងមុខ)។ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំង១០ នេះដល់សាមណេរទាំងឡាយម៉្យាងទៀត អនុញ្ញាតឱ្យពួកសាមណេរសិក្សា ក្នុងសិក្ខាបទទាំងឡាយ១០នេះ ។

**សុភាសិត**

**រៀនច្រើនចេះច្រើនកើនបញ្ញា**
**មើលហើយកត់ត្រាមកគិតគូ**
**រៀនកត់ចំណាំចាំបានយូរ**
**អ្នកជាវិញ្ញូក្នុងលោកា។**

## ព្រះអង្គបញ្ញត្តិទណ្ឌកម្ម១០ ដល់សាមណេរ

## (បិដកលេខ ៦ ទំព័រទី២៧៨)

(១២១)សម័យនោះឯង សាមណេរទាំងឡាយមិនគោរព មិនកោតក្រែង មានការចិញ្ចឹមជីវិតមិនស្មើភាគគ្នាក្នុងភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយ ក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសាមណេរមិនសមបើមិនគោរព មិនកោតក្រែងមានការចិញ្ចឹមជីវិតមិនស្មើភាគគ្នា ក្នុងភិក្ខុទាំងឡាយ(ដូច្នេះ) សោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថាម្នាលភិក្ខុទាំងឡាយតថាគត អនុញ្ញាតឱ្យភិក្ខុធ្វើទណ្ឌកម្មដល់សាមណេរដែលប្រកបដោយអង្គទាំងឡាយ៥គឺ (ទណ្ឌកម្មមាននូវក្នុងទំព័រខាងមុខ)។

## ព្រះអង្គបញ្ញត្តិ នាសនង្គដល់សាមណេរ ១០ :

## (បិដកលេខ ៦ ទំព័រទី២៨១)

(១២៤)សម័យនោះឯងសាមណេរឈ្មោះកណ្តកៈ (ជាសិស្ស)របស់ ព្រះឧបនន្ទសក្យ ដ៏មានអាយុប្រទុស្ត (សេពមេថុនធម្ម)និងភិក្ខុនី ឈ្មោះកណ្តកី។ ភិក្ខុទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា មិនសម បើសាមណេរមកប្រព្រឹត្តអនាចារមានសភាពដូច្នោះសោះ ។ ភិក្ខុទាំងឡាយ ក្រាបទូលរឿងនោះ ចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់អនុញ្ញាតថាម្នាល ភិក្ខុទាំងឡាយតថាគតអនុញ្ញាតឱ្យភិក្ខុញ៉ាំងសាមណេរដែលប្រកបដោយអង្គទាំងឡាយ ១០ ឱ្យវិនាស។

(នាសនង្គៈមាននូវក្នុងទំព័រខាងមុខ)

**សិក្ខាបទ ១០ របស់សាមណេរ**

**អដ្ឋកថា សាមន្តបាសាទិកា ទំព័រទី១៥៧**

(១១៩) ច្រើនបទថា **យាចតកេ ទា បន ឧស្សរមាតិ:** ម្យ៉ាងវិញទៀតបើភិក្ខុនោះអាចមានសេចក្តីថា រមែងដាស់តឿនទូន្មានសាមណេរ មានប្រមាណ ប៉ុនណា។

(១២០) ក្នុងសិក្ខាបទ ១០ សេចក្តីល្មើស ៥ សិក្ខាបទខាងដើម ជាវត្ថុនៃនាសនង្គ: សេចក្តីល្មើស ៥ សិក្ខាបទខាងចុងជាវត្ថុនៃទណ្ឌកម្ម។

**សុភាសិត**

បើអ្នករៀនចេះកុំមើលងាយគេ
ចេះឯងប៉ុនទន្លេរចេះគេប៉ុនសមុទ្រ
ទោះអ្នករៀនចេះគ្មានទីបំផុត
តែត្រូវធ្លាក់ស្រុតព្រោះមើលងាយគេ។

**អនាបត្តិ: ក្នុងសិក្ខាបទ ១០**

**(១) បាណាតិបាត: មានអនាបត្តិ ៧**

១. **អសញ្ចិច្ចៈ** ភិក្ខុមិនក្លែង

២. **អជានន្តស្សៈ** ភិក្ខុមិនដឹង

៣. **ន មរណាធិប្បាយស្សៈ** ភិក្ខុមិនប្រាថ្នានឹងសម្លាប់

៤. **ខិត្តចិត្តស្សៈ** ភិក្ខុមានចិត្តរវើរវាយ

៥. **វេទនដ្ដស្សៈ** ភិក្ខុមានវេទនាគ្របសង្កត់

៦. **អាទិកម្មិកស្ស** ភិក្ខុដើមបញ្ញត្តិ

៧. **ឧម្មត្តកស្សៈ** ភិក្ខុឆ្កួត ។

**មានអនាបត្តិ៨ :អទិន្នទាន (២)**

១. **សកសញ្ញិស្សៈ** ភិក្ខុកាន់យកដោយសំគាល់ថាជារបស់ខ្លួន

២. **វិស្សាសគ្គាហៈ** ភិក្ខុកាន់យកដោយសេចក្ដីស្និទ្ធស្នាល

៣. **តាវកាលិកៈ** ភិក្ខុកាន់យកដោយរបស់ខ្ចីគ្នា

៤. **បេតបរិគ្គហៈ** ភិក្ខុកាន់យករបស់ដែលពួកប្រេតហួងហែងរក្សា

៥.**តិរច្ឆានគតបរិគ្គហ**ភិក្ខុកាន់យករបស់ដែលពួកសត្វតិរច្ឆានហួងហែងរក្សា

៦. **បង្សុកូលសញ្ញិស្ស** ភិក្ខុយកដោយសំគាល់ថាជារបស់បង្សុកូល

៧. **អាទិកម្មិកស្សៈ** ភិក្ខុដើមបញ្ញត្តិ

៨. **ឧម្មត្តកស្សៈ** ភិក្ខុឆ្កួត ។

**មានអនាបត្តិ៦ :និងអព្រហ្មចរិយ :កាមេសុ មិច្ឆាចារ (៣)**

១. **អជានន្តស្សៈ** ភិក្ខុមិនដឹង

២. **អសាទិយន្តស្សៈ** ភិក្ខុមិនត្រេកអរ

៣. **ខិត្តចិត្តស្សៈ** ភិក្ខុមានចិត្តរវើរវាយ

**៤. ទេទនដ្ឋស្ស:** ភិក្ខុមានទុក្ខវេទនាគ្របសង្កត់

**៥.អាទិកម្មិកស្ស** ភិក្ខុដើមបញ្ញត្តិ

**៦. ឧម្មត្តកស្ស:** ភិក្ខុឆ្កួត ។

**៤ មានអនាបត្តិ :មុសាវាទ (៤)**

**១. ទវាយ ភណតិ** ភិក្ខុពោលដោយញាប់មាត់

**២. រវាយ ភណតិ** ភិក្ខុពោលដោយភ្លាត់មាត់

**៣. អាទិកម្មិកស្ស** ភិក្ខុដើមបញ្ញត្តិ

**៤. ឧម្មត្តកស្ស:** ភិក្ខុឆ្កួត ។

**មានអនាបត្តិ៨ :សុរាមេរយ (៥)**

**១.អមជ្ជញ្ច ហោតិ មជ្ជវណ្ណំ មជ្ជគន្ធំ មជ្ជរសំ តំ បិវតិ** ភិក្ខុផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចទឹកស្រវឹងមានក្លិនដូចទឹកស្រវឹងមានរសដូចទឹកស្រវឹង

**២. សូបសំបាកេ** ទឹកស្រវឹងដែលគេចំអិនលាយនឹងសម្ល

**៣. មំសសំបាកេ** ទឹកស្រវឹងដែលគេចំអិនលាយនឹងសាច់

**៤. តេលសំបាកេ** ទឹកស្រវឹងដែលគេលាយនឹងប្រេង

**៥. អាមលកផាណិតេ** ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ទួតព្រៃ

**៦. អមជ្ជំ អរិដ្ឋំ បិវតិ** ភិក្ខុផឹកថ្នាំអរិដ្ឋៈ មិនស្រវឹង

**៧. អាទិកម្មកស្ស** ភិក្ខុដើមបញ្ញត្តិ

**៨. ឧម្មត្តកស្ស:** ភិក្ខុឆ្កួត ។

**មានអនាបត្តិ៣ :វិកាលភោជន (៦)**

**១. យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ**
**បរិភុញ្ជតិ** ភិក្ខុឆាន់នូវវត្ថុ ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដោយមានហេតុ ដែលគួរឆាន់បាន

**២. អាទិកម្មិកស្ស** ភិក្ខុដើមបញ្ញត្តិ

**៣. ឧម្មត្តកស្សៈ** ភិក្ខុឆ្កួត ។

**មានអនាបត្តិ៧ :នច្ចគីត (៧)**

**១គេហេ ឋិតោ បស្សតិ វា សុណាតិ វា** (ភិក្ខុ)បានមើល ឬស្តាប់ ក្នុងលំនៅរបស់ខ្លួន

**២. ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា នច្ចន្តិ វាគាយន្តិ វា វាទេន្តិ វា** ជនទាំងឡាយមកកាន់ទីលំនៅរបស់ខ្លួន ដែលឈរ ឬអង្គុយ ឬក៏ដេក ហើយរាំក្តី ច្រៀងក្តី ប្រគំក្តី

**៣. បដិបថំ គច្ឆន្តិ បស្សតិ វា សុណាតិ វា** (ភិក្ខុ) កំពុងដើរទៅជួបតាមផ្លូវ ហើយឃើញក្តី ស្តាប់ក្តី

**៤. សតិ ករណីយេ គន្ត្វា បស្សតិ វា សុណាតិ វា** (ភិក្ខុ) កាលបើខ្លួនមានកិច្ចដើរទៅហើយឃើញក្តី ឮក្តី

**៥. អាបទាសុ** (ភិក្ខុ) មានសេចក្តីអន្តរាយ

**៦.អាទិកម្មិកសរក្ស** ភិក្ខុដើមបញ្ញត្តិ

**៧. ឧម្មត្តកស្ស** (ភិក្ខុ) ឆ្កួត ។

**មាលា មានអនាបត្តិ៣ (៨)**

**១. អាពាធា** (ភិក្ខុ) មានអាពាធ

**២. អាទិកម្មកស្ស** ភិក្ខុដើមបញ្ញត្តិ

**៣. ឧម្មត្តកស្ស** (ភិក្ខុ) ឆ្កួត ។

**មាននអនាបត្តិ៩ :ឧច្ចាសយន (៩)**

១. ដេក ឬអង្គុយលើគ្រែ នឹងតាំងដែលមានជើងកម្ពស់ត្រឹម ៨ ធ្នាប់ព្រះសុគត ឬថយ ចុះជាងនោះ។

២.បានគ្រែឬតាំងដែលអ្នកដទៃធ្វើឱ្យកន្លងហួសប្រមាណហើយយកមក កាត់ចេញឱ្យត្រូវនិងប្រមាណក្តីជីកកប់ទៅក្នុងផែនដីសល់នូវត្រឹមល្មម ប្រមាណក្តី ធ្វើឱ្យជាពិដានក្តី ធ្វើជារានក្តី  ហើយទើបប្រើប្រាស់អង្គុយ ដេក។

៣. ដេកឬអង្គុយលើគ្រែអង្គ ៧   សូម្បីមានជើងខ្ពស់ហួសប្រមាណ។

៤. ដេកអង្គុយលើតាំង ៤ជ្រុង សូម្បីមានជើងខ្ពស់ហួសប្រមាណ។

៥.បានគ្រែ/តាំង/ពូកដែលញាត់ដោយសំឡីគ ហើយយកមកកាយចេញទើប ប្រើប្រាស់ អង្គុយ ដេក។

៦. ដេក ឬអង្គុយលើពូក ៥យ៉ាង។

៧. មិនដេកគ្រាន់តែអង្គុយលើអាសនៈ ១៧ យ៉ាងដែលជា គិហិវិកដ។

**៨. អាទិកម្មកស្ស** ភិក្ខុដើមបញ្ញត្តិ។

**៩. ឧម្មត្តកស្ស** (ភិក្ខុ) ឆ្កួត ។

**មាននអនាប :ជាតរូប (១០)ត្តិ ៣**

**១. អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហាបេត្វា វា ឧបគ្គហាបេត្វា វា និក្ខិបតិ យស្ស តវ៍ស្សតិ សោ ហរិស្សតីតិ** ភិក្ខុរើសយកដោយខ្លួនឯងឬប្រើគេឱ្យរើស យករូបិយៈ ដែលធ្លាក់ចុះក្នុងអារាមក្តី ក្នុងលំនៅរបស់ខ្លួនក្តី ដោយគិតថា រូបិយៈនេះ ជារបស់អ្នកណា អ្នកនោះ នឹងនាំយកទៅចុះ ។

**២. អាទិកម្មិកស្សៈ** ភិក្ខុដើមបញ្ញត្តិ

**៣. ឧត្តកម្មកស្សៈ** ភិក្ខុឆ្កួត។

## មេសូត្រអប់រំ

❖ បួសតូចប្រឹងរៀនមានបញ្ញា បួសតូចឧស្សាហ៍ថ្វាគំនិត
បួសតូចស្តាប់គ្រូចេះដឹងពិត បួសតូចប្រព្រឹត្តតាមសាស្តា
បួសតូចខ្ជិលរៀនល្ងង់ខ្លៅពិត បួសមួយជីវិតឥតបានការ។
បួសមិនចេះដឹងសីលសិក្ខា ពិតនាំអាត្មាធ្លាក់ទៅអបាយ។

១ វិន័យធ្វើឱ្យអ្នកបួសត្រឹមត្រូវ វិន័យជាផ្លូវនាំឆ្ងាយអបាយ
បើគ្មានវិន័យអ្នកបួសអន្តរាយ ធ្លាក់ទៅអបាយព្រោះប្រព្រឹត្តខុស

២ យើងជាអ្នកបួសក្នុងសាសនា ត្រូវប្រឹងសិក្សាធម៌វិន័យ
បដិបត្តិរៀនសូត្រទាំងយប់ថ្ងៃ សូមជាបច្ច័យផុតចាកទុក្ខ

៣ បើចង់ស្រណុកកុំប្បាច់សិក្សា ចង់បានវិជ្ជាត្រូវលះក្តីសុខ
វិជ្ជាម្តេចមានដល់អ្នកស្រុកណុក ក្តីសុខម្តេចមានដល់អ្នកសិក្សា

៤ បើចង់បានផ្លែត្រូវខំថែគល់ នោះទើបភោគផលផ្តល់ឱ្យតាមការ
បើចង់បានចេះត្រូវខំសិក្សា នោះទើបបញ្ញាចម្រើនឡើងបាន
រឿងរ៉ាវជីវិតត្រូវគិតឱ្យឆ្ងាយ កុំងប់សប្បាយក្រែងក្លាយជាទុក្ខ
ត្រូវគិតដោះកុនមុនគិតរកសុខ កុំចង់ស្រណុកព្រោះខ្ជិលឱ្យសោះ។

៥ មានកូនមិនឱ្យកូនសូត្ររៀន ចំណេះរបៀនការនានា
មាតាលោកថាជាវេរា បិតាទុកជាសត្រូវធំ
កូនពេញរូបពាលពត់មិនឡើង ហៅថាមិនថ្កើងក្នុងជុំនុំ
ប្រៀបដូចកុកគ្រោងចូលទន្លំ កណ្តាលជុំនុំនៃរាជហង្ស

៦ បើវិជ្ជាមានតែក្នុងសៀវភៅ ទ្រព្យធនមាននៅដៃអ្នកដទៃ
ដល់ពេលត្រូវការនោះពុំប្រពៃ ទ្រព្យធននោះនៃហៅថាគ្មានហោង

៧ អ្នកល្ងង់ធំបានតែក្នុងផ្ទះខ្លួន អ្នកមានម៉ាំមួនក្នុងភូមិអាត្មា
គេបូជាស្ដេចតែក្នុងរដ្ឋា អ្នកមានវិជ្ជានោះទើបសព្វកាល
៨ សច្ចៈជាម្ដាយញ្ញាណជាបិតា ធម៌ជាភាតាករុណាជាមិត្ត
ក្តីស្ងប់ប្រពន្ធខន្តីកូនស្និទ្ធ ប្រាំមួយនេះពិតជាផៅពង្សខ្ញុំ

៩ ស្រមោចតូចពិតតែបើបឹងដើរ គង់ធ្វើដំណើររអស់រយយោជន៍បាន
ត្រុឌអាចហោះហើរតែបើពុំថ្កាន សូម្បីជំហានមួយក៏ពុំដល់

១០ធម៌ល្អតែឈ្នះនូវអធម៌ សច្ចៈបវរឈ្នះពាក្យភូតព្រាង
អំណាស់អស់ឱនឈ្នះគោងតូងតាង ទេព្ហាបុណ្យសាងឈ្នះអស់អសុរ

១១ខ្ញុំសូមពោលពាក្យកន្លះគាថា តាមបាទតម្រាលោកចារចែងចង
ថាធ្វើគុណគេជាបុណ្យកន្លង ធ្វើទោសអ្នកផងជាបាបអនេក

១២ហៃចៅជាតិពិសី ចូរលះក្តីស្រវឹងទៅ
ដោយជនពាលឃោរឃៅ ចូរគប់នូវនឹងសប្បុរស
ចូរធ្វើបុណ្យប្រក្រតី គ្រប់រាត្រីថ្ងៃទាំងអស់
ចូរមានចិត្តសោមនស្ស នឹករឭកព្រះត្រៃលក្ខណ៍

១៣កុលបុត្របរិបូរណ៍ដោយរូបទ្រង់ កើតក្នុងត្រកូលកបសន្តា
ឆោតឆៅខ្លៅមិនចេះសិល្បិ៍សាស្ត្រា ប្រៀបដូចផ្កាចារចាំងឥតក្លិនក្លី

១៤ពេលពន់ព្រលប់ប្រទីបចន្ទ្រា រះលើមេឃារស្មីត្រចះ
លុះពេលភ្លឺស្វាងព្រះអាទិត្យរះ ជាប្រទីបច្បាស់ភ្លឺប្លែកអស្ចារ្យ
ព្រះធម៌ល្អឯកលើសលុបកន្លង បំភ្លឺសត្វផងក្នុងត្រៃលោកា
ឯបុត្រដែលល្អកបញ្ញាណបញ្ញា ជាប្រទីបាក្នុងវង្សត្រកូល។

១៥ឈើល្អសូម្បីមួយដើមសោះ បញ្ចេញសម្រស់ដោយផ្កាភ្ញី
ក្រអូបផ្សព្វផ្សាយគ្រប់ទិសទី ក្នុងដងគិរីព្រៃជុំជិត
ដូចជាត្រកូលមានកូនល្អ ឆើតឆាយបវរម្នាក់ពិត
កបញ្ញាណាបញ្ញាថ្លាគំនិត បងប្អូនញាតិមិត្តពឹងអាស្រ័យ។

១៦លក្ស្មីនៅត្រង់ចុងអណ្តាត ផៅពង្សមិត្តញាតិស្មោះមេត្រី
ដោយសារអណ្តាតអាទិ៍សម្តី កើតសុខសួស្តីល្អកន្លង
អណ្តាតគ្រលាស់ខុសប្រក្រតី គ្រោតគ្រាតអប្រិយកើតសៅហ្មង
ជាប់គុកច្រវ៉ាក់ឬស្លាប់ផង ទៀងទាត់តែម្តងព្រោះអណ្តាត។

១៧បិយវាចាផ្អែមពិរោះ មិនមានហ្មងមោះកន្ទុលចិត្ត
សត្វផងត្រេកអរស្មោះសរពិត រួមរស់ស្នេហ៍ស្និទ្ធចិត្តមេត្រី។
ដោយគ្រាន់តែពោលពាក្យទន់ភ្លន់ ពុំមានស្រាលធ្ងន់ទំលក្រអ្វី
ឬគ្រាន់តែពោលពាក្យសម្តី សម្តែងវចីបិយវាចា។

១៨វិជ្ជាជាទ្រព្យក្នុងប្រទេសផ្សេង មតិយល់ឈ្វេងជាទ្រព្យផ្ទាល់កាយ
សម្រាប់ការពារក្តីអន្តរាយ ក្នុងទីជិតឆ្ងាយទូទៅនានា។
ព្រះធម៌ជាទ្រព្យក្នុងលោកខាងមុខ សីលទុកជាទ្រព្យគប់ក្នុងទីយា
គ្រប់ទីទាំងពួងក្នុងភពនានា សម្រាប់គ្រប់គ្នាប្រតិបត្តិតាម។

១៩មិនទាន់ត្រិះរិះពិចារណា ជនគ្រប់រូបាមិនត្រូវពោល
បើបានត្រិះរិះទុកជាគោល ទើបពោលបានល្អមិនឃ្លៀតឃ្លាត
ពោលក្នុងទីណាសម្រេចផល ត្រូវជួយយោបល់បន្ថែមទៀត
ពង្រឹងទីនោះដោយខ្មីឃ្មាត ទើបពង្សផៅញាតិរីកចម្រើន។

២០កិច្ចការទាំងឡាយតែងសម្រេច ដោយការប្តូរផ្តាច់ប្រឹងប្រែងពិត

មិនមែនបានមកដោយការគិត		តាមតែគំនិតចង់បានទេ
ព្រោះថាសត្វម្រឹគមិនមែនឆោត		ចង់ឱ្យគេកោតខ្លាំងលើសគេ
ប្លោលចូលក្នុងមាត់រាជសីហ		ដែលវាឆ្វេសឆ្វេងដេកលក់ឡើយ។

# វិន័យថ្នាក់មធ្យម

**សិក្ខា** បានដល់គុណជាតិដែលបព្វជិតត្រូវសិក្សាមានសីលសិក្ខា សមាធិសិក្ខា និងបញ្ញាសិក្ខា ។ការសង្រួមកាយវាចាដោយប្រពៃហៅថា សីលសិក្ខា ។ ការសង្រួមរក្សាចិត្តឲ្យស្ងប់រម្ងាប់ហៅថា សមាធិសិក្ខា ការសិក្សាឲ្យដឹងច្បាស់ក្នុងកងសង្ខារហៅថា បញ្ញាសិក្ខា ។

**សិក្ខាបទ** គឺវិន័យបញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម លើកឡើងជាប្រការ ឬជាមាត្រាមួយៗ ដែលហៅថាសិក្ខាបទ មានក្នុងបាតិមោក្ខខ្លះ មិនមានក្នុងបាតិមោក្ខខ្លះ។សិក្ខាបទដែលមានក្នុងបាតិមោក្ខនោះគឺៈ បារាជិក៤ សង្ឃាទិសេស១៣ អនិយតៈ២ និស្សគ្គិយបាចិត្តិយៈ៣០ សុទ្ធិកបាចិត្តិយៈ៩២ ចត្តារោបដិទេសនីយៈ៤ សេខិយវត្ត៧៥ អធិករណសមថៈ៧ រួមទាំងអស់ជា ២២៧សិក្ខាបទ។

**អនុញ្ញាត** ខដែលទ្រង់យល់ព្រមឲ្យប្រព្រឹត្តតាម ហៅថាអនុញ្ញាតឬពុទ្ធានុញ្ញាត

**បញ្ញត្តិ** ខដែលព្រះពុទ្ធទ្រង់ហាមមិនឲ្យបព្វជិតប្រព្រឹត្តរាយពាយតាមអំពើចិត្ត ព្រមទាំងប្រាប់ទោសកំហុសធ្ងន់ស្រាល ហៅថា បញ្ញត្តិ ឬ ពុទ្ធប្បញ្ញត្តិ ។

**អភិសមាចារ** ការរៀបរយល្អ ឬកិច្ចវត្តដែលបព្វជិត ត្រូវប្រព្រឹត្ត ត្រូវបំពេញឲ្យបរិបូណ៌ល្អ ហៅថា **អភិសមាចារ**

## អាបត្តិមាន៧កង

**អាបត្តិ** គឺជាឈ្មោះនៃទោសផ្សេងៗដែលភិក្ខុសាមណេរប្រព្រឹត្តកន្លងមាន៧កង

**បារាជិក** ប្រែថា បុគ្គលអ្នកដល់នូវការចាលចាញ់ កាលភិក្ខុត្រូវទោសនេះហើយ គឺដាច់ភេទជាភិក្ខុ ហើយត្រូវផ្សឹកចេញ អាចបួសបានត្រឹមជាសាមណេរប៉ុណ្ណោះ

**សង្ឃាទិសេស** ភិក្ខុកាលបើត្រូវទោសនេះហើយ គប្បីចូលទៅរកសង្ឃកម្មជាខាងដើម និងកម្មដ៏សេស គឺថាកាលបើភិក្ខុត្រូវហើយ ត្រូវអាស្រ័យសង្ឃជា

ដរាប សូមឲ្យសង្ឃឲ្យបរិវាក្នុងកម្មជាខាងដើម ឲ្យមានត្តក្នុងកម្មកណ្តាល ឲ្យអព្ភានក្នុងកម្មជាទីបំផុត ។សង្ឃាទិសេសនេះជាវុដ្ឋានគាមិនី។

**ថុល្លច្ច័យ** ប្រែថា កំហុសដ៏ថ្លោស ឬទោសដ៏គ្រោតគ្រាត

**បាចិត្តិយៈ** ប្រែថា អាបត្តិញុំាងកុសលឲ្យធ្លាក់ចុះឬ អាបត្តិទំលាក់ចុះនូវ កុសលធម៌ចេញអំពីសន្តាន

**ទុក្កដ** ប្រែថា អំពើអាក្រក់ ឬកិច្ចការដែលភិក្ខុធ្វើអាក្រក់ ។អាបត្តិនេះសំដៅយកកាយកម្ម វចីកម្មដែលប្រព្រឹត្តអាក្រក់គួរអ្នកដទៃតិះដៀលបាន

**ទុព្ភាសិត** ប្រែថា ពោលពាក្យអាក្រក់ ឬពាក្យសំដីដែលរបូតចេញ ទៅដោយគ្រោតគ្រាត។

## អនុសាសនៈ

ពាក្យប្រៀនប្រដៅដែល ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុជាឧបជ្ឈាយ៍ប្រៀនប្រដៅកុលបុត្រ ដែលទើបបានឧបសម្បទាថ្មីៗ ក្នុងពេលជាលំដាប់ទ្បាប់អំពីញត្តិចតុត្ថកម្មវាចា ដើម្បីឲ្យភិក្ខុថ្មីនោះ បានចេះដឹងបណ្តើរជាការបណ្តោះអាសន្នហៅថា អនុសាសនៈ។ មាន៨ យ៉ាង គឺ និស្ស័យ៤ អករណីយកិច្ច៤ ។

## និស្ស័យ ៤

បច្ច័យជាគ្រឿងអាស្រ័យរបស់បព្វជិត ហៅថា និស្ស័យ មាន ៤ យ៉ាងគឺ ដើរបិណ្ឌបាត១ ស្លៀកដណ្តប់សំពត់បង្សុកូល១ អាស្រ័យនៅក្រោមម្លប់ឈើ១ ឆាន់ថ្នាំត្រាំដោយទឹកមូត្រ១

## អករណីយកិច្ច ៤

កិច្ចដែលបព្វជិតមិនត្រូវធ្វើ មាន៤ យ៉ាងគឺ សេពមេថុនធម្ម១ លួចទ្រព្យគេ១ សម្លាប់សត្វ១ និងពោលអួតគុណវិសេសដែលមិនមានក្នុងខ្លួន១ ។

**ត្រៃសិក្ខា**

គុណជាតិដែលបព្វជិតត្រូវសិក្សាហៅថា សិក្ខាមាន ៣ យ៉ាងគឺ សីល ១ សមាធិ១ បញ្ញា១។

១, ការសង្រួមកាយ វាចាដោយប្រពៃហៅថា **សីល** ។

២, ការរក្សាចិត្តឲ្យស្ងប់រំងាប់ហៅថា **សមាធិ** ។

៣, ការដឹងច្បាស់ក្នុងកងសង្ខារទាំងឡាយហៅថា **បញ្ញា** ។

**ចរិយាវត្ត កិច្ចរបស់ភិក្ខុសាមណេរ ១០ យ៉ាង**

១, មិនឲ្យជាន់ផ្ទត់សំពត់ស ដែលគេលាតក្នុងទីនិមន្ត ។

២, មិនទាន់ពិចារណា ជាមុនកុំអាលអង្គុយលើអាសនៈ

៣, ភិក្ខុ សាមណេរ កំពុងឆាន់មិនត្រូវក្រោកចោលគ្នា ។

៤, មិនត្រូវអង្គុយលើអាសនៈវែងជាមួយនឹងស្ត្រី ឬ ខ្ទើយ តែបើអង្គុយជា មួយមនុស្សមានអាសនៈមិនស្មើគ្នាបាន។

៥, មុនសិងសម្រាកក្នុងវេលាថ្ងៃត្រូវបិទទ្វារ ។

៦, មិនត្រូវបន្ទោបង់ឧច្ចារៈ បស្សាវៈ ឬចោលរបស់ជាសំណល់ទៅក្រៅជញ្ជាំង ឬក្រៅកំពែង ។

៧,មិនត្រូវឡើងដើមឈើ វៀរលែងតែមានកិច្ច ដូចជាវង្វេងផ្លូវឬមានអន្តរាយ

៨, មិនត្រូវទៅមើលការរាំ ឬស្តាប់ចម្រៀងភ្លេងប្រគំណាមួយឡើយ ។

៩, មិនត្រូវសូត្រធម៌ដោយសម្លេងច្រៀងវែងៗ តែសូត្របទសារភញ្ញបាន ។

១០, មិនត្រូវចាប់ពាល់វត្ថុជាអនាមាសៈ ៦ យ៉ាងមានមាសប្រាក់ជាដើម ។

**សមណៈ ប្រែថា អ្នកមានព្យាយាមដុតកម្តៅបាប**

អ្នកខំប្រឹងប្រព្រឹត្តធម៌ធ្វើកាយវាចាធ្វើចិត្តឲ្យស្ងប់បាប អ្នកស្ងប់រម្ងាប់បាបសំដៅដល់បព្វជិតដែលបានបំពេញសមណៈធម៌មានការហ្វឹកហាត់អប់រំទូន្មាន

ខ្លួនឯងដោយ **សីល សមាធិ បញ្ញា** រហូតមាន កាយ វាចា ចិត្ត ស្ងប់ហើយចាក បាប ហៅថាសមណៈ

## លក្ខណៈរបស់សមណៈក្នុងការបដិបត្តិមាន៤យ៉ាង

១, **សមណៈ មិនត្រូវធ្វើអន្តរាយផ្សេងៗ** មិនថាតាមផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត ក៏មិនធ្វើសេចក្តីក្តៅក្រហាយឲ្យដល់អ្នកណាៗ សូម្បីតែក្នុងការគិត គឺមិន ត្រូវបៀតបៀនគេ ។

២, **សមណៈមិនត្រូវលោភលន់ក្នុងលាភ** ត្រូវញុំាងជីវិតឲ្យស្ថិតនៅត្រឹមតែដើម្បីសេចក្តីព្យាយាម ត្រូវមានសេចក្តី សន្តោស មិនត្រូវជាសមណៈដែលឃើញតែការឆាន់ មិនដឹងប្រមាណ ក្នុងភោជន។

៣, **សមណៈ ត្រូវបំពេញតបៈធម៌** ត្រូវធ្វើសេចក្តីព្យាយាមដើម្បីលះបង់កិលេស តាំងចិត្តយកឈ្នះកិលេស មិនថាដោយឥរិយាបថដើរចង្ក្រម ការធ្វើសមាធិ ឬសមាទានធុតង្គណាមួយ ។

៤, **សមណៈត្រូវសង្រួមអប់រំខ្លួន** គឺព្យាយាមហ្វឹកហាត់អប់រំទូន្មានខ្លួនឯងមិនឃើញតែពីការសិង និងការឆាន់នោះទេ គឺត្រូវបំពេញនូវកិច្ចវត្តរបស់ខ្លួន មានការសិក្សានិងការបដិបត្តិ

## ទិសដៅរបស់សមណៈមាន៥យ៉ាង

កុលបុត្រដែលជាអ្នកមានសទ្ធា បានចូលមកបំពេញបព្វជ្ជាឬឧបសម្បទា ក្នុងបវរ នៃព្រះពុទ្ធសាសនាហើយ ត្រូវប្រកាន់ភ្ជាប់នៅទិសដៅរបស់ខ្លួន៥ ប្រការនេះ

១, **ត្រូវមានខន្តី និងសោរច្ចៈ** គឺត្រូវជាអ្នកមាននូវសេចក្តីអត់និងស្ងប់ស្ងៀម

២, **ត្រូវត្រិះរិះរកផ្លូវប្រាជ្ញា** ពិចារណាសិក្សារកផ្លូវចេញចាកពីសេចក្តីទុក្ខដែលកើតពី ជាតិ ជរាព្យាធិ និងមរណៈ ។

៣, **ត្រូវជាអ្នកមានសីលបរិសុទ្ធ**

៤, ត្រូវតែជាអ្នកមិនមានកង្វល់ ខុសត្រូវនាទីរបស់ខ្លួន

៥, សមណៈ ត្រូវមានព្រះនិព្វានជាទិសដៅ

## ធម៌ជាមន្ទិល ៩ យ៉ាង

១, កោធៈ ក្រោធ

២, មក្ខ រមិលគុណគេ

៣,ឥស្សា ច្រណែន

៤, មច្ឆរិយ កំណាញ់

៥, មាយា ពុកក្បុត

៦, សាថេយ្យៈ អួតអាង

៧, មុសា ពោលកុហក

៨, បាបិច្ឆៈ ប្រាថ្នាអាក្រក់

៩, មិច្ឆាទិដ្ឋិ យល់ឃើញខុស

## ព្រះពុទ្ធទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយភិក្ខុមិនត្រូវឆាន់រួមភាជន៍ជាមួយគ្នា មិនត្រូវផឹកទឹក រួមផ្តិលជាមួយគ្នា មិនត្រូវដេកលើគ្រែជាមួយគ្នាមិនត្រូវដេកលើកម្រាល ជាមួយគ្នា ត្រូវដេកដណ្តប់ជាមួយគ្នាមិនត្រូវដេកលើកម្រាលនិងដណ្តប់ ជាមួយគ្នាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ៕

## អ្នកបួសត្រូវមានធម៌៥យ៉ាងគឺ

១, ត្រូវមានសីលធម៌រស់នៅដោយល្អ

២, ត្រូវសង្រួមកាយវាចាចិត្ត

៣, មិនត្រូវនិយាយច្រើនពាក្យចាក់ដោត ឬពាក្យឥតប្រយោជន៍

៤, ត្រូវមានសមាធិក្នុងទីស្ងប់ស្ងាត់

៥, ជាអ្នកមានសមាទិដ្ឋិ ជឿជាក់ក្នុងគុណរបស់ព្រះពុទ្ធ

## ជំនួញខុស ៥ យ៉ាងដែលមិនគួរប្រព្រឹត្តិ

១.សត្ថវណិជ្ជា ការជួញគ្រឿងសស្ត្រាវុធ

២.សត្តវណិជ្ជា ការជួញមនុស្ស

**៣.មំសវណិជ្ជា** ការជួញ( សត្វដែលគេសម្លាប់យក )សាច់

**៤.មជ្ជវណិជ្ជា** ការជួញគ្រឿងស្រវឹង

**៥.វិសវណិជ្ជា** ការជួញថ្នាំពិស

# ទោកវដ្ដសិក្ខាបទ៤៩

១ **សុក្កវិស្សដ្ឋិ**សាមណេរក្លែងធ្វើឲ្យទឹកអសុចិកំរើកឃ្លាតចាកទី ត្រូវទណ្ឌកម្ម ។

២ **កាយសំសគ្គៈ** សាមណេរមានតម្រេកចាប់ពាល់ត្រូវកាយស្ត្រី ត្រូវទណ្ឌកម្ម ។

៣ **ទុដ្ឋុល្លវាចា** សាមណេរមានតម្រេក និយាយពាក្យអាក្រក់ចែចង់ស្ត្រី ត្រូវទណ្ឌកម្ម ។

៤ **អត្តកាមបារិចរិយា** សាមណេរមានតម្រេក និយាយល្បួងលួងលោមស្ត្រី ឲ្យបម្រើខ្លួនដោយកាម ត្រូវទណ្ឌកម្ម ។

៥ **អមូលកៈ** សាមណេរក្រោធខឹងនឹងភិក្ខុដទៃ ហើយក្លែងចោទដោយអាបត្តិបារាជិកដោយមិនមានមូល ត្រូវទណ្ឌកម្ម ។

៦ **អញ្ញភាគិយៈ** សាមណេរក្រោធខឹងនឹងភិក្ខុដទៃ ហើយក្លែងរកលេស មានជាតិជាដើម មកចោទដោយអាបត្តិបារាជិក ត្រូវទណ្ឌកម្ម ។

៧ **សង្ឃភេទៈ** សាមណេរព្យាយាមបំបែកសង្ឃឲ្យបែកគ្នា ភិក្ខុឯទៀតហាមឃាត់មិនស្តាប់ ត្រូវទណ្ឌកម្ម ។

៨ **ភេទានុវត្តកៈ** សាមណេរប្រព្រឹត្តតាមសាមណេរដែលបំបែកសង្ឃនោះ ភិក្ខុឯទៀតហាមឃាត់មិនស្តាប់ ត្រូវទណ្ឌកម្ម ។

៩ **ទុព្វចជាតិកៈ** សាមណេរមានជាតិ ជាអ្នករបឹងរឹងរូសប្រដៅក្រ ភិក្ខុឯទៀតហាមឃាត់មិនស្តាប់ ត្រូវទណ្ឌកម្ម ។

១០ **កុលទូសកៈ** សាមណេរទ្រុស្តត្រកូល គឺសាមណេរដែលប្រធុបប្រចែងផ្កាប់គុណគ្រហស្ថ សង្ឃបានបណ្តេញចេញអំពីវត្ត ត្រូវទណ្ឌកម្ម ។

១១ **ចីវរាច្ឆិន្ទនៈ** សាមណេរបានឲ្យចីវរដល់សាមណេរឯទៀត ហើយដល់ក្រោធខឹងក៏ទៅដណ្តើមយកវិញដោយខ្លួនឯងក្តីប្រើគេឲ្យទៅដណ្តើមវិញក្តីបានមក ត្រូវទណ្ឌកម្ម ។

**១២ ថេរ៉ណ្ណៈ** សាមណេរដឹងថាលាភដែលទាយកគេបំរុងនឹងប្រគេនដល់សង្ឃ ហើយបង្អោនសង្ឃលាភនោះ មកដើម្បីខ្លួនវិញត្រូវទណ្ឌកម្ម ។
**១៣ មុសាវាទៈ** សាមណេរពោលពាក្យកុហក ត្រូវនាសនង្គៈ ។
**១៤ ឱមសវាទៈ**សាមណេរជេរប្រទេចឬពោលពាក្យចាក់ដោតសាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។
**១៥ បេសុញ្ញៈ** សាមណេរនិយាយញុះញង់ សាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។
**១៦ទុដ្ឋុល្លារោចនៈ**សាមណេរប្រាប់អាបត្តិអាក្រក់( គឺប្រាប់អាបត្តិសង្ឃាទិសេស ) របស់ភិក្ខុដទៃ ដល់សាមណេរផងគ្នា ត្រូទណ្ឌកម្ម ។
**១៧ អញ្ញវាទកៈ** សាមណេរប្រព្រឹត្តអនាចារ សង្ឃបានហៅខ្លួនមកសាកសួរ ក្លែងនិយាយត្រឡប់ត្រឡិនក្តី ស្ងៀមមិននិយាយក្តី បើសង្ឃបានសូត្រប្រកាស សេចក្តីនោះចប់ នៅតែធ្វើដូច្នេះទៀត ត្រូវទណ្ឌកម្ម ។
**១៨ ឧជ្ឈាបនកៈ** សាមណេរពោលតិះដៀលភិក្ខុឯទៀតដែលសង្ឃសម្មតិឱ្យជា អ្នកធ្វើការសង្ឃ មានក្រាលអាសនៈ និងចែកលាភជាដើម បើភិក្ខុនោះ ធ្វើការ សង្ឃដោយប្រពៃ សាមណេរអ្នកតិះដៀលនោះ ត្រូវទណ្ឌកម្ម ។
**១៩ អនុប្បខជ្ជៈ** សាមណេរដឹងថា កុដិជារបស់សង្ឃមានភិក្ខុចូលទៅនៅ មុន ហើយ ក្លែងយកសំពត់ទៅក្រាលដេកហើយបានអង្គុយ ឬ ដេកជ្រៀតបៀត ក្នុងទីនោះដើម្បីឲ្យភិក្ខុដែលនៅមុននោះមានសេចក្តីចង្អៀតចង្អល់ទុញទាល់ចិត្ត ហើយនឹងចៀសចេញទៅ ត្រូវទណ្ឌកម្ម ។
**២០ និក្កឌ្ឍនៈ** សាមណេរក្រោធខឹងនឹងភិក្ខុឯទៀត ហើយទៅចាប់អូសភើច កន្ត្រាក់ ដេញភិក្ខុនោះឲ្យចេញចាកកុដិជារបស់សង្ឃ ត្រូវទណ្ឌកម្ម ។
**២១ អាមិសៈ** សាមណេរពោលតិះដៀលភិក្ខុឯទៀតថា ប្រដៅភិក្ខុនីព្រោះ អាស្រ័យលាភសក្ការៈ ត្រូវទណ្ឌកម្ម ។

**២២ ទុតិយបព្វាជនា** សាមណេរដឹងថា ភិក្ខុ ឬ សាមណេរឯទៀត ហាមភោជនដូច្នោះហើយ គិតនឹងលើកទោសភិក្ខុឬសាមណេរនោះ ៗ ហើយក្លែងយកខាទនីយភោជនីយាហារ ដែលមិនមែនជាដែលភិក្ខុឃើ ឬមិនបានធ្វើវិន័យកម្ម ទៅអង្គុរ ឬ បង្ខំភិក្ខុសាមណេរនោះ ៗ ឲ្យឆាន់ ត្រូវទណ្ឌកម្ម ។

**២៣ ឧយ្យោជនៈ** សាមណេរបបួលភិក្ខុ ឬ សាមណេរឯទៀតទៅបិណ្ឌបាតជាមួយគ្នាគិតនឹងប្រព្រឹត្តអនាចារ ហើយបណ្តេញភិក្ខុ ឬ សាមណេរនោះ ឲ្យទៅវិញ ត្រូវទណ្ឌកម្ម ។

**២៤ បឋមរហោនិសជ្ជៈ** សាមណេរអង្គុយ ឬ ដេកក្នុងទីកំបាំងភ្នែក តែពីរនាក់នឹងស្ត្រី មិនមានប្រុសនៅជាមួយផង ត្រូវទណ្ឌកម្ម ។

**២៥ ទុតិយរហោនិសជ្ជៈ** សាមណេរអង្គុយ ឬដេកក្នុងទីកំបាំងត្រចៀក ពីរនាក់នឹងស្ត្រី ត្រូវទណ្ឌកម្ម ។

**២៦ ឧយ្យុត្តៈ** សាមណេរទៅមើលកងទ័ព ដែលគេលើកទៅដើម្បីច្បាំងគ្នា ត្រូវទណ្ឌកម្ម វៀរលែងតែមានហេតុ គឺមានញាតិឈឺក្នុងទីនោះ ។

**២៧ សុរាបានៈ** សាមណេរផឹកសុរា ត្រូវនាសនង្គៈ ។

**២៨ អង្គុលិបតោទកៈ** សាមណេរយកម្រាមដៃចាក់ភិក្ខុឬសាមណេរផងគ្នា ត្រូវទណ្ឌកម្ម។

**២៩ ហាសធម្មៈ** សាមណេរហែលទឹកលេងត្រូវទណ្ឌកម្ម ។

**៣០ អនាទរិយៈ**សាមណេរសម្តែងសេចក្តីមិនអើពើនឹងវិន័យឬនឹងបុគ្គលអ្នកសម្តែងវិន័យ ត្រូវទណ្ឌកម្ម ។

**៣១ ភឹសាបនៈ** សាមណេរបញ្ឆោត ឬលងបន្លាចភិក្ខុឬសាមណេរផងគ្នាត្រូវទណ្ឌកម្ម ។

៣២ **អមនិឆានៈ** សាមណេរលាក់បរិក្ខារ ៥ យ៉ាងគឺ បាត្រ១,ចីវរ១,បំពងម្ភុល១, វត្តពន្ធចង្កេះ១,និសីទនៈ១, បរិក្ខារណាមួយ ជារបស់ភិក្ខុ ឬ សាមណេរឯទៀត ដោយមានបំណងនឹងសើចលេង ត្រូវទណ្ឌកម្ម ។
៣៣ **សញ្ចិច្ចឃាតនៈ** សាមណេរក្លែងសម្លាប់សត្វតិរច្ឆាន ត្រូវនាសនង្គៈ ។
៣៤ **សប្បាណកៈ**សាមណេរដឹងថា ទឹកមានសត្វរស់ហើយបរិភោគនៅទឹកនោះ គឺ ផឹកងូត លាងដៃ ជើង ឬ លាងភាជន៍ជាដើម ត្រូវទណ្ឌកម្ម ។
៣៥ **ឧក្កោដនៈ** សាមណេរដឹងថា អធិករណ៍ណាមួយដែលសង្ឃបានរម្ងាប់ ដោយសមថៈ ៧ យ៉ាង ឯណាមួយដោយត្រឹមត្រូវតាមធម៌ជាស្រេចហើយ មក សើរើសេចក្ដីនោះជាថ្មីទៀត ត្រូវទណ្ឌកម្ម ។
៣៦ **ទុដ្ឋុល្លប្បដិច្ឆាទនៈ** សាមណេរដឹងថា ភិក្ខុឯទៀតត្រូវទុដ្ឋុល្លាបត្តិ គឺអាបត្តិ សង្ឃាទិសេស ហើយជួយបិតបាំងអាបត្តិនោះ ត្រូវទណ្ឌកម្ម ។
៣៧ **អរិដ្ឋៈ** សាមណេរប្រកាន់ទិដ្ឋិបាបគឺមានសេចក្ដីឃើញខុសចាកធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងហើយ ភិក្ខុឯទៀតពោលហាមប្រាមមិនស្ដាប់ កាលបើសង្ឃបានសូត្រសមនុភាសនកម្មចប់អនុស្សាវនា ជាគំរប់បីដងហើយ នៅតែមិនស្ដាប់ ត្រូវទណ្ឌកម្ម ។
៣៨ **កណ្ឌកៈ** សាមណេរដឹងថា ភិក្ខុឯទៀដែលភិក្ខុដទៃឲ្យវិនាសហើយ ព្រោះ ទោសដែលឃើញខុសចាកធម៌វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែង ហើយ ប្រលោមសាមណេរនោះមកឲ្យបម្រើខ្លួនក្ដី រួមបរិភោគក្ដី ឲ្យដេកនៅក្នុងទីប្រក់ ទីបាំងជាមួយគ្នាក្ដី ត្រូវទណ្ឌកម្ម ។
៣៩ **សហធម្មិកៈ** សាមណេរប្រព្រឹត្តអនាចារកាលបើភិក្ខុដទៃនិយាយដាស់តឿន ក៏និយាយប្រកែចប្រណាំងា ខ្ញុំព្រះករុណាមិនទាន់សិក្សាសិក្ខាបទនេះទេ ចាំខ្ញុំ ព្រះករុណាសួរលោកអ្នកឈ្លាស អ្នកចេះដឹង អ្នកទ្រទ្រង់វិន័យសិន ពោលពាក្យ ដូច្នេះ ត្រូវទណ្ឌកម្ម ។

**៥០ ទីលេខនៈ** កាលបើភិក្ខុ ឬ សាមណេរឯទៀត កំពុងទន្ទេញវិន័យ សាមណេរក្លែងនិយាយបន្ទច់បង្អាក់ ឲ្យគេកើតសេចក្តីរាយមាយចាកសេចក្តីព្យាយាមនោះ ត្រូវទណ្ឌកម្ម ។

**៥១ មោហនៈ** សាមណេរត្រូវទោសទណ្ឌកម្ម ហើយក្លែងនិយាយថា ខ្ញុំព្រះករុណាទើបនឹងដឹងក្នុងកាលអម្បាញ់មិញនេះឯងថា សេចក្តីនេះមានក្នុងវិន័យ បើភិក្ខុ ឬ សាមណេរដទៃដឹងថា សាមណេរនោះធ្លាប់ដឹងមកហើយ ដែលពោលដូច្នេះនោះ គឺពោលដោយក្លែងពើធ្វើជាមិនដឹងទៅទេ សង្ឃគប្បីសូត្រប្រកាសមោហារោបនកម្ម កាលបើសូត្រចប់ហើយ នៅតែក្លែងធ្វើជាមិនដឹងដូច្នោះទៀត ត្រូវទណ្ឌកម្ម ។

**៥២ បហារទានៈ** សាមណេរក្រោធខឹងនឹងភិក្ខុ ឬសាមណេរឯទៀតហើយប្រហារភិក្ខុ ឬ សាមណេរនោះដោយ បហារទាន មានទះតប់ ដាល់ ទាត់ ធាក់ជាដើម ត្រូវទណ្ឌកម្ម។

**៥៣ តលសត្តិកៈ** សាមណេរក្រោធខឹងនឹងភិក្ខុឬសាមណេរឯទៀត ហើយងារដៃឡើងជន្ល ដូចជាប្រហារនូវភិក្ខុ សាមណេរនោះ ត្រូវទណ្ឌកម្ម ។

**៥៤ អមូលកៈ** សាមណេរចោទភិក្ខុឯទៀតដោយអាបត្តិ មិនមានមូលសង្ឃាទិសេសដោយមិនមានមូល គឺថាមិនបានរង្កៀសសោះ ត្រូវទណ្ឌកម្ម ។

**៥៥ សញ្ចិច្ចៈ** សាមណេរក្លែងបង្កហេតុឲ្យសេចក្តីរង្កៀសសង្ស័យព្រួយចិត្តកើតឡើងដល់ភិក្ខុ ឬសាមណេរឯទៀត សូម្បីមួយស្របក់ ត្រូវទណ្ឌកម្ម ។

**៥៦ ឧបស្សុតិ** កាលបើភិក្ខុ ឬសាមណេរ កំពុងវិវាទ ទាស់ទែងគ្នា សាមណេរទៅលបចាំស្តាប់ដោយគិតថា ភិក្ខុ ឬសាមណេរនោះពោលពាក្យណា អញនឹងស្តាប់ពាក្យនោះហើយប្រាថ្នាចោទលើកទោសផង ត្រូវទណ្ឌកម្ម ។

**៥៧ កម្មប្បដិពាហនៈ** សាមណេរបានឲ្យឆន្ទៈ គឺសេចក្ដីប្រាថ្នាព្រមថាឲ្យសង្ឃកម្មប្រកបដោយធម៌ ហើយមកខាងក្រោយត្រឡប់ពោលទោសតិះដៀលសង្ឃ ដែលធ្វើសង្ឃកម្មនោះវិញ ត្រូវទណ្ឌកម្ម ។
**៥៨ ឆន្ទំ អទត្វា គមនៈ** កាលបើសង្ឃកំពុងប្រជុំគ្នារម្ងាប់អធិករណ៍ ឬ ក៏ពោលទូន្មានវិន័យត្រង់ណាមួយ សង្ឃធ្វើការនៈនៅមិនទាន់ហើយស្រេច សាមណេរមិនទានឲ្យឆន្ទៈហើយចៀសចេញទៅ ត្រូវទណ្ឌកម្ម ។
**៥៩ បរិណាមនៈ** សាមណេរដឹងថា លាភដែលទាយកគេបំរុងនឹងប្រគេន ដល់សង្ឃ ហើយបង្អោនលាភនោះមកដើម្បីបុគ្គលវិញ ត្រូវទណ្ឌកម្ម ។

# សេខិយវត្ត ៧៥

( បិដកលេខ ៤ ទំ.៤៣៥ )

**ឥមេ ខោ បនាយស្មន្តោ (បញ្ចសត្តតិ) សេខិយា ធម្មា ឧទ្ទេសំអាគច្ឆន្តិ** បពិត្រលោកអ្នកមានអាយុទាំងឡាយ! វត្តដែលគប្បីសិក្សាទាំងឡាយ(ចិតសិបប្រាំ)នេះឯងមកកាន់ឧទ្ទេស(គឺការសម្តែងឡើង)។

**១. បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងស្លៀកស្បង់ឱ្យជាបរិមណ្ឌល។(បិ.៤ ទំ.៤៣៥)

**២.បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងដណ្តប់(គឺគ្រង)ចីវរឱ្យជាបរិមណ្ឌល

**៣.សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញនឹងបិទបាំងកាយ(គឺឃ្លុំ)ឱ្យល្អដើរទៅក្នុងចន្លោះ ផ្ទះ។

**៤. សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងបិទបាំងកាយ(គឺឃ្លុំ)ឱ្យល្អអង្គុយក្នុងចន្លោះផ្ទះ។

**៥. សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បី ធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងសង្រួមឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ។

**៦. សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងសង្រួមឱ្យល្អ អង្គុយក្នុងចន្លោះផ្ទះ។

**៧. ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមានភ្នែកសំឡឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ។

**៨. ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តី សិក្សាថា អាត្មាអញ នឹងមានភ្នែកសំឡឹងចុះអង្គុយក្នុងចន្លោះផ្ទះ។

**៩. ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ។

**១០. ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសើយចីវរ អង្គុយក្នុងចន្លោះផ្ទះ។

**បរិមណ្ឌលវគ្គោ បឋមោ បរិមណ្ឌលវគ្គទី១(ចប់)**

**១១. ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បី ធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ។

**១២. ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេ ចក្តីសិក្សាថា អាត្មាអញ នឹងមិនសើចខ្លាំងអង្គុយក្នុងចន្លោះផ្ទះ។

**១៣. អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងនិយាយសំឡេងតិច ដើរទៅក្នុងចន្លោះផ្ទះ។

**១៤. អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងនិយាយសំឡេងតិចអង្គុយក្នុងចន្លោះផ្ទះ។

**១៥. ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនគ្រវែងកាយដើរទៅក្នុងចន្លោះផ្ទះ។

**១៦.ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនគ្រវែងកាយអង្គុយក្នុងចន្លោះផ្ទះ។

**១៧. ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនបង់ហោយដើរទៅក្នុងចន្លោះផ្ទះ។

**១៨. ន ពាហុប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនឆ្កាវដៃអង្គុយក្នុងចន្លោះផ្ទះ។

**១៩. ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ។

**២០. ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនអង្រួនក្បាលអង្គុយក្នុងចន្លោះផ្ទះៗ

**គជ្ជត្ថិកវគ្គោ ទុតិយោ គជ្ជត្ថិកវគ្គទី២(ចប់)។**

**២១. ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនយកដៃស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះៗ

**២២. ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនយកដៃស្ទឹមចង្កេះអង្គុយក្នុងចន្លោះផ្ទះៗ

**២៣. ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះៗ

**២៤. ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនទទូរក្បាលអង្គុយក្នុងចន្លោះផ្ទះៗ

**២៥. ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនចំអើតជើងដើរទៅក្នុងចន្លោះផ្ទះៗ

**២៦.ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញនឹងមិនអង្គុយផ្ទាបោយក្បាលជង្គង់នៅក្នុងចន្លោះផ្ទះៗ

**ឆព្វីសតិ សារុប្បា (ចប់)សារុប្ប២៦ៗ**

**២៧. សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងទទួល(អាហារ)បិណ្ឌបាតដោយគោរពៗ

**២៨. បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងសម្គាល់តែក្នុងបាត្រ ទទួលបិណ្ឌបាតៗ

**២៩. សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងទទួលបិណ្ឌបាតឱ្យល្មមគ្នានឹងសម្លៗ

**៣០.សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញនឹងទទួលបិណ្ឌបាតឱ្យស្មើត្រឹមកណ្តាប់មាត់បាត្រ។

**ខម្ពកវគ្គោ តតិយោ ខម្ពកៈវគ្គទី៣(ចប់)**

**៣១. សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងឆាន់បិណ្ឌបាតដោយគោរព។

**៣២. បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងសម្គាល់តែក្នុងបាត្រឆាន់បិណ្ឌបាត។

**៣៣. សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងឆាន់បិណ្ឌបាតរាងឱ្យស្មើ។

**៣៤. សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងឆាន់បិណ្ឌបាតឱ្យល្មមគ្នានិងសម្ល។

**៣៥. ន ថូបតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនច្របាច់ពីកំពូលបាយ ហើយឆាន់បិណ្ឌបាត។

**៣៦. ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេស្សាមិ ភិយ្យោ កម្យតំ ឧបាទាយាតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន។

**៣៧.ន សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** *កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ កាលមានជំងឺនឹង មិនសូមសម្ល ឬបាយដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់។(បិ.៤.ទំ៤៦១)*

**៣៨. ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញនឹងមិនប្រុងលើកទោសហើយសម្លឹងមើលបាត្រពួកកិច្ចសាមណេរទៃ(បិ.៤.ទំ៤៦២)

**៣៩. នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនធ្វើពំនូតបាយឱ្យធំពេក។

**៥០. បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងធ្វើពំនូតបាយឱ្យជាបរិមណ្ឌលគឺឱ្យមូល។

**សក្កច្ចវគ្គោ ចតុត្ថោ សក្កច្ចវគ្គ ទី៤(ចប់)**

**៥១.ន អនាហដេ កពឡេ មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ កាលពំនូតបាយមិនទាន់មកដល់នឹងមិនបើកទ្វារមាត់ចាំ។

**៥២.ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញកាលឆាន់នឹងមិនញាត់ម្រាមដៃទាំងអស់ចូលទៅក្នុងមាត់។

**៥៣. ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់។

**៥៤. ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឆាន់បោះដុំបាយទៅក្នុងមាត់។(បិ.៤ទំ.៤៦៦)

**៥៥ . ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនឆាន់កាត់ ពំនូតបាយ។

**៥៦. ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនឆាន់ញៀមពំនូតបាយក្នុងថ្ពាល់។

**៥៧.ន ហត្ថនិទ្ធូនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញនឹងមិនឆាន់រលាស់ដៃ។

**៥៨. ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឆាន់ធ្វើគ្រាប់បាយឱ្យជ្រុះរោយរាយ។

**៤៩. ន ជីវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់លៀនអណ្តាត។(បិ.៤.ទំ.៤៦៨)
**៥០. ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឆាន់ធ្វើសូរឱ្យឮផ្លប់ៗ។
**កពឡវគ្គោ បញ្ចមោ** កពឡវគ្គទី ៥ (ចប់) ។
**៥១. ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរគប្បីធ្វើសេចក្តីថាអាត្មាអញនឹងមិនឆាន់ធ្វើសូរឱ្យឮគ្រូកៗ។(បិ.៤ទំ.៤៧១)
**៥២. ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឆាន់លិទ្ធដៃ។
**៥៣. ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឆាន់លិទ្ធបាត្រ។
**៥៤. ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឆាន់លិទ្ធបបូរមាត់។
**៥៥. ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ មានដៃប្រឡាក់ដោយអាមិសនឹងមិនទទួលភាជនៈទឹកសម្រាប់ឆាន់។
**៥៦. ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ។(បិ.៤ទំ.៤៧៦)

**សមត្តឹស ភោជនប្បដិសំយុត្តា** (ចប់) ភោជនប្បដិសំយុត្ត ៣០ គត់។

**៥៧. ន ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺមានឆត្រក្នុងដៃ។(បិ.៤ទំ.៤៧៨)

**៥៨. ន ឧណ្ណបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺមានដំបងក្នុងដៃ។(បិ.៩ទំ.៤៧៩)

**៥៩. ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ មានគ្រឿងសាស្ត្រាក្នុងដៃ។

**៦០.ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺមានគ្រឿងអាវុធក្នុងដៃ។(បិ.៩ទំ.៤៨០)

**សុរុសុរុវគ្គោ ឆដ្ឋោ** សុរុសុរុវគ្គទី៦ (ចប់)។

**៦១. ន បាទុការុឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខាករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺពាក់ទ្រនាប់ជើង។(បិ.៩ទំ.៤៨២)

**៦២. ន ឧបាហនារុឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺពាក់ស្បែកជើង។(បិ.៩ទំ.៤៨២)

**៦៣. ន យានគតស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ នៅលើយាន ។(បិ.៩ទំ.៤៨៣)

**៦៤. ន សយនគតស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺនៅលើដំណេក។(បិ.៩ទំ.៤៨៤)

**៦៥. ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា**

កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយគ្របបោមក្បាលដង្គង់ ។

**៦៦. ន វេដ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ជួតក្បាល ។(បិ.៤ទំ.៤៨៥)

**៦៧. ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ទទូរក្បាល ។(បិ.៤ទំ.៤៨៦)

**៦៨. ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនអង្គុយផ្ទាល់លើផែនដី សម្តែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយលើអាសនៈ។

**៦៩. ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនអង្គុយលើអាសនៈទាប ហើយសម្តែងធម៌ ដល់មនុស្សគ្មានជំងឺអង្គុយលើអាសនៈខ្ពស់។

**៧០.ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនឈរសម្តែងធម៌ដល់មនុស្សគ្មានជំងឺដែលអង្គុយ។ (បិ.៤ទំ.៤៩១)

**៧១. ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** កិច្ចសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនដើរខាងក្រោយ ហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺដើរខាងមុខ។

**៧២. ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមិនដើរក្រៅផ្លូវ ហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺដើរតាមផ្លូវ។

**សោឡស ធម្មទេសនាបដិសំយុត្តា** (ចប់)ធម្មទេសនាបដិសំយុត្ត១៦

**៧៣. ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជំងឺនឹងមិនឈរបន្ទោបង់ឧច្ចារៈឬបស្សាវៈ។

**៧៤. ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា** ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ គ្មានជំងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់។

**៧៥. ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា** ករិស្សាមីតិ សិក្ខា ករណីយា ភិក្ខុសាមណេរ គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជំងឺនឹងមិនបន្ទោបង់ឧច្ចារៈឬបស្សាវៈ ឬក៏ស្តោះទឹកមាត់ដាក់លើទឹក។

**តយោ បកិណ្ណកា និដ្ឋិតា** ចប់បកិណ្ណកៈ៣។

**បាទុកាវគ្គោ សត្តមោ** បាទុកាវគ្គទី៧ (ចប់)។

**ឧទ្ទិដ្ឋា ខោ អាយស្មន្តោ (បញ្ចសត្តតិ) សេខិយា ធម្មា:** បពិត្រលោកអ្នកមានអាយុទាំងឡាយ វត្តដែលគប្បីសិក្សាទាំងឡាយ (ចិតសិបប្រាំ) ខ្ញុំព្រះករុណា បានសម្តែងរួចហើយ។

**តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?** ខ្ញុំព្រះករុណាសូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងសេខិយវត្តទាំងនោះ លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

**ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា?** ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

**តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?** ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

**បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី** លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងសេខិយវត្តទាំងនោះហើយព្រោះហេតុនោះបានជានៅស្ងៀម ៗ

**ឯវមេតំ ធារយាមិ** ខ្ញុំព្រះករុណាសូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ **សេខយា និដ្ឋិតា** ចប់សេក្ខិយវត្ត។

**សង្ឃាទិសេស១៣**

**១ សុក្កវិស្សដ្ឋិ** ភិក្ខុក្លែងញុំាងទឹកសុក្កឲ្យកំរើកចាកទី ត្រូវអាបត្តិសង្ឃាទិសេស។

**២ កាយសំសគ្គ** ភិក្ខុមានតម្រេក ចាប់ពាល់កាយស្ត្រី ត្រូវអាបត្តិសង្ឃាទិសេស

**៣ ទុដ្ឋុល្លវាចា** ភិក្ខុមានតម្រេកនិយាយពាក្យអាក្រក់ចំពោះនិមិត្តស្ត្រី ត្រូវអាបត្តិសង្ឃាទិសេស។

**៤ អត្តកាមបារិចរិយា** ភិក្ខុមានតម្រេក និយាយល្បួងស្ត្រីឲ្យបំរើខ្លួនដោយកាម ត្រូវអាបត្តិសង្ឃាទិសេស។

**៥ សញ្ចរិត្តៈ** ភិក្ខុនិយាយដឹកនាំឲ្យបុរសនិងស្ត្រី ឲ្យបានគ្នាជាប្តីប្រពន្ធ ត្រូវអាបត្តិសង្ឃាទិសេស។

**៦ សញ្ញាចិកាយៈ** ភិក្ខុធ្វើកុដិបូកដោយកំបោរ ឬដីស្អិត មិនមានអ្នកណាជាម្ចាស់របស់សម្រាប់ជាទីនៅរបស់ខ្លួន ត្រូវធ្វើឲ្យត្រូវនិងប្រមាណ គឺបណ្តោយ ១២ចំអាម ទទឹង៧ចំអាម ដោយចំអាមព្រះសុគត កាលដែលនឹងធ្វើនោះ ត្រូវឲ្យសង្ឃសម្តែងទីឲ្យជាមុនសិន បើមិនបានឲ្យសង្ឃសម្តែងឲ្យក្តី ធ្វើឲ្យកន្លងហួសប្រមាណក្តី ត្រូវអាបត្តិសង្ឃាទិសេស។

**៧ មហល្លកៈ** បើកុដិដែលធ្វើនោះ មានទាយកជាម្ចាស់របស់ធ្វើឲ្យយកកន្លងហួសប្រមាណនោះបាន ប៉ុន្តែត្រូវឲ្យសង្ឃសម្តែងទីឲ្យជាមុន បើមិនបានឲ្យសង្ឃសម្តែងទីឲ្យ ត្រូវអាបត្តិសង្ឃាទិសេស។

**៨ អមូលកៈ** ភិក្ខុក្រោធខឹង នឹងភិក្ខុឯទៀតហើយក្លែងចោទគេដោយអាបត្តិបារាជិក មិនមានមូល ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេស។

**៩ អញ្ញភាគិយៈ** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយក្លែងរកលេសមកចោទគេដោយអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេស។

**១០ សង្ឃភេទៈ** ភិក្ខុព្យាយាមបៅបែកសង្ឃឲ្យបែកគ្នាភិក្ខុដទៃហាមប្រាមមិន

ស្តាប់ សង្ឃបានសូត្រ សមនុភាសនកម្មដើម្បីឲ្យលះបង់ បើមិនព្រមលះបង់ត្រូវអាបត្តិសង្ឃាទិសេស។

**១១ នានានុវត្តកៈ** ភិក្ខុប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃ ភិក្ខុដទៃហាមប្រាមដើម្បីឲ្យលះបង់ បើមិនព្រមលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។

**១២ ទុព្វចជាតកៈ** ភិក្ខុមានជាតិជាអ្នកប្រដៅក្រ ភិក្ខុឯទៀតឃាត់មិនស្តាប់ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់ បើមិនព្រមលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។

**១៣ កុលទូសកៈ** ភិក្ខុទ្រុស្តត្រកូល គឺភិក្ខុប្រព្រឹត្តិអាក្រក់ប្រុចុកផ្តាប់ផ្គុនគ្រហស្ថ សង្ឃបានបណ្តេញចេញពីវត្ត ហើយត្រឡប់មកតិះដៀលសង្ឃវិញ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់ បើមិនព្រមលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ ***តាំងពីទី១ដល់ទី៩សិក្ខាបទនេះឈ្មោះថា បឋមាបត្តិកា ព្រោះត្រូវអាបត្តិក្នុងខណៈប្រព្រឹត្តិកន្លងដំបូង ក្រៅពីនេះ៤សិក្ខាបទទៀតឈ្មោះថាយាវតតិយកា ព្រោះត្រូវអាបត្តិ ក្នុងខណៈដែលសង្ឃបានសូត្រសមនុភាសនកម្មរួច។***

# គោលព្រះវិន័យសូត្រឆ្នាំទី១

## អ្នកបួស១៣យ៉ាងមិនចម្រើនដល់សាសនា

១ អ្នកបួសមិនធ្វើសង្ឃកម្មមានឧបោថសកម្មជាដើម

២ អ្នកបួសមិនបដិបត្តិតាមធម៌វិន័យ

៣ អ្នកបួសល្ងង់ខ្លៅធ្វើធំ តែមិនស្តាប់អ្នកដទៃ

៤ អ្នកបួសមិនយកធម៌វិន័យជាធំ

៥ អ្នកបួសមិនអានព្រះត្រៃបិដក

៦ អ្នកបួសមិនរៀនសូត្រនូវពុទ្ធវចនៈ ហើយរៀនតែវិជ្ជាក្រៅសាសនា

៧ អ្នកបួសមិនគោរពគ្រូអាចារ្យ ឬអ្នកមានវស្សាចាស់ជាងខ្លួន

៨ អ្នកបួសច្រណែនគ្នាព្រោះតែយកប្រយោជន៍ខ្លួនជាធំ

៩ អ្នកបួសយកសាសនាធ្វើជាអាជីកម្ម

១០ អ្នកបួសមិនមាន ហិរិនិងឱត្តប្ប

១១ អ្នកបួសរៀនសូត្រមិនប្រាថ្នាឱ្យរួចចាកទុក្ខប្រាថ្នាតែលាភសក្ការៈ

១២ អ្នកបួសរៀនតិរច្ឆានវិជ្ជា គឺទទឹងនឹងសាសនាព្រោះមិនជឿកម្មផល

១៣ អ្នកបួសប្រព្រឹត្តិបាបធម៌  និងអនេសនៈ៕

ចង្រៃធំៗក្នុងសាសនា៤យ៉ាង

១ អ្នកបួសសេពមេថុនធម្ម

២ អ្នកបួសផឹកសូរា

៣ អ្នកបួសកាន់ប្រើប្រាស់រូបិយដោយខ្លួនឯង

៤ អ្នកបួស

## អន្តរាយរបស់ភិក្ខុសាមណេរបួសថ្មី៤យ៉ាង

១.អត់ធន់ចំពោះការទូន្មានមិនបាន ខ្ជិលធ្វើតាម
២.ជាមនុស្សឃើញតែការបរិភោគជាប្រមាណអត់ធន់
សេចក្តីស្រេកឃ្លានមិនបាន
៣.ត្រេកអរក្នុងកាមគុណចង់បានសេចក្តីសុខលើសលប់ឡើងទៅ
៤.ស្រលាញ់ស្ត្រីភាព។

## សមណត្រូវប្រកបដោយអង្គ៤យ៉ាង

**១.ខន្តី** ត្រូវមានសេចក្តីអត់ធន់
**២.អប្បមាទោ** ត្រូវកុំប្រហែសធ្វេសក្នុងកុសលធម៌
**៣.នេក្ខម្មំ** ការលះបង់នូវសេចក្តីត្រេកអរក្នុងវត្ថុកាមនិងកិលេសកាម
**៤.អកិញ្ចនំ** ឥតខ្វល់ខ្វាយក្នុងកិច្ចការដែលឥតប្រយោជន៍។

## ភិក្ខុក្រាលកឋិនបានអានិសង្ស៥យ៉ាង

**១/ អនាមន្តចារោ** ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា
**២/អសមាទានចារោ** ត្រាច់ទៅណាមិនបាច់យកចីវរគ្រប់ប្រដាប់ទៅ
**៣/យាវទត្ថចីវរំ** ទុកដាក់អតិរេកចីវរតាមត្រូវការមិនបាច់អធិដ្ឋាន ឬវិកប្ប
**៤ / គណភោជនំ** ឆាន់គណភោជនបាន
**៥/យោ ច តត្ថ ចីវរុប្បាទោ តស្មឹ អាវាសេ សង្ឃស្ស ឧប្បន្នចីវរំ**
ចីវរណាកើតឡើងក្នុងអាវាសនោះ គឺចីវរដែលកើតឡើងដល់សង្ឃក្នុងអាវាស
នោះរមែងបានដល់លោក។( កង្ខា.១/១៧២ )

## អ្នកធ្វើកឋិនបានអានិសង្ស ៦យ៉ាង

**១/ សុវណ្ណតា** រមែងមានពណ៌សម្បុរល្អស្អាត
**២/ សុរូបតា** រមែមានរូបល្អ
**៣/ សុសណ្ឋានតា** រមែងមានសណ្ឋានទ្រង់ទ្រាយល្អ

៤/ តិក្ខប្បញ្ញោ ជីសាវនោ រមែងជាអ្នកមានបញ្ញាខ្លាវក្លា

៥/ ចក្កពត្តិរាជា៖ នឹងបានជាស្តេចចក្រពត្តិ

៦/ ឯហិភិក្ខុ ឧបសម្បទា៖ រមែងបានបួសជាឯហិភិក្ខុ

**អង្គប្រគេនមាន៥យ៉ាង**

(សមន្ត ៤/២២៥)

១ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ របស់ល្មមបុរសមានកម្លាំងយ៉ាងកណ្តាលលើករួច

២ ហត្ថបាសោ បញ្ញាយតិ ហត្ថបាសប្រាកដ(ទាយកោអឌ្ឍតេយ្យហត្ថប្បមាណេ ឱកាសេ ហោតិ ទាយកស្ថិតនៅក្នុងឱកាសប្រមាណ២ ហត្ថ ១ ចំអាម ឈ្មោះថាហត្ថបាសប្រគេន)

៣ អភិហារោ បញ្ញាយតិ គេបង្អោនប្រាកដ(រុញផ្អៀងលើកចូលទៅ)

៤ ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា ទេតិ ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តីប្រគេន

៥ តំ បន ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ ភិក្ខុទទួលរបស់នោះដោយកាយក្តី ឬរបស់ជាប់ដោយកាយក្តី។

**ការដាច់ប្រគេនមាន ៧យ៉ាង**

១.លិង្គបរិវត្តនេន ព្រោះត្រឡប់ភេទ

២.កាលកិរិយាយ ព្រោះធ្វើកាលកិរិយា

៣.សិក្ខាបច្ចក្ខានេន ព្រោះពោលលាសិក្ខា

៤.ហីនាយាវត្តនេន ព្រោះត្រឡប់ទៅកាន់ភេទថោកទាប

៥.អនុបសម្បន្នស្ស ទានេន ព្រោះឱ្យដល់អនុប្បសម្បន្ន

៦.អនបេក្ខវិស្សជ្ជនេន ព្រោះមិនស្តាយលះបង់

**៧.អច្ឆិន្ទិត្វា គាហេន ច វិជ្ជាហិ** ព្រោះត្រូវចោរដណ្តើមយកទៅ។(អដ្ឋកថា៣/២១៤)(សមន្តភាគ២)

**អកប្បិយវត្ថុ វត្ថុដែលភិក្ខុមិនគួរឆាន់មាន៥យ៉ាង**

**១.អទិន្នញ្ច ហោតិ** របស់ដែលគេមិនបានឱ្យ

**២.អវិទិតញ្ច ហោតិ** របស់ដែលភិក្ខុមិនស្គាល់ជាក់លាក់

**៣.អកប្បិយញ្ច ហោតិ** របស់ដែលមិនគួរ

**៤.អប្បដិគ្គហិតញ្ច ហោតិ** របស់ដែលមិនបានទទួលប្រគេន

**៥.អកតាតិរិត្តញ្ច ហោតិ** របស់ដែលភិក្ខុមិនបានធ្វើវិនយកម្ម។

**ភោជន៥យ៉ាង**

( បិ.៤/១២៣ )

**១/ ឱទនោ** បាយ

**២/ កុម្មាសោ** នំស្រស់

**៣/ សត្តុ** នំក្រៀម

**៤/ មច្ឆោ** ត្រី

**៥/ មំសំ** សាច់

**ប្រយោគនៃបាណាតិបាត៦យ៉ាង**

**១/ សាហត្ថិក** សម្លាប់ដោយដៃខ្លួនឯង

**២/ អាណត្តិក** សម្លាប់ដោយប្រើគេ

**៣/ និស្សគ្គិយ** សម្លាប់ដោយវត្ថុចោលឬគ្រវែង

**៤/ ថាវរ** សម្លាប់ដោយវត្ថុមាំមួន

**៥/វិជ្ជាមយ** សម្លាប់ដោយវិជ្ជា

**៦/ ឥទ្ធិមយ** សម្លាប់ដោយឫទ្ធិ។

**គ្រឿងកំណត់នៃការប្រើមាន ៦ យ៉ាង**

(វត្ថុ កាល ឱកាស អាវុធ ឥរិយាបថ  កិរិយាវិសេស)

**១. វត្ថុនិយាម**   កំណត់វត្ថុ គឺកំណត់បុគ្គលដែលត្រូវសម្លាប់

**២. កាលនិយាម** កំណត់ពេល គឺកំណត់ពេលថ្ងៃ ឬយប់ជាដើម

**៣.ឱកាសនិយាម** កំណត់ឱកាស គឺកណត់ទីកន្លែង ដែលសត្វរស់នៅ មានស្រុកជាដើម

**៤. អាវុធនិយាម** កំណត់អាវុធ គឺមានដាវ លំពែង ជាដើម

**៥. ឥរិយាបថនិយាម**  កំណត់ឥរិយាបថណាមួយ

**៦. កិរិយាវិសេសនិយាម** កំណត់កិរិយាដ៏វិសេសមានចាក់ ឬកាប់ជាដើម។

**អាទានៈ  អាការៈលួច២៥យ៉ាង**

**ចែកចេញជាពួកមាន៥ពួក នានាភណ្ឌបញ្ចកៈ ពួកទី១**

| | |
|---|---|
| **១/ អាទិយេយ្យ** | គប្បីដណ្តើមយក |
| **២/ ហរេយ្យ** | គប្បីនាំទៅ |
| **៣/ អវហរេយ្យ** | គប្បីឆបោក |
| **៤/ ឥរិយាបថំ វិកោបេយ្យ** | គប្បីញុំាងឥរិយាបថឲ្យកម្រើក |
| **៥/ ឋានាចាវេយ្យ** | គប្បីឲ្យឃ្លាតចាកឋាន។ |

**ឯកភណ្ឌបញ្ចកៈ ពួកទី២**

ឯកភណ្ឌបញ្ចកៈ មាន៥ដូចគ្នានឹងនានាភណ្ឌបញ្ចកៈពួកទី១ដែរ ប៉ុន្តែឯកភណ្ឌបញ្ចកៈនេះសំដៅយកការលួចទ្រព្យដែលមានវិញ្ញាណតែម្យ៉ាង។

**សាហត្ថិកបញ្ចកៈ ពួកទី៣**

**១១/ សាហត្ថិក**   ការលួចដោយដៃខ្លួនឯង

**១២/ អាណត្តិក**  ការលួចដោយប្រើគេ

**១៣/ និស្សគ្គិយ**   ការលួចដោយបោះ ឬគ្រវែងទៅ

**១៤/ អត្ថសាធក** ការលួចដោយញុំាងប្រយោជន៍ឲ្យសម្រេច

**១៥/ ធុរនិក្ខេប** ការលួចកំណត់ដោយការដាក់ធុរៈ

**បុព្វប្បយោគបញ្ចកៈ ពួកទី៤**

**១៦/ បុព្វប្បយោគ** ប្រយោគខាងដើម

**១៧/ សហប្បយោគ** ប្រយោគព្រមគ្នា

**១៨/ សំវិធាវហារ** ការបបួលរួមគ្នាលួច

**១៩/ សង្កេតកម្ម** ធ្វើការកំណត់

**២០/ និមិត្តកម្ម** ធ្វើនិមិត្ត។

**ថេយ្យាវហារបញ្ចកៈ ពួកទី៥**

**២១/ ថេយ្យាវហារ** លួចដោយភាពជាចោរ

**២២/ បសយ្ហាវហារ** លួចដោយកំហែង

**២៣/ បរិកប្បាវហារ** លួចដោយកំណត់ទ្រព្យ និងទីកន្លែង

**២៤/ បដិច្ឆន្នាវហារ** លួចដោយបំបិទបំបាំង

**២៥/កុសាវហារ** លួចដោយផ្លាស់ប្តូរស្លាក។

(អដ្ឋកថា ទុតិយបារាជិក/កង្ខា.១/៨១)

**គរុភណ្ឌមាន៥ពួក**

ពួកទី១ **អារាមោ** សួនច្បារ **អារាមវត្ថុ**ទីដីដាំសួនច្បារ

ពួកទី២ **វិហារោ** លំនៅ **វិហារវត្ថុ** ទីដីសម្រាប់សង់លំនៅ

ពួកទី៣ **មញ្ចោ** គ្រែ **បីឋំ** តាំងឬកៅអី **ភិសិ** ពូក **ពិម្ពោហនំ** ខ្នើយ

ពួកទី៤ **លោហកុម្ភី** ឆ្នាំងដែលធ្វើពីលោហជាតិ **លោហភាណកំ** ខ្ទះលោហៈ **លោហវារកោ** ក្អមលោហៈ **លោហកដាហំ** ផើងលោហៈ **វាសិ** កាំបិត **ផរសុ** ពូថៅ **កុឋារី** ដឹងចាំងកុទ្ធាលោ ចប **និខាទនំ** ពន្លាកឬដែកកណ្តារ

**ពួកទី៥ខល្លិ វល្លិ ខេឡ ឫស្សី មុញ្ជ ស្មៅដំណេកទន្សាយចព្វជ ស្មៅយាប្លង តិណស្មៅធម្មតាមត្តិការដីស្អិតឆារុតណ្ឌុំគ្រឿងឈើមត្តិភាតណ្ឌុំ គ្រឿងធ្វើពីដី។**

## ភូតគាម៥យ៉ាង

(បិ.៣/៣៤៩)

**១.មូលពីជំ** ពូជកើតពីមើមឬឫស

**២.ខន្ធពីជំ** ពូជកើតពីដើម

**៣.ផឡុពីជំ** ពូជកើតពីថ្នាំង

**៤.អគ្គពីជំ** ពូជកើតពីចុងឬគល់

**៥.ពីជពីជំ** ពូជកើតពីផ្លែឬគ្រាប់

## សំពត់ដែលទ្រង់អនុញ្ញាតឱ្យធ្វើចីវរមាន៦យ៉ាង

(កង្ខា.១/១៧២)

**១.ខោមំ** សំពត់សំបកឈើ

**២.កប្បាសិកំ** សំពត់កប្បាស

**៣.កោសេយ្យំ** សំពត់សូត្រ

**៤.កម្ពលំ** សំពត់រោមសត្វ វៀររោមមនុស្ស និងសក់មនុស្ស

**៥.សាណំ** សំពត់សំបកធ្មៃ

**៦.ភង្គំ** សំពត់ដែលធ្វើលាយដោយវត្ថុទាំង៥ខាងដើម។

## ចីវររជនំ ទឹកជ្រលក់ចីវរមាន៦យ៉ាង

**១.មូលរជនំ** ទឹកជ្រលក់កើតពីមើម វៀរតែមើមរមៀត

**២.ខន្ធរជនំ** ទឹកជ្រលក់កើតពីដើម វៀរតែដើមស្លែង និងដើមឃ្លៃ

**៣.តចរជនំ** ទឹកជ្រលក់កើតពីសំបក វៀរតែសំបកព្រហូត

**៤.បត្តរជនំ** ទឹកជ្រលក់កើតពីស្លឹក វៀរតែស្លឹកមក្លឿ និងស្លឹកត្រុំ

**៥.បុប្ផរជនំ** ទឹកជ្រលក់កើតពីផ្កា វៀរតែផ្កាចា និងផ្កាដកគាំ

**៦.ផលរជនំ** ទឹកជ្រលក់កើតពីផ្លែ។

**អគោចរដ្ឋាន ទីមិនគួរត្រាច់ទៅ៦យ៉ាង**

**១.វេសិយាគោចរោ** កន្លែងស្រីពេស្យា

**២.វិធវាគោចរោ** កន្លែងស្រីមេម៉ាយ

**៣.ថុល្លកុមារីគោចរោ** កន្លែងក្រមុំចាស់

**៤.បណ្ឌកគោចរោ** កន្លែងខ្ទើយ

**៥.ភិក្ខុនិគោចរោ** កន្លែងភិក្ខុនី

**៦.បានគារគោចរោ** កន្លែងរោងសុរា។

**បណីតភោជន៩យ៉ាង**

**១.សប្បិ** ទឹកដោះថ្លា

**២.នវនីត** ទឹកដោះខាប់

**៣.តេលំ** ប្រេង

**៤.មធុ** ទឹកឃ្មុំ

**៥.ផាណិតំ** ស្ករអំពៅ

**៦.មច្ឆោ** ត្រី

**៧.មំសំ** សាច់

**៨.ខីរំ** ទឹកដោះស្រស់

**៩.ទធិ** ទឹកដោះជូរ។

**អង្គនៃចីវរ៩យ៉ាង**

**១.កុសិ** ចម្រៀកវែង

**២.អឌ្ឍកុសិ** ចម្រៀកខ្លី

**៣.មណ្ឌលំ** កន្សែងធំ

**៤.អឌ្ឍមណ្ឌលំ** កន្សែងតូច

**៥.ឋិវង្គ** ផ្ទាំងកណ្តាល

**៦.អនុឋិវង្គ** ផ្ទាំងអម

**៧.ពាហន្តំ** ផ្ទាំងខាងចុង(សំពត់រុំដើមដៃ)

**៨.ឧឌ្ឍេយ្យកំ** សំពត់គ្របស្មង

**៩.គីវេយ្យកំ** សំពត់ព័ទ្ធត្រង់ក។

**បរិក្ខារ ៨ យ៉ាងរបស់ភិក្ខុ**

**១.សង្ឃាដី** សង្ឃាដី

**២.ឧត្តរាសង្គោ** ចីវរ

**៣.អន្តរវាសកោ** ស្បង់

**៤.បត្តោ** បាត្រ

**៥.សត្ថកេសរោ** កាំបិតកោរ

**៦.សុចិឃរំ** បំពង់ម្ជុល

**៧.កាយពន្ធនំ** វត្ថពន្ធចង្កេះ

**៨.ធម្មករកំ** ធម្មក្រក ឬសម្លត់តម្រងទឹក

**កប្បិយៈចីវរ៩យ៉ាង**

**១.សង្ឃាដី** សង្ឃាដី

**២.ឧត្តរាសង្គោ** ចីពរ

**៣.អន្តរវាសកោ** ស្បង់

**៤.វស្សិកសាដិកោ** សំពត់ចំណាំវស្សា

**៥.និសីទនំ** សំពត់ទ្រាប់អង្គុយ

**៦.បច្ចត្ថរណំ** កម្រាល

**៧.កណ្ឌុប្បដិច្ឆាទិ** សំពត់គ្របបូស ឬកម

**៨,មុខបុញ្ឆនំ** សំពត់ជូតមុខ

**៩.បរិក្ខារចោឡំ** សំពត់បរិក្ខាររាយរង។

**ចីវរជាអកប្បិយៈ ភិក្ខុមិនគួរប្រើប្រាស់១០យ៉ាង**

**១.សព្វនីលកំ** ចីវរខៀវសុទ្ធ

**២.សព្វបីតកំ** ចីវរលឿងសុទ្ធ

**៣.សព្វលោហិតកំ** ចីវរក្រហមសុទ្ធ

**៤.សព្វមញ្ជេដ្ឋកំ** ចីវរពណ៌ហង្សបាទសុទ្ធ

**៥.សព្វកណ្ហំ** ចីវរខ្មៅសុទ្ធ

**៦.សព្វមហារង្គរត្តំ** ចីវរក្រហមក្រមៅសុទ្ធដូចពណ៌ខ្នងក្អែប

**៧.សព្វមហានាមរត្តំ** ចីវរលឿងទុំសុទ្ធដូចពណ៌ផ្កាឈូក

**៨.អច្ឆិន្នទសំ** ចីវរមានជាយមិនបានកាត់ចេញ

**៩.ទីឃទសំ** ចីវរមានជាយវែង

**១០.បុប្ផទសំ** ចីវរមានជាយជាផ្កាឈើ។

**ចីវរមាន៤យ៉ាង**

**១. ចីវរបញ្ចខណ្ឌ** ចីវរខណ្ឌ៥មានកន្សែង១០

**២. ចីវរសត្តខណ្ឌ** ចីវរខណ្ឌ៧ មានកន្សែង១៤

**៣. ចីវរនវខណ្ឌ** ចីវរខណ្ឌ៩មានកន្សែង១៨

**៤. ចីវរឯកាទសខណ្ឌ** ចីវរខណ្ឌ១១មានកន្សែង២២។

**អក្កោសវត្ថុ ១០ យ៉ាង**(បិដក ៣. ទំ២៤០) *(សេចក្ដីពន្យល់មាននៅក្នុងបិដក)*

(ជាតិ ឈ្មោះ ត្រកូលការងារសិល្បសាស្ត្រ អាពាធ ភេទ កិលេស អាបត្តិ និងពាក្យជេរ)

**១/ជាតិយាបិ** ដោយជាតិ

**២/នាមេនបិ** ដោយនាម(ឈ្មោះ)

**៣/គោត្តេនបិ** ដោយគោត្ត(ត្រកូល)

**៤/កម្មេនបិ** ដោយការងារ

**៥/សិប្បេនចិ** ដោយសិល្បសាស្ត្រ

**៦/អាពាធេនចិ** ដោយអាពាធ

**៧/លិង្គេនចិ** ដោយភេទ

**៨/កិលេសេនចិ** ដោយកិលេស

**៩/អាបត្តិយាចិ** ដោយអាបត្តិ

**១០/ហីនេនចិ** ដោយពាក្យជេរដ៏ថោកទាប។

# ពាក្យថាវិន័យ

**កាយវាចាយោ វិនេតិ ទមេតីតិ=វិនយោ (សភាវោ)** (សភាវៈ)ឯណាទូន្មាន នូវកាយ និង វាចាសភាវៈនោះឈ្មោះថាវិន័យ។

## ប្រយោជន៍វិន័យ១០យ៉ាង

*(បិដកលេខ២៣ ទំព័រ១១១)*

**១.សង្ឃសុដ្ឋុតាយ** ដើម្បីសេចក្តីល្អដល់សង្ឃ

ដើម្បីសេចក្តីល្អដល់សង្ឃ

ដើម្បីសេចក្តីល្អដល់សង្ឃ

**២.សង្ឃផាសុតាយ** ដើម្បីសេចក្តីស្រួលដល់សង្ឃ

ដកដើម្បីសេចក្តីស្រួលដល់សង្ឃ

**៣.ទុម្មង្គូនំ បុគ្គលានំ និគ្គហាយ** ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលទ្រុស្តសីល

**៤.បេសលានំ ភិក្ខូនំផាសុវិហារាយ** ដើម្បីកិរិយានៅជាសុខ ដល់ភិក្ខុទាំងឡាយអ្នកមានសីលជាទីស្រឡាញ់

**៥.ទិដ្ឋធម្មិកានំអាសវានំសំវរាយ**ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន

**៦.សម្បរាយិកាន អាសវានំបដិឃាតាយ** ដើម្បីហាមឃាត់នូវអាសវធម៌ទាំងឡាយក្នុងបរលោក

**៧.អប្បសន្នានំបសាទាយ** ដើម្បីញុំាងជនដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើង

**៨.បសន្នានំ ភិយ្យោភាវាយ** ដើម្បីញុំាងជនដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើង

**៩.សទ្ធម្មដ្ឋិតិយា** ដើម្បីឱ្យព្រះសទ្ធម្មតម្កល់នៅមាំ

**១០.វិនយានុគ្គហាយ** ដើម្បីអនុគ្រោះដល់ព្រះវិន័យ

## អានិសង្សអ្នកទ្រទ្រង់វិន័យ៥យ៉ាង

**១.អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ** វិន័យធរភិក្ខុ មានសីលក្ខន្ធរបស់ខ្លួន គ្រប់គ្រងល្អហើយ រក្សាត្រឹមត្រូវហើយគឺថាមិនត្រូវអាបត្តិតូចធំ

**២.កុក្កុច្ចប្បកតានំ បដិសរណំ ហោតិ** វិន័យធរភិក្ខុ នឹងបានជាទីពឹងរបស់ភិក្ខុទាំងឡាយ ដែលមានសេចក្តីសង្ស័យ

**៣.វិសារទោ សង្ឃមជ្ឈេ វោហរតិ** វិន័យធរភិក្ខុនឹងជាអ្នកក្លៀវក្លាក្នុងកណ្តាលជំនុំសង្ឃ

**៤.បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ** វិន័យធរភិក្ខុជាអ្នកសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលជាសត្រូវនិងព្រះសាសនដោយសហធម៌គឺពាក្យប្រកបដោយហេតុបាន

**៥.សទ្ធម្មដ្ឋិតិយាបដិបន្នោហោតិ** វិន័យធរភិក្ខុជាអ្នកប្រតិបត្តិដើម្បីឱ្យព្រះសទ្ធម្មតម្កល់នៅមាំ។

## អ្នកបួស៦យ៉ាង

**១.ឧបកីឡិកា** បួសពេញចិត្តនឹងការលេង

**២.ឧបទុស្សិកា** បួសទ្រុស្តសីល ទ្រុស្តសាសនា

**៣.ឧបមុយ្ហិកា** បួសល្ងង់ខ្លៅ

**៤.ឧបជីវិកា** បួសគ្រាន់តែចិញ្ចឹមជីវិត

**៥.ឧបចិណ្ណកា** បួសសន្សំទ្រព្យ

**៦.ឧបនិស្សរណា** បួសដើម្បីរលាស់ខ្លួនចេញចាកភព។

## បរិភោគ៤យ៉ាង

**១.ថេយ្យបរិភោគ** បរិភោគដោយការលួច

**២.ឥណបរិភោគ** បរិភោគដោយបំណុល

**៣.ទាយជ្ជបរិភោគ** បរិភោគនូវមត៌កដែលត្រូវទទួលបាន

**៤.សាមិបរិភោគ** បរិភោគរបស់ជនជាម្ចាស់។

## បាបធម៌៥យ៉ាង

**១.កុហនា** ការកុហកដោយឫកពារ

**២.លបនា** ការនិយាយរាក់ទាក់ដោយវាចា

**៣.នេមិត្តិកតា**ការធ្វើនិមិត្តគឺប្រើឧបាយកលដោយកាយខ្លះដោយវាចាខ្លះ

**៤.និប្បេសិកតា** ការពោលគម្រាមឬសង្កត់គឺប្រើសម្តីជាខ្នោសកោសការយកលាភ

**៥.លាភេន លាភំ និជិគីសនតា** ការរកលាភដោយលាភ គឺយកលាភទៅទាក់លាភ

## អនេសនៈ២១

**១.វេឡុទានំ** ការឱ្យឫស្សី

**២.បត្តទានំ** ការឱ្យស្លឹកឈើ

**៣.បុប្ផទានំ** ការឱ្យផ្កាឈើ

**៤.ផលទានំ** ការឱ្យផ្លែឈើ

**៥.ទន្តកដ្ឋទានំ** ការឱ្យឈើស្ទន់

**៦.មុខោទកទានំ** ការឱ្យទឹកលុបមុខ

**៧.សិនានទានំ** ការឱ្យវត្ថុសម្រាប់ងូត សម្រាប់កក់

**៨.ចុណ្ណទានំ** ការឱ្យគ្រឿងលម្អិតសម្រាប់លាប

**៩.មត្តិកទានំ** ការឱ្យដីស្អិត

**១០.ចាដុកម្យតា** ការប្រព្រឹត្តបន្ទាបកាយវាចា

**១១.មុគ្គសូបតា** ការពោលពិតខ្លះ មិនពិតខ្លះដូចសម្លសណ្តែកបាយ

**១២.បរិភដ្យតា** ការផ្គាប់ផ្គុនត្រកូល

**១៣.ជង្ឃបេសនិកំ** ការបម្រើត្រកូលដោយកម្លាំងស្មង

**១៤.វេជ្ជកម្មំ** ការធ្វើពេទ្យមើលជំងឺ

**១៥.ទូតកម្មំ** ការធ្វើទូត

**១៦.បហិណគមនំ** ការទទួលបម្រើត្រកូលឱ្យគេប្រើទៅមក

**១៧.មិណ្ឌប្បដីបណ្ណិកំ** ការឱ្យអាហារបិណ្ឌបាតដល់ត្រកូល ហើយស្វែងរកបរិភោគដោយខ្លួនឯងជាខាងក្រោយ

**១៨.ទានូបទានំ** ការឱ្យទៅវិញទៅមក

**១៩,វត្ថុវិជ្ជា** ការរៀនវិជ្ជាធ្វើគ្រូមើលទីដីជ័យភូមិ

**២០.នក្ខត្តវិជ្ជា** ការរៀនវិជ្ជាធ្វើគ្រូមើលនក្ខត្តឫក្ស

**២១.អង្គវិជ្ជា** ការរៀនវិជ្ជាធ្វើគ្រូទាយលក្ខណៈរូបរាងកាយ។

**អកប្បិយមំសៈសាច់មិនគួរឆាន់១០យ៉ាង**

**១.មនុស្សមំសៈ** សាច់មនុស្ស

**២.ហត្ថិមំសៈ** សាច់ដំរី

**៣.អស្សមំសៈ** សាច់សេះ

**៤.សុនខមំសៈ** សាច់ឆ្កែស្រុក

**៥.តរច្ឆមំសៈ** សាច់ខ្លារខិន

**៦.អហិមំសៈ** សាច់ពស់

**៧.សីហមំសៈ** សាច់សីហៈ

**៨.ព្យគ្ឃមំសៈ** សាច់ខ្លាធំ

**៩.ទីបិមំសៈ** សាច់ខ្លាដំបង

**១០.អច្ឆមំសៈ** សាច់ខ្លាឃ្មុំ ។

**បច្ចវេក្ខណកាលៈ កាលនៃការពិចារណា៣យ៉ាង**

**១.បដិលាភកាលៈ** កាលកំពុងបាន កំពុងទទួល

**២.បរិភោគកាលៈ** កាលកំពុងប្រើប្រាស់ កំពុងឆាន់

**៣.អតីតកាលៈ** កាលដែលបានបរិភោគប្រើប្រាស់រួចហើយ ។

**បច្ចវេក្ខណវិធី  វិធីពិចារណា ៤យ៉ាង**

**១.ធាតុប្បច្ចវេក្ខណៈ** ពិចារណាឱ្យឃើញថា គ្រាន់តែជាធាតុ

**២.បដិកូលប្បច្ចវេក្ខណៈ** ពិចារណាឱ្យឃើញថា ជាគ្រឿងបដិកូល

**៣.តំខណិកប្បច្ចវេក្ខណៈ**ពិចារណាក្នុងខណៈកំពុងបរិភោគកំពុងប្រើប្រាស់

**៤.អតីតប្បច្ចវេក្ខណៈ** ពិចារណាក្នុងពេលដែលបានបរិភោគប្រើប្រាស់រួចហើយ

**អវន្ទិយបុគ្គល  បុគ្គលដែលមិនគួរសំពះថ្វាយបង្គំមាន២៥ប្រភេទ**

**១.អន្តរឃរំ បវិដ្ឋោ** ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ

**២.រច្ឆគតោ** ភិក្ខុកំពុងដើរតាមច្រកល្ហក

**៣.ឱតមសិតោ** ភិក្ខុកំពុងនៅក្នុងទីងងឹត

**៤.អសមន្នាហរន្តោ** ភិក្ខុកំពុងខ្វល់ខ្វាយក្នុងកិច្ចការអ្វីមួយ

**៥.សុត្តោ** ភិក្ខុកំពុងសិងលក់

**៦.យាគុបានេ** ភិក្ខុកំពុងឆាន់បបរ

**៧ខាទន្តោ** ភិក្ខុកំពុងឆាន់ខាទនីយ

**៨.ភុញ្ជន្តោ** ភិក្ខុកំពុងឆាន់ភោជនីយ

**៩.ភត្តគ្គេ** ភិក្ខុកំពុងនៅក្នុងរោងភត្ត

**១០.ឯកាវត្តោ** ភិក្ខុជាសត្រូវនឹងគ្នា

**១១.អញ្ញវិហិតោ** ភិក្ខុកំពុងភាំងគំនិតគិតអ្វីមួយ

**១២.ឧច្ចារំ ករោន្តោ** ភិក្ខុកំពុងបន្ទោបង់ឧច្ចារៈ

**១៣.បស្សាវំ ករោន្តោ** ភិក្ខុកំពុងបន្ទោបង់បស្សាវៈ

**១៤.នគ្គោ** ភិក្ខុអាក្រាត

**១៥.ឧក្ខិត្តកោ** ភិក្ខុដែលសង្ឃលើកវត្ត

**១៦.បច្ឆា ឧបសម្បន្នោ** ភិក្ខុបានឧបសម្បទាក្រោយ

**១៧.អនុបសម្បន្នោ** អនុបសម្បន្ន

**១៨.នានាសំវាសកោ ឧុឡ្ហតរោ អធម្មវាទី** ភិក្ខុនានាសំវាសកៈជាអធម្មវាទី ទោះបីចាស់វស្សាជាងក៏ដោយ

**១៩.មាតុគាមោ** មាតុគ្រាម

**២០.បណ្ឌកោ** បណ្ឌកៈ(ខ្ទើយ)

**២១.បរិវាសិកោ** ភិក្ខុកំពុងចូលបរិវាស

**២២.មូលាយ បដិកស្សនារហោ** ភិក្ខុដែលគួរនឹងទាញកាន់មូលាបត្តិ

**២៣.មានត្តារហោ** ភិក្ខុដែលគួរដល់មានត្ត

**២៤.មានត្តចារិកោ** ភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត

**២៥.អព្ភានារហោ** ភិក្ខុដែលគួរដល់អព្ភានកម្ម ។

**វន្ទិយបុគ្គល បុគ្គលដែលគួរសំពះថ្វាយបង្គំមាន៥ប្រភេទ**

**១.បុរេ ឧបសម្បន្នោ** ភិក្ខុដែលបានឧបសម្បទាមុន

**២.នានាសំវាសកោ ឧុឡ្ហតរោ ធម្មវាទី** ភិក្ខុនានាសំវាសកៈជាធម្មវាទីដែលមានវស្សាចាស់ជាង

**៣.អាចរិយោ** ភិក្ខុជាអាចារ្យ

**៤.ឧបជ្ឈាយោ** ភិក្ខុជាឧបជ្ឈាយ៍

**៥.តថាគតោ សម្មាសម្ពុទ្ធោ** ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។

**កាលិក ៤យ៉ាង**

**១.យាវកាលិក** វត្ថុទុកឆាន់បានពីព្រឹកដរាបដល់ថ្ងៃត្រង់

**២.យាមកាលិក** វត្ថុទុកឆាន់បានមួយយប់មួយថ្ងៃ

**៣.សត្តាហកាលិក** វត្ថុទុកឆាន់បាន៧ថ្ងៃ

**៤.យាវជីវិក** វត្ថុទុកឆាន់បានដរាបដល់អស់ ។

## ភេសជ្ជៈ ៥យ៉ាង

១.សប្បិ ទឹកដោះថ្លា

២.នវនីតំ ទឹកដោះខាប់

៣.តេលំ ប្រេង

៤.មធុ ទឹកឃ្មុំ

៥.ផាណិតំ ស្ករអំពៅ ។

## ស្រូវ ៧ ប្រការ

(បិ.១.ទំ.១៦២)

១.សាលិ ស្រូវសាលី ៥.កង្គុ ស្តៅ

២.វីហិ ស្រូវខ្សាយ ៦.វរកោ ពោត ស្លួយ ឬស្មៅកន្ទុយដំរី

៣.យវោ ស្រូវដំណើប ៧.កុទ្រូសកោ ស្មៅគែលលក ។

៤.គោធុមោ ស្រងែ

## មហាផល ៩ យ៉ាង

១.នាឡិកេរផលំ ផ្លែដូង

២.តាលផលំ ផ្លែត្នោត

៣.បនសផលំ ផ្លែខ្នុរ

៤.លពុជផលំ ផ្លែខ្នុរសម្ល

៥.តិម្ពុសផលំ ផ្លែឪឡឹក

៦.មុស្សផលំ ផ្លែត្រសក់

៧.ឯឡាលុកផលំ ផ្លែត្រឡាច

៨.កុម្ពណ្ឌផលំ ផ្លែល្ពៅ

៩.អលាពុផលំ ផ្លែឃ្លោក

**អង្គរបស់សាមណេរ ៣ យ៉ាង**

**១.កេសច្ឆេទនំ** កោសក់

**២.កាសាយ អច្ឆាទនំ** ស្លៀកដណ្តប់សំពត់កាសាយៈ

**៣.សរណគមនំ** ឱ្យត្រៃសរណគមន៍

**ចតុប្បារិសុទ្ធិសីល ៤យ៉ាង**

**១.បាតិមោក្ខសំវរសីល** សីលគឺការសង្រួមក្នុងបាតិមោក្ខ

**២.ឥន្ទ្រិយសំវរសីល** សីលគឺការសង្រួមឥន្ទ្រិយទាំង៦

**៣.អាជីវបារិសុទ្ធិសីល** សីលគឺការចិញ្ចឹមជីវិតឱ្យបរិសុទ្ធ

**៤.បច្ចយសន្និស្សិតសីល** សីលគឺការអាស្រ័យនូវបច្ច័យទាំង៤ ។

**លក្ខណៈវិនិច្ឆ័យព្រះវិន័យ ១៧ប្រការ**

**១.និទានំ** រឿងរ៉ាវជាខាងដើម

**២.បុគ្គលំ** អ្នកប្រព្រឹត្តកន្លងមុនគេ

**៣.វត្ថុំ** កំហុសដែលបុគ្គលនោះប្រព្រឹត្តកន្លង

**៤.បញ្ញត្តិ** សេចក្តីហាមប្រាម

**៥.អាណត្តិ** ការធ្វើខ្លួនឯង ឬបង្គាប់អ្នកដទៃ

**៦.អាបត្តិ** ឈ្មោះនៃទោសផ្សេងៗ

**៧.អនាបត្តិ** ការមិនត្រូវទោសដល់អ្នកធ្វើ

**៨.វិបត្តិ** ការវិនាសចាកសីលជាដើម

**៩.អង្គំ** គ្រឿងប្រកបនាំឱ្យមានទោស

**១០.សមុដ្ឋានំ** ទីតាំងនាំឱ្យត្រូវអាបត្តិ

**១១.កិរិយា** ត្រូវព្រោះធ្វើ ឬមិនធ្វើ

**១២.សញ្ញា** រួចចាកទោសដោយការសម្គាល់ ឬមិនសម្គាល់

**១៣.ចិត្តំ** មានចិត្ត ឬគ្មានចិត្ត

១៤.ទជ្ជំ ទោសតាមផ្លូវលោក ឬផ្លូវបញ្ញត្តិ

១៥.កម្មំ អំពើដែលសម្រេចដោយទ្វារទាំងបី

១៦.កុសលត្តិកំ ជាកុសល អកុសល ឬអព្យាក្រឹត្យ

១៧.វេទនត្តិកំ ជាសុខវេទនា ទុក្ខវេទនា ឬឧបេក្ខាវេទនា

**អាបត្តាបជ្ជនាការ អាការៈដែលភិក្ខុនឹងត្រូវអាបត្តិមាន៦យ៉ាង**

១.អលជ្ជីតា ត្រូវដោយមិនមានខ្មាស

២.អញ្ញាណតា ត្រូវដោយមិនស្គាល់អាបត្តិ

៣.កុក្កុច្ចប្បកតត្តា ត្រូវដោយសង្ស័យហើយចេះតែធ្វើ

៤.អកប្បិយេ កប្បិយសញ្ញិតា ត្រូវដោយសម្គាល់ថាគួរ ក្នុងរបស់ដែលមិនគួរ

៥.កប្បិយេ អកប្បិយសញ្ញិតា ត្រូវដោយសម្គាល់ថាមិនគួរក្នុងរបស់ដែលគួរ

៦.សតិសម្មោសា ត្រូវដោយភ្លេចស្មារតី ។

## ***ចប់វិន័យឆ្នាំទី១ តែប៉ុណ្ណោះ***

**១. យាវកាលិក បានដល់ភោជន ៥យ៉ាង**

១. ឱទនោ បាយ

២. កុម្មាសោ នំស្រស់

៣. សត្តុ នំក្រៀម

៤. មច្ឆោ ត្រី

៥. មំសំ សាច់

**២. យាមកាលិក បានដល់ទឹកផ្លែឈើ**

១. អម្ពបានំ ទឹកផ្លែស្វាយ

២. ជម្ពុបានំ ទឹកផ្លែព្រីង

៣. ចោចបានំ ទឹកផ្លែចេកមានគ្រាប់

៤. **មោចបានំ** ទឹកផ្លែចេកឥតគ្រាប់

៥. **មធុកបានំ** ទឹកផ្លែស្រគំ

៦. **មុទ្ទិកបានំ** ទឹកផ្លែចាន់

៧. **សាលុកបានំ** ទឹកផ្លែក្រអៅឈូក

៨. **ផារុសកបានំ** ទឹកផ្លែម៉ាក់ប្រាង

* ទឹកអដ្ឋបានទាំង ៨ នេះក្តី ផ្លែឈើដទៃ ៗ ក្តី វៀរតែ បុព្វន្នជាតិ អបរន្នជាតិ និងមហាផលចេញ គួរធ្វើបានទាំងអស់ ហើយធ្វើដោយទឹកត្រជាក់ ឬកម្តៅថ្ងៃ បើចំអិនដោយភ្លើងមិនគួរ។

***បុព្វន្នជាតិ បានដល់ធញ្ញជាតិ គឺស្រូវ ៧ប្រការ**

***អបរន្នជាតិ បានដ ល់ មហាផល ៩ យ៉ាង**

**៣.សត្តាហកាលិក បានដល់ ភោជន ៥ យ៉ាង**

**ទ្រង់អនុញ្ញាតខ្លាញ់ ៥ យ៉ាង**

១. **អច្ឆវសំ** ខ្លាញ់ខ្លាឃ្មុំ

២. **មច្ឆវសំ** ខ្លាញ់ត្រី

៣. **សុសុការវសំ** ខ្លាញ់ត្រីឆ្លាម

៤. **សូករវសំ** ខ្លាញ់ជ្រូក

៥. **គទ្រភវសំ** ខ្លាញ់លា ។

* សូម្បីប្រេងនៃ ល្ង ស្ពៃ ស្រគំ ល្ហុង ដូង ពង្រ សង្ស័រ និងសំរោង ជាដើម ក៏យើងអាចបរិភោគក្នុងវេលាវិកាលបាន។

៤. **យាវជីវិក**

វត្ថុដែលភិក្ខុទទួលឆាន់បាន ដរាបដល់អស់ មាន៦ យ៉ាង

១.**មូលភេសជ្ជៈ** មើមជាភេសជ្ជៈ

២.កសាវភេសជ្ជៈ ទឹកអម្ចត់ជាភេសជ្ជៈ

៣.បណ្ណភេសជ្ជៈ ស្លឹកជាភេសជ្ជៈ

៤.ផលភេសជ្ជៈ ផ្លែជាភេសជ្ជៈ

៥.ជតុភេសជ្ជៈ ជ័រភេសជ្ជៈ

៦.លោណភេសជ្ជៈ អំបិលជាភេសជ្ជៈ។

**១.មូលភេសជ្ជៈមាន ៨ យ៉ាង**

១.ហលិទ្ទ ល្មៀត

២.សិង្គិវេរំ ខ្ញី

៣.វចំ លំពាន់-----

៤.វចត្ថំ ប្រស់---------

៥.អតិវិសំ អាចម៍ធ្លីស

៦.កដុករោហិណី រំដេង

៧.ឧសីរំ ស្បូវភ្លាំង

៨.ភទ្ទមុត្តកំ ក្រវាញជ្រូក។

**២.កសាវភេសជ្ជៈមាន ៥ យ៉ាង**

១.និម្ពកសាវោ ទឹកអម្ចត់ស្ដៅ

២.កុដជកសាវោ ទឹកអម្ចត់ក្លែងគង់

៣.បដោលកសាវោ ទឹកអម្ចត់អំបែងថ្ងៃ ឬពុលឯក

៤.ផគ្គវកសាវោ ទឹកអម្ចត់បណ្ដូលពេជ ឬអង្កាញ់

៥.នត្តមាលកសាវោ ទឹកអម្ចត់ទន្លា ឬថ្ងាន់។

**៣.បណ្ណភេសជ្ជៈមាន ៥ យ៉ាង**

១.និម្ពបណ្ណំ ស្លឹកស្ដៅ

២.កុដជបណ្ណំ ស្លឹកក្លែងគង់

៣.**មធោលមណ្ណាំ** ស្លឹកអំបែងថ្ងៃ ឬពុលឯក

៤.**សុលសិមណ្ណាំ** ស្លឹកម្រះព្រៅ ឬជីលីងលាក់

៥.**កប្បាសិមណ្ណាំ** ស្លឹកកប្បាស ។

**៤.ផលភេសជ្ជៈមាន ៧ យ៉ាង**

១.**ទ័លឡំ** ផ្លែពិលង្គ

២.**មិច្ឆលិ** ដីប្លី

៣.**មរិចិ** ម្រេច

៤.**ហរីតកំ** សម៉ធំ

៥.**វិភីតកំ** សម៉ពិភេទក៍

៦.**អាមលកំ** កន្ទួតព្រៃ

៧.**គោថផលំ** ផ្លែក្រវាញ។

**៥.ជតុភេសជ្ជៈមាន ៧យ៉ាង**

១.**ហិង្គុ** ជ័រដែលហូរចេញអំពីដើមហិង្គុ

២.**ហិង្គុជតុំ** ជ័រដែលគេយកស្លឹកនិងមែកហិង្គុមករំងាស់

៣.**ហិង្គុសិបាតិកំ** ជ័រដែលគេយកស្លឹកហិង្គុតែម្យ៉ាងមករំងាស់

៤.**តកំ** ជ័រដែលហូរចេញអំពីត្រួយឈើ

៥.**តកមត្តី** ជ័រដែលហូរចេញអំពីស្លឹកឈើ

៦.**តកមណ្ណី** ជ័រដែលគេបេះស្លឹកឈើយកមកធ្វើ

៧.**សជ្ជុលសំ** កំញាន ។

**៦.លោណភេសជ្ជៈមាន ៥យ៉ាង**

១.**សាមុទ្ទំ** អំបិលកើតក្បែរឆ្នេរសមុទ្រ មានបែបដូចដីខ្សាច់

២.**កាឡលោណំ** អំបិលមានពណ៌ខ្មៅ(អំបិលប្រក្រតី)

៣.**សិន្ធវំ** អំបិលមានពណ៌ស កើតលើភ្នំ

**៤.ឧត្តិធំ** អំបិលដែលមានពន្លកដុះអំពីដែនដី(អំបិលដែលកើតអំពីអាចម៍ដីមានរសប្រៃ)។

**៥.ពិលំ** អំបិលមានពណ៌ក្រហម ដែលចំអិនជាមួយនឹងគ្រឿងសម្ភារៈទាំងពួង ។

## ថ្ងៃខែឆ្នាំខ្មែរ

កូនខ្មែរគ្រប់រូប ទោះគ្រហស្ថក្តី បព្វជិតក្តី ត្រូវចេះចាំថ្ងៃខែឆ្នាំរបស់ខ្លួនឱ្យបានច្បាស់ ។

## ខែខ្មែរទាំង ១២

មិគសិរ បុស្ស មាឃ ផគ្គុន ចេត្រ ពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក

## ឆ្នាំខ្មែរទាំង ១២

ជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែ វក រកា ច កុរ

# គោលព្រះវិន័យសូត្រ ឆ្នាំទី៣

*សមណសិស្សឆ្នាំទី៣ ដែលត្រូវត្រៀមប្រឡងចូលសាលាពុទ្ធិកវិទ្យាល័យ អឹង ធួង ត្រូវសិក្សាព្រះវិន័យឆ្នាំទី៣ ហើយត្រូវរំឭកវិន័យឆ្នាំទី១ឱ្យបានចាំស្ទាត់ដើម្បីជំនួយដល់ការប្រឡង*

## ព្រះវិន័យមានគោល ៣ យ៉ាង

**១ បញ្ញត្តិ** ការហាមប្រាមមិនឱ្យធ្វើ

**២ អនុញ្ញាត** ទ្រង់អនុញ្ញាតឱ្យធ្វើឬឱ្យប្រព្រឹត្តតាម

**៣ អភិសមាចារ** ទំនៀមទម្លាប់ដ៏ល្អ ឬចរិយាមារយាទដ៏ថ្លៃថ្នូរ។

## ព្រះវិន័យមាន ២ យ៉ាង

(ធ្លាប់ប្រឡងចេញ ឆ្នាំ ២០១៨)

**១ អាគារិយវិន័យ** វិន័យរបស់គ្រហស្ថ

**២ អនាគារិយវិន័យ** វិន័យរបស់បព្វជិត។

## ព្រះវិន័យ ២ យ៉ាងផ្សេងទៀត

**១ សំវរវិនយោ** វិន័យគឺការសង្រួម

**២ បហានវិនយោ** វិន័យគឺការលះបង់ ។

## ព្រះវិន័យមានអត្ថ ៣ យ៉ាង

**១ អត្ត សម្មាបណិធិ** គប្បីតម្កល់ខ្លួនដោយប្រពៃ

**២ ចិន្តា មុនី** គំនិតដែលគិតត្រឹមត្រូវ

**៣ សម្បជញ្ញ** បុគ្គលអ្នកមានស្មារតី ។

## បាតិមោក្ខ មាន២យ៉ាង

**១ ឱវាទបាតិមោក្ខ** ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ

**២ អាណាបាតិមោក្ខ** បានដល់ និទាន បារាជិក សង្ឃាទិសេស ទ្វេអនិយត និង វិត្ថារុទ្ទេស ។

**សិក្ខា  គុណជាតិដែលបព្វជិតគប្បីសិក្សាមាន ២យ៉ាង**

**១ អាទិព្រហ្មចារិយសិក្ខា** សេចក្តីជាខាងដើមនៃព្រហ្មចរិយដែលត្រូវសិក្សា

**២ អភិសមាចារិកាសិក្ខា** បានដល់ទំនៀមទម្លាប់មារយាទដ៏ល្អ។

**សិក្ខាបទ**

វិន័យដែលព្រះពុទ្ធទ្រង់បញ្ញត្តិបានដល់សិក្ខាបទវិភង្គគឺភិក្ខុបាតិមោក្ខ២២៧ សិក្ខាបទ និង ភិក្ខុនីបាតិមោក្ខ ៣០៤សិក្ខាបទ

**អាបត្តិ គឺតជាទោសមាន៣សណ្ឋាន**

**១ គរុកាបត្តិ** បានដល់  អាបត្តិបារាជិក

**២ មជ្ឈិមកាបត្តិ** បានដល់ អាបត្តិសង្ឃាទិសេស ភិក្ខុត្រូវនូវ បរិវាសដោយវុដ្ឋានវិធី

**៣ លហុកាបត្តិ** បានដល់អាបត្តិ ៥កងខាងចុង ។

**អាបត្តិមាន ៧កង**

**១ បារាជិក** ចាលចាញ់

**២ សង្ឃាទិសេស** ត្រូវមានសង្ឃជាខាងដើមដ៏សេស

**៣ ថុល្លច្ច័យ** កំហុសដែលថ្លោស ឬទោសគ្រោតគ្រាត

**៤ បាចិត្តិយ** ញុំាងកុសលធម៌ឱ្យធ្លាក់ចុះ

**៥ បាដិទេសនីយ** គប្បីសំដែងឡើងវិញ

**៦ ទុក្កដ** ការសន្សំអាក្រក់

**៧ ទុព្ភាសិត** ការពោលពាក្យដ៏អាក្រក់

**វិបត្តិ  ការវិនាស ៤យ៉ាង**

**១ សីលវិបត្តិ** ការវិនាសចាកសីល បានដល់ សង្ឃាទិសេស និងបារាជិក

**២ អាចារវិបត្តិ** ការវិនាសចាក មារយាទដ៏ល្អ បានដល់អាបត្តិ៥កងខាងចុង

**៣ ទិដ្ឋិវិបត្តិ** ការវិនាសចាកសម្មាទិដ្ឋិ គឺយល់ខុស

**៤ អាជីវវិបត្តិ** ការចញ្ចឹមជីវិតខុស ព្រោះប្រព្រឹត្ត បាបធម៌និងអនេសនៈ

**បរិសុទ្ធិ ៤យ៉ាង**

**១ ទេសនាសុទ្ធិ** បរិសុទ្ធដោយការសម្តែង

**២ សំវរសុទ្ធិ** បរិសុទ្ធដោយការសង្រួម

**៣ បរិយេដ្ឋិសុទ្ធិ** បរិសុទ្ធដោយការស្វែងរក

**៤ បច្ចវេក្ខណសុទ្ធិ** បរិសុទ្ធដោយការពិចារណា។

**ហត្ថបាសមាន ២ យ៉ាង**

**១ និយមិ្ឋ ហត្ថបាសោ** ហត្ថបាស(សង្ឃកម្ម)ប្រវែង ១ហត្ថ ១ចំអាម

**២ អឌ្ឍតេយ្យ ហត្ថបាសោ** ហត្ថបាសគ្រគេនប្រវែង ២ហត្ថ១ចំអាម។

**ឧបសម្បទា ការបំបួសភិក្ខុ មាន៤យ៉ាង**

**១ ឯហិភិក្ខុបសម្បទា** បួសជាឯហិភិក្ខុ

**២ តិសរណគមនូបសម្បទា** បួសដោយត្រៃសរណគមន៍

**៣ ញត្តិចតុត្ថកម្មូបសម្បទា** បួសដោយសូធ្យញត្តិ

**៤ អដ្ឋវាចិកូបសម្បទា** បួសដោយញត្តិកម្មវាចាក្នុងសង្ឃទាំង២ពួក រួមជា៨កម្មវាចានេះចំពោះតែភិក្ខុនីតែម្យ៉ាង។

**វត្ត គឺកិច្ចប្រព្រឹត្ត មាន៣យ៉ាង**

**១ កិច្ចវត្ត** កិច្ចដែលគួរធ្វើ

**២ ចរិយាវត្ត** គឺមារយាទដែលគួរប្រព្រឹត្ត

**៣ វិធីវត្ត** គឺបវេណី។

**វត្តខន្ធកៈ ១៤**

**១ អាគន្តុកវត្ត** វត្តរបស់ភិក្ខុអ្នកមកថ្មី

**២ អាវាសិកវត្ត** វត្តរបស់ភិក្ខុជាចៅអាវាស

**៣ គមិកវត្ត** វត្តរបស់ភិក្ខុអ្នកធ្វើដំណើរចេញទៅ

**៤ អនុមោទនាវត្ត** វត្តរបស់ភិក្ខុក្នុងពេលអនុមោទនា

**៥ ភត្តគ្គវត្ត** វត្តរបស់ភិក្ខុអ្នកឆាន់ចង្ហាន់ក្នុងរោងភត្ត

**៦ បិណ្ឌចារិកវត្ត** វត្តរបស់ភិក្ខុអ្នកត្រាច់ទៅបិណ្ឌបាត្រ

**៧ អារញ្ញិកវត្ត** វត្តរបស់ភិក្ខុអ្នកនៅក្នុងព្រៃ

**៨ សេនាសនវត្ត** វត្តរបស់ភិក្ខុអ្នករៀបចំសេនាសនៈ

**៩ វច្ចកុដីវត្ត** វត្តរបស់ភិក្ខុ គប្បីប្រតិបត្តិក្នុងវច្ចកុដិ

**១០ ជន្តាឃរវត្ត** វត្តរបស់ភិក្ខុជាអ្នកគប្បីត្រាច់ទៅក្នុងចន្លោះស្រុក

**១១ ឧបជ្ឈាយវត្ត** វត្តរបស់ភិក្ខុ ជាឧបជ្ឈាយ៍

**១២ សទ្ធិវិហារិកវត្ត** វត្តរបស់ភិក្ខុ ជាសទ្ធិវិហារិក

**១៣ អាចារិយវត្ត** វត្តរបស់ភិក្ខុ ជាអាចារ្យ

**១៤ អន្តេវាសិកវត្ត** វត្តរបស់ភិក្ខុ ជាអន្តេវាសិក ។

**ព្រះវិន័យបិដក មាន៥គម្ពីរគឺ(អា.បា.ម.ចុ.ប.)**

**១ អាទិកម្មៈ** អដ្ឋកថាឈ្មោះ បឋមសមន្តប្បាសាទិកា

**២ បាចិត្តិយៈ** អដ្ឋកថាឈ្មោះ ទុតិយសមន្តប្បាសាទិកា

**៣ មហាវគ្គ** អដ្ឋកថាឈ្មោះ តតិយសមន្តប្បាសាទិកា

**៤ ចុល្លវគ្គ** អដ្ឋកថាឈ្មោះ ចតុត្ថសមន្តប្បាសាទិកា

**៥ បរិវារៈ** អដ្ឋកថាឈ្មោះ បញ្ចសមន្តប្បាសាទិកា

ព្រះវិន័យមាន១៣ភាគ មាន២ម៉ឺន ១ពាន់ព្រះធម្មក្ខន្ធ។

**ព្រះសូត្រមាន ៥គម្ពីរគឺ(ទី.ម.សំ.អំ.ខុ.)**

**១ ទីឃនិកាយ** មាន៣៤ព្រះសូត្រ ព្រហ្មជាលសូត្រជាដើម

**២ មជ្ឈិមនិកាយ** មាន១៥២ព្រះសូត្រ មូលបរិយាយសូត្រជាដើម

**៣ សំយុត្តនិកាយ** ៧៧៦២ព្រះសូត្រ ឱឃតរណសូត្រជាដើម

**៤ អង្គុត្តរនិកាយ** មាន៩៥៥៧ព្រះសូត្រ ចិត្តបរិយាទានសូត្រជាដើម

**៥ ខុទ្ទកនិកាយ** មាន១៥គម្ពីរព្រះសូត្រមាន ៦៤ភាគ មាន ២ម៉ឺន ១ពាន់ព្រះធម្មក្ខន្ធ។

**ព្រះអភិធម្មមាន ៧ គម្ពីរគឺ**

១ ធម្មសង្គណី២ វិភង្គ៣ ធាតុកថា ៤បុគ្គលប្បញ្ញត្តិ ៥កថាវត្ថុ ៦យមក ៧ មហាបដ្ឋាន។

ព្រះអភិធម្មមាន៣៣ភាគ មាន៤ម៉ឺន ២ពាន់ព្រះធម្មក្ខន្ធ។

**បរិក្ខារ ៨ យ៉ាងរបស់ភិក្ខុ**

**១.សង្ឃាដី** សង្ឃាដី

**២.ឧត្តរាសង្គោ** ចីវរ

**៣.អន្តរវាសកោ** ស្បង់

**៤.បត្តោ** បាត្រ

**៥.សត្ថកេសរោ** កាំបិតកោរ

**៦.សុចិឃរំ** បំពង់ម្ជុល

**៧.កាយពន្ធនំ** វត្ថពន្ធចង្កេះ

**៨.ធម្មករកំ** ធម្មក្រក ឬសម្ពត់តម្រងទឹក

**ចីវរ ២យ៉ាង**

**១ បង្សុកូលចីវរ** ចីវរបានមកពីការបង្សុកូល

**២ គហបតីចីវរ** ចីវរដែលទាយក ទាយិកាប្រគេន។

**ពណ៌ពិន្ទុចីវរ៣យ៉ាង**

**១/ នីលំ** ពណ៌ខៀវ

**២/ កទ្ទមំ** ពណ៌ភក់

**៣/កាឡសាមំ** ពណ៌ខ្មៅជាំ

**នាសនង្គៈ ៣យ៉ាង**

(ធ្លាប់ប្រឡងចេញ ឆ្នាំ២០១៦)

**១ ទណ្ឌកម្មនាសនា** វិនាសដោយត្រូវទណ្ឌកម្ម

**២ លិង្គនាសនា** វិនាសចាកភេទគឺឱ្យសឹកចេញ

**៣ សំវាសនាសន** វិនាសការនៅរួមជាមួយសង្ឃ

**វិធី អធិដ្ឋានមាន២យ៉ាង ដោយកាយ១ ដោយវាចា១**

**បាលី អធិដ្ឋានត្រៃចីវរ**

**១ ឥមំ សង្ឃាដឹ អធិដ្ឋាមិ** អាត្មាអញអធិដ្ឋាននូវសង្ឃាដីនេះ

**២ ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ** អាត្មាអញអធិដ្ឋាននូវចីវរនេះ

**៣ ឥមំ អន្តរវាសកំ អធិដ្ឋាមិ** អាត្មាអញអធិដ្ឋាននូវស្បង់នេះ ។

**បាលី ដកអធិដ្ឋាន**

**១ ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** អាត្មាអញដកនូវស្បង់នេះ

**២ ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ** អាត្មាអញដកនូវចីវរនេះ

**៣ ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ** អាត្មាអញដកនូវស្បង់នេះ។

**អន្តេវាសិករបស់អាចារ្យ៤យ៉ាង**

**១ បព្វជ្ជន្តេវាសិកៈ** អន្តេវាសិករបស់បព្វជ្ជាចារ្យ

**២ ឧបសម្បទន្តេវាសិកៈ** អន្តេវាសិករបស់ឧបសម្បទាចារ្យ

**៣ និស្សយន្តេវាសិកះ** អន្តេវាសិករបស់និស្សយាចារ្យ

**៤ ឧទ្ទេសន្តេវាសិកះ** អន្តេវាសិករបស់ឧទ្ទេសាចារ្យ

**៥ ឱវាទន្តេវាសិកះ** អន្តេវាសិករបស់ឱវាទាចារ្យ៕

## សង្ឃ មាន៥ពួក

**១/ ចតុវគ្គោ ភិក្ខុសង្ឃោ** សង្ឃមានភិក្ខុបួនរូបគួរដល់កម្មទាំងពួង វៀរតែឧបសម្បទាកម្មក្នុងមជ្ឈិមប្រទេស១ បវារកម្ម១ អព្ភានកម្ម១

**២/ បញ្ចវគ្គោ ភិក្ខុសង្ឃោ** សង្ឃមានភិក្ខុប្រាំរូបគួរដល់កម្មទាំងពួង វៀរតែឧបសម្បទាកម្មក្នុងមជ្ឈិមប្រទេស១ អព្ភានកម្ម១

**៣/ទសវគ្គោភិក្ខុសង្ឃោ** សង្ឃមានភិក្ខុដល់ដប់រូបគួរដល់កម្មទាំងពួង វៀរតែអព្ភានកម្ម

**៤/ វីសតិវគ្គោ ភិក្ខុសង្ឃោ** សង្ឃមានភិក្ខុម្ភៃរូប គួរដល់កម្មទាំងពួង

**៥/អតិរេកវគ្គោភិក្ខុសង្ឃោ** សង្ឃមានភិក្ខុលើសពីម្ភៃរូបគួរដល់កម្មទាំងពួង

## អបលោកនកម្ម មានស្ថាន៥យ៉ាង

**១/ និស្សារណា** ការធ្វើនាសនាដល់សាមណេរ

**២/ ឱសារណា** ការធ្វើបវេសនាដល់សាមណេរ

**៣/ ភណ្ឌុកម្ម** ការប្រាប់សង្ឃក្នុងអាវាស មុននឹងកោរសក់កុលបុត្រ

**៤/ ព្រហ្មទណ្ឌ** ការតមមាត់ចំពោះភិក្ខុរឹងត្អឹង

**៥/ កម្មលក្ខណា** ភិក្ខុនីសង្ឃ មិនឲ្យភិក្ខុនីសំពះភិក្ខុ។

## ញត្តិកម្ម មានស្ថាន៩យ៉ាង

១/ ឱសារណា ការសូត្រហៅឧបសម្បទាបេក្ខៈ ចូលជំនុំសង្ឃ

២/ និស្សារណា ការសូត្រដេញធម្មកថិកចចេស

៣/ ឧបោសថោ ការធ្វើឧបោសថកម្ម

៤/ បវារណា ការធ្វើបវារណាកម្ម

៥/ សម្មុតិ ការសន្មតដើម្បីទូន្មានឧបសម្បទាបេក្ខៈជាដើម

៦/ ទាន ការប្រគល់បាត្រចីវរជានិស្សគ្គីយ៍ ដល់ម្ចាស់របស់វិញ

៧/ បដិគ្គហោ ការទទួលអាបត្តិរបស់ភិក្ខុដទៃ

៨/ បច្ចុក្កឌ្ឍនា ការពន្លឿនបវារណាកម្ម តទៅមុខទៀត

៩/ កម្មលក្ខណ ការសូត្រ សព្វសង្គាហិកញត្តិ ជាដើម។

## ញត្តិទុតិយកម្ម មានស្ថាន៧យ៉ាង

១/ និស្សារណា ការផ្កាប់បាត្រចំពោះគ្រហស្ថ

២/ ឱសារណា ការផ្ងារបាត្រចំពោះគ្រហស្ថ

៣/ សម្មុតិ ការសន្មតសីមាជាដើម

៤/ ទាន ការឲ្យសំពត់កឋិន និងមតកចីវរ

៥/ ឧទ្ធារោ ការដោះកឋិន

៦/ ទេសនា ការសម្តែងទីសាងសង់កុដិ

៧/ កម្មលក្ខណ ការរម្ងាប់អធិករណ៍ដោយតិណវត្ថារកវិន័យជាដើម។

## ញត្តិចតុត្ថកម្ម មានស្ថាន៧យ៉ាង

១/ និស្សារណា ការដាក់កម្ម៧យ៉ាង មានតជ្ជនីយកម្មជាដើម

២/ ឱសារណា ការរម្ងាប់កម្ម៧យ៉ាង មានតជ្ជនីយកម្មជាដើម

៣/ សម្មុតិ ការសន្មតភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនី

៤/ ទាន ការឲ្យបរិវាសកម្ម និងមានត្ត

៥/ និគ្គហោ ការទាញចូលមូលាបត្តិ

៦/ សមនុភាសនា ការធ្វើសមនុភាសនាកម្ម១១យ៉ាងណាមួយ

៧/ កម្មលក្ខណ ការធ្វើឧបសម្បទាកម្ម និងអព្ភានកម្ម។

**រតនជាអនាមាស មាន១០យ៉ាង**

**(ចី.៤/៣៧០)**

**១.មុត្តា** កែវមុក្តា

**២.មណិ** កែវមណី

**៣.វេឡុរិយោ** កែវពិទូរ្យ

**៤.សង្ខោ** ស័ង្ខ

**៥.សិលា** កែវសិលា

**៦.បវាឡំ** កែវប្រវាឡ

**៧.រជតំ** ប្រាក់

**៨.ជាតរូបំ** មាស

**៩.លោហិតង្គោ** កែវទទឹម

**១០.មសារគល្លំ** កែវពព្រុះ។

**វត្ថុនិស្សគ្គិយមាន៤យ៉ាង**

**១.សុវណ្ណំ** មាស

**២.រជតំ** ប្រាក់

**៣.កហាបណោ** កហាបណៈ

**៤.មាសកោ** មាសកៈ ។

**ចត្តុជានិស្សគ្គិយ ក្នុងខណរឤរុណរះឡើងមាន៧យ៉ាង:**

**១.អតិរេកចីវរំ** អតិរេកចីវរកន្លងហួស១០ថ្ងៃ

**២.តិចីវរំ** ត្រៃចីវរដែលភិក្ខុនៅប្រាសចាក១រាត្រី

**៣.អកាលចីវរំ** អកាលចីវរកន្លងហួស១ខែ

**៤.អតិរេកបត្តំ** អតិរេកបាត្រកន្លងហួស១០ថ្ងៃ

**៥.ភេសជ្ជំ** ភេសជ្ជៈ៥យ៉ាងដែលកន្លងហួស៧ថ្ងៃ

**៦.អច្ចេកចីវរំ** អច្ចេកចីវរដែលភិក្ខុទុកឱ្យកន្លងចីវរកាល

**៧.តិចីវរំ** ត្រៃចីវរដែលភិក្ខុអ្នកនៅចាំវស្សាក្នុងព្រៃដែលប្រកបដោយភ័យលុះចេញវស្សាហើយ បើចង់ទុកដាក់ចីវរណាមួយក្នុងស្រុកត្រូវទុកបានត្រឹម១ខែបើមានហេតុ នឹងចេញចាកពីទីនោះទៅទៀតត្រូវទុកបានត្រឹម៦យប់នឹងទុកឱ្យកន្លងលើសពីនោះជានិស្សគ្គិយ។

**អាបត្តិចែកដោយកិរិយាមាន៥យ៉ាង**

**១.កិរិយា** អាបត្តិកើតឡើងព្រោះការធ្វើ

**២.អកិរិយា** បត្តិកើតឡើងព្រោះការមិនធ្វើ

**៣.កិរិយាកិរិយា** អាបត្តិកើតឡើងព្រោះការធ្វើនិងមិនធ្វើ

**៤.សិយា កិរិយា សិយា អកិរិយា** អាបត្តិកើតឡើងព្រោះការធ្វើក៏មាន ព្រោះការមិនធ្វើក៏មាន

**៥.សិយា កិរិយា សិយា កិរិយាកិរិយា** អាបត្តិកើតឡើងព្រោះការធ្វើក៏មាន ព្រោះការធ្វើនិងមិនធ្វើក៏មាន។

## **បទេសប្បញ្ញត្តិ មាន៤យ៉ាង**

**១/ វិនយធរបញ្ចមេន គណេន ឧបសម្បទំ** ឧបសម្បទាដោយគណសង្ឃមានភិក្ខុវិន័យធរជាគម្រប់ប្រាំ។

**២/ គុណង្គុណូបាហនំ** ស្បែកជើងតាំងពីបួនជាន់ឡើងទៅ។

**៣/ ធុវនហានំ** ស្រង់ទឹកជានិច្ច

**៤/ ចម្មានិ អត្ថរណានិ** កម្រាលស្បែកទាំងឡាយ។

## **បញ្ញត្តិ មាន៩យ៉ាង**

**១.មូលប្បញ្ញត្តិ** បញ្ញត្តិជាដំបូង

**២.អនុប្បញ្ញត្តិ** បញ្ញត្តិជាបន្ទាប់ៗ

**៣.អនុប្បន្នប្បញ្ញត្តិ** បញ្ញត្តិទុកជាមុន

**៤.សព្វត្ថប្បញ្ញត្តិ** បញ្ញត្តិក្នុងទីទាំងពួង

**៥.បទេសប្បញ្ញត្តិ** បញ្ញត្តិចំពោះប្រទេស

**៦.សាធារណប្បញ្ញត្តិ** បញ្ញត្តិទូទៅ

**៧.អសាធារណប្បញ្ញត្តិ** បញ្ញត្តិមិនទូទៅ

**៨.ឯកតោបញ្ញត្តិ** បញ្ញត្តិតែម្ខាង

**៩.ឧភតោបញ្ញត្តិ** បញ្ញត្តិទាំងពីរខាង។

## **អន្តេវាសិករបស់អាចារ្យ៥យ៉ាង**

**១ បព្វជ្ជន្តេវាសិកៈ** អន្តេវាសិករបស់បព្វជ្ជាចារ្យ

**២ ឧបសម្បទន្តេវាសិកៈ** អន្តេវាសិករបស់ឧបជ្ឈាយ៍អាចារ្យ

**៣ និស្សយន្តេវាសិកៈ** អន្តេវាសិករបស់និស្សយាចារ្យ

**៤ ឧទ្ទេសន្តេវាសិកៈ** អន្តេវាសិករបស់ឧទ្ទេសាចារ្យ

**៥ ឱវាទន្តេវាសិកៈ** អន្តេវាសិករបស់ឱវាទាចារ្យ៕

## ភិក្ខុជាសិស្សត្រូវគោរពអាចារ្យ៥យ៉ាង

១ បព្វជ្ជាចារ្យ អាចារ្យអ្នកឱ្យបព្វជ្ជាដល់សាមណេរ

២ ឧបជ្ឈាយាចារ្យ អាចារ្យសូត្រឧបសម្បទាកម្មជាភិក្ខុ

៣ និស្សយាចារ្យ អាចារ្យឱ្យនិស្ស័យ

៤ ឧទ្ទេសាចារ្យ ឬ ធម្មាចារ្យ អាចារ្យបង្រៀនបាលី

៥ ឱវាទាចារ្យ អាចារ្យអ្នកឱ្យវាទ៕

## បុព្វករណរបស់ឧបោសថមាន៤យ៉ាង

១/ សម្មជ្ជនី បោសសំអាតរោងឧបោសថ

២/ បទីបោ ការអុជប្រទីបក្នុងរោងឧបោសថ

៣/ ឧទកំ តម្កល់ទឹកក្នុងរោងឧបោសថ

៤/ អាសនេន ក្រាលអាសនៈក្នុងរោងឧសថ។

## បុព្វកិច្ច របស់ឧបោសថមាន៥យ៉ាង

១/ ឆន្ទ ការប្រាប់ឆន្ទៈរបស់ភិក្ខុដែលមិនបានចូលរួម

២/ បារិសុទ្ធិ ការប្រាប់បរិសុទ្ធិរបស់ភិក្ខុដែលមិនបានចូលរួម

៣/ ឧតុក្ខានំ ការប្រាប់រដូវ

៤/ ភិក្ខុគណនា ការរាប់ចំនួនភិក្ខុ

៥/ ឱវាទោ ការឲ្យឱវាទដល់ភិក្ខុនី។

## បត្តកល្លៈរបស់ឧបោសថមាន៤យ៉ាង

១/ ឧបោសថោ ថ្ងៃឧបោសថទាំងបីណាមួយ

២/យាវតិកា ច ភិក្ខុ កម្មប្បត្តា ភិក្ខុចាប់ពីបួនរូបឡើងទៅ

៣/សភាគាបត្តិយោច នវិជ្ជន្តិ ភិក្ខុទាំងឡាយមិនត្រូវសភាគាបត្តិ

**៥/វជ្ជនីយា ច បុគ្គលា តស្មឹ ន ហោន្តិ** វជ្ជនីយបុគ្គលមិនមាក្នុងទីនោះ។

## សីមាមាន២យ៉ាង

**១/ ពទ្ធសីមា** សីមាដែលសង្ឃសូត្រចង

**២/ អពទ្ធសីមា** សីមាដែលសង្ឃមិនបានសូត្រចង

## ពទ្ធសីមា មាន៣យ៉ាង

**១/ខណ្ឌសីមា** សីមាតូច

**២/ សមានសំវាសសីមា** សីមាមានសំវាសស្មើគ្នា

**៣/អវិប្បវាសសីមា** សីមាដែលនៅប្រាសចាកត្រៃចីវរមិនត្រូវទោស

## អពទ្ធសីមា មាន៣យ៉ាង

**១/ គាមសីមា** សីមាក្នុងស្រុក

**២/ សត្តព្ភន្តរសីមា** សីមា៧អព្ភន្តរៈ

**៣/ ឧទកុក្ខេបសីមា** សីមាជះទឹក។

## និមិត្តសីមា មាន៨យ៉ាង

**១/ បព្វតនិមិត្តំ** យកភ្នំជានិមិត្ត

**២/ បាសាណនិមិត្តំ** យកថ្មជានិមិត្ត

**៣/ វននិមិត្តំ** យកព្រៃជានិមិត្ត

**៤/រុក្ខនិមិត្តំ** យកដើមឈើជានិមិត្ត

**៥/ មគ្គនិមិត្តំ** យកផ្លូវជានិមិត្ត

**៦/ វម្មិកនិមិត្តំ** យកដំបូកជានិមិត្ត

**៧/ នទីនិមិត្តំ** យកស្ទឹងជានិមិត្ត

**៨/ ឧទកនិមិត្តំ** យកទឹកជានិមិត្ត។

## សីមាសម្បត្តិ មាន៣យ៉ាង

១/ **និមិត្តសម្បត្តិ** ប្រកបព្រមដោយនិមិត្ត

២/ **បរិសសម្បត្តិ** ប្រកបព្រមដោយបរិស័ទ

៣/ **កម្មវាចាសម្បត្តិ** ប្រកបព្រមដោយកម្មវាចា។

## សីមាវិបត្តិ មាន១១យ៉ាង

១/ **អតិខុទ្ទកា** សីមាតូចពេក

សីមាតូចពេក

២/ **អតិមហតី** សីមាធំពេក

៣/ **ខណ្ឌនិមិត្តា** សីមាមាននិមិត្តដាច់

៤/ **ឆាយានិមិត្តា** សីមាមានស្រមោលជានិមិត្ត

៥/ **អនិមិត្តា** សីមាមិនមាននិមិត្ត

៦/ **ពហិសីមេ ឋិតា សម្មតា** សីមាដែលភិក្ខុឈរសន្មតក្រៅដែនសីមា

៧/ **នទិយា សម្មតា** សីមាដែលភិក្ខុសន្មតក្នុងស្ទឹង

៨/ **សមុទ្ទេ សម្មតា** សីមាដែលភិក្ខុសន្មតក្នុងសមុទ្រ

៩/ **ជាតស្សរេ សម្មតា** សីមាដែលភិក្ខុសន្មតក្នុងជាតស្រះ

១០/ **សីមាយ សីមំ សម្ភិន្ទន្តេន សម្មតា** សីមាដែលភិក្ខុសន្មតទម្លាយសីមាដោយសីមា

១១/ **សីមាយ សីមំ អជ្ឈោត្ថរន្តេន សម្មតា** សីមាដែលភិក្ខុសន្មត សង្កត់សីមាដោយសីមា។

**ភិក្ខុមិនត្រូវអាស្រ័យនៅនឹងភិក្ខុ ដែលប្រកបដោយអង្គ៣យ៉ាង**

**១/ អលជ្ជី ហោតិ** ភិក្ខុជាអ្នកមិនមានខ្មាស

**២/ ពាលោ ហោតិ** ភិក្ខុជាអ្នកល្ងង់

**៣/ អបកតត្តោ ហោតិ** មិនមែនជាបកតត្តភិក្ខុ។

**បុព្វករណៈ របស់កឋិនមាន៧យ៉ាង**

**១/ ធោវនំ** ការបោកគក់

**២/ វិចារោ** ការចាត់ចែងវាស់

**៣/ ឆេទនំ** ការកាត់ឬហែក

**៤/ ពន្ធនំ** ការដានផ្គុំ

**៥/ សិព្វនំ** ការដេរ

**៦/ រជនំ** ការជ្រលក់

**៧/ កប្បំ** ការធ្វើពិន្ទុកប្ប។

**កឋិនដោះដោយមាតិកា៨យ៉ាង**

**១/ បក្កមនន្តិកា** ការជៀសចេញទៅជាកំណត់

**២/ និដ្ឋានន្តិកា** ការធ្វើចីវរសម្រេចជាកំណត់

**៣/ សន្និដ្ឋានន្តិកា** មានសេចក្តីសន្និដ្ឋានជាកំណត់

**៤/ នាសនន្តិកា** មានចីវរវិនាសទៅជាកំណត់

**៥/ សវនន្តិកា** មានការឮដំណឹងជាកំណត់

**៦/ អាសាវច្ឆេទិកា** អស់សេចក្តីសង្ឃឹម

**៧/ សីមាតិក្កន្តិកា** មានការកន្លងខេត្តកឋិនជាកំណត់

**៨/ សហុព្ភារា** សង្ឃព្រមព្រៀងគ្នាដោះកឋិន។

## សេនាសនៈ៥យ៉ាង

១.វិហារោ លំនៅឬកុដិធំ

២.អឌ្ឍយោគោ រោងបាំងមួយចំហៀង

៣.បាសាទោ ប្រាសាទវែងឬថែវមានជាន់

៤.ហម្មិយំ ប្រាសាទដំបូលត្រងិល ឬមានកំពូល ឬថែវទាប

៥.គុហា រូងភ្នំ ឬរូងដែលគេធ្វើដោយឥដ្ឋ ដោយថ្ម។

## គ្រែមាន៤យ៉ាង

(បិដក.៣/៣៧០)

១.មសារកោ គ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង

២.ពុន្ទិកាពទ្ធោ គ្រែដែលមានមេដាប់នឹងជើង

៣.កុឡីរបាទកោ គ្រែដែលមានជើងដូចជាជើងក្តាម

៤.អាហច្ចបាទកោ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ។( សូម្បីតាំងក៏ដូចគ្រែដែរ )។

## កៅអី ៤ យ៉ាង

ទំព័រ៣៧១ បិដក៣)ឬ(១២៣/៣.បិដក))

១.វាកមយំ កៅអីដែលគេធ្វើដោយសំបកឈើ

២.ឧសីរមយំ កៅអីដែលគេធ្វើដោយស្បូវភ្លាំង

៣.មុញ្ជមយំ កៅអីដែលគេធ្វើដោយស្មៅដំណេកទន្សាយ

៤.បព្វជមយំ កៅអីដែលគេធ្វើដោយស្មៅយ៉ាប្លង។

## សុរា៥យ៉ាង

(បិ.៤/២០៩)

**១.បិដ្ឋសុរា** សុរាធ្វើដោយម្សៅ

**២.បូវសុរា** សុរាធ្វើដោយនំ

**៣.ឱទនសុរា** សុរាធ្វើដោយបាយ

**៤.កិណ្ណបក្ខិត្តា** សុរាដែលគេដាក់មេស្រា

**៥.សម្ភារសំយុត្តា** សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ។

## មេរ័យ៥យ៉ាង

(បិ.៤/២០៩)

**១.បុប្ផាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ

**២.ផលាសវោ** ទឹកត្រាំដែលធ្វើគេដោយផ្លែឈើ

**៣.មធ្វាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទឬទឹកឃ្មុំ

**៤.គុឡាសវោ** ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ

**៥.សម្ភារសំយុត្តា** ទឹកត្រាំដែលគេធ្វើដោយគ្រឿងផ្សំផ្សេងៗ

**បញ្ចអាទីនវាកុលូបកេ** **ភិក្ខុអ្នកទៅកាន់ត្រកូលតែងមានទោស៥យ៉ាង**

**១.អនាមន្តចារេអាបជ្ជតិ** ត្រូវអាបត្តិព្រោះមិនបានប្រាប់ភិក្ខុដែលនៅក្នុងអាវាស

**២.រហោ និសជ្ជាយ អាបជ្ជតិ** ត្រូវអាបត្តិព្រោះអង្គុយក្នុងទីស្ងាត់

**៣.បដិច្ឆន្នេ អាសនេ អាបជ្ជតិ** ត្រូវអាបត្តិក្នុងអាសនៈដែលកំបាំង

**៤.មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេន្តោ អាបជ្ជតិ** ត្រូវអាបត្តិព្រោះសម្តែងធម៌ដល់មាតុគ្រាមលើសជាងប្រាំឬប្រាំមួយមាត់

**៥.កាមសង្កប្បពហុលោ** មានសេចក្តីត្រិះរិះជាច្រើនក្នុងកាមគុណ។

**អនតិរិត្តភោជន ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្មដោយអាការៈ៧យ៉ាង**

**១.អកប្បិយកតំ ហោតិ** របស់ដែលគេមិនបានធ្វើឱ្យជាវត្ថុគួរ

**២.អប្បដិគ្គហិតកតំ ហោតិ** របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឱ្យជារបស់គួរ

**៣.អនុច្ចារិតកតំ ហោតិ** របស់ដែលភិក្ខុមិនបានបង្អោនចូលទៅជិត ដើម្បីឱ្យភិក្ខុធ្វើជារបស់គួរ

**៤.អហត្ថបាសេ កតំ ហោតិ** ភិក្ខុមិនស្ថិតនៅក្នុងហត្ថបាស ហើយធ្វើឱ្យជារបស់គួរ

**៥.អភុត្តាវិនា កតំ ហោតិ** ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ

**៦.ភុត្តាវិនា បវារិតេន អាសនា វុដ្ឋិតេន កតំ ហោតិ** ភិក្ខុឆាន់ហើយបានហាមភោជន ហើយក្រោកចាកអាសនៈហើយធ្វើ

**៧.អលមេតំ សព្វន្តិ អវុត្តំ ហោតិ ន គិលានាតិរិត្តំ ហោតិ** របស់ដែល ភិក្ខុ មិនពោលថា របស់ទាំងអស់នេះគួរហើយ និងមិនមែនជារបស់សល់អំពីភិក្ខុឈឺ។

**ប្រធាននៃសមុដ្ឋាន អាបត្តិមាន១៣យ៉ាង**

**១.បឋមបារាជិកសមុដ្ឋាន** មានសមុដ្ឋាន១គឺ កាយចិត្ត

**២.អទិន្នាទានសមុដ្ឋាន**មានសមុដ្ឋាន៣គឺ កាយចិត្ត១ វាចាចិត្ត១កាយវាចាចិត្ត១

**៣.សញ្ចរិត្តសមុដ្ឋាន** មានសមុដ្ឋានគ្រប់ទាំង៦

**៤.សមនុភាសនសមុដ្ឋាន** មានសមុដ្ឋាន១ គឺកាយវាចាចិត្ត

**៥.កឋិនសមុដ្ឋាន** មានសមុដ្ឋាន២គឺ កាយវាចា១កាយវាចាចិត្ត១

**៦.ឯឡកលោមសមុដ្ឋាន** មានសមុដ្ឋាន២គឺ កាយ១ កាយចិត្ត១

**៧.បទសោធម្មសមុដ្ឋាន** មានសមុដ្ឋាន២គឺ វាចា១ វាចាចិត្ត១

**៨.អទ្ធានសមុដ្ឋាន** មានសមុដ្ឋាន៤គឺ កាយ១ កាយវាចា១ កាយចិត្ត១កាយវាចាចិត្ត១

**៩.ថេយ្យសត្ថសមុដ្ឋាន** មានសមុដ្ឋាន២គឺ កាយចិត្ត១ កាយវាចាចិត្ត១

**១០.ធម្មទេសនាសមុដ្ឋាន** មានសមុដ្ឋាន ១គឺ វាចាចិត្ត
**១១.ត្ថេយ្យសត្ថសមុដ្ឋាន** មានសមុដ្ឋាន៣គឺ កាយ១ វាចា១ កាយវាចា១
**១២.ចោរីវុដ្ឋាបនសមុដ្ឋាន** មានសមុដ្ឋាន២គឺ វាចាចិត្ត១ កាយវាចាចិត្ត១
**១៣.អននុញ្ញាតសមុដ្ឋាន** មានសមុដ្ឋាន៤គឺ វាចា១ កាយវាចា១ វាចាចិត្ត១ កាយវាចាចិត្ត១។

## ភិក្ខុជាមហាចោរដោយអាការៈ ៥យ៉ាង

(បិដកលេខ១.ទំព័រ២៩៣)

**១/ ភិក្ខុបាបខ្លះបាន** (ត្រិៈរិៈ) ថាបើដល់កាលណាអញបានបរិសទ្យ ១រយឬ ១ពាន់ចោមរោមជាគ្នាហើយ នឹងត្រេចទៅកាន់ចារិកក្នុងស្រុកនិគមរាជធានី ក៏នឹងបាននូវចីវរ បិណ្ឌបាត សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារដែលពួកគ្រហស្ថក្តីពួកបព្វជិតក្តីធ្វើសក្ការគោរពរាប់អានបូជាកោតក្រែង។ភិក្ខុនេះហៅថាមហាចោរទី១ ដែលមានប្រាកដក្នុងលោក។

២ ម្នាលភិក្ខុទាំងឡាយហេតុដទៃមានតទៅទៀតក្នុងសាសនានេះមានភិក្ខុបាបខ្លះ រៀនសូត្រធម្មវិន័យដែលតថាគតបានសំដែងហើយដុតកំដៅខ្លួនឯងចោល។ភិក្ខុនេះហៅថា មហាចោរទី២ ដែលមានប្រាកដក្នុងលោក។ទំព័រ (២៩៤)

៣ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀ តក្នុងសាសនានេះ មានភិក្ខុបាបខ្លះពោលចោទភិក្ខុដែ លប្រព្រឹត្តធម៌ប្រសើរដ៏ស្អាត ដែលកំពុង ប្រព្រឹត្តធម៌ប្រសើរដ៏បរិសុទ្ធចោទដោយការប្រព្រឹត្តមិនប្រសើរ រកមូលគ្មាន។ ភិក្ខុ នេះហៅថា មហាចោរទី៣ មានប្រាកដក្នុងលោក។

**៤/** ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មាន ភិក្ខុបាបខ្លះ សង្គ្រោះផ្គាប់ផ្គុនគ្រហស្ថដោយគ្រឿង គរុភណ្ឌរបស់ សង្ឃឬគ្រឿងគរុបរិក្ខារគ្រឿងគរុភណ្ឌគឺអ្វីខ្លះ គ្រឿងគរុភណ្ឌនោះគឺ គុម្ពផ្កា និងដើម

ឈើ១ ទីដែលសម្រាប់ដាំគុម្ពផ្កានិងដើមឈើ១ កុដិ១ទី សំរាប់ សង កុដិ១ គ្រែ១ តាំង១ ពូក១ ខ្នើយ១ ឆ្នាំងលោហៈ១ ស្នូកលោហៈ១ ក្អមលោហៈ១ ផើងលោហៈ១ កាំបិត១ ពូថៅ១ ដឹង១ ចប១ ពន្លាក(ឬដែកកណ្ដារ)១ វល្លិប្រវែងមួយលូកឡើងទៅ១ ឫស្សីប្រវែង៨ធ្នាប់ឡើងទៅ១ ស្មៅដំណេកទន្សាយ១ ស្មៅយាប្លង១ ស្មៅធម្មតា១ដីស្អិត១គ្រឿងធ្វើនិងឈើ១ គ្រឿងធ្វើនិងដី១ ។ភិក្ខុនេះហៅថា មហាចោរទី៤ មានប្រាកដក្នុងលោក។

៥/ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលអួតឧត្ដរិមនុស្សធម្ម ដែលមិនមានមិនប្រាកដក្នុងខ្លួន ភិក្ខុនេះជា **មហាចោរទី៥** ជាចោរធំបំផុតក្នុងលោក ព្រមទាំងទេវលោកមារលោកព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជា សម្មតិទេពនិងមនុស្សដ៏សេស ហេតុអ្វីបានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯងលួចយកមកបរិភោគ។

***ចប់វិន័យឆ្នាំទីពាតែប៉ុណ្ណោះ***

## ៣:វស្សូបនាយិកក្ខន្ធក.

**១. អនុជានាមិ ភិក្ខវេ វស្សំ ឧបគន្តុំ ។** ម្នាលភិក្ខុទាំងឡាយតថាគត អនុញ្ញាតឲ្យភិក្ខុចូលវស្សា ។

**២. អនុជានាមិ ភិក្ខវេ វស្សានេ វស្សំ ឧបគន្តុំ ។** ម្នាលភិក្ខុទាំងឡាយតថាគត អនុញ្ញាត ឱ្យភិក្ខុចូលវស្សាក្នុងវស្សានរដូវ។

**៣.ទ្វេមា ភិក្ខវេ វស្សូបនាយិកា បុរិមិកា បច្ឆិមិកា អបរជ្ជុគតាយ អាសាឡ្ហិយា បុរិមិកា ឧបគន្តព្វា មាសគតាយ អាសាឡ្ហិយា បច្ឆិមិកា ឧបគន្តព្វា ឥមា ខោ ភិក្ខវេ ទ្វេ វស្សូបនាយិកា ។**ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សានេះមានពីរ គឺ ថ្ងៃបុរិមិកា វស្សា ១ ថ្ងៃបច្ឆិមិកា វស្សា ១ ភិក្ខុគួរចូលបុរិមិកាវស្សា ក្នុងថ្ងៃបន្ទាប់នៃថ្ងៃពេញបូរមីខែអាសាឍ (គឺ ថ្ងៃ ១ រោចខែអាសាឍ) ភិក្ខុគួរចូលបច្ឆិមិកាវស្សា ក្នុងថ្ងៃដែលកន្លងហួស១ខែ អំពីថ្ងៃ ពេញបូណ៌មីខែអាសាឍ (គឺ ថ្ងៃ ១ រោចខែស្រាពណ៍) ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សាមានតែ២ យ៉ាងនេះឯង។

**៤.ន ភិក្ខវេ វស្សំ ឧបគន្ត្វា បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ អវសិត្វា ចារិកា បក្កមិតព្វា យោ បក្កមេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយមិននៅចាំបុរិមិកាវស្សាអស់ខែ៣ ឬបច្ឆិមិកាវស្សាអស់ខែ ៣ ទេ មិនត្រូវជៀស ចេញទៅកាន់ចារិកឡើយភិក្ខុណាជៀសចេញទៅ ត្រូវអាបត្តិទុក្កដ។

**៥. ន ភិក្ខវេ វស្សំ ន ឧបគន្តព្វំ យោ ន ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស។**ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនចូលវស្សាឡើយ (គឺត្រូវតែចូលវស្សា)ភិក្ខុណាមិនចូលវស្សាត្រូវអាបត្តិទុក្កដ។

**៦. ន ភិក្ខវេ តទហុវស្សូបនាយិកាយ វស្សំ អនុបគន្តុកាមេ សញ្ចិច្ច អាវាសោ អតិក្កមិតព្វោ យោ អតិក្កមេយ្យ អាបត្តិ ទុក្កដស្ស។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន

ប្រាថ្នានឹងចូលវស្សា ក៏ក្លែងដើរចេញពីអាវាសទៅ ក្នុងថ្ងៃចូលវស្សានោះមិនបានទេ ភិក្ខុណាចេញដើរទៅ ត្រូវអាបត្តិទុក្កដ។

**៧. អនុជានាមិ ភិក្ខវេ រាជូនំ អនុវត្តិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឱ្យភិក្ខុប្រព្រឹត្តិទៅតាមស្តេច ទាំងឡាយចុះ ។

**៨. អនុជានាមិ ភិក្ខវេ សត្តន្នំ សត្តាហករណីយេន បហិតេ គន្តុំ ន ត្វេវ អប្បហិតេ ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស សាមណេរិយា ឧបាសកស្ស ឧបាសិកាយ អនុជានាមិ ភិក្ខវេ ឥមេសំ សត្តន្នំ សត្តាហករណីយេន បហិតេ គន្តុំ នត្វេវ អប្បហិតេ។ សត្តាហំ សន្និវត្តោ កាតព្វោ។** ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង៧ ពួក គឺ ភិក្ខុ ១ ភិក្ខុនី១ សិក្ខមានា១ សាមណេរ១ សាមណេរី១ ឧបាសក១ឧបាសិកា១ បានបញ្ជូលបម្រើមកហើយ តថាគតអនុញ្ញាត ឱ្យភិក្ខុទៅដោយសត្តាហករណីយ(កិច្ចដែលគួរធ្វើបាន៧ថ្ងៃ) កាលបើគេមិន បានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង៧ពួកនេះ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាត ឱ្យភិក្ខុទៅបាន កាលបើគេមិនបញ្ជូលបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់ក្នុងរវាង ៧ថ្ងៃ។

**៩.អនុជានាមិ ភិក្ខវេ បញ្ចន្នំ សត្តាហករណីយេន អប្បហិតេបិ គន្តុំ បគេវ បហិតេ ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស សាមណេរិយា ។ អនុជានាមិ ភិក្ខវេ ឥមេសំ បញ្ចន្នំ សត្តាហករណីយេន អប្បហិតេបិ គន្តុំ បគេវ បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។** ម្នាលភិក្ខុទាំងឡាយ កាលបើសហធម្មិកបុគ្គលទាំង ៥ពួកគឺភិក្ខុ ១ ភិក្ខុនី ១ សិក្ខាមានា ១ សាមណេរ ១ សាមណេរី ១ មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ ម្នាលភិក្ខុទាំងឡាយ ពួកសហធម្មិកបុគ្គលទាំង ៥ ពួកនេះ ទុកជាមិនបានបញ្ជូនបម្រើមកក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណី

យបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។

**១០ អនុជានាមិ ភិក្ខវេ សត្តន្នំ សត្តាហករណីយេន អប្បហិតេបិ គន្តុំ បគេវ បហិតេ, ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស សាមណេរិយា មាតុយា ច បិតុស្ស ច ។ អនុជានាមិ ភិក្ខវេ ឥមេសំ សត្តន្នំ សត្តាហករណីយេន អប្បហិតេបិ គន្តុំ, បគេវ បហិតេ, សត្តាហំ សន្និវត្តោ កាតព្វោ** ។ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង ៧ គឺ ភិក្ខុ ភិក្ខុនី សិក្ខាមានា សាមណេរ សាមណេរី មាតា បិតា មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ច ដែលគេបានបញ្ជូនបម្រើមកហើយនោះម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង៧នេះ មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ

**១១អនុជានាមិ ភិក្ខវេ សង្ឃករណីយេន គន្តុំ សត្តាហំ សន្និវត្តោកាតព្វោ** ។ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសង្ឃករណីយ( កិច្ចដែលសង្ឃគួរធ្វើ ) បាន ហើយត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។

**១២ អនុជានាមិ ភិក្ខវេ យេន គាមោ តេន គន្តុំ** ។ម្នាលភិក្ខុទាំងឡាយ ស្រុកជាទីគោចរមានក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយ ទៅនៅក្នុងទីនោះចុះ ។

**១៣ អនុជានាមិ ភិក្ខវេ យេន ពហុតរា តេន គន្តុំ** ។ ម្នាលភិក្ខុទាំងឡាយ អ្នកស្រុកទាំងឡាយមានចំនួនច្រើនជាងនៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះបាន ។

**១៤ អនុជានាមិ ភិក្ខវេ, យេន សទ្ធា បសន្នា តេន តន្តុំ ។** ម្នាលភិក្ខុទាំងឡាយ ពួកអ្នកស្រុក ដែលមានសទ្ធាជ្រះថ្លា មាននៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅក្នុងទីនោះឯង។
**១៥ អនុជានាមិ ភិក្ខវេ វជេ វស្សំ ឧបគន្តុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងលំនៅរបស់គង្វាលគោបាន ។
**១៦ អនុជានាមិ ភិក្ខវេ យេន វជោ តេនឧបគន្តុំ ។**ម្នាលភិក្ខុទាំងឡាយ លំនៅគង្វាលគោទៅក្នុងទីណា តថាគតអនុញ្ញាតឱ្យភិក្ខុទៅក្នុងទីនោះបាន ។
**១៧ អនុជានាមិ ភិក្ខវេ សត្ថេ វស្សំ ឧបគន្តុំ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុចូលវស្សាក្នុងពួកឈ្មួញរទេះបាន ។
**១៨ អនុជានាមិ ភិក្ខវេ នាវាយំ វស្សំ ឧបគន្តុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុចូលវស្សាក្នុងទូកបាន ។
**១៩ ន ភិក្ខវេ រុក្ខសុសិរេ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។**ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សា ក្នុងរូងឈើទេភិក្ខុណាចូល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។
**២០ ន ភិក្ខវេ រុក្ខវិដភិយា វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។**ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សា លើប្រគាបឈើទេ ភិក្ខុណាចូល ត្រូវអបត្តិទុក្កដ ។
**២១. ន ភិក្ខវេ អជ្ឈោកាសេ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស។**ម្នាលភិក្ខុទាំងឡាយភិក្ខុមិនត្រូវចូលវស្សា ក្នុងទីវាលទេភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ
**២២.ន ភិក្ខវេ អសេនាសនិកេន វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាដោយឥតមានទីសេនាសនៈទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។

**២៣. ន ភិក្ខវេ ឆវកុដិកាយ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។**ម្នាល ភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងខ្ទមខ្មោចទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។

**២៤. ន ភិក្ខវេ ឆត្តេ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងឆត្តទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។

**២៥.ន ភិក្ខវេ ចាដិយា វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។**ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សា ក្នុងពាងទឹកទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ

**២៦.ន ភិក្ខវេ ឯវរូបា កតិកា កាតព្វា អន្តរាវស្សំ ន បព្វាជេតព្វ”ន្តិ យោ ករេយ្យ អាបត្តិ ទុក្កដស្ស ។**ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកតិកាបែបនេះ“ភិក្ខុមិនត្រូវបំបួសកុលបុត្ត ក្នុងកណ្តាលវស្សាទេ” ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

**២៧.ឥធ បន ភិក្ខវេ ភិក្ខុ នោ វស្សាវាសោ បដិស្សុតេ ហោតិ បុរិមិកាយ។ សោ តំ អាវាសំ គច្ឆន្តោ បស្សតិ អន្តរាមគ្គេ ទ្វេ អាវាសេ ពហុចីវរកេ តស្ស ឯវំ ហោតិ “យន្នូនាហំ ឥមេសុ ទ្វីសុ អាវាសេសុ វស្សំ វសេយ្យំ ឯវំ មេ ពហុចីវរំ ឧប្បជ្ជិស្សតី”តិ ។ សោ តេសុ ទ្វីសុ អាវាសេសុ វស្សំ វសតិ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។**ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថា នៅចាំវស្សាដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះកំពុងតែដើរទៅកាន់អាវាសនោះ ក៏បានឃើញអាវាសពីរក្នុងពាក់កណ្តាលផ្លូវ ជាអាវាសមានចីវរច្រើន។ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា “បើដូច្នោះគួរអាត្មាអញនឹងនៅចាំវស្សាក្នុងទាំងពីរនេះចុះ ចីវរមុខជានឹងកើត ដល់អាត្មាអញជាច្រើនដោយអាការយ៉ាងនេះ”។ ភិក្ខុនោះ ក៏នៅចាំអាវាសទាំងពីរនោះ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះមិនប្រាដកផង ភិក្ខុនោះ ត្រូវអាបត្តិទុក្កដព្រោះទទួលពាក្យប្តេជ្ញាផង ។

**២៨.សោ សត្តាហំ អនាគតាយ បវារណាយ សករណីយោ បក្កមតិ។ អាគច្ឆេយ្យ វា សោ ភិក្ខវេ ភិក្ខុ តំ អាវាសំ ន វា អាគច្ឆេយ្យ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច បញ្ញាយតិ បដិស្សវេច អនាបត្តិ។** ភិក្ខុនោះកាលបើនៅខ្វះ ៧ថ្ងៃទៀតនឹងដល់ថ្ងៃបវារណាក៏ប្រកបដោយកិច្ចហើយថយចេញទៅ។ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមកកាន់អាវាសនោះក្តី មិនបានមកក្តី។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិទុក្កដព្រោះទទួលពាក្យប្តេជ្ញាផង។

**វស្សូបនាយិកក្ខន្ធកោ តតិយោ និដ្ឋិតោ ចប់ វស្សូបនាយិកក្ខន្ធកៈទី៣។**

# ប្រជុំកថាធម៌

## ធម្មវិភាគ

## ទុកៈពួក២

### ធម៌មានឧបការៈច្រើន ២ យ៉ាង

១ **សតិ** *សេចក្តីរលឹកបាន*

២ **សម្បជញ្ញៈ** *សេចក្តីដឹងខ្លួន។*

### ធម៌លោកបាល " គ្រប់គ្រងរក្សាលោក " ២ យ៉ាង

១ **ហិរិ** *សេចក្តីខ្មាសបាប*

២ **ឱត្តប្បៈ** *សេចក្តីកោតខ្លាចបាប ។*

### ធម៌ធ្វើឲ្យល្អ ២យ៉ាង

១ **ខន្តី** *សេចក្តីអត់ធន់*

២ **សោរច្ចៈ** *សេចក្តីស្ងប់ស្ងៀម។*

### បុគ្គលរកបានដោយកម្រ ២ ពួក

១ **បុព្វការី** *អ្នកធ្វើឧបការៈមុន*

២ **កតញ្ញូ កតវេទី** *អ្នកដឹងឧបការៈដែលលោកធ្វើហើយ ធ្វើតបវិញ ។*

# តិកៈ ពួក ៣

## រតនៈ ៣ យ៉ាង

**ព្រះពុទ្ធ ១ ព្រះធម្ម ១ ព្រះសង្ឃ ១ៗ**

១ លោកអ្នកប្រដៅពួកជនឲ្យប្រតិបត្តិល្អដោយកាយ វាចា ចិត្ត តាមធម៌វិន័យ ហៅថា ព្រះពុទ្ធ

២ ធម៌វិន័យពាក្យប្រដៅរបស់ព្រះពុទ្ធ ហៅថា **ព្រះធម៌**

៣ ពួកជនដែលបានស្តាប់ពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយបួសប្រតិបត្តិល្អ តាមព្រះធម៌វិន័យ ហៅថា **ព្រះសង្ឃ**ៗ

## គុណរបស់ព្រះរតនៈ ៣ យ៉ាង

**១ ព្រះពុទ្ធ** ទ្រង់ត្រាស់ដឹងប្រពៃ ដោយព្រះអង្គជាមុន ហើយប្រដៅអ្នកដទៃ ឲ្យដឹងតាមផង

**២ ព្រះធម៌** រក្សាអ្នកប្រតិបត្តិ មិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់

**៣ ព្រះសង្ឃ** លោកប្រតិបត្តិល្អ តាមពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយប្រដៅអ្នកដទៃឲ្យធ្វើតាមផង ៗ

## អាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង

**១ អភិញ្ញាយៈ** ទ្រង់ប្រដៅដើម្បីឲ្យអ្នកស្តាប់ដឹងពិត ឃើញពិត ក្នុងធម៌ដែលគួរដឹងគួរឃើញ

**២ សនិទានៈ** ទ្រង់ប្រដៅមានហេតុ កាលអ្នកស្តាប់ត្រិះរិះតាម រមែងឃើញពិតបាន

**៣ សប្បាដិហារិយៈ** ទ្រង់ប្រដៅជាអស្ចារ្យ គឺកាលអ្នកស្តាប់ប្រតិបត្តិតាម រមែងសម្រេចប្រយោជន៍ តាមគួរដល់សេចក្តីប្រតិបត្តិៗ

## ឱវាទរបស់ព្រះពុទ្ធ ៣យ៉ាង

**១ សព្វបាបស្ស អករណំ** មិនឲ្យធ្វើបាបទាំងពួង គឺឲ្យវៀរចាកទុច្ចរិត (ប្រព្រឹត្តអាក្រក់) ដោយកាយ វាចា ចិត្ត

**២ កុសលស្សូបសម្បទា** ឲ្យញុំាំងកុសលឲ្យព្រមគឺឲ្យប្រកបសុចរិត (ប្រព្រឹត្តល្អ) ដោយកាយ ចាវា ចិត្ត

**៣ សចិត្តបរិយោទបនំ** ឲ្យជម្រះចិត្តរបស់ខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត មានលោភៈ ទោសៈ មោហៈ ជាដើម ។

## ទុច្ចរិត ៣ យ៉ាង

**១ កាយទុច្ចរិត** ប្រព្រឹត្តអាក្រក់ដោយកាយ

**២ វចីទុច្ចរិត** ប្រព្រឹត្តអាក្រក់ដោយវាចា

**៣ មនោទុច្ចរិត** ប្រព្រឹត្តអាក្រក់ដោយចិត្ត ។

## កាយទុច្ចរិត ៣ យ៉ាង

**១ បាណាតិបាតៈ** សម្លាប់សត្វ

**២ អទិន្នាទានៈ** លួចទ្រព្យគេ

**៣ កាមេសុ មិច្ឆាចារៈ** ប្រព្រឹត្តខុសក្នុងកាម ។

## វចីទុច្ចរិត ៤ យ៉ាង

**១ មុសាវាទៈ** និយាយកុហកគេ

**២ បិសុណាវាចា** និយាយញុះញង់គេ

**៣ ផរុសវាចា** និយាយចាក់ដោតគេ

**៤ សម្ផប្បលាបៈ** និយាយពាក្យឥតប្រយោជន៍ ។

## មនោទុច្ចរិត ៣ យ៉ាង

**១ អភិជ្ឈា** សម្លឹងរំពៃចង់បានរបស់គេ

**២ ព្យាបាទៈ** ចងចិត្តប្រទូស្តគេ

៣ **មិច្ឆាទិដ្ឋិ** ឃើញខុសចាកគន្លងធម៌ ។

**ទុច្ចរិត ៣ យ៉ាងនេះ ជាធម៌មិនគួរប្រព្រឹត្ត, គួរលះចេញ ។**

## សុចរិត ៣ យ៉ាង

១ **កាយសុចរិត** ប្រព្រឹត្តល្អដោយកាយ

២ **វចីសុចរិត** ប្រព្រឹត្តល្អដោយវាចា

៣ **មនោសុចរិត** ប្រព្រឹត្តល្អដោយចិត្ត ។

## ១ កាយសុចរិត ៣ យ៉ាង

ក ) វៀរចាកការសម្លាប់សត្វ

ខ ) វៀរចាកការលួចទ្រព្យគេ

គ ) វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។

## ២ វចីសុចរិត ៤ យ៉ាង

ក ) វៀរចាកការនិយាយកុហកគេ

ខ ) វៀរចាកការនិយាយញុះញង់គេ

គ ) វៀរចាកការនិយាយចាក់ដោតគេ

ឃ ) វៀរចាកការនិយាយពាក្យឥតប្រយោជន៍ ។

## ៣ មនោសុចរិត ៣ យ៉ាង

ក ) មិនសម្លឹងរំពៃចង់បានរបស់គេ

ខ ) មិនចងចិត្តប្រទូស្តគេ

គ ) ឃើញត្រូវតាមគន្លងធម៌

សុចរិត ៣ យ៉ាងនេះ ជាធម៌គួរប្រព្រឹត្ត ។

## អកុសលមូល ៣ យ៉ាង

បូសគល់របស់អកុសល ហៅថា **អកុសលមូល** មាន ៣ យ៉ាងគឺ

**១ លោភៈ** ចង់បានមិនចេះស្កប់(១)

**២ ទោសៈ** គិតប្រទូស្តគេ

**៣ មោហៈ** វង្វេងមិនដឹងការពិត ។

កាលបើអកុសលមូល ៣ នេះ ណាមួយមានហើយ អកុសលដទៃដែលមិនទាន់កើតរមែងកើតឡើង ដែលកើតឡើងហើយ ក៏ចម្រើនច្រើនឡើង ហេតុនេះគួរលះបង់ឲ្យអស់ចេញ ។

## កុសលមូល ៣ យ៉ាង

បូសគល់របស់កុសល ហៅថា កុសលមូល មាន ៣ យ៉ាងគឺ

**១ អលោភៈ** មិនចង់បាន

**២ អទោសៈ** មិនគិតប្រទូស្តគេ

**៣ អមោហៈ** មិនវង្វេង ។

កាលបើកុសលមូល ៣ នេះ ណាមួយមានហើយ កុសលដទៃដែលមិនទាន់កើត រមែងកើតឡើងដែលកើតឡើងហើយ ក៏ចម្រើនច្រើនឡើង ហេតុនេះគួរធ្វើឲ្យកើតមានក្នុងសន្តាន ។

## សប្បុរិសប្បញ្ញត្តិ បញ្ញត្តិរបស់សប្បុរស ៣ យ៉ាង

**១ ទានៈ** ឲ្យវត្ថុរបស់ខ្លួន ដើម្បីប្រយោជន៍ដល់អ្នកដទៃ

**២ បព្វជ្ជា** កាន់ភេទបួស ដើម្បីជាឧបាយ វៀរចាកធម៌សម្រាប់គ្រហស្ថ

**៣ មាតាបិតុឧបដ្ឋានៈ** ប្រតិបត្តិមាតាបិតាតាមគន្លងធម៌ ។

## អបុណ្ណកប្បដិបទា ប្រតិបត្តិមិនខុស ៣ យ៉ាង

១ **ឥន្ទ្រិយសំវរៈ** សង្រួមឥន្ទ្រិយទាំង ៦ គឺភ្នែកត្រចៀកច្រមុះអណ្ដាត កាយចិត្ត មិនឲ្យមានសោមនស្ស ទោមនស្សក្នុងវេលាដែល ឃើញរូបឮសំឡេងធុំក្លិនស្លូបរស កាយពាល់ត្រូវដឹងធម្មារម្មណ៍ ដោយចិត្ត

២ **ភោជនេ មត្តញ្ញុតា** ស្គាល់ប្រមាណ ក្នុងការបរិភោគអាហារ តែល្មម សមគួរ មិនច្រើនមិនតិច

៣ **ជាគរិយានុយោគៈ** ប្រកបសេចក្ដីព្យាយាមដើម្បីជម្រះចិត្តឲ្យបរិសុទ្ធ ហ្មត់ចត់ មិនឃើញដល់ការដេកច្រើន

## បុញ្ញកិរិយាវត្ថុ ៣ យ៉ាង

វត្ថុជាទីតាំងនៃការបំពេញបុណ្យហៅថា **បុញ្ញកិរិយាវត្ថុ** ដោយខ្លី មាន ៣ យ៉ាង

១ **ទានមយៈ** បុណ្យសម្រេចដោយការបរិច្ចាគទាន

២ **សីលមយៈ** បុណ្យសម្រេចដោយការរក្សាសីល

៣ **ភាវនាមយៈ** បុណ្យសម្រេចដោយការចម្រើនភាវនា ។

## សាមញ្ញលក្ខណៈ ៣ យ៉ាង

លក្ខណៈដែលមានស្មើទូទៅដល់សង្ខារទាំងពួង ហៅថា សាមញ្ញលក្ខណៈ ឬ ត្រៃលក្ខណៈ ចែកជា ៣ យ៉ាង

១ **អនិច្ចតា** សភាពជារបស់មិនទៀង

២ **ទុក្ខតា** សភាពជាទុក្ខ

៣ **អនត្តតា** សភាពជារបស់មិនមែនខ្លួន ។

## ចតុក្កៈ ពួក ៤

## វឌ្ឍិៈ ធម៌ជាគ្រឿងចម្រើន ៤ យ៉ាង

**១ សប្បុរិសូបសំសេវៈ** សេពគប់សប្បុរស គឺលោកអ្នកប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត

**២ សទ្ធម្មស្សវនៈ** ស្តាប់ពាក្យប្រដៅរបស់លោកដោយគោរព

**៣ យោនិសោមនសិការៈ** ត្រិះរិះឲ្យស្គាល់របស់ល្អ ឬ អាក្រក់ ដោយឧបាយដែលត្រូវ

**៤ ធម្មានុធម្មប្បដិបត្តិ** ប្រតិបត្តិធម៌សមគួរដល់ធម៌ ដែលបានត្រិះរិះឃើញហើយ ។

## ចក្កៈ ៤ យ៉ាង

**១ បដិរូបទេសវាសៈ** នៅក្នុងប្រទេសដ៏សមគួរ

**២ សប្បុរិសូបសំសេវៈ** សេពគប់សប្បុរស

**៣ អត្តសម្មាបណិធិ** តាំងខ្លួនទុកដោយប្រពៃ

**៤ បុព្វេ កតបុញ្ញតា** ភាពជាអ្នកបានធ្វើបុណ្យទុកមកពីក្នុងកាលមុន

ធម៌ ៤ យ៉ាងនេះ បីដូចកង់រថ នាំទៅកាន់សេចក្តីចម្រើន ។

## អគតិ ៤ យ៉ាង

**១ ឆន្ទាគតិ** លំអៀងព្រោះស្រឡាញ់

**២ ទោសាគតិ** លំអៀងព្រោះស្អប់

**៣ មោហាគតិ** លំអៀងព្រោះល្ងង់

**៤ ភយាគតិ** លំអៀងព្រោះខ្លាច

អគតិ ៤ យ៉ាងនេះ មិនគួរប្រព្រឹត្តឡើយ ។

## អន្តរាយរបស់ភិក្ខុសាមណេរបួសថ្មី ៤ យ៉ាង

១ អត់ធន់ចំពោះការទូន្មានមិនបាន ខ្ជិលធ្វើតាម

២ ជាមនុស្សឃើញតែការបរិភោគជាប្រមាណ អត់ធន់សេចក្តីស្រេចឃ្លានមិនបាន

៣ ត្រេកអរក្នុងកាមគុណ ចង់បានសេចក្តីសុខលើសលប់ឡើងទៅ

៤ ស្រឡាញ់ស្ត្រីភាព ។

ភិក្ខុសាមណេរប្រាថ្នាសេចក្តីចម្រើនដល់ខ្លួន គួរប្រយ័ត្នកុំឲ្យអន្តរាយ ៤ យ៉ាងនេះមកញាំញីបាន ។

## បធានៈ ការព្យាយាម ៤ យ៉ាង

១ **សំវរប្បធានៈ** ព្យាយាមប្រយ័ត្ន មិនឲ្យបាបកើតឡើងក្នុងសន្តាន

២ **បហានប្បធានៈ** ព្យាយាមលះបាបដែលកើតឡើងហើយ

៣ **ភាវនាបធានៈ** ព្យាយាមញ៉ាំងកុសល ឲ្យកើតឡើងក្នុងសន្តាន

៤ **អនុរក្ខនាបធានៈ** ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឲ្យសាបសូន្យទៅវិញ ។

ព្យាយាម៤យ៉ាងនេះជាធម៌ប្រពៃ គួរប្រកបឲ្យកើតមានក្នុងសន្តាន

## អធិដ្ឋានធម៌ ធម៌ដែលគួរតាំងទុកក្នុងចិត្ត ៤ យ៉ាង

១ **បញ្ញា** ដឹងរបស់ដែលគួរដឹង

២ **សច្ចៈ** សេចក្តីពិតក្នុងចិត្ត គឺតាំងចិត្តនឹងធ្វើអ្វី ក៏ធ្វើពិត

៣ **ចាគៈ** លះរបស់ដែលជាសត្រូវដល់សេចក្តីពិតក្នុងចិត្ត

៤ **ឧបសមៈ** ស្ងប់ចិត្តចាក់របស់ ដែលជាសត្រូវចំពោះសេចក្តីស្ងប់ ។

## ឥទ្ធិបាទធម៌ គុណធម៌ជាជំហរឲ្យសម្រេចប្រយោជន៍ ៤ យ៉ាង

១ **ឆន្ទៈ** ចូលចិត្តស្រឡាញ់ក្នុងកិច្ចការនោះ ៗ

២ **វីរិយៈ** ព្យាយាមប្រកបក្នុងកិច្ចការនោះ ៗ

៣ **ចិត្តៈ** យកចិត្តទុកដាក់ក្នុងកិច្ចការនោះៗ មិនដាក់ធុរៈ

៤ **វីមំសា** ឧស្សាហ៍ត្រិះរិះពិចារណា រកហេតុផល ក្នុងកិច្ចការនោះៗ

ធម៌ ៤ យ៉ាងនេះមានបរិបូណ៌ក្នុងសន្តានដៃបុគ្គលណា អាចដឹកនាំបុគ្គលនោះ ឲ្យសម្រេចតាមសេចក្តីប្រាថ្នាដែលមិនហួសវិស័យ ។

## គួរធ្វើសេចក្តីមិនប្រមាទក្នុងទី ៤ ស្ថាន

១ **កាយទុច្ចរិតប្បហានៈ** ការលះកាយទុច្ចរិត ប្រព្រឹត្តកាយសុចរិត

២ **វចីទុច្ចរិតប្បហានៈ** ការលះវចីទុច្ចរិត ប្រពឹត្តវចីសុចរិត

៣ **មនោទុច្ចរិតប្បហានៈ** ការលះមនោទុច្ចរិត ប្រពឹត្តមនោសុចរិត

៤ **មិច្ឆាទិដ្ឋិប្បហានៈ** ការលះសេចក្តីឃើញខុស ធ្វើសេចក្តីឃើញឲ្យត្រូវ ។

## មួយទៀត គួរប្រយ័ត្នចិត្តកុំឲ្យវង្វេងក្នុងទី ៤ ស្ថាន

១ **រជនីយៈ** កុំត្រេកអរក្នុងអារម្មណ៍ដែលនាំឲ្យមានតម្រេក

២ **ទោសនីយៈ** កុំខឹងក្នុងអារម្មណ៍ដែលនាំឲ្យខឹង

៣ **មោហនីយៈ** កុំវង្វេងក្នុងអារម្មណ៍ដែលនាំឲ្យវង្វេង

៤ **មទនីយៈ** កុំស្រវឹងក្នុងអារម្មណ៍ដែលនាំឲ្យស្រវឹង ។

## អារក្ខកម្មដ្ឋាន កម្មដ្ឋានគួរចម្រើនជានិច្ច ៤ យ៉ាង

១ **ពុទ្ធានុស្សតិ** រលឹកគុណព្រះពុទ្ធដែលមានក្នុងព្រះអង្គនិងគុណដែលទ្រង់សង្គ្រោះដល់អ្នកដទៃ

២ **មេត្តា** ផ្សាយមេត្តាចិត្ត គិតឲ្យមនុស្សសត្វទាំងពួងបានសុខគ្រប់គ្នា

៣ **អសុភៈ** ពិចារណារាងកាយខ្លួននិងអ្នកដទៃ ឲ្យឃើញថាជារបស់បដិកូល គួរខ្ពើម

៤ **មរណស្សតិ** នឹកដល់សេចក្តីស្លាប់ដែលនឹងមានដល់ខ្លួន ។

## ព្រហ្មវិហារធម៌ ៤ យ៉ាង

១ **មេត្តា** សេចក្តីប្រាថ្នា ចង់ឲ្យគេបានសុខ

២ **ករុណា** សេចក្តីអាណិតគិតជួយឲ្យគេរួចចាក់ទុក្ខ

៣ **មុទិតា** សេចក្តីត្រេកអរតាម ក្នុងវេលាគេបានល្អ

៤ **ឧបេក្ខា** សេចក្តីតាំងចិត្តជាកណ្តាលមិនឲ្យសោមនស្សទោមនស្ស ក្នុងវេលាដែលបានសេចក្តីវិបត្តិ ។

## សតិប្បដ្ឋាន ៤ យ៉ាង

១ **កាយានុបស្សនា** សតិរលឹកពិចារណាកាយ ជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយប៉ុណ្ណោះ មិនមែនសត្វជាបុគ្គល ជាខ្លួនប្រាណ ជាយើងជាគេឡើយ

២ **វេទនានុបស្សនា** សតិរលឹកពិចារណាវេទនាគឺសេចក្តីដឹងសុខ ទុក្ខ ឧបេក្ខា ជាអារម្មណ៍ថា វេទនាគ្រាន់តែវេទនាតែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វជាបុគ្គលជាខ្លួនប្រាណ ជាយើងជាគេឡើយ

៣ **ចិត្តានុបស្សនា** សតិរលឹកពិចារណាចិត្តដែលសៅហ្មងនិងផូរផង់ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វជាបុគ្គលជាខ្លួនប្រាណ ជាយើងជាគេឡើយ

៤ **ធម្មានុបស្សនា** សតិរលឹកពិចារណាធម៌ជាកុសលឬអកុសលដែលកើតឡើងជាមួយចិត្តជាអារម្មណ៍ថា ធម៌នេះគ្រាន់តែជាធម៌ប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

## ធាតុកម្មដ្ឋាន ៤ យ៉ាង

## ធាតុ ៤ យ៉ាង

១ **បឋវីធាតុ** ធាតុដី

២ **អាបោធាតុ** ធាតុទឹក

៣ **តេជោធាតុ** ធាតុភ្លើង

៤ **វាយោធាតុ** ធាតុខ្យល់ ។

ធាតុណា មានលក្ខណៈរឹង ធាតុនោះឈ្មោះថា **បឋវីធាតុ** ធាតុនោះដែលជាខាងក្នុង ១៩ គឺ **កេសា** សក់ **លោមា** រោម **នខា** ក្រចក **ទន្តា** ធ្មេញ **តចោ** ស្បែក **មំសំ** សាច់ **ន្ហារូ** សរសៃ **អដ្ឋិ** ឆ្អឹង **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង **វក្កំ** តម្រងបស្សាវៈ **ហទយំ** បេះដូង **យកនំ** ថ្លើម **កិលោមកំ** វាវ **បិហកំ** ក្រពះ **បប្ផាសំ** សួត **អន្តំ** ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ ។

ធាតុណា មានលក្ខណៈ **រាវជ្រួតជ្រាប** ធាតុនោះឈ្មោះថា អាបោធាតុ ធាតុនោះដែលខាងក្នុង១២ គឺ **បិត្តំ** ប្រមាត់ **សេម្ហំ** ស្លេស្ម **បុព្វោ** ខ្ទុះ **លោហិតំ** ឈាម **សេទោ** ញើស **មេទោ** ខ្លាញ់ខាប់ **អស្សុ** ទឹកភ្នែក **វសា** ខ្លាញ់រាវ **ខេឡោ** ទឹកមាត់ **សិង្ឃាណិកា** ទឹកសំបោរ **លសិកា** រំអិល **មុត្តំ** ទឹកមូត្រ ធាតុណា មានលក្ខណៈក្តៅ ធាតុនោះឈ្មោះថា **តេជោធាតុ** ធាតុនោះដែលជាខាងក្នុង ៤ គឺ

១ **សន្តប្បគ្គិ** ភ្លើងដែលញុំាងកាយឲ្យក្តៅ

២ **ជីរណគ្គិ** ភ្លើងដែលញុំាងកាយឲ្យទ្រុឌទ្រោម

៣ **បរិណាមគ្គិ** ភ្លើងដែលញុំាងកាយឲ្យក្រហល់ក្រហាយ

៤ **បរិទយ្ហគ្គិ** ភ្លើងដែលដុតអាហារឲ្យរលួយ ។

**ធាតុណា មានលក្ខណៈបក់ទៅមក ធាតុនោះឈ្មោះថា វាយោធាតុ ធាតុនោះដែលជាខាងក្នុង ៦ គឺ**

១ **ឧទ្ធង្គមវាត** ខ្យល់បក់ឡើងលើ

២ **អធោគមវាត** ខ្យល់បក់ចុះក្រោម

៣ **កុច្ឆិសយវាត** ខ្យល់បក់ក្នុងពោះ

**៤ អាកាសធាតុ** ខ្យល់បក់ក្នុងពោះវៀន

**៥ អង្គមង្គានុសារីវាត** ខ្យល់បក់តាមរាងកាយ

**៦ អស្សាសបស្សាសវាត** ខ្យល់ដកដង្ហើមចេញចូលសេចក្តីកំណត់ពិចារណាកាយនេះឲ្យឃើញថា គ្រាន់តែជាធាតុ៤ គឺដី ទឹក ភ្លើង ខ្យល់ ប្រជុំគ្នាប៉ុណ្ណោះ មិនមែនយើង មិនមែនរបស់យើង ដូច្នេះហៅថា **ធាតុកម្មដ្ឋាន** ។

## អរិយសច្ច ៤ យ៉ាង

**១ ទុក្ខៈ**

**២ សមុទយៈ**

**៣ និរោធៈ**

**៤ មគ្គៈ**

សេចក្តីមិនសប្បាយកាយ មិនសប្បាយចិត្ត ឈ្មោះថា **ទុក្ខ** ព្រោះជារបស់ដែលសត្វអត់ធន់បានដោយកម្រ ។

**តណ្ហា** គឺសេចក្តីអន្ទះអន្ទែងចង់បាន ឈ្មោះថា **សមុទយៈ** ព្រោះជាហេតុនាំឲ្យកើតទុក្ខ ។ តណ្ហានេះមាន ៣ ប្រភេទគឺ តណ្ហាក្នុងអារម្មណ៍ដែលជាទីស្រឡាញ់ពេញចិត្ត ហៅថា **កាមតណ្ហា ១** តណ្ហា ក្នុងសេចក្តីចង់បានជានេះជានោះ ហៅថា **ភវតណ្ហា ១** តណ្ហាក្នុងសេចក្តីមិនចង់បានជានេះជានោះ ហៅថា **វិភវតណ្ហា ១** ។ សេចក្តីរលត់តណ្ហាបាន ទុក្ខរមែងរលត់រស់ ឈ្មោះថា និរោធ ព្រោះជាសេចក្តីរលត់ទុក្ខ ។ បញ្ញាដែលឃើញប្រពៃថា នេះជាតួទុក្ខ នេះជាតួហេតុនាំឲ្យកើតទុក្ខ, នេះជាសេចក្តីរលត់ទុក្ខ, នេះជាផ្លូវនាំឲ្យរលត់ទុក្ខ ឈ្មោះថា មគ្គ ព្រោះជាផ្លូវប្រតិបត្តិឲ្យរលត់ទុក្ខ ។

មគ្គនោះមានអង្គ៨គឺ **សម្មាទិដ្ឋិ** បញ្ញាឃើញដោយប្រពៃ ១ **សម្មាសង្កប្បៈ** សេចក្តីត្រិះរិះដោយប្រពៃ ១ **សម្មាវាចា** វាចាប្រពៃ ១ **សម្មាកម្មន្តៈ** ការងារប្រពៃ ១ **សម្មាអាជីវៈ** ការចិញ្ចឹមជីវិតដោយប្រពៃ ១ **សម្មាវាយាមៈ** ការព្យាយាមដោយប្រពៃ ១ **សម្មាសតិ** សេចក្តីរលឹកដោយប្រពៃ ១ **សម្មាសមាធិ** តាំងចិត្តខ្ជាប់ដោយប្រពៃ ១ ។

## បញ្ចកៈ ពួក ៥

### អនន្តរិយកម្ម ៥យ៉ាង

**១ មាតុឃាតៈ** សម្លាប់មាតា

**២ បិតុឃាតៈ** សម្លាប់បិតា

**៣ អរហន្តឃាតៈ** សម្លាប់ព្រះអរហន្ត

**៤ លោហិតុប្បាទៈ**ប្រទូស្តព្រះពុទ្ធ រហូតដល់ញុំាងព្រះលោហិតឲ្យពុរពង ឬដាំ

**៥ សង្ឃភេទៈ** ញុំាងសង្ឃឲ្យបែកគ្នា ។

កម្ម ៥ យ៉ាងនេះជាបាបដ៏ធ្ងន់ ឃាត់សួគ៌ ឃាត់និព្វាន តាំងនៅក្នុងឋានបារាជិករបស់អ្នកកាន់ព្រះពុទ្ធសាសនា ហាមមិនឲ្យធ្វើយ៉ាងដាច់ខាត ។

### អភិណ្ហប្បច្ចវេក្ខណៈ ៥ យ៉ាង

គ្រហស្ថបព្វជិត គួរពិចារណាធម៌ ៥ ប្រការនេះរាល់ថ្ងៃ ថា

**១ ជរាធម្មោម្ហិ** អាត្មាអញមានសេចក្តីចាស់ជរាជាធម្មតា មិនមិនកន្លងសេចក្តីចាស់ជរានេះបានឡើយ

**២ ព្យាធិធម្មោម្ហិ** អាត្មាអញមានសេចក្តីឈឺចាប់ជាធម្មតា មិនកន្លងសេចក្តីឈឺចាប់នេះបានឡើយ

**៣ មរណធម្មោម្ហិ** អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់នេះបានឡើយ

**៤ សព្វេហិ មេ បិយេហិ** អាត្មាអញនឹងព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ ជាគាប់ចិត្តទាំងអស់មិនខាន
**៥ កម្មស្សកោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួន អាត្មាអញធ្វើកម្មល្អក្តីអាក្រក់ក្តី នឹងជាអ្នកទទួលនូវផលនៃកម្មនោះមិនខាន ។

## វេសារជ្ជករណធម៌ ធម៌ធ្វើឲ្យក្លាហាន ៥ យ៉ាង

**១ សទ្ធា** ជឿរបស់ដែលគួរជឿ គឺជឿកម្មផល
**២ សីលៈ** រក្សាកាយវាចាឲ្យមានរបៀបរៀបរយ
**៣ ពាហុសច្ចៈ** ភាពជាអ្នករៀនសូត្រចេះចាំច្រើន
**៤ វីរិយារម្ភៈ** ប្រារព្ធសេចក្តីព្យាយាម
**៥ បញ្ញា** ដឹងរបស់ដែលគួរដឹង ។

## អង្គរបស់ភិក្ខុ ៥ យ៉ាង

**១ សំវរក្នុងបាតិមោក្ខ** វៀរចាកទោសដែលទ្រង់ហាមធ្វើតាមខដែលទ្រង់អនុញ្ញាត
**២ សំវរក្នុងឥន្ទ្រិយ៍ទាំង៦** គឺប្រយ័ត្នភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនឲ្យសោមនស្សទោមនស្សគ្របសង្កត់ចិត្ត ក្នុងវេលាដែលបានឃើញរូបជាដើម
៣ ជាអ្នកមិននិយាយសប្បាយហ៊ឺហា
៤ នៅក្នុងសេនាសនៈស្ងាត់
៥ មានសេចក្តីឃើញត្រូវ ។
ភិក្ខុត្រូវតាំងនៅក្នុងធម៌ ៥ យ៉ាងនេះឲ្យខ្ជាប់ខ្ជួន ។

## អង្គរបស់ធម្មកថិក ៥ យ៉ាង

១ សម្តែងតាមលំដាប់ មិនច្រូតកាត់ពេក ឲ្យខូចសេចក្តី
២ លើកយកហេតុផលមកអាង ណែនាំឲ្យអ្នកស្តាប់ងាយយល់ចូលចិត្ត

៣ តាំងចិត្តមេត្តាប្រាថ្នាឲ្យជាប្រយោជន៍ដល់អ្នកស្តាប់
៤ មិនសម្តែងធម៌ ព្រោះឃើញលាភសក្ការៈឬអាមិសៈ
៥ មិនសម្តែងធម៌លើកខ្លួនឯង ហើយបន្តុះបង្អាប់អ្នកដទៃ ។
ភិក្ខុជាធម្មកថិក គប្បីតាំងអង្គ ៥ យ៉ាងនេះទុកក្នុងខ្លួន ។

## អានិសង្សនៃការស្តាប់ធម៌ ៥ យ៉ាង

១ **អស្សុតំ សុណាតិ** រមែងបានស្តាប់ធម៌ ដែលមិនទាន់បានស្តាប់
២ **សុតំ បរិយោទបេតិ** ធម៌ណាដែលធ្លាប់ស្តាប់ហើយតែមិនទាន់ចូលចិត្ត នឹងចូលចិត្តច្បាស់ឡើង
៣ **កង្ខំ វិហនតិ** រមែងកម្ចាត់បង់សេចក្តីសង្ស័យចេញបាន
៤ **ទិដ្ឋុជុកំ ករោតិ** រមែងធ្វើសេចក្តីឃើញឲ្យត្រង់តាមការពិត
៥ **ចិត្តមស្ស បសីទតិ** ចិត្តរបស់អ្នកស្តាប់ រមែងជ្រះថ្លា ។

## ពលៈ ធម៌ជាកម្លាំង ៥ យ៉ាង

១ **សទ្ធា** សេចក្តីជឿកម្មផល
២ **វីរិយៈ** សេចក្តីព្យាយាម
៣ **សតិ** សេចក្តីរលឹកបាន
៤ **សមាធិ** សេចក្តីតាំងចិត្តខ្ជាប់
៥ **បញ្ញា** សេចក្តីដឹងស្គាល់ការខុសត្រូវ ។
ធម៌ ៥ យ៉ាងនេះហៅថា ឥន្ទ្រីយ៍ក៏បាន ព្រោះជាធំក្នុងកិច្ចរបស់ខ្លួន

## នីវរណៈ ធម៌ ៥ យ៉ាង

ធម៌ដែលជាគ្រឿងរារាំង ហាមចិត្តមិនឲ្យលុះក្នុងសេចក្តីល្អ ហៅថា**នីវរណៈ**
១ **កាមច្ឆន្ទៈ** ស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍ មានរូបជាដើមដែលជាទីគាប់ចិត្ត
២ **ព្យាបាទៈ** ចងចិត្តគុំគួនអ្នកដទៃ

៣ **ថីនមិទ្ធៈ** ដំណើរដែលចិត្តរួញថយ និងងងុយងោកងក់

៤ **ឧទ្ធច្ចកុក្កុច្ចៈ** ដំណើរដែលចិត្តរាយមាយនិងរសាប់រសល់

៥ **វិចិកិច្ឆា** សេចក្ដីសង្ស័យមិនចេះដាច់ស្រេច ។

**ខន្ធ ៥**

១ **កាយនិងចិត្ត**នេះ ចែកចេញជា ៥ កង ហៅថា **ខន្ធ** ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ប្រជុំគ្នាជាកាយ នេះហៅថា **រូប**

២ **ការកំណត់ដឹងអារម្មណ៍ជាសុខ** គឺ សប្បាយកាយ សប្បាយចិត្ត ឬជាទុក្ខ គឺមិនសប្បាយកាយ មិនសប្បាយចិត្ត ឬឧបេក្ខា គឺព្រងើយ មិនសុខ មិនទុក្ខ ហៅថា **វេទនា**

៣ **សេចក្ដីគត់សម្គាល់ចាំប្មាន** គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ អារម្មណ៍ដែលកើតចំពោះចិត្ត ហៅថា **សញ្ញា**

៤ **ចេតសិក** គឺអារម្មណ៍ដែលកើតរលត់ជាមួយចិត្ត ចំណែកខាងល្អ ហៅថា **កុសល** ខាងអាក្រក់ ហៅថា **អកុសល** ខាងកណ្ដាលមិនល្អ មិនអាក្រក់ ហៅថា **អព្យាក្រឹត** រួមទាំង ៣ យ៉ាងនេះ ហៅថា **សង្ខារ**

៥ **សេចក្ដីដឹងអារម្មណ៍** ក្នុងវេលាដែលអាយតនៈខាងក្រៅមានរូបជាដើម មកប៉ះអាយតនៈខាងក្នុងមានភ្នែកជាដើម ហៅថា **វិញ្ញាណ** ខន្ធ ៥ នេះហៅដោយបំប្រួញថា នាមរូប ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ រួមចូលគ្នាជានាមឬជានាមធម៌ ឯរូបគង់នៅជារូបឬជារូបធម៌ ។

**គារវតា ការគោរព ៦ យ៉ាង**

១ **ពុទ្ធគារវតា** គោរពព្រះពុទ្ធ

២ **ធម្មគារវតា** គោរពព្រះធម៌

៣ **សង្ឃគារវតា** គោរពព្រះសង្ឃ
៤ **សិក្ខាគារវតា** គោរពសិក្សាសូត្ររៀន
៥ **អប្បមាទគារវតា** គោរពសេចក្ដីមិនប្រមាទ
៦ **បដិសន្ថារគារវតា** គោរពបដិសណ្ឋារៈ ។

## សារាណីយធម៌៦យ៉ាង

ធម៌ជាទីតាំងនៃសេចក្ដីរលឹក ហៅថា **សារាណីយធម៌**

១ **មេត្តាកាយកម្ម** តាំងកាយកម្មប្រកបដោយមេត្តាចំពោះគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺ ជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈ ផងគ្នាដោយកាយ មានជួយព្យាបាល ក្នុងវេលាមានអាពាធជាដើម ដោយមេត្តា

២ **មេត្តាវចីកម្ម** តាំងវចីកម្មប្រកបដោយមេត្តាចំពោះគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈផងគ្នាដោយវាចា មានប្រដៅដាស់តឿនជាដើម ដោយមេត្តា ។

៣ **មេត្តាមនោកម្ម** តាំងមនោកម្មប្រកបដោយមេត្តាចំពោះគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺគិតតែរបស់ដែលជាប្រយោជន៍ឲ្យដល់គ្នា

៤ **សាធារណភោគី** ចែកលាភដែលខ្លួនបានមកហើយដោយធម៌ ឲ្យភិក្ខុសាមណេរផងគ្នា មិនហួងហែងឬត្បិតត្បៀតលាក់លៀមទុកបរិភោគតែម្នាក់ឯង

៥ **សីលៈ** រក្សាសីលបរិសុទ្ធស្មើគ្នានឹងភិក្ខុសាមណេរដទៃមិនធ្វើខ្លួនឲ្យជាទីរង្កៀសព្រោះសីលរបស់ខ្លួន

៦ **ទិដ្ឋិ** មានសេចក្ដីឃើញរួមគ្នានឹងភិក្ខុសាមណេរដទៃ មិនវិវាទនឹងអ្នកណា ព្រោះហេតុមានសេចក្ដីឃើញខុសគ្នាឡើយ ។

ធម៌ ៦ យ៉ាងនេះរមែងធ្វើប្រព្រឹត្តឲ្យជាទីស្រឡាញ់ ជាទីគោរពរបស់អ្នកដទៃ ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះដល់គ្នានឹងគ្នា ដើម្បីមិនវិវាទគ្នា ដើម្បីព្រមព្រៀងគ្នា ។

## **អាយតនៈខាងក្នុង ៦**

ភ្នែកត្រចៀកច្រមុះអណ្ដាតកាយចិត្ត **ហៅថាអាយតនខាងក្នុង**

## **អាយតនៈខាងក្រៅ ៦**

រូបសំឡេងក្លិនរសផោដ្ឋព្វនិងធម្មារម្មណ៍ **ហៅថាអាយតនខាងក្រៅ** ។

## **វិញ្ញាណ ៦**

រូប ប៉ះ ភ្នែក កើតសេចក្ដីដឹងឡើង ហៅ **ចក្ខុវិញ្ញាណ** សំឡេង ប៉ះត្រចៀក កើតសេចក្ដីឡើង ហៅ **សោតវិញ្ញាណ** ក្លិន ប៉ះច្រមុះកើតសេចក្ដីដឹងឡើង ហៅ **ជិវ្ហាវិញ្ញាណ** ផោដ្ឋព្វៈ ប៉ះពាល់កាយ កើតសេចក្ដីដឹងឡើង ហៅ **កាយវិញ្ញាណ** ធម៌ កើតចំពោះចិត្ត កើតសេចក្ដីដឹងឡើង ហៅ **មនោវិញ្ញាណ** ។

## **សម្ផស្ស ៦**

អាយតនៈខាងក្នុងមានភ្នែកជាដើម អាយតនៈខាងក្រៅមានរូបជាដើម អាយតនៈខាងក្រៅមានរូបជាដើម វិញ្ញាណមានចក្ខុវិញ្ញាណជាដើម គមខ្ទប់គ្នា ទាំង ៣ នេះ ហៅថា សម្ផស្សៈ មានឈ្មោះហៅតាមអាយតនៈខាងក្នុង ៦ គឺ ចក្ខុសម្ផស្សៈ សោតសម្ផស្សៈ ឃានសម្ផស្សៈ ជិវ្ហាសម្ផស្សៈ កាយសម្ផស្សៈ មនោសម្ផស្សៈ ។

## វេទនា ៦

សម្ផស្ស ជាបច្ច័យឲ្យកើតវេទនា គឺជាសុខខ្លះ ទុក្ខខ្លះ មិនសុខមិនទុក្ខ មានឈ្មោះហៅតាម**អាយតនៈ** ខាងក្នុង ៦ គឺ កើតផ្លូវភ្នែក ហៅ **ចក្ខុសម្ផស្ស**ជា វេទនា កើតផ្លូវត្រចៀក ហៅ **សោតសម្ផស្ស**ជា វេទនា កើតផ្លូច្រមុះ ហៅ **ឃានសម្ផស្ស**ជា វេទនា កើតផ្លូវកាយ ហៅ **កាយសម្ផស្ស**ជា វេទនា កើតផ្លូវចិត្ត ហៅ **មនោសម្ផស្ស**ជា វេទនា ។

## ធាតុ ៦

**១ បឋវីធាតុ** ធាតុដី **២ អាបោធាតុ** ធាតុទឹក **៣ តេជោធាតុ** ធាតុភ្លើង

**៤ វាយោធាតុ** ធាតុខ្យល់ **៥ អាកាសធាតុ** ចន្លោះដែលមានក្នុងកាយ

**៦ វិញ្ញាណធាតុ** សេចក្តីដឹងអ្វី ៗ បាន ។

## សត្តកៈ ពួក ៧

## អបរិហានិយធម៌ ៧ យ៉ាង

ធម៌ដែលនាំឱ្យចម្រើន ហៅថា **អបរិហានិយធម៌**មាន ៧យ៉ាង

១ ឧស្សាហ៍ប្រជុំគ្នារឿយ ៗ

២ កាយប្រជុំគ្នា ក៏ព្រមព្រៀងគ្នាប្រជុំគ្នា កាលលើកលែងប្រជុំក៏ព្រមព្រៀងគ្នាលើក ទាំងព្រមព្រៀងគ្នាជួយធ្វើករណីយកិច្ច ដែលសង្ឃនឹងគប្បីធ្វើផង

៣ ខណៈដែលព្រះពុទ្ធមិនបានបញ្ញត្ត មិនបញ្ញត្តឡើង ទាំងមិនដកខដែលទ្រង់បញ្ញត្តហើយ សមាទានរក្សា តាមសិក្ខាបទដែលទ្រង់បញ្ញត្តហើយ

៤ ភិក្ខុណាជាធំជាប្រធានក្នុងសង្ឃ គោរពរាប់អានភិក្ខុនោះជឿស្តាប់ពាក្យលោក

៥ មិនលុះតាមអំណាចចំណង់ដែលកើតឡើង

៦ ត្រេកអរក្នុងសេនាសនៈស្ងាត់
៧ តាំងចិត្តគិតថា សព្រហ្មចារី គឺ ភិក្ខុសាមណេរ ជាអ្នកមានសីល មិនទាន់មកកាន់អាវាសនេះ សូមឲ្យមក ដែលមកហើយ សូមឲ្យនៅជាសុខសប្បាយ ។

ធម៌ ៧ យ៉ាងនេះ កាលបើបានតាំងនៅក្នុងបុគ្គលណា បុគ្គលនោះមិនមានសេចក្តីសាបសូន្យឡើយ មានតែសេចក្តីចម្រើនប៉ុណ្ណោះ ។

## អរិយទ្រព្យ ៧ ប្រការ

១ **សទ្ធាធនំ** ទ្រព្យគឺសេចក្តីជឿ គឺជឿលើកម្មផល
២ **សីលធនំ** ទ្រព្យគឺការរក្សាកាយឲ្យរៀបរយល្អ
៣ **ហិរីធនំ** ទ្រព្យគឺសេចក្តីខ្លាសអំពើបាប
៤ **ឱត្តប្បធនំ** ទ្រព្យគឺសេចក្តីខ្លាចអំពើបាប
៥ **សុតធនំ** ទ្រព្យគឺការបានស្តាប់នូវធម៌របស់ព្រះសម្មាសម្ពុទ្ធ
៦ **ចាគធនំ** ទ្រព្យគឺការបរិច្ចាគទាន
៧ **បញ្ញាធនំ** ទ្រព្យគឺសេចក្តីដឹងស្គាល់របស់ដែលជាប្រយោជន៍និងមិនជាប្រយោជន៍ ។អរិយទ្រព្យ ៧ ប្រការនេះ ល្អជាងទ្រព្យខាងក្រៅមានមាសប្រាក់ជាដើម ។

## សប្បុរិសទាន ៥ យ៉ាង

**១.សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយគោរពចំពោះវត្ថុដែលគួរឱ្យ
**២.ចិត្តី កត្វា ទានំ ទេតិ**ឱ្យទានដោយតាំងចិត្តគោរពចំពោះវត្ថុនិងបដិគ្គាហកៈ
**៣.សហត្ថា ទានំ ទេតិ** ឱ្យទានដោយដៃខ្លួនឯង
**៤.អនបវិទ្ធំ ទានំ ទេតិ** ឱ្យទានដោយមិនបោះឱ្យ
**៥.អាគមនទិដ្ឋិកោទានំ ទេតិ** ឱ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត។

# សប្បុរិសធម៌ ធម៌របស់សប្បុរស៧ យ៉ាង

**១ ធម្មញ្ញុតា** ភាពជាអ្នកស្គាល់ហេតុ

**២ អត្ថញ្ញុតា** ភាពជាអ្នកស្គាល់ប្រយោជន៍

**៣ អត្តញ្ញុតា** ភាពជាអ្នកស្គាល់ខ្លួន

**៤ មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណ

**៥ កាលញ្ញុតា** ភាពជាអ្នកស្គាល់កាល

**៦ បរិសញ្ញុតា** ភាពជាអ្នកស្គាល់ទីប្រជុំ

**៧ បុគ្គលញ្ញុតា** ភាពជាអ្នកស្គាល់បុគ្គលថា អ្នកនេះជាមនុស្សល្អគួរគប់រក អ្នកនេះជាមនុស្សមិនល្អមិនគួរគប់រក ជាដើម ។

## សប្បុរិសធម៌ ៧ យ៉ាងផ្សេងទៀត

១ មានសទ្ធា មានសេចក្តីខ្មាសបាបខ្លាចបាប ជាអ្នកបានឮបានស្តាប់ច្រើន ជាអ្នកមានព្យាយាម ជាអ្នកមានសេចក្តីខ្ជាប់ខ្ជួន ជាអ្នកមានបញ្ញា

២ នឹងប្រឹក្សាអ្វីជាមួយអ្នកណា ក៏មិនប្រឹក្សា ដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ

៣ នឹងគិតអ្វី ក៏មិនគិតដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ

៤ នឹងពោលអ្វី ក៏មិនពោលដើម្បីបៀតបៀនខ្លួនអ្នកដទៃ

៥ នឹងធ្វើអ្វី ក៏មិនធ្វើដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ

៦ មានសេចក្តីឃើញប្រពៃ គឺឃើញថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ជាដើម

៧ ឲ្យទានដោយគោរព គឺរើរើពើនឹងរបស់ដែលខ្លួនឲ្យ រើពើដល់អ្នកទទួលទាន មិនធ្វើអាការដូចជាបោះចោល ។

## **ពោជ្ឈង្គៈ ៧ យ៉ាង**

១ **សតិ** សេចក្តីរលឹកបាន

២ **ធម្មវិចយៈ** សេចក្តីពិចារណាជ្រើសរកធម៌

៣ **វីរិយៈ** សេចក្តីព្យាយាម

៤ **បីតិ** សេចក្តីឆ្អែតចិត្ត

៥ **បស្សទ្ធិ** សេចក្តីស្ងប់ចិត្ត

៦ **សមាធិ** សេចក្តីតាំងចិត្តខ្ជាប់

៧ **ឧបេក្ខា** សេចក្តីតាំងចិត្តជាកណ្តាល ។

ហៅតាមប្រភេទថា **សតិសម្ពោជ្ឈង្គ** ដោយលំដាប់ ដល់ឧបេក្ខាសម្ពោជ្ឈង្គ ។

## **អដ្ឋកៈ ពួក ៨**

### **លោកធម៌ ៨ យ៉ាង**

ធម៌ដែលគ្របសង្កត់សត្វលោក សត្វលោកប្រព្រឹត្តទៅតាម ធម៌នោះហៅថា **លោកធម៌ៗ** នោះមាន ៨ គឺ មានលាភ ១ គ្មានលាភ ១ មានយស ១, គ្មានយស ១ និន្ទា ១សរសើរ ១ សុខ ១ទុក្ខ ១ ។ លោកធម៌ទាំង ៨ នេះណាមួយកើតឡើង គួរពិចារណាថា របស់នេះកើតឡើងហើយដល់អាត្មាអញ សុទ្ធតែជារបស់មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឲ្យដឹងពិតតាមធម្មតា កុំឲ្យមកគ្របសង្កត់ចិត្តបាន គឺកុំឲ្យមានសោមនស្សចំពោះអារម្មណ៍ដដែលជាទីប្រាថ្នាកុំមានទោមនស្ស ចំពោះអារម្មណ៍មិនជាទីប្រាថ្នា ។

# លក្ខណៈសម្រាប់វិនិច្ឆ័យធម៌វិន័យមាន ៨ ប្រការ

១ **សរាគាយ** ធម៌ណាប្រព្រឹត្តទៅ ដើម្បីតម្រេក

២ **សំយោគាយ** ធម៌ណាប្រព្រឹត្តទៅ ដើម្បីប្រកបដោយទុក្ខ

៣ **អាចយាយ** ធម៌ណាប្រព្រឹត្តទៅ ដើម្បីសន្សំកិលេស

៤ **មហិច្ឆតាយ** ធម៌ណាប្រព្រឹត្តទៅ ដើម្បីប្រាថ្នាធំ

៥ **អសន្តុដ្ឋិយា** ធម៌ណាប្រព្រឹត្តទៅ ដើម្បីសន្ដោសតាមមានតាមបាន

៦ **សង្គណិកាយ** ធម៌ណាប្រព្រឹត្តទៅដើម្បីច្រឡូកច្រឡំដោយពួកគណៈ

៧ **កោសជ្ជាយ** ធម៌ណាប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស

៨ **ទុព្ភរតាយ** ធម៌ណាប្រព្រឹត្តទៅ ដើម្បីការចិញ្ចឹមក្រ

ធម៌នោះគប្បីដឹងថា មិនមែនជាធម៌ ជាវិន័យ មិនមែនជាពាក្យប្រៀនប្រដៅ របស់ព្រះសាស្ដាទេ ។ ធម៌ណាប្រព្រឹត្តទៅខុសផ្ទុយគ្នានឹងលក្ខណៈ ៨ ប្រការ ដូចពោលហើយ មាន ៨ ប្រការដែរគឺ

១ **វិរាគាយៈ** ប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក

២ **វិសំយោគាយៈ** ប្រព្រឹត្តទៅ ដើម្បីប្រាសចាកទុក្ខ

៣ **អបចយាយៈ** ប្រព្រឹត្តទៅ ដើម្បីមិនសន្សំកិលេស

៤ **អប្បិច្ឆតាយៈ** ប្រព្រឹត្តទៅ ដើម្បីប្រាថ្នាតិច

៥ **សន្តុដ្ឋិយា** ប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ចំពោះវត្ថុ តាមមានតាមបាន

៦ **វិវេកាយៈ** ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងាត់ចាកពួកគណៈ

៧ **វិរិយារម្ភាយៈ** ប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម

៨ **សុភរតាយៈ** ប្រព្រឹត្តទៅ ដើម្បីការចិញ្ចឹមងាយ

ធម៌៨ប្រការនេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ។

## **អដ្ឋង្គិកមគ្គ មានអង្គ៨**

**១ សម្មាទិដ្ឋិ** បញ្ញាឃើញប្រពៃ គឺឃើញអរិយសច្ចៈ ៤

**២ សម្មាសង្កប្បៈ** ត្រិះរិះប្រពៃ គឺត្រិះរិះនឹងចេញចាកកាម ១ ត្រិះរិះ ក្នុងការមិនជាហេតុឲ្យកើតជាបាប ១ ត្រិះរិះ ក្នុងការមិនជាហេតុបៀតបៀន ១

**៣ សម្មាវាចា** វាចាប្រពៃ គឺវៀរចាកវចីទុច្ចរិត ៤

**៤ សម្មាកម្មន្តៈ** ការងារប្រពៃ គឺវៀរកាយទុច្ចរិត ៣

**៥ សម្មាអាជីវៈ** ចិញ្ចឹមជីវិតប្រពៃ គឺវៀរចាកការចិញ្ចឹមជីវិតដោយផ្លូវខុស

**៦ សម្មាវាយាមៈ** ព្យាយាមប្រពៃ គឺព្យាយាមក្នុងទី ៤ ស្ថានមានព្យាយាមការពារមិនឲ្យបាបអកុសលកើតឡើងក្នុងសន្តានជាដើម

**៧ សម្មាសតិ** រលឹកប្រពៃ គឺរលឹកក្នុងសតិប្បដ្ឋាន ៤

**៨ សម្មាសមាធិ** តាំងចិត្តខ្ជាប់ប្រពៃ គឺចម្រើន ឈាន ៤ ។

ក្នុងអដ្ឋមគ្គទាំង ៨ នេះសម្មាទិដ្ឋិ សម្មាសង្កប្ប: សង្គ្រោះចូលក្នុងបញ្ញាសិក្ខា សម្មាវាចា សម្មាកម្មន្ត: សម្មាជីវ: សង្គ្រោះចូលក្នុងសីលសិក្ខា សម្មាវាយាម: សម្មាសធិ សង្គ្រោះចូលក្នុងចិត្តសិក្ខា ។

## **នវកៈ ពួក ៩**

## **មលៈ ធម៌ជាមន្ទិល ៩ យ៉ាង**

**កោធៈ** ក្រោធ ១ **មក្ខៈ** រមិលគុណគេ១ **ឥស្សា** ច្រណែន ១ **មច្ឆរិយៈ** កំណាញ់ ១ **មាយា** លាក់ពុត ១ **សាថេយ្យៈ** អួតអាង ១ **មុសា** ពោលកុហក ១ **បាបិច្ឆៈ** ប្រាថ្នាអាក្រក់ ១ **មិច្ឆាទិដ្ឋិ** យល់ឃើញខុស ១ ។

# ទសកៈ ពួក ១០

## អកុសលកម្មបថ ១០

### កាយកម្ម ៣

១ **បាណាតិបាតះ** សម្លាប់សត្វ

២ **អទិន្នាទានះ** លួចទ្រព្យគេ

៣ **កាមេសុ មិច្ឆាចារះ** ប្រព្រឹត្តខុសក្នុងកាម ។

### វចីកម្ម៤

៤ **មុសាវាទះ** និយាយកុហក

៥ **បិសុណាវាចា** និយាយញុះញង់

៦ **ផរុសវាចា** និយាយចាក់ដោត

៧ **សម្ផប្បលាបះ** និយាយពាក្យឥតប្រយោជន៍ ។

### មនោកម្ម៣

៨ **អភិជ្ឈា** សម្លឹងរំពៃចង់បានរបស់គេ

៩ **ព្យាបាទះ** ចងចិត្តគុំគួនគេ

១០ **មិច្ឆាទិដ្ឋិ** ឃើញខុសចាកគន្លងធម៌ ។

កម្ម ១០ យ៉ាងនេះ ជាផ្លូវបាប មិនគួរប្រព្រឹត្ត ។

## កុសលកម្មបថ ១០

### កាយកម្ម ៣ យ៉ាង

១ **បាណាតិបាតា វេរមណី** វៀរចាកការសម្លាប់សត្វ

២ **អទិន្នាទានា វេរមណី** វៀរចាកការលួចទ្រព្យគេ

៣ **កាមេសុ មិច្ឆាចារា វេរមណី** វៀរចាកការប្រព្រឹត្តខុសក្នុងកាម

### វចីកម្ម ៤ យ៉ាង

៤ **មុសាវាទា វេរមណី** វៀរចាកការនិយាយកុហក

៥ **បិសុណាយ វាចាយ វេរមណី** វៀរចាកការនិយាយញុះញង់

៦ **ផរុសាយ វាចាយ វេរមណី** វៀរចាកការនិយាយចាក់ដោត

៧ **សម្ផប្បលាប វេរមណី** វៀរចាកការនិយាយពាក្យឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

៨ **អនភិជ្ឈា** មិនសម្លឹងរំពៃចង់បានរបស់គេ

៩ **អព្យាបាទៈ** មិនគិតគុំគួនគេ

១០ **សម្មាទិដ្ឋិ** ឃើញត្រូវតាមគន្លងធម៌ ។

កម្ម ១០ យ៉ាងនេះ ជាផ្លូវបុណ្យ គួរប្រព្រឹត្ត ។

## បុញ្ញកិរិយាវត្ថុ ១០ យ៉ាង

១ **ទានមយៈ** បុណ្យសម្រេចដោយការបរិច្ចាគទាន

២ **សីលមយៈ** បុណ្យសម្រេចដោយការរក្សាសីល

៣ **ភាវនាមយៈ** បុណ្យសម្រេចដោយការភាវនា

៤ **អបចាយនមយៈ** បុណ្យសម្រេចដោយការប្រព្រឹត្តឱនលំទោនគោរព

៥ **វេយ្យាវច្ចមយៈ** បុណ្យសម្រេចដោយការជួយខ្វល់ខ្វាយ ក្នុងកល្យាណកិច្ច

៦ **ធម្មទេសនាមយៈ** បុណ្យសម្រេចដោយការសម្ដែងធម៌

៧ **ធម្មស្សវនមយៈ** បុណ្យសម្រេចដោយការស្ដាប់ធម៌

៨ **បត្តិទានមយៈ** បុណ្យសម្រេចដោយការឲ្យចំណែកបុណ្យ

៩ **បត្តានុមោទនាមយៈ** បុណ្យសម្រេចដោយការអនុមោទនាបុណ្យ

១០ **ទិដ្ឋុជុកម្ម** ការធ្វើសេចក្ដីយល់ឃើញឲ្យត្រង់តាមការពិត ។

## អភិណ្ហប្បច្ចវេក្ខណៈ១០យ៉ាង

ធម៌ដែលបព្វជិតគួរចារណារឿយ ៗ

**១ វេវណ្ណិយម្ហិ អជ្ឈូបគតោ** អាត្មាអញមានភេទផ្សេងអំពីគ្រហស្ថហើយ អាការកិរិយាណា របស់សមណៈ អាត្មាអញប្រព្រឹត្តធ្វើអាការកិរិយានោះ

**២ បរប្បដិពទ្ធា មេ ជីវិកា** ការចិញ្ចឹមជីវិតរបស់អាត្មាអញជាប់ដោយសារអ្នកដទៃ អាត្មាអញគួរធ្វើខ្លួនឲ្យគេចិញ្ចឹមងាយ

**៣ អញ្ញោ មេ អាកប្បោ ករណីយោ** អាកាកិរិយា កាយ វាចា យ៉ាងដទៃៗ ដែលអាត្មាអញនឹងត្រូវប្រព្រឹត្ត ឲ្យល្អជាងនេះនៅមានទៀត

**៤ កច្ចិ នុខោ មេ អត្តា សីលតោ នឧបវទតិ** ខ្លួនអាត្មាអញមិនតិះដៀលខ្លួនឯង ព្រោះសីល (មិនបរិបូណ៌) បានដែរឬទេ ?

**៥ កច្ចិ នុខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ នឧបវទន្តិ** ពួកព្រហ្មចារីអ្នកដឹងទាំងឡាយ ពិចារណាហើយមិនតិះដៀលអាត្មាអញ ព្រោះសីល (មិនបរិបូណ៌) បានដែរឬទេ ?

**៦ សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ** អាត្មាអញ គង់តែនឹងព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ពេញចិត្តទាំងអស់

**៧ កម្មស្សកោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួន អាត្មាអញធ្វើនូវកម្មណាជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងជាអ្នកទទួលនូវផលនៃកម្មនោះ

**៨ កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ** ថ្ងៃនឹងយប់កន្លងទៅៗ ឥឡូវនេះអាត្មាអញបានធ្វើខ្លះហើយ

**៩ កច្ចិ នុខោហំ សុញ្ញាគារេ អភិរមាមិ** អាត្មាអញត្រេកអរក្នុងផ្ទះស្ងាត់ដែរឬទេ ?

**១០ អត្ថិ នុខោ មេ ឧត្តរិមនុស្សធម្មា** ឧត្តរិមនុស្សធម៌ របស់អាត្មាអញ មានឬទេ ? បើពួកព្រហ្មចារីមកសួរក្នុងបច្ឆិមកាលតើអាត្មាអញនឹងមិនអៀនខ្មាសឬទេ ?

## នាថករណធម៌ ធម៌ធ្វើទីពឹង ១០ យ៉ាង

**១ សីល** រក្សាកាយវាចា ឲ្យរៀបរយ

**២ ពាហុសច្ចៈ** ភាពជាអ្នកបានរៀន បានស្តាប់ច្រើន

**៣ កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តសម្លាញ់ល្អ

**៤ សោវចស្សតា** ភាពជាអ្នកគេប្រដៅងាយ

**៥ កឹករណីយេសុ ទក្ខតា** ភាពជាអ្នកប៉ិនប្រសប់ព្រមទាំងឧស្សាហ៍យកចិត្តទុកដាក់ជួយក្នុងកិច្ចធុរៈ របស់ភិក្ខុសាមណេរផងគ្នា

**៦ ធម្មកាមតា** ភាពជាអ្នកស្រឡាញ់ធម៌

**៧ វីរិយៈ** ព្យាយាមលះសេចក្តីអាក្រក់ ប្រព្រឹត្តល្អ

**៨ សន្តុដ្ឋី** សន្តោសត្រេកអរចំពោះបច្ច័យ ៤ តាមមានតាមបាន

**៩ សតិ** ចាំការដែលបានធ្វើ នឹងពាក្យដែលបានពោលហើយសូម្បីយូរអង្វែងបាន

**១០ បញ្ញា** ដឹងសេចក្តីប្រព្រឹត្តទៅនៃកងសង្ខារ ។

## កថាវត្ថុ ពាក្យដែលគួរពោល ១០ យ៉ាង

**១ អប្បិច្ឆកថា** ពាក្យដែលនាំឲ្យមានប្រាថ្នាតិច

**២ សន្តុដ្ឋីកថា** ពាក្យដែលនាំឲ្យមានសន្តោស ត្រេកអរចំពោះបច្ច័យតាមមានតាមបាន

**៣ បវិវេកកថា** ពាក្យដែលនាំឲ្យមានស្ងាត់កាយ ស្ងាត់ចិត្ត

**៤ អសំសគ្គកថា** ពាក្យដែលនាំមិនឲ្យច្រឡូកច្រឡំដោយពួកគណៈ

**៥ វីរិយារម្ភកថា** ពាក្យដែលនាំឲ្យប្រាថ្នាព្យាយាម

៦ **សីលកថា** ពាក្យដែលនាំឲ្យតាំងនៅក្នុងសីល

៧ **សមាធិកថា** ពាក្យដែលនាំឲ្យធ្វើចិត្តឲ្យស្ងប់

៨ **បញ្ញាកថា** ពាក្យដែលនាំឲ្យកើតបញ្ញា

៩ **វិមុត្តិកថា** ពាក្យដែលនាំឲ្យធ្វើចិត្តឲ្យផុតចាកកិលេស

១០ **វិមុត្តិញ្ញាណទស្សនកថា** ពាក្យដែលនាំឲ្យកើតសេចក្តីដឹងឃើញ ក្នុងការដែលចិត្តផុតចាកកិលេស ។

## អនុស្សតិ អារម្មណ៍ដែលគួររលឹក ១០ យ៉ាង

១ **ពុទ្ធានុស្សតិ** រលឹកដល់គុណព្រះពុទ្ធ

២ **ធម្មានុស្សតិ** រលឹកដល់គុណព្រះធម៌

៣ **សង្ឃានុស្សតិ** រលឹកដល់គុណព្រះសង្ឃ

៤ **សីលានុស្សតិ** រលឹកដល់សីលរបស់ខ្លួន

៥ **ចាគានុស្សតិ** រលឹកដល់ទានដែលខ្លួនបានបរិច្ចាគហើយ

៦ **ទេវតានុស្សតិ** រលឹកដល់គុណធម៌ ដែលធ្វើបុគ្គលឲ្យជាទេវតា

៧ **មរណានុស្សតិ** រលឹកដល់សេចក្តីស្លាប់ដែលនឹងមានដល់ខ្លួន

៨ **កាយគតានុស្សតិ** រលឹកទូទៅក្នុងកាយ ឲ្យឃើញថា ជារបស់មិនស្អាតគួរខ្ពើម

៩ **អានាបានស្សតិ** តាំងសតិកំណត់ដង្ហើមចេញចូល

១០ **ឧបសមានុស្សតិ** រលឹកដល់ព្រះនិព្វាន ជាទីរម្ងាប់កិលេសនិងកងទុក្ខ

## បកិណ្ណកៈ ពួកធម៌រាយរង

## ឧបក្កិលេស ទោសជាគ្រឿងសៅហ្មង ១៦ យ៉ាង

១ **អភិជ្ឈាវិសមលោភៈ** *លោភមិនស្មើ គឺគយគន់រំពៃចង់បានមិនរើសមុខ*

២ **ទោសៈ** គិតប្រទូស្ត

៣ **កោធៈ** ក្រោធ

៤ **ឧបនាហៈ** ចងក្រោធទុក

៥ **មក្ខៈ** រមិលគុណគេ

៦ **បឡាសៈ** ធ្វើខ្លួនស្មើ គឺលើកខ្លួនផ្ទឹមនឹងអ្នកខ្ពង់ខ្ពស់

៧ **ឥស្សា** ឫស្យា គឺសេចក្ដីច្រណែនឈ្នានីស

៨ **មច្ឆរិយៈ** កំណាញ់

៩ **មាយា** មាយា គឺលាក់ពុតបាំងទោសខ្លួន

១០ **សាថេយ្យៈ** អួតអាង

១១ **ថម្ភៈ** មុខរឹង

១២ **សារម្ភៈ** ប្រណាំងវាសនា

១៣ **មានៈ** ប្រកាន់ខ្លួន

១៤ **អតិមានៈ** មើលងាយគេ

១៥ **មទៈ** ស្រវឹង

១៦ **បមាទៈ** ប្រហែសធ្វេស ។

ពោធិបក្ខិយធម៌ ៣៧ ប្រការ

សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤

ឥន្ទ្រីយ ៥ ពលៈ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ ៨

# ចតុក្កៈ ពួក ៤

## កម្មក្កិលេស កម្មជាគ្រឿងសៅហ្មង ៤ យ៉ាង

**១ បាណាតិបាតៈ** សម្លាប់សត្វ

**២ អទិន្នាទានៈ** លួចទ្រព្យគេ

**៣ កាមេសុ មិច្ឆាចារៈ** ប្រព្រឹត្តខុសក្នុងកាម

**៤ មុសាវាទៈ** និយាយកុហក

កម្ម ៤ យ៉ាងនេះ អ្នកប្រាជ្ញចៀសវាងជានិច្ច ។

## អបាយមុខ ហេតុជាគ្រឿងវិនាស ៤ យ៉ាង

**១ ឥត្ថីធុត្តៈ** ជាអ្នកលេងស្រី

**២ សុរាធុត្តៈ** ជាអ្នកលេងស្រា

**៣ អក្ខធុត្តៈ** ជាអ្នកលេងល្បែងភ្នាល់ឬល្បែងស៊ីសង

**៤ បាបមិត្តៈ** យកមនុស្សអាក្រក់ជាមិត្ត ។

ទោស ៤ យ៉ាងនេះ មិនគួរប្រព្រឹត្តឡើយ ។

## ទិដ្ឋធម្មិកត្ថ ប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាង

**១ ឧដ្ឋានសម្បទា** ដល់ព្រមដោយសេចក្តីព្យាយាម គឺព្យាយាម ក្នុងការប្រកបកិច្ចគ្រឿងចិញ្ចឹមជីវិតក្តី ក្នុងការសិក្សាសូត្ររៀនក្តី ក្នុងការកិច្ចធុរៈ ជាមុខការនាទីរបស់ខ្លួនក្តី

**២ អារក្ខសម្បទា** ដល់ព្រមដោយការរក្សា គឺរក្សាទ្រព្យដែលរកបានមកដោយសេចក្តីព្យាយាមមិនឲ្យវិនាសទៅក្តី រក្សាការងាររបស់ខ្លួនមិនឲ្យសាបសូន្យទៅក្តី

**៣ កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ មិនសេពគប់មិត្តអាក្រក់

**៤ សមជីវិតា** ការចិញ្ចឹមជីវិតតាមសមគួរដល់កម្លាំងទ្រព្យដែលរកបានមក គឺមិនត្បិតត្បៀតពេក មិនកញ្ជះកញ្ជាយពេក ។

## សម្បរាយិកត្ថ: ប្រយោជន៍ខាងមុខ ៤ យ៉ាង

**១ សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា គឺជឿរបស់ដែលគួរជឿ ដូចជឿថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ជាដើម

**២ សីលសម្បទា** ដល់ព្រមដោយសីល គឺរក្សាកាយវាចាឲ្យរៀបរយ ឲ្យផុតចាកទោស

**៣ ចាគសម្បទា** ដល់ព្រមដោយការបរិច្ចាគទាន ជាការចែកសុខដល់អ្នកដទៃ

**៤ បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា គឺស្គាល់បុណ្យបាបគុណទោស ប្រយោជន៍ឥតប្រយោជន៍ជាដើម ។

## មិត្តដែលមិនគួរសេពគប់ មាន ៤ ប្រភេទ

**១ អញ្ញទត្ថុហរៈ** មិត្តឃើញតែខាងបាបរំពីគេ

**២ វចីបរមៈ** មិត្តល្អតែមាត់

**៣ អនុប្បិយភាណី** មិត្តប្រចុប

**៤ អបាយសហាយៈ** មិត្តដឹកនាំក្នុងផ្លូវវិនាស ។

មនុស្ស ៤ ពួកនេះ ហៅថា មិត្តប្បដិរូប មិត្តប្លម

**១ អញ្ញទត្ថុហរៈ** មនុស្សឃើញតែខាងបានរំពីគេមានលក្ខណៈ ៤ យ៉ាង

ក ) គិតពីតែខាងបាប

ខ ) ឲ្យតិច ចង់បានច្រើន

គ ) កាលមានភ័យដល់ខ្លួន ទើបជួយធ្វើកិច្ចរបស់មិត្ត

ឃ ) សេពគប់មិត្ត ព្រោះឃើញប្រយោជន៍ខ្លួន ។

**២ វចីបរមៈ** មនុស្ស ល្អតែមាត់ មានលក្ខណៈ ៤ យ៉ាង

ក ) រើសយករឿងហេតុដែលកន្លងទៅហើយមកពិពណ៌នា
ខ ) អាងយករឿងហេតុមកពិពណ៌នា
គ ) សង្គ្រោះដោយរបស់ឥតប្រយោជន៍
ឃ ) កាលមានកិច្ចកើតឡើង ពឹងប្រាស្រ័យផងពុំបាន ។
**៣ អនុប្បិយភាណី** មនុស្សប្រុចុប មានលក្ខណៈ ៤ យ៉ាង
ក ) មិត្រធ្វើអាក្រក់ ក៏បណ្ដោយតាម
ខ ) មិត្រធ្វើល្អ ក៏បណ្ដោយតាម
គ ) ចំពោះមុខសរសើរ
ឃ ) កំបាំងពីមុខ និន្ទា ។
**៤ អបាយសហាយៈ** មនុស្សដឹកនាំក្នុងផ្លូវវិនាសមានលក្ខណៈ ៤ យ៉ាង
ក ) ដឹកនាំឲ្យផឹកទឹកស្រវឹង
ខ ) ដឹកនាំឲ្យដើរលេងយប់
គ ) ដឹកនាំឲ្យចូលចិត្តឬមើលមហោស្រព
ឃ ) ដឹកនាំឲ្យលេងល្បែងភ្នាល់ឬល្បែងស៊ីសង ។

## មិត្រដែលគួរសេពគប់ មាន ៤ យ៉ាង

**១ ឧបការមិត្ត** មិត្រមានឧបការៈ
**២ សុខទុក្ខមិត្តៈ** មិត្ររួមសុខរួមទុក្ខ
**៣ អត្ថក្ខាយីមិត្ត** មិត្រប្រាប់ផ្លូវប្រយោជន៍ឲ្យ
**៤ អនុកម្បកមិត្ត** មិនមានសេចក្ដីអាណិត
**ឧបការមិត្ត** មិត្រមានឧបការមានលក្ខណៈ ៤ យ៉ាង
ក ) ការពារមិត្រដែលប្រហែសហើយ
ខ ) ការពារទ្រព្យរបស់មិត្រដែលប្រហែសហើយ
គ ) ការមានភ័យយកជាទីពឹងបាន

ឃ ) កាលមានធុរៈកើតឡើង ជួយចេញទ្រព្យ លើសជាងមិត្រ
និយាយខ្ទី
**២ សុខទុក្ខមិត្ត** មិត្ររួមសុខរួមទុក្ខ មានលក្ខណៈ ៤ យ៉ាង
ក ) បញ្ចេញសេចក្ដីកំបាំងរបស់ខ្លួនប្រាប់ដល់មិត្រ
ខ ) បិទសេចក្ដីបាំងរបស់មិត្រមិនឲ្យសាយកាយ
គ ) មិនលះចោលគ្នាក្នុងកាលមានភ័យអន្តរាយ
ឃ ) សូម្បីជីវិត ក៏លះជំនួសបាន ។
**៣ អត្ថក្ខាយីមិត្តៈ** មិត្រប្រាប់ផ្លូវប្រយោជន៍ឲ្យ មានលក្ខណៈ ៤ យ៉ាង
ក ) ហាមមិនឲ្យធ្វើសេចក្ដីអាក្រក់
ខ ) ដឹកនាំឲ្យតាំងនៅក្នុងសេចក្ដីល្អ
គ ) ឲ្យបានស្ដាប់សេចក្ដីដែលមិនទាន់បានស្ដាប់
ឃ ) ប្រាប់ផ្លូវសួគ៌ឲ្យស្គាល់ ។
**៤ អនុកម្បកមិត្តៈ** មិត្រមានសេចក្ដីអាណិត មានលក្ខណៈ ៤ យ៉ាង
ក ) មិនត្រេកអរឲ្យមិត្រសាបសូន្យ
ខ ) ត្រេកអរចំពោះមិត្រអ្នកបានសេចក្ដីចម្រើន
គ ) ហាមឃាត់មនុស្សអ្នកនិយាយតិះដៀលមិត្រ
ឃ ) សរសើរមនុស្សអ្នកនិយាយលើកមិត្រ

## ការបែងទ្រព្យជាចំណែក ៤

គ្រហស្ថអ្នករកទ្រព្យបានមក គប្បីបែងជាចំណែក ៤មួយចំណែកទុកចាយប្រើប្រាស់ចិញ្ចឹមជីវិត ព្រមទាំងធ្វើការកុសលផងពីរចំណែក ទុកសម្រាប់ប្រកបការរបរមួយចំណែកទៀត ទុកការពារក្នុងវេលាមានការគ្រ មានឈឺចាប់ជាដើម ។កាលបើគ្រហស្ថបែងទ្រព្យបានយ៉ាងនេះរមែងបានសេចក្ដីចម្រើន

## សង្គហវត្ថុ ៤ យ៉ាង

១ **ទានៈ** បែងវត្ថុរបស់ខ្លួនឲ្យដល់មនុស្សដែលគួរឲ្យ

២ **បិយវាចា** ពោលវាចាពិរោះជាទីស្រឡាញ់

៣ **អត្ថចរិយា** ប្រព្រឹត្តក្នុងការជាប្រយោជន៍ដល់អ្នកដទៃ

៤ **សមានត្តតា** ភាពជាអ្នកធ្វើខ្លួនស្មើមិនប្រកាន់ខ្លួន ។

គុណធម៌ ៤ យ៉ាងជាគ្រឿងទាញចិត្តអ្នកដទៃឲ្យរាប់អានខ្លួន ។

## សុខរបស់គ្រហស្ថ ៤ យ៉ាង

១ សុខកើតអំពីការមានទ្រព្យ

២ សុខកើតអំពីការចាយទ្រព្យបរិភោគ

៣ សុខកើតអំពីការមិនជំពាក់បំណុលគេ

៤ សុខកើតអំពីការប្រកបការងារប្រាសចាកទោស ។

## សេចក្តីប្រាថ្នារបស់បុគ្គលក្នុងលោកដែលដោយកម្រមាន ៤ យ៉ាង

១ សូមឲ្យសម្បត្តិកើតមានដល់អាត្មាអញ ដោយផ្លូវប្រពៃ

២ សូមឲ្យយសកើតមានដល់អាត្មាអញនិងញាតិរបស់អាត្មាអញ

៣ សូមឲ្យអាត្មាអញមានអាយុវែង

៤ កាលបើអាត្មាអញអស់ជីវិតទៅ សូមឲ្យទៅកើតក្នុងស្ថានសួគ៌

## ធម៌ជាហេតុឲ្យបានផលដូចសេចក្តីប្រាថ្នា ៤ យ៉ាង

១ **សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា

២ **សីលសម្បទា** ដល់ព្រមដោយសីល

៣ **ចាគសម្បទា** ដល់ព្រមដោយការបរិច្ចាគទាន

៤ **បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា ។

## ត្រកូលស្តុកស្តម្ភដែលនឹងតាំងនៅយូរមិនបាន

## ព្រោះស្ថាន ៤ យ៉ាង

១ មិនស្វែងរករបស់ដែលបាត់ទៅហើយ

២ មិនជួសជុលរបស់ដែលគ្រាំគ្រា

៣ មិនដឹងប្រមាណក្នុងការចាយប្រើទ្រព្យធន

៤ តាំងស្ត្រីឬបុរសទ្រុស្តសីលឲ្យជាមេផ្ទះ ។

អ្នកដែលចង់ឲ្យត្រកូលគង់វង្សនៅ ត្រូវលះវៀរស្ថាន ៤ យ៉ាងនេះចេញ ។

## ធម៌របស់ឃរាវាស ៤ យ៉ាង

**១ សច្ចៈ** ពិតត្រង់ដល់គ្នានឹងគ្នា

**២ ទមៈ** ទូន្មានចិត្ត

**៣ ខន្តី** អត់ធន់

**៤ ចាគៈ** លះចែកវត្ថុរបស់ខ្លួនដល់បុគ្គលដែលគួរឲ្យ

## បញ្ចកៈ ពួក ៥

ការប្រើប្រាស់ភោគទ្រព្យដោយស្ថាន ៥ យ៉ាង

**អ្នកដែលរកភោគទ្រព្យបានមកដោយផ្លូវល្អហើយ ត្រូវប្រើប្រាស់យ៉ាងនេះគឺ**

១ ចិញ្ចឹមខ្លួន និងមាតាបិតា បុត្រភរិយា ទាសកម្មករ ឲ្យជាសុខ

២ ចិញ្ចឹមមិត្រសំឡាញ់ឲ្យជាសុខ

៣ បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ

៤ ធ្វើពលី ៥ យ៉ាងគឺ

**ក) ញាតិពលី** សង្គ្រោះញាតិ

**ខ) អតិថិពលី** ទទួលភ្ញៀវ

**គ) បុព្វបេតពលី** ធ្វើបុណ្យឧទ្ទិសផលដល់អ្នកដែលចែកឋានទៅហើយ

**ឃ) រាជពលី** បង់ពន្ធស្អួយសារអាករជាដើមដល់រាជការ

**៥) ទេវតាពលិ** កាលណាធ្វើបុណ្យឧទ្ទិសផលដល់ទេវតាផង

៥ បរិច្ចាគទានដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អ ។

## សីល ៥

**១ បាណាតិបាតា វេរមណី** វៀរចាកការធ្វើជីវិតសត្វឲ្យធ្លាក់ចុះ

**២ អទិន្នាទានា វេរមណី** វៀរចាកការកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ

**៣ កាមេសុ មិច្ឆាចារា វេរមណី** វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

**៤ មុសាវាទា វេរមណី** វៀរចាកនិយាយកុហក

**៥ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** វៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ ។

សីល ៥នេះគ្រហស្ថគួររក្សាជានិច្ច ទើបបរិបូណ៌ដោយសេចក្ដីចម្រើន សមតាមបំណង ។

## កល្យាណធម៌

ធម៌ដែលល្អ ហៅថា **កល្យាណធម៌** មាន ៥ យ៉ាង

**១ មេត្តា** គិតចង់ឲ្យគេបានសុខ និងករុណា ចង់ឲ្យគេប្រាសចាកទុក្ខ

**២ សម្មាអាជីវៈ** ចិញ្ចឹមជីវិតប្រពៃ

**៣ សទារសន្តោសៈ** សន្តោសតែស្រីការអរ ចំពោះភរិយារបស់ខ្លួន

**៤ សច្ចៈ** ប្រព្រឹត្តខ្លួនជាមនុស្សពុតត្រង់

**៥ សតិ** មានស្មារតីបរិបូណ៌ ។

កល្យាណធម៌ ៥ យ៉ាងនេះ ជាគូនឹងសីល ៥ គ្រហស្ថគួរបំពេញឲ្យបរិបូណ៌ ។

# មិច្ឆាវណិជ្ជា ការលក់ដូរមិនប្រពៃ ៥ យ៉ាង

**១ សត្ថវណិជ្ជា** លក់គ្រឿងប្រហារ

**២ សត្តវណិជ្ជា** លក់មនុស្ស

**៣ មំសវណិជ្ជា** លក់សត្វដែលគេនឹងសម្លាប់យកសាច់

**៤ មជ្ជវណិជ្ជា** លក់ទឹកស្រវឹង

**៥ វិសវណិជ្ជា** លក់ថ្នាំពិស ។

ការលក់ដូររបស់ ៥ យ៉ាងនេះ ជាហាមឧបាសកមិនឲ្យប្រកប ។

១ ប្រកបដោយសទ្ធា

២ មានសីលបរិសុទ្ធ

៣ មិនភ្ញាក់ផ្អើលដោយមង្គល គឺជឿកម្ម មិនជឿមង្គលភ្ញាក់ផ្អើល

៤ មិនស្វែងរកខេត្តបុណ្យក្រៅព្រះពុទ្ធសាសនា

៥ បំពេញបុណ្យតែក្នុងព្រះពុទ្ធសាសនា ។

ឧបាសកគប្បីតាំងនៅក្នុងសម្បត្តិ ៥ យ៉ាងនេះ វៀរចាកវិបត្តិ ៥ យ៉ាងនេះ ដែលជាទំនាស់នឹងសម្បត្តិនេះចេញ ។

# គោលព្រះធម៌ផ្សេងៗ

## ប្រភេទឧបាសក ឧបាសិកា

(បិកដ៤៥ទំព័រ១៥៥)

ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌៥យ៉ាង ឈ្មោះថា

**១ ចណ្ឌាលឧបាសក**

**២ មលឧបាសក**

**៣ បដិកិដ្ឋឧបាសក**

ឧបាសកនោះគឺ ជាអ្នកមិនមានសទ្ធា១ ជាអ្នកទ្រុស្តសីល១ ប្រកាន់មង្គលភ្ញាក់ផ្អើល១ ជឿតែមង្គល មិនជឿកម្ម១ ស្វែងរកទក្ខិណេយ្យបុគ្គល

**អង្គនៃការឧទ្ទិសបុណ្យឱ្យញាតិ ៣ យ៉ាង** *(អដ្ឋកថា តិរោកុឌ្ឌសូត្រ)*

**១.បេតានំ អត្តនោ អនុមោទនេន** ប្រេត ទាំងឡាយមកអនុមោទនាដោយខ្លួនឯង

**២.ទាយកានំ ឧទ្ទេសេន** ទាយកទាំងឡាយបានឧទ្ទិសឱ្យ

**៣.ទក្ខិណេយ្យ សម្បទាយ** ដោយការដល់ព្រមដោយទក្ខិណេយ្យបុគ្គល។(គឺបុគ្គលអ្នកញុំាងទក្ខិណាទានឱ្យមានផលច្រើនបានដល់ព្រះសង្ឃ និងលោកអ្នកមាសីល)

## ព្រះសទ្ធម្ម ៣ យ៉ាង

**១.បរិយត្តិសទ្ធម្ម** បានដល់ការសិក្សា

**២.បដិបត្តិសទ្ធម្ម** បានដល់សេចក្តីប្រតិបត្តិ។

**៣.បដិវេធសទ្ធម្ម** បានដល់ការត្រាស់ដឹង។

## អត្ថប្រយោជន៍ ៣ យ៉ាង

**១.ទិដ្ឋធម្មិកត្ថ** ប្រយោជន៍ក្នុងភពនេះ

**២.សម្បរាយិកត្ថ** ប្រយោជន៍ក្នុងភពមុខ

**៣.បរមត្ថ** ប្រយោជន៍ខ្ពង់ខ្ពស់ គឺព្រះនិព្វាន។

## ទិដ្ឋធម្មិកត្ថ មានអត្ថ ៤ យ៉ាង

**១.ឧដ្ឋានសម្បទា** ការដល់ព្រមដោយសេចក្តីប្រឹងប្រែង ក្នុងកិច្ចការគ្រប់យ៉ាង

**២.អារក្ខសម្បទា** ការដល់ព្រមដោយកិច្ចថៃរក្សា

**៣.កល្យាណមិត្តតា** ភាពនៃបុគ្គលមានមិត្តល្អ

**៤សមជីវិតា** ភាពនៃបុគ្គលមានជីវិតស្មើល្អ

## សម្បរាយិកត្ថ មានអត្ថ ៤ យ៉ាង

**១.សទ្ធាសម្បទា** ការដល់ព្រមដោយសទ្ធា

**២.សីលសម្បទា** ការដល់ព្រមដោយសីល

**៣.ចាគសម្បទា** ការដល់ព្រមដោយកិច្ចបរិចាគទាន

**៤.បញ្ញាសម្បទា** ការដល់ព្រមដោយបញ្ញា។

**ឥទ្ធិបាទ** គុណធម៌ជាជំហរឱ្យសម្រេចប្រយោជន៍ ៤ យ៉ាង

**១ ឆន្ទ**: ចូលចិត្តស្រឡាញ់ក្នុងកិច្ចការនោះៗ

**២ វីរិយ**: ព្យាយាមប្រកបកិច្ចការនោះៗ

**៣ ចិត្ត**: យកចិត្តទុកដាក់ក្នុងកិច្ចការនោះៗ មិនដាក់ធុរ:

**៤ វីមំសា** ឧស្សាហ៍ត្រិះរិះពិចារណារកហេតុផល ក្នុងកិច្ចការនោះៗ។

## ព្រហ្មវិហារ ៤ យ៉ាង

**១ មេត្តា** សេចក្ដីប្រាថ្នា ចង់ឱ្យគេបានសុខ

**២ ករុណា** សេចក្ដីអាណិតគិតជួយឱ្យគេរួចចាកទុក្ខ

**៣ មុទិតា** សេចក្ដីត្រេកអរតាម ក្នុងវេលាគេបានល្អ

**៤ ឧបេក្ខា** សេចក្ដីតាំងចិត្តជាកណ្ដាល(មិនឱ្យមានសោមនស្ស ទោមនស្សក្នុងវេលាដែលបានសេចក្ដីវិបត្តិ)។

## កំណើត ៤ យ៉ាង

**១.អណ្ឌជយោនិ** កើតក្នុងពង(មាន់ជាដើម)

**២. ជលាពុជយោនិ** កើតក្នុងគភ៌(គោជាដើម)

**៣. សំសេទជយោនិ** កើតក្នុងញើសក្អែល(ដង្កូវជាដើម)

**៤.ឱបបាតិកយោនិ** កើតហើយធំភ្លាម(នរកជាដើម)។

**បុគ្គល ៤ ពួក**

**១.ឧគ្ឃដិតញ្ញូ** អ្នកដឹងធម៌ឆាប់រហ័ស ក្នុងកាលលើកឡើងសំដែង

**២.វិបចិតញ្ញូ** អ្នកដឹងធម៌ក្នុងកាលដែលអធិប្បាយ

**៣.នេយ្យ** អ្នកដឹងធម៌ដែលអាចពន្យល់បាន

**៤.បទបរម** អ្នកមានបទធម៌យ៉ាងក្រៃលែង។

**ធម៌៥យ៉ាង***ធ្វើឱ្យព្រះធម៌មិនសាបសូន្យ(បិដកលេខ ៤៥/៩៦)*

**១. សក្កច្ចំ ធម្មំ សុណន្តិ** ស្ដាប់ធម៌ដោយគោរព

**២. សក្កច្ចំ ធម្មំ បរិយាបុណន្តិ** រៀនធម៌ដោយគោរព

**៣. សក្កច្ចំ ធម្មំ ធារេន្តិ** ទ្រទ្រង់ធម៌ដោយគោរព

**៤. សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** ពិចារណាអត្ថនៃព្រះធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព

**៥. សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ** ដឹងអត្ថ ដឹងធម៌ ហើយប្រតិបត្តិធម៌តាមកាលគួរដល់ធម៌ដោយគោរព។

## ទោសនៃបុគ្គលទ្រុស្តសីល ៥ យ៉ាង

*(បិដកលេខ ៧. ៣០៣)(ម្ចាស់គហបតិ)*

១.តែងបាននូវសេចក្តីវិនាសនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាទ នេះជាទោសទី១

២.តែងមានកិត្តិសព្ទអាក្រក់ ឮ ខ្ចរខ្ចាយ នេះជាទោសទី២

៣.បើចូលទៅកាន់បរិសទ្យណា ទោះបីខត្តិយបរិសទ្យក្តី ជាព្រាហ្មណ៍បរិសទ្យក្តី ជាគហបតិបរិសទ្យក្តី ជាសមណៈបរិសទ្យក្តី ក៏គ្មានក្លៀវក្លា មានមុខឱនចុះ ហើយដើរចូលទៅ នេះជាទោសទី៣

៤.វេលាទៀបស្លាប់ តែងវង្វេងស្មារតី នេះជាទោសទី៤

៥.លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់អបាយ (តិរច្ឆាន) ទុគ្គតិ (ប្រេត) វិនិបាត(អសុរកាយ) និរយ (នរក) នេះជាទោសទី៥។

## ការបរិច្ចាគ ៥ យ៉ាងរបស់ព្រះដ៏មានព្រះភាគ

( **អង្គ. ធន. បុត្ត ភរិយា. ជីវិត.** )

១. **អង្គបរិច្ចាគ** បរិច្ចាគអវយវៈចំណែកណាមួយ ឱ្យទៅជាទាន

២. **ធនបរិច្ចាគ** បរិច្ចាគទ្រព្យឱ្យទៅជាទាន

៣. **បុត្តបរិច្ចាគ** បរិច្ចាគបុត្តឱ្យទៅជាទាន

៤. **ភរិយាបរិច្ចាគ** បរិច្ចាគប្រពន្ធឱ្យទៅជាទាន

៥. **ជីវិតបរិច្ចាគោ** បរិច្ចាគជីវិតឱ្យទៅជាទាន។ (បបញ្ចសូទនី)

## អានិសង្សនៃការស្តាប់ធម៌ ៥ យ៉ាង

**១.អស្សុតំ សុណាតិ** រមែងបានស្តាប់ធម៌ ដែលមិនទាន់បានស្តាប់

**២.សុតំ បរិយោទបេតិ** ធម៌ណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្ត នឹងចូលចិត្តច្បាស់ឡើង

**៣,កង្ខំ វិហនតិ** រមែងកម្ចាត់បង់សេចក្តីសង្ស័យចេញបាន

**៤.ទិដ្ឋុជុកំ ករោតិ** រមែងធ្វើសេចក្តីឃើញឱ្យត្រង់តាមការពិត

**៥.ចិត្តមស្ស បសីទតិ** ចិត្តអ្នកស្តាប់នោះ រមែងជ្រះថ្លា។

## សប្បុរិសទាន ៥ យ៉ាង

**១.សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយគោរពចំពោះវត្ថុដែលគួរឱ្យ

**២.ចិត្តី កត្វា ទានំ ទេតិ** ឱ្យទានដោយតាំងចិត្តគោរពចំពោះវត្ថុ និងបដិគ្គាហក

**៣.សហត្ថា ទានំ ទេតិ** ឱ្យទានដោយដៃខ្លួនឯង

**៤.អនបវិដ្ឋំ ទានំ ទេតិ** ឱ្យទានដោយមិនបោះឱ្យ

**៥.អាគមនទិដ្ឋិកោទានំ ទេតិ** ឱ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត។

## អ្នកសម្តែងធម៌មានអង្គ ៥ យ៉ាង

១.សម្តែងតាមលំដាប់ មិនច្រូតកាត់ពេក ឱ្យខូចសេចក្តី

២.លើកយកហេតុផលមកអាង ណែនាំឱ្យអ្នកស្តាប់ងាយចូលចិត្ត

៣.តាំងចិត្តមេត្តាប្រាថ្នាឱ្យជាប្រយោជន៍ ដល់អ្នកស្តាប់

៤.មិនសម្តែងធម៌ ព្រោះឃើញអាមិសៈ

៥.មិនសម្តែងលើកតម្កើងខ្លួន បន្ទុះបង្អាប់អ្នកដទៃ។

## ទោសនៃការនិយាយច្រើន ៥ យ៉ាង

១.ជាហេតុឱ្យនិយាយកុហកភូតភរ

២.ជាហេតុឱ្យពោលពាក្យស៊កសៀត

៣.ជាហេតុឱ្យពោលពាក្យគ្រោតគ្រាត

៤.ជាហេតុឱ្យពោលពាក្យអាក្រក់

៥.ជាហេតុឱ្យទៅទុគ្គតិ។

## ព្យសនៈ **ការវិនាស ៥ យ៉ាង** ( *បិដកលេខ ៤៧.៣៨)*

( ញាតិ. ភោគ. រោគ. សីល. ទិដ្ឋិ. )

**១.ញាតិព្យសន** វិនាសញាតិ

**២.ភោគព្យសន** វិនាសភោគៈ

**៣.រោគព្យសន** វិនាសព្រោះរោគ

**៤.សីលព្យសន** វិនាសសីល

**៥.ទិដ្ឋិព្យសន** វិនាសសម្មាទិដ្ឋិ

## ទេវទូត ៥ យ៉ាង

*(ទារក. ជរា. ព្យាធិ. ទណ្ឌ. មរណ. )*

**១.ទារកោ** ទារកទើបនឹងកើត

**២.ជរា** ការគ្រាំគ្រានៃបញ្ចក្ខន្ធ

**៣.ព្យាធិ** មនុស្សឈឺ

**៤,ទណ្ឌោ** អ្នកដែលត្រូវដាក់អាជ្ញា ( គឺអ្នកទោស )

**៥,មរណំ** មនុស្សស្លាប់។

**លក្ខណៈ របស់អ្នកមិនប្រមាទ ៥ យ៉ាង**

**១.សីលេ បតិដ្ឋិតោ** ជាអ្នកតាំងមាំនៅក្នុងសីល

**២.ឥន្ទ្រិយេសុ ច សំវុតោ** ជាអ្នកសង្រួមក្នុងឥន្ទ្រិយទាំងឡាយ

**៣, ភោជនម្ហិ ច មត្តញ្ញូ** ជាអ្នកស្គាល់ប្រមាណក្នុងភោជន( គឺក្នុងការឆាន់នូវអាហារ )។

**៤.ជាគរិយំ អនុយុញ្ជតិ ឯវំ វិហារមាតាបី អហោរត្តមតន្ទិតោ** តាំងប្រកបភាពជាអ្នកមិនឃើញដល់ការដេកច្រើន ជាអ្នកមានសេចក្តីព្យាយាម មិនខ្ជិលច្រអូសទាំងថ្ងៃ និងយប់

**៥.ភាវយំ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា** ចម្រើននូវកុសលធម៌ ដើម្បីសម្រេចនូវគុណដ៏ក្សេមចាកយោគៈយ៉ាងនេះ។

**វាចាជាសុភាសិត ៥ យ៉ាង** ( សុត្ត,អង្គុត្តរ .បញ្ចក្ក )

**១.ការលេន ភាសិតា** និយាយត្រូវតាមកាល

**២.សច្ចភាសិតា** និយាយពាក្យពិត

**៣,សណ្ហាភាសិតា** និយាយពាក្យផ្អែមល្ហែម

**៤.អត្ថសណ្ហិតា** និយាយពាក្យជាប្រយោជន៍

**៥,មេត្តចិត្តភាសិតា** និយាយដោយចិត្តមេត្តា

**កម្មចតុក្កៈ៤ពួក** *(បរិច្ឆេទទី៥)*

**១កិច្ចចតុក្កៈ** កម្មឱ្យផលតាមកិច្ច

**១ ជនកកម្ម** កម្មដែលតែងតែធ្វើវិបាកឱ្យកើតឡើង។

**២ ឧបត្ថម្ភកកម្ម** កម្មដែលតែងតែជួយទំនុកបម្រុង។

**៣ ឧបបីឡកកម្ម** កម្មដែលចូលទៅបៀតបៀន។

**៤ ឧបឃាតកកម្ម** កម្មដែលចូលទៅកាត់ផ្តាច់

**២បាកទានបរិយាយ ចតុក្ក:** កម្មឱ្យផលតាមលំដាប់

**១ គរុកកម្ម** កម្មយ៉ាងធ្ងន់ដែលកម្មដទៃ មិនអាចនឹងហាមបាន

**២ អាសន្នកម្ម** កម្មដែលបានធ្វើមុនពេលជិតស្លាប់

**៣ អាចិណ្ណកម្ម** កម្មដែលបានសន្សំរឿយៗជានិច្ច

**៤ កដត្តាកម្ម** កម្មដែលបានធ្វើល្មមប្រមាណក្រៅពីកម្មទាំង៣ខាងដើម

**៣បាកកាលចតុក្ក: កម្មឱ្យផលតាមកាល**

**១ ទិដ្ឋធម្មវេទនីយកម្ម** កម្មដែលឱ្យផលក្នុងបច្ចុប្បន្នជាតិ

**២ ឧបបជ្ជវេទនីយកម្ម** កម្មដែលឱ្យផលក្នុងជាតិទី២

**៣ អបរាបរិយវេទនីយកម្ម** កម្មដែលឱ្យផលក្នុងជាតិទី៣រហូតដល់និព្វាន

**៤ អហោសិកម្ម** កម្មដែលមិនឱ្យផល។

**៤បាកដ្ឋានចតុក្ក: កម្មឱ្យផលតាមឋាន**

**១ អកុសលកម្ម** បានដល់អកុសលចេតនា១២

**២ កាមាវចរកុសលកម្ម** បានដល់មហាកុសលចេតនា៨

**៣ រូបាវចរកុសលកម្ម** បានដល់រូបាវចរកុសលចេតនា៥

**៤ អរូបាវចរកុសលកម្ម** បានដល់អរូបាវចរកុសលចេតនា៤

**ទសពិធរាជធម៌១០យ៉ាង( រាជធម៌ )**

**១ ទាន** *ការធ្វើអំណោយ*

**២ សីល** *រក្សាសីលជានិច្ច*

**៣ បរិច្ចាគ** *ចំណាយទ្រព្យទំនុកបម្រុងប្រទេសជាតិ*

**៤ អាជ្ជវ** *មានសេចក្តីស្មោះត្រង់*

**៥ មទ្ទវ** *មានការទន់ភ្លន់ស្លូតបូតសុភាពរាបសារ*

**៦ តប** *ដុតកម្តៅកិលិលេស (កាន់ឧបោសថ)*

**៧ អក្កោធន** មិនក្រោធ

**៨ អវិហឹសា** មិនបៀតបៀនអ្នកដទៃ

**៩ ខន្តិ** មានសេចក្តីអត់ធន់

**១០ អវិរោធន** មិនបំពានលើច្បាប់ៗ

**សិង្គាលកសូត្រ** (បិដកលេខ១៩/៦៨)

១ តួនាទីអ្នកបួស៥យ៉ាង

១ ហាមឃាត់បរិសទ័ចាកអំពើអាក្រក់

២ ឲ្យតាំងនៅក្នុងអំពើល្អ

៣ អនុគ្រោះដោយចិត្តល្អ

៤ ឲ្យស្តាប់នូវធម៌ដែលមិនធ្លាប់បានស្តាប់

៥ ប្រាប់ផ្លូវសួគ៍

២ តួនាទីពុទ្ធសាសនិក៥យ៉ាង

១ ធ្វើអ្វីដោយកាយដែលប្រកបដោយមេត្តា

២ និយាយអ្វីដោយវាចាដែលប្រកបដោយមេត្តា

៣ គិតអ្វីដោយមនោវាចាដែលប្រកបមេត្តា

៤ មិនបិទទ្វារផ្ទះរបស់ខ្លួន(ធ្វើទានជាមួយព្រះសង្ឃ)

៥ ប្រគេនរបស់ដែលសមគួរដល់ព្រះសង្ឃ។

៣ តួនាទីអ្នកបម្រើ ៥យ៉ាង

១ ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ

២ ឈប់ធ្វើការងារចៅហ្វាយនាយ

៣ កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ

៤ ធ្វើការងារឲ្យល្អប្រសើរឡើង

៥ពោលសរសើរគុណរបស់ចៅហ្វាយនាយ។

៤ តួនាទីចៅហ្វាយនាយ៥យ៉ាង

១ ឲ្យការងារសមគួរដល់កម្លាំង

២ ឲ្យអាហារនិងរង្វាន់លើកទឹកចិត្ត

៣ រក្សាព្យាបាលពេលមានជំងឺ

៤ ចែកអាហារមានរសប្រណីតឲ្យបរិភោគ

៥ អនុញ្ញាតឲ្យឈប់សម្រាក ។

៥ តួនាទីភរិយា៥យ៉ាង

១ ចាត់ចែងការងារឲ្យបានល្អ

២ សង្គ្រោះញាតិរបស់ស្វាមី

៣ មិនប្រព្រឹត្តក្បត់ចិត្តស្វាមី

៤ រក្សាទ្រព្យដែលស្វាមីរកបានមក

៥ ខំធ្វើកិច្ចការងារទាំងពួង។

៦ តួនាទីស្វាមី៥យ៉ាង

១ លើកតម្កើងរាប់អានថាជាភរិយា

២ មិនមើលងាយប្រពន្ធ

៣ មិនប្រព្រឹត្តក្បត់ប្រពន្ធ

៤ ប្រគល់ភាពជាធំឲ្យដល់ប្រពន្ធ

៥ ឲ្យគ្រឿងអលង្ការទៅដល់ប្រពន្ធ។

៨ តួនាទីមិត្ត៥យ៉ាង

១ រក្សាមិត្តអ្នកដែលធ្វេសប្រហែសហើយ

២ រក្សាទ្រព្យរបស់មិត្តដែលធ្វេសប្រហែស

៣ កាលមានភ័យយកជាទីពឹងពំនាក់បាន

៤ មិនលះបង់ចោលមិត្តក្នុងពេលមានវិបត្តិ
៥ រាប់អានគ្នារហូតវង្សត្រកូលរបស់មិត្ត ។

៩ តួនាទីមិត្តអ្នកធ្វើឧបការៈមុន៥យ៉ាង

១ ចាត់ចែងរបស់
២ និយាយដោយពាក្យពីរោះ
៣ ប្រព្រឹត្តក្នុងអំពើដែលជាប្រយោជន៍
៤ ដោយភាពជាអ្នកមានខ្លួនស្មើ
៥ មិនពោឲ្យឃ្លាតពីការពិត ។

១០តួនាទីសិស្ស៥យ៉ាង

១ លោកអញ្ជើញមកត្រូវក្រោកឈរទទួល
២ ចូលទៅឈរចាំទទួលបម្រើលោក
៣ ស្តាប់ពាក្យទូន្មានប្រៀនប្រដៅរបស់លោក
៤ ត្រូវបម្រើគ្រូ
៥ រៀនសិល្បវិជ្ជាដោយគោរព ។

១១ តួនាទីគ្រូអាចារ្យ៥យ៉ាង

១ ណែនាំសិស្សឲ្យបានដោយល្អ
២ ឲ្យសិស្សរៀនដោយល្អ
៣ ប្រាប់សិល្បវិជ្ជាអស់ដោយមិនមានការលាក់បិទបាំងទុក
៤ លើកតម្កើងឲ្យប្រាកដក្នុងពួកមិត្ត
៥ ធ្វើសេចក្តីការពារគ្រប់ទិសទាំងពួង ។

១២ តួនាទីរបស់កូន៧៥យ៉ាង

១ ត្រូវចិញ្ចឹមថែរក្សាមាតាបិតា
២ ត្រូវជួយធ្វើកិច្ចការងាររមាតាបិតា

៣ ត្រូវរក្សាវង្សត្រកូលឲ្យល្អ

៤ ត្រូវប្រព្រឹត្តខ្លួនជាអ្នកគួរទទួលមរតក

៥ ពេលមាតាបិតាអស់ជីវិត កូនគប្បីធ្វើបុណ្យឧទ្ទិសឲ្យ។

១៣ តួនាទីមាតាបិតា៥យ៉ាង

១ ហាមកូនមិនឲ្យធ្វើសេចក្តីអាក្រក់

២ ឲ្យកូនតាំងនៅក្នុងសេចក្តីល្អ

៣ ឲ្យកូនសិក្សាសិល្បវិជ្ជាផ្សេងៗ

៤ រកភរិយាដែលសមគួរឲ្យកូន

៥ ប្រគល់ទ្រព្យឲ្យកូនក្នុងសម័យដ៏សមគួរ ។

ទោសរបស់អ្នកប្រមឹក៦យ៉ាង

១ ខាតលុយខាតពេល

២ កើតអំពើហិង្សា

៣ មានរោគច្រើន

៤ ខូចឈ្មោះ

៥ បង្ហាញកេរ្តិ៍ខ្មាស

៦ ខ្សោយបញ្ញា

**សង្គហធម៌** ធម៌ជួយសង្គ្រោះគ្នាទៅវិញទៅមក៤យ៉ាង

**១.ទាន:** ការចែករំលែករបស់ដែលយើងមានទៅកាន់អ្នកដទៃ ។

**២.បិយវាចា:** ការប្រើពាក្យសម្តីពិរោះពិសាដាក់គ្នាទៅវិញទៅមក។

**៣.អត្ថចរិយា:** ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់គ្នានិងគ្នា ។

**៤.សមានត្តតា:** ការតាំងខ្លួនឱ្យស្មើស្មោះត្រង់ដល់គ្នានិងគ្នាមិនប្រកាន់ខ្លួន

## មនុស្សមាន៥ប្រភេទ

**១.មនុស្សនិរយោ** មនុស្សនរក

**២.មនុស្សបេតោ** មនុស្សប្រេត

**៣.មនុស្សតិរច្ឆានោ** មនុស្សតិរច្ឆាន

**៤.មនុស្ស មនុស្សោ** មនុស្សពេញភាពជាមនុស្ស

**៥.មនុស្សទេវោ** មនុស្សទេវតា ៕

## មិត្តប្លម៤ពួក (**បិ១៩/ទំ៧៨**)

១. មនុស្សដែលគិតយកតែប្រយោជន៍ផ្ទាល់ខ្លួន

២. មនុស្សដែលល្អតែសម្ដី

៣. មនុស្សដែលនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត

៤. មនុស្សជាសម្លាញ់ក្នុងការវិនាសភោគៈទាំងឡាយ (ជាអ្នកនាំផ្លូវវិនាសភោគៈ)

## ទិសទាំង៦ (**បិ១៩/ទំ៨៤**)

១. មាតាបិតា ជាទិសខាងកើត

២. អាចារ្យ ជាទិសខាងត្បូង

៣. កូន នឹងប្រពន្ធ ជាទិសខាងលិច

៤. មិត្តអាមាត្យ ជាទិសខាងជើង

៥. ទាសៈកម្មករ ជាទិសខាងក្រោម

៦. សមណព្រាហ្មណ៍ ជាទិសខាងលើ

## ខ្ជិល៦យ៉ាង (**បិ១៩/ទំ៧៥**)

១. មិនធ្វើការងារ ដោយអាងថាត្រជាក់ណាស់

២. មិនធ្វើការងារ ដោយអាងថាក្ដៅណាស់

៣.មិនធ្វើការងារ ដោយអាងថាល្ងាចណាស់

៤. មិនធ្វើការងារ ដោយអាងថាព្រឹកណាស់

៥. មិនធ្វើការងារ ដោយអាងថាឃ្លានណាស់

៦. មិនធ្វើការងារ ដោយអាងថាស្រេកណាស់

## ទោសនៃការផឹកទឹកស្រវឹង៦យ៉ាង (ចិ១៩/ទំ៧២)

១. វិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង

២. ការបង្កឱ្យកើតជម្លោះ

៣. ហេតុនាំឱ្យកើតរោគទាំងឡាយ

៤. ការនាំឱ្យខូចឈ្មោះ

៥. ការបង្ហាញកេរ្តិ៍ខ្មាស

៦. ធ្វើឱ្យបញ្ញាមានកម្លាំងខ្សោយ

## ទោសនៃការលេងល្បែង៦យ៉ាង (ចិ១៩/ទំ៧៤)

១. បុគ្គលនោះបើឈ្នះគេ តែងបានពៀរ

២. បើចាញ់តែង សោកស្តាយទ្រព្យសម្បត្តិ

៣. វិនាសទ្រព្យសម្បត្តិ ដែលឃើញជាក់ស្តែងទាន់ភ្នែក

៤. កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ

៥. ពួកមិត្តអាមាត្យ តែងលះបង់ចោល

៦. មិនត្រូវការដណ្តឹង ឬឱ្យកូនស្រី ព្រោះលេងល្បែងមិនអាចចិញ្ចឹមប្រពន្ធបាន

## សេចក្តីបរិសុទ្ធរបស់ទក្ខិណាទាន៤យ៉ាង (ចិ១៩/ទំ១៦៩)

១. ទក្ខិណាទានបរិសុទ្ធអំពីទាយកមិនបរិសុទ្ធអំពីបដិគ្គាហក

២. ទក្ខិណាទានបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក

៣. ទក្ខិណាទានមិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក

៤. ទក្ខិណាទានមិនបរិសុទ្ធអំពីទាយកផងបរិសុទ្ធអំពីបដិគ្គាហកផង

ទាយក(អ្នកឱ្យ) បដិគ្គាហក(អ្នកទទួល)
ទី៤មានផលច្រើនមានអានិសង្សច្រើនប្រមាណមិនបាន

## អានិសង្សសីល ៥យ៉ាង (បិ១៩/ទំ១៧៨)

១. បុគ្គលមានសីលហើយរមែងនាំមកនូវគំនរភោគច្រើន
២. កត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីល ផ្សាយទៅសព្វទិស
៣. បុគ្គលបរិបូណ៌ដោយសីលចូលទៅទិសណា ទោះបី ខត្តិយ ព្រាហ្មណ៍ គហបតី សមណបរិស័ទក្តី រមែងក្លៀវក្លាមិនឱនមុខចុះ
៤. បុគ្គលអ្នកមានសីល រមែងមិនវង្វេងពេលធ្វើមរណកាលទៅ
៥. បុគ្គលមានសីលលុះបែកធ្លាយរាងកាយរមែងទៅសុគតិភពទេវលោក

## បុគ្គល៤ពួក (បិ១៩/ទំ ១៧៣)

១. សមណមិនកម្រើក (សោតាបន្នសមណ)
២. សមណដូចផ្កាឈូកក្រហម(សកទាគាមិសមណ)
៣. សមណដូចផ្កាឈូកសរ(អនាគាមិសមណ)
៤. ជាអ្នកទន់ល្អិតល្អក្នុងពួកសមណ(អរហន្តសមណ)

## អនាគាមិបុគ្គល៥ពួក (បិ១៩/១៨២)

១. បរិនិព្វានពាក់កណ្តាលអាយុ
(មិនទាន់កណ្តាលអាយុសម្រេចជាព្រះអរហន្ត)
២. លោកបរិនិព្វានដោយកន្លងហួសពាក់កណ្តាលអាយុ
(កន្លងហួសពាក់កណ្តាលអាយុហើយសម្រេចជាព្រះអរហន្ត)
៣. បរិនិព្វានដោយកន្លងហួសពាក់កណ្តាលអាយុ
(មិនលំបាកដោយព្យាយាមសម្រេចជាព្រះអរហន្ត)
៤. បរិនិព្វានដោយសេចក្តីព្យាយាមយ៉ាងខ្លាំង
(លំបាកដោយព្យាយាមទើបសម្រេចជាព្រះអរហន្ត)

៥. មានខ្សែខាងលើហើយទៅកាន់អកនិដ្ឋភព

(ទៅកើតក្នុងសុទ្ធាវាសទាំង៥ពី អវិហាទៅដល់ អកនិដ្ឋភព)

**សត្តាវាសៈ** (**ប្រទេសជាទីនៅរបស់សត្វ៩**)

(**បិ១៩/ទំ២៣៥**)

១. ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា (មនុស្សនិងទេវតា)

២. ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា (ព្រហ្មបឋមជ្ឈានភូមិ)

៣. មានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា (ទេវតាក្នុងជាន់អាភស្សរៈ)

៤. មានកាយដូចគ្នា មានសញ្ញាដូចគ្នា (ទេវតាក្នុងសុភកិណ្ហៈ)

៥. ពួកសត្វឥតសញ្ញាមិនដឹងច្បាស់នូវអារម្មណ៍( ទេវតាជាអសញ្ញិតសត្វ)

៦. ពួកសត្វចូលកាន់អាកាសនញ្ចាយតនជ្ឈាន

៧. ពួកកន្លងបង់អាកាសានញ្ចាយតនជ្ឈាន ចូលកាន់វិញ្ញាណញ្ចាយតជ្ឈាន

៨. ពួកកន្លងបង់វិញ្ញាណញ្ចាយតនជ្ឈាន ចូលកាន់អាកិញ្ចញ្ញាយតជ្ឈាន

៩. កន្លងបង់អាកិញ្ចញ្ញាយតនជ្ឈាន ចូលកាន់នេវសញ្ញានាសញ្ញាយតជ្ឈាន

**និព្វេធភាគិយសញ្ញា**(**សេចក្តីសម្គាល់នូវធម៌បែរទៅជិតព្រះនិព្វាន**)

១. សេចក្តីសម្គាល់ថាមិនទៀង

២. សេចក្តីសម្គាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ

៣. សេចក្តីសម្គាល់ក្នុងរបស់ជាទុក្ខថាមិនមែនជារបស់ខ្លួន

៤. សេចក្តីសម្គាល់ក្នុងរបស់គួរលះបង់

៥. សេចក្តីសម្គាល់ក្នុងរបស់គួរនឿយណាយ

៦. សេចក្តីសម្គាល់ក្នុងធម៌ជាគ្រឿងរំលត់ទុក្ខ

**សម្បទា ៨ យ៉ាង** (បិដកលេខ ៤៨ /៣២១)

( ឧ អា ក ស សទ្ធ សីល ចាគ បញ្ញ)

ឧដ្ឋានសម្បទា១ អារក្ខសម្បទា ១ កល្យាណមិត្តតា១ សមជីវិតា១ សទ្ធាសម្បទា១ សីលសម្បទា១ ចាគសម្បទា១ បញ្ញាសម្បទា១ ។

(សេចក្តីពន្យល់ពិស្តារមានក្នុងបិដក)

**សង្វេគវត្ថុ ៨ យ៉ាង**

**១.ជាតិទុក្ខ** រំពឹងដល់ទុក្ខក្នុងការកើត មាន ៧ យ៉ាងគឺ

**១ គព្ភោក្កន្តិមូលកទុក្ខ** ទុក្ខព្រោះមានការចុះកាន់គភ៌ជាមូល

**២ គព្ភបរិហរណមូលកទុក្ខ**ទុក្ខព្រោះមានការថែរក្សាគភ៌ជាមូល ៣

**៣គព្ភវិបត្តិមូលកទុក្ខ** ទុក្ខមានវិបត្តិនៃគភ៌ជាមូល

**៤គព្ភវិជាយនមូលកទុក្ខ**ទុក្ខមានការកំពុងសម្រាលចាកគភ៌ជាមូល

**៥គព្ភនិក្ខមនមូលកទុក្ខ** ទុក្ខមានការចេញចាកគភ៌ជាមូល

**៦ អត្តូបក្កមមូលកទុក្ខ** ទុក្ខមានសេចក្តីព្យាយាមរបស់ខ្លួនជាមូល

**៧បរូបក្កមមូលកទុក្ខ** ទុក្ខមានសេចក្តីព្យាយាមរបស់អ្នកដទៃជាមូល

**២.ជរាទុក្ខ** រំពឹងដល់ទុក្ខក្នុងការចាស់គ្រាំគ្រា មាន ២ យ៉ាងគឺ

**១អប្បដិច្ឆន្នជរា** ជរាប្រាកដឬមិនកំបាំង

**២ បដិច្ឆន្នជរា** ជរាមិនប្រាកដ ឬកំបាំង

**៣. ព្យាធិទុក្ខ** រំពឹងដល់ទុក្ខក្នុងការឈឺចាប់

**៤.មរណទុក្ខ** រំពឹងដល់ទុក្ខក្នុងការស្លាប់

**៥. អបាយទុក្ខ** រំពឹងដល់ទុក្ខក្នុងអបាយភូមិ

**៦. អតីតទុក្ខ** រំពឹងដល់ទុក្ខក្នុងអតីត

**៧. អនាគតទុក្ខ** រំពឹងដល់ទុក្ខក្នុងអនាគត

៨. **អាហារបរិយេដ្ឋិតទុក្ខ** រំពឹងដល់ទុក្ខក្នុងការស្វែងរកអាហារ

## បុញ្ញកិរិយាវត្ថុ ១០ យ៉ាង (បរិច្ឆេទទី១ ទំ.១៦៥)

( ទាន. សីល. ភា. អ. វេយ្យា. បត្តិ. បត្តា. ធម្ម. ធម្ម. ទិដ្ឋិ.)

១. **ទានមយ** បុណ្យសម្រេចអំពីការឱ្យវត្ថុជាទាន មាន ៣យ៉ាងគឺ

-**អាមិសទាន** ការឱ្យវត្ថុនានា

-**អភយទាន** ឱ្យការមិនភ័យ គឺមិនបង្កភ័យ

-**ធម្មទាន** ការឱ្យធម៌ ជាការឱ្យចំណេះដឹង ឱ្យការយល់ត្រូវ

២.**សីលមយ** បុណ្យសម្រេចអំពីការរក្សាសីល មាន ២ យ៉ាងគឺ

-**ចារិត្តសីល** សីលគឺការប្រព្រឹត្តត្រឹមត្រូវតាមផ្លូវកាយវាចា

- **វារិត្តសីល** សីលគឺការវៀរចាក ទុច្ចរិតតាមផ្លូវកាយវាចា

៣. **ភាវនាមយ**បុណ្យសម្រេចអំពីការចម្រើនភាវនាមាន២យ៉ាងគឺ

-**សមថភាវនា** ការចម្រើនចិត្តឱ្យស្ងប់ក្នុងអារម្មណ៍សមថៈទាំង៤០

-**វិបស្សនាភាវនា** ការចម្រើនបញ្ញាឱ្យឃើញច្បាស់នូវរូបនឹងនាម

៤.**អបចាយនមយ** បុណ្យសម្រេចអំពីការគោរពឱ្យតម្លៃអ្នកដទៃ

៥.**វេយ្យាវច្ចមយ**បុណ្យសម្រេចអំពីការខ្វល់ខ្វាយបម្រើជួយខ្នះខ្នែង

៦. **បត្តិទានមយ** បុណ្យសម្រេចអំពីការឱ្យចំណែកបុណ្យ

៧ **បត្តានុមោទនាមយ** បុណ្យសម្រេចអំពីការត្រេកអរនឹងបុណ្យ

៨. **ធម្មទេសនា** បុណ្យសម្រេចអំពីការសម្តែងធម៌

៩. **ធម្មស្សវនមយ** បុណ្យសម្រេចអំពីការស្តាប់ធម៌

១០.**ទិដ្ឋិជុកម្ម** ការតម្រង់ទិដ្ឋិឱ្យត្រង់ តម្រង់ការយល់ត្រូវ ជាកម្មស្សកតាបញ្ញា សត្វមានកម្មជារបស់ខ្លួន។

## **អារម្មណ៍សមថកម្មដ្ឋាន ៤០** (បរិច្ឆេទទី១ ទំ.២០៧)

## **កសិណ១០**

(បឋវី ដី អាបោ ទឹក តេជោ ភ្លើង វាយោ ខ្យល់ នីលៈពណ៌ខៀវ បីតៈពណ៌លឿង លោហិតៈពណ៌ក្រហម ឱទាតៈពណ៌ស អាលោកៈពន្លឺ អាកាសៈអាកាសឬលំហ)

១.**បឋវីកសិណ** យកដីជានិមិត្ត

២.**អាបោកសិណ** យកទឹកជានិមិត្ត

៣.**តេជោកសិណ** យកភ្លើងជានិមិត្ត

៤.**វាយោកសិណ** យកខ្យល់ជានិមិត្ត

៥.**នីលកសិណ** យកពណ៌ខៀវជានិមិត្ត

៦.**បីតកសិណ** យកពណ៌លឿងជានិមិត្ត

៧.**លោហិតកសិណ** យកពណ៌ក្រហមជានិមិត្ត

៨.**ឱទាតកសិណ** យកពណ៌សជានិមិត្ត

៩.**អាលោកសិណ** យកពន្លឺជានិមិត្ត

១០.**អាកាសកសិណ** យកអាកាសឬលំហ ជានិមិត្ត

## **អសុភ ១០**

១.**ឧទ្ធុមាតក** អសុភហើមប៉ោង

២.**នីលក** អសុភឡើងខៀវ

៣,**វិបុព្វក** អសុភខ្ទុះហូរចេញ

៤.**វច្ឆិទក** អសុភដែលគេកាត់ដាច់ពាក់កណ្ដាល

៥.**វិខាយិតក** អសុភដែលសត្វខាំហែកស៊ី

៦.**វិក្ខិតក** អសុភដែលមានដៃ និងខ្វាត់ខ្វាយ

**៧.ហតវិក្ខិត្តក** អសុភដែលគេកាត់សាច់ចិញ្ច្រាំចោលរាត់រាយ

**៨.លោហិតក** អសុភដែលមានឈាមហូរប្រឡាក់

**៩.បុឡុវក** អសុភដែលដង្កូវចោះច្រើន

**១០.អដ្ឋិក** អសុភដែលសល់តែរាងឆ្អឹង

## អនុស្សតិ ១០

**១.ពុទ្ធានុស្សតិ** រឭកដល់គុណព្រះពុទ្ធ

**២.ធម្មានុស្សតិ** រឭកដល់គុណព្រះធម៌

**៣.សង្ឃានុស្សតិ** រឭកដល់គុណព្រះសង្ឃ

**៤.សីលានុស្សតិ** រឭកដល់សីល ដែលមានអានុភាពកម្ចាត់នូវទុច្ចរិត

**៥.ចាគានុស្សតិ** រឭកដល់ការលះបង់របស់ខ្លួន

**៦.ទេវានុស្សតិ** រឭកដល់គុណធម៌ដែលនាំឱ្យកើតជាទេវតា

**៧.ឧបសមានុស្សតិ** រឭកដល់គុណនៃព្រះនិព្វានដែលស្ងប់កិលេស

**៨.មរណានុស្សតិ** រឭកដល់សេចក្តីស្លាប់ដែលមានចំពោះសត្វ

**៩.កាយគតានុស្សតិ** រឭកដល់កាយដែលមិនស្អាត

**១០.អនាបានុស្សតិ** រឭកដល់ខ្យល់ដង្ហើមចេញចូល

## ព្រហ្មវិហារធម៌ ៤ អរូបជ្ឈាន ៤ អាហារេបដិកូលសញ្ញា១ ចតុធាតុវវត្ថាន ១

## អកុសលកម្មបថ ១០ *(បរិ.១ ទំ.៨៩)*

## កាយកម្ម ៣

**១.បាណាតិបាត** ការសម្លាប់សត្វ

**២.អទិន្នាទាន** ការលួចទ្រព្យអ្នកដទៃ

**៣.កាមេសុ មិច្ឆាចារ** ការប្រព្រឹត្តខុសក្នុងកាម

**វចីកម្ម ៤**

៤.**មុសាវាទ** ការនិយាយពាក្យកុហក

៥.**បិសុណាវាចា** ការនិយាយពាក្យញុះញង់

៦.**ផរុសវាចា** ការនិយាយគ្រោតគ្រាត

៧.**សម្ផប្បលាប** ការនិយាយពាក្យឥតប្រយោជន៍។

**មនោកម្ម ៣**

៨.**អភិជ្ឈា** ការសម្លឹងរំពៃ ចង់បានរបស់គេ

៩.**ព្យាបាទ** ការចងគំនុំព្យាបាទ

១០.**មិច្ឆាទិដ្ឋិ** ការយល់ខុស (គឺនិយតមិច្ឆាទិដ្ឋិ។

**កុសលកម្មបថ ១០**

**កាយកម្ម ៣**

១.**បាណាតិបាតា វេរមណី** វៀរចាកការសម្លាប់សត្វ

២.**អទិន្នាទានា វេរមណី** វៀរចាកការលួចទ្រព្យអ្នកដទៃ

៣.**កាមេសុ មិច្ឆាចារា វេរមណី** វៀរចាកការប្រព្រឹត្តខុសក្នុងកាម

**វចីកម្ម ៤**

៤,**មុសាវាចា វេរមណី** វៀរចាកការនិយាយកុហក

៥**បិសុណាយ វាចាយ វេរមណី**វៀរចាកការនិយាយពាក្យញុះញង់

៦.**ផរុសាយ វាចាយ វេរមណីវៀរចាកការនិយាយពាក្យគ្រោតគ្រាត**

៧.**សម្ផប្បលាបា វេរមណី** វៀរចាកការនិយាយពាក្យឥតប្រយោជន៍

**មនោកម្ម ៣ យ៉ាង**

៨.**អនភិជ្ឈា** មិនសម្លឹងរំពៃចង់បានរបស់គេ

៩.**អព្យាបាទ** មិនគិតគុំគួនគេ

**១០.សម្មាទិដ្ឋិ** ឃើញត្រូវតាមគន្លងធម៌។

**កថាវត្ថុ** ពាក្យដែលគួរពោល ១០ យ៉ាង

**១.អប្បិច្ឆកថា** ពាក្យដែលនាំឱ្យប្រាថ្នាតិច

**២.សន្តុដ្ឋិកថា** ពាក្យដែលនាំឱ្យមានសន្តោស ត្រេកអរចំពោះបច្ច័យ តាមមានតាមបាន

**៣.បវិវេកកថា** ពាក្យដែលនាំឱ្យស្ងាប់កាយ ស្ងាត់ចិត្ត

**៤.អសំសគ្គកថា** ពាក្យដែលនាំមិនឱ្យច្រឡូកច្រឡំដោយពួកគណៈ

**៥.វីរិយារម្ភកថា** ពាក្យដែលនាំឱ្យប្រារព្ធព្យាយាម

**៦.សីលកថា** ពាក្យដែលនាំឱ្យតាំងនៅក្នុងសីល

**៧.សមាធិកថា** ពាក្យដែលនាំឱ្យធ្វើចិត្តឱ្យស្ងប់

**៨.បញ្ញាកថា** ពាក្យដែលនាំឱ្យកើតបញ្ញា

**៩.វិមុត្តិកថា** ពាក្យដែលនាំឱ្យធ្វើចិត្តផុតចាកកិលេស

**១០.វិមុត្តិញ្ញាណទស្សនកថា** ពាក្យដែលនាំឱ្យកើតសេចក្តីដឹងឃើញក្នុងការដែលចិត្តផុតចាកកិលេស។

**នាថករណធម៌** ធម៌ធ្វើទីពឹង ១០ យ៉ាង

**១.សីល** រក្សាកាយវាចា ឱ្យរៀបរយ

**២.ពាហុសច្ច** ភាពជាអ្នកបានរៀន បានស្តាប់ច្រើន

**៣.កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តសំឡាញ់

**៤.សោវចស្សតា** ភាពជាអ្នកដែលគេប្រដៅងាយ

**៥.កឹករណីយេសុ ទក្ខតា** ភាពជាអ្នកប៉ិនប្រសប់ព្រមទាំងឧស្សាហ៍យកចិត្តទុកដាក់ជួយក្នុងកិច្ចធុរៈរបស់ភិក្ខុសាមណេរផងគ្នា

**៦.ធម្មកាមតា** ភាពជាអ្នកស្រឡាញ់ធម៌

**៧.វីរិយ** ព្យាយាមលះសេចក្ដីអាក្រក់ ប្រព្រឹត្តល្អ

**៨.សន្តុដ្ឋិ** សន្ដោសត្រេកអរចំពោះបច្ច័យ ៤ តាមមានតាមបាន

**៩.សតិ** ចាំការដែលបានធ្វើ និងពាក្យដែលបានពោលហើយ សូម្បីយូរអង្វែងបាន

**១០. បញ្ញា** ដឹងសេចក្ដីប្រព្រឹត្តទៅនៃកងសង្ខារ។

**សុបិន ១៦ ប្រការ** (បិដក ៥៨.៣៣)

១,គោឡើងកទ.១ ២,ឈើទ.១ ៣,មេគោទ.១ ៤,គោឈ្មោលទ.១

៥,សេះ១ ៦,ភាជន៍(មាស)១ ៧,មេចចក១ ៨,ក្អម១

៩,ស្រះបោក្ខរណី១ ១០,បាយឆៅ១ ១១,ខ្លឹមចន្ទន៍១

១២,ផ្លែឃ្លោកទទាំងឡាយលិច១

១៣,ថ្មទាំងឡាយអណ្ដែត១

១៤,មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ១

១៥,រាជហង្សមាសទាំងឡាយចោមរោមក្អែក១

១៦,ខ្លាដំបងទាំងឡាយ(រត់ទៅ)ព្រោះភ្ញាក់ផ្អើលដោយសេចក្ដីខ្លាចអំពីពពែទាំងឡាយ១

**ឧបក្កិលេស** ទោសគ្រឿងសៅហ្មង ១៦ យ៉ាង

**១.អភិជ្ឈាវិសមលោភ** លោភមិនស្មើ គឺគយគន់រំពៃចង់បានមិនរើសមុខ

**២.ទោស** គិតប្រទូស្ត

**៣.កោធ** ក្រោធ

**៤ឧបនាហ** ចងក្រោធទុក

**៥.មក្ខ** រមិលគុណ

**៦.បលាស** ធ្វើខ្លួនស្មើ គឺលើកខ្លួនផ្ទឹមនឹងអ្នកខ្ពង់ខ្ពស់

**៧.ឥស្សា** ឫស្យា គឺសេចក្ដីច្រណែនឈ្នាសនីស

**៨.មច្ឆរិយ** កំណាញ់

**៩.មាយា** មាយា គឺលាក់ពុតបាំងទោសខ្លួន

**១០.សាថេយ្យ** អួតអាង

**១១.ថម្ភ** មុខរឹង

**១២.សារម្ភ** ប្រណាំងវាសនា

**១៣.មាន** ប្រកាន់ខ្លួន

**១៤.អតិមាន** មើលងាយគេ

**១៥.មទ** ស្រវឹង

**១៦. បមាទ** ប្រហែសធ្វេស។

# ព្រះអភិធម្ម

## ចេតសិក ៥២ ដួង

១,អញ្ញសមានាចេតសិក ១៣ដួង

២,អកុសលចេតសិក ១៤ដួង

៣,សោភណចេតសិក ២៥ដួង

**១,អញ្ញសមានាចេតសិក ១៣ដួងគឺ**

**១ ផស្សោ** ប៉ះអារម្មណ៍

**២ វេទនា** សោយអារម្មណ៍

**៣ សញ្ញា** សម្គាល់អារម្មណ៍

**៤ ចេតនា** គិតចាត់ចែងអារម្មណ៍

**៥ ឯកគ្គតា** ផ្គងចិត្តឱ្យមានអារម្មណ៍តែមួយ

**៦ ជីវិតិន្ទ្រិយំ** ញុំាំងសហជាតធម៌ឱ្យរស់នៅ

**៧ មនសិការោ** ធ្វើទុកក្នុងចិត្ត។

ចេតសិក៧ដួងនេះ ឈ្មោះថា*សព្វចិត្តសាធារណចេតសិក*

*បកិណ្ណកចេតសិក៦ដួងគឺ*

**៨ វិតក្កោ** ត្រិះរិះនូវអារម្មណ៍

**៩ វិចារោ** ពិចារណានូវអាម្មណ៍

**១០ អធិមោក្ខោ** ចុះស៊ប់ក្នុងអារម្មណ៍

**១១ វីរិយំ** ព្យាយាម

**១២ បីតិ** ឆ្អែតក្នុងកាយក្នុងចិត្ត

**១៣ ឆន្ទោ** បំណងក្នុងអារម្មណ៍

## ២ អកុសលចេតសិក ១៤ដួងគឺ

**១ មោហោ** វង្វេងក្នុងអារម្មណ៍

**២ អហិរិកំ** មិនខ្មាសបាប

**៣ អនោត្តប្បំ** មិនតក់ស្លុតក្នុងបាប

**៤ ឧទ្ធច្ចំ** រវើរវាយក្នុងអារម្មណ៍

**៥ លោភោ** ជាប់ជំពាក់ក្នុងអារម្មណ៍

**៦ ទិដ្ឋិ** ការយល់ខុស

**៧ មានោ** រឹងត្អឹង

**៨ ទោសោ** ប្រទុស្តក្នុងអារម្មណ៍

**៩ ឥស្សា** ច្រណែន

**១០ មច្ឆរិយំ** កំណាញ់

**១១ កុក្កុច្ចំ** ក្តៅក្រហាយស្តាយក្រោយ

**១២ ថីនំ** រួញរាចំពោះកុសល

**១៣ មិទ្ធំ** ងងុយងោកងក់

**១៤ វិចិកិច្ឆា** សង្ស័យ

## ៣ សោភណចេតសិក ២៥ដួងគឺ

**១ សទ្ធា** ជឿកម្មផល

**២ សតិ** រលឹកដឹងខុសត្រូវ

**៣ ហិរិ** ខ្មាសបាប

**៤ ឱត្តប្បំ** តក់ស្លុតក្នុងអំពើបាប

**៥ អលោភោ** មិនជាប់ជាក់

**៦ អទោសោ** មិនប្រទូស្ត

**៧ តត្រមជ្ឈត្តតា** សម្លឹងកណ្តាល

**៨ កាយបស្សទ្ធិ** ស្ងប់កាយ

**៩ ចិត្តបស្សទ្ធិ** ស្ងប់ចិត្ត

**១០ កាយលហុតា** ស្រាលកាយ

**១១ ចិត្តលហុតា** ស្រាលចិត្ត

**១២ កាយមុទុតា** ទន់ភ្លន់កាយ

**១៣ ចិត្តមុទុតា** ទន់ភ្លន់ចិត្ត

**១៤ កាយកម្មញ្ញតា** កាយគួរដល់ការងារ

**១៥ ចិត្តកម្មញ្ញតា** ចិត្តគួរដល់ការងារ

**១៦ កាយបាគុញ្ញតា** កាយស្ទាត់ជំនាញ

**១៧ ចិត្តបាគុញ្ញតា** ចិត្តស្ទាត់ជំនាញ

**១៨ កាយុជុកតា** កាយត្រឹមត្រូវ

**១៩ ចិត្តុជុកតា** ភាវៈនៃចិត្តត្រង់

ចេតសិកទាំង១៩ដួងនេះហៅថា *សោភណសាធារណចេតិសិក*

*វិរតិចេតសិក ៣ដួងគឺ*

**២០ សម្មាវាចា** សម្តីប្រពៃ

**២១ សម្មាកម្មន្តោ** ការងារប្រពៃ

**២២ សម្មាអាជីវោ** អាជីវៈប្រពៃ

*អប្បមញ្ញាចេតសិក២ដួងគឺ*

**២៣ ករុណា** អាណិត

**២៤ មុទិតា** ទន់ភ្លន់

២៥ បញ្ញិន្ទ្រិយំ ភាវៈជាធំក្នុងការចេះដឹងបញ្ញា
ចប់ចេតសិក៥២ដួងតែប៉ុណ្ណោះ។

# បរមត្ថធម៌ ៤ គឺ

(បញ្ជាក់គោលព្រះអភិធម្មនេះ គឺចម្លងចេញពីសៀវភៅលោកម្ចាស់
គ្រូ ចន្ទប្បញ្ញោអឺបភារុណដោយបានការអនុញ្ញាតពីលោកហើយ)

**ចិត្ត ៨៩ ឬ១២១ ដួង ចេតសិក ៥២ ដួង រូប ២៨ និង និព្វាន**

- ❖ ចិត្តបរមត្ថ ៨៩ ដួង ឬ ១២១ដួង ចែកតាមភូមិមាន ៤ភូមិ គឺ
- កាមាវចរភូមិ មាន ៥៤ដួង
- រូបាវចរភូមិ មាន ១៥ដួង
- អរូបាវចរភូមិ មាន ១២ដួង
- លោកុត្តរភូមិ មាន ៨ ឬ ៤0ដួង

កាមាវចរភូមិ មាន៥៤ដួង ចែកចេញជា ៣គឺ

១. អកុសលចិត្ត ១២ ដួង
២. អហេតុកចិត្ត ១៨ ដួង
៣. កាមាវចរសោភណចិត្ត ២៤ ដួង

អកុសលចិត្ត ១២ដួង ចែកចេញ ៣ក្រុម គឺ

១. លោភមូលចិត្ត ៨ដួង
២. ទោសមូលចិត្ត ២ដួង
៣. មោហមូលចិត្ត ២ដួង

## លោភមូលចិត្ត ៨ដួង គឺ

| | |
|---|---|
| ១.សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ<br>២.សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ<br>៣.សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ<br>៤. សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ | លោភមូលចិត្តំ |
| ៥. ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ<br>៦. ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ<br>៧. ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ<br>៨. ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ | លោភមូលចិត្តំ |

## ទោសមូលចិត្ត ២ដួង គឺ

| | |
|---|---|
| ១. ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ<br>២. ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ | ទោសមូលចិត្តំ |

## មោហមូលចិត្ត ២ដួងគឺ

| | |
|---|---|
| ១. ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ អសង្ខារិកំ<br>២. ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ អសង្ខារិកំ | មោហមូលចិត្តំ |

## អហេតុកចិត្ត ១៨ដួងចែកចេញ ៣ក្រុម គឺ

១.អកុសលវិបាកចិត្ត ៧ដួង

២.អហេតុកកុសលវិបាកចិត្ត ៨ដួង

៣.អហេតុកកិរិយាចិត្ត ៣ដួង

## អកុសលវិបាកចិត្ត ៧ដួងគឺ

១.ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណអកុសលវិបាកចិត្តំ ។

២.ឧបេក្ខាសហគតំ សោតវិញ្ញាណអកុសលវិបាកចិត្ត ។

៣.ឧបេក្ខាសហគតំ ឃានវិញ្ញាណអកុសលវិបាកចិត្តំ ។

៤. ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណអកុសលវិបាកចិត្តំ ។

៥.ទុក្ខសហគតំ កាយវិញ្ញាណអកុសលវិបាកចិត្តំ ។
៦.ឧបេក្ខាសហគតំ មនោធាតុអកុសលវិបាកចិត្តំ ។
៧.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុអកុសលវិបាកចិត្តំ ។

## អហេតុកកុសលវិបាកចិត្ត ៨ដួង គឺ

១.ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណកុសលវិបាកចិត្តំ ។
២.ឧបេក្ខាសហគតំ សោតវិញ្ញាណកុសលវិបាកចិត្តំ ។
៣.ឧបេក្ខាសហគតំ ឃានវិញ្ញាណកុសលវិបាកចិត្តំ ។
៤.ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណកុសលវិបាកចិត្តំ ។
៥.សុខសហគតំ កាយវិញ្ញាណកុសលវិបាកចិត្តំ ។
៦.ឧបេក្ខាសហគតំ មនោធាតុកុសលវិបាកចិត្តំ ។
៧.សោមនស្សសហគតំ មនោវិញ្ញាណធាតុអហេតុកកុសលវិបាកចិត្តំ ។
៨.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុអហេតុកកុសលវិបាកចិត្តំ ។

## អហេតុកកិរិយាចិត្ត ៣ដួង គឺ

១.ឧបេក្ខាសហគតំ មនោធាតុកិរិយាចិត្តំ ។
២.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្តំ ។
៣.សោមនស្សសហគតំ មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្តំ ។
៣.កាមាវចរសោភណចិត្ត ២៤ដួង ចែកចេញជា ៣ក្រុម គឺ
១.មហាកុសលចិត្ត ៨ដួង
២.មហាវិបាកចិត្ត ៨ដួង
៣.មហាកិរិយាចិត្ត ៨ដួង

## មហាកុសលចិត្ត ៨ដួង គឺ

១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ
៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ

} មហាកុសលចិត្តំ

៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

} មហាកុសលចិត្តំ

## មហាវិបាកចិត្ត ៨ដួង គឺ

១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ
៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ

} មហាវិបាកចិត្តំ

៨ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

## មហាកិរិយាចិត្ត ៨ដួង គឺ

១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ
៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

} មហាកិរិយាចិត្តំ

រូបាវចរភូមិ មាន១៥ ដួងចែកចេញជា ៣ក្រុម គឺ

១.រូបាវចរកុសលចិត្ត ៥ដួង ២.រូបាវចរវិបាកចិត្តដួង ៣.រូបាវចរកិរិយាចិត្ត ៥ ដួង

## រូបាវចរកុសលចិត្ត ៥ដួង គឺ

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ

## រូបាវចរវិបាកចិត្ត ៥ដួង គឺ

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានវិបាកចិត្តំ

៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ

៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តំ

**រូបាវចរកិរិយាចិត្ត ៥ដួង គឺ**

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយាចិត្តំ

២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកិរិយាចិត្តំ

៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ

៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយាចិត្តំ

៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយាចិត្តំ

អរូបាវចរភូមិ មាន១២ ដួង ចែកចេញជា ៣ក្រុម គឺ

១.អរូបាវចរកុសលចិត្ត ៤ដួង

២.អរូបាវចរវិបាកចិត្ត ៤ដួង

៣.អរូបាវចរកិរិយាចិត្ត ៤ដួង

**អរូបាវចរកុសលចិត្ត ៤ដួង គឺ**

១.អាកាសានញ្ចាយតនំ កុសលចិត្តំ

២.វិញ្ញាណញ្ចាយតនំ កុសលចិត្តំ

៣.អាកិញ្ចញ្ញាយតនំ កុសលចិត្តំ

៤.នេវសញ្ញានាសញ្ញាយតនំ កុសលចិត្តំ

**អរូបាវចរវិបាកចិត្ត ៤ដួង គឺ**

១.អាកាសានញ្ចាយតនំ វិបាកចិត្តំ

២.វិញ្ញាណញ្ចាយតនំ វិបាកចិត្តំ

៣.អាកិញ្ចញ្ញាយតនំ វិបាកចិត្តំ

៤.នេវសញ្ញានាសញ្ញាយតនំ វិបាកចិត្តំ

## អរូបាវចរកិរិយាចិត្ត ៤ដួង គឺ

១.អាកាសានញ្ចាយតនំ កិរិយាចិត្តំ

២.វិញ្ញាណញ្ចាយតនំ កិរិយាចិត្តំ

៣.អាកិញ្ចញ្ញាយតនំ កិរិយាចិត្តំ

៤.នេវសញ្ញានាសញ្ញាយតនំ កិរិយាចិត្តំ

## លោកុត្តរចិត្តមាន ៨ឬ៤០ដួង ចែកចេញជា ២ក្រុម គឺ

១.លោកុត្តរកុសលចិត្ត ៤ដួង ឬ២០ ដួង

២.លោកុត្តរវិបាកចិត្ត ៤ដួង ឬ២០ ដួង

## លោកុត្តរកុសលចិត្ត ៤ដួង គឺ

១.សោតាបត្តិមគ្គចិត្តំ ២.សកទាគាមិមគ្គចិត្តំ

៣.អនាគាមិមគ្គចិត្តំ ៤.អរហត្តមគ្គចិត្តំ

## លោកុត្តរវិបាកចិត្ត ៤ដួង គឺ

១.សោតាបត្តិផលចិត្តំ ២.សកទាគាមិផលចិត្តំ

៣.អនាគាមិផលចិត្តំ ៤.អរហត្តផលចិត្តំ

លោកុត្តរចិត្តទាំង ៨ដួងនេះ បើរាប់ដោយអំណាចអង្គឈាន មាន ៤០ដួង គឺ លោកុត្តរមគ្គជ្ឈានចិត្ត ២០ដួង និងលោកុត្តរផលជ្ឈានចិត្ត ២០ដួង ។

លោកុត្តរមគ្គជ្ឈានចិត្ត មាន២០ដួង ចែកចេញជា ៤ក្រុម គឺ

១.សោតាបត្តិមគ្គជ្ឈានចិត្ត ៥ដួង

២.សកទាគាមិមគ្គជ្ឈានចិត្ត ៥ដួង

៣.អនាគាមិមគ្គជ្ឈានចិត្ត ៥ដួង

៤.អរហត្តមគ្គជ្ឈានចិត្ត ៥ដួង

## សោតាបត្តិមគ្គជ្ឈានចិត្ត ៥ដួង គឺ

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិមគ្គចិត្តំ

២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិមគ្គចិត្តំ

៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសោតាបត្តិមគ្គចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្តំ

**សកទាគាមិមគ្គជ្ឈានចិត្ត ៥ដួង គឺ**

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសកទាគាមិមគ្គចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសកទាគាមិមគ្គចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសកទាគាមិមគ្គចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសកទាគាមិមគ្គចិត្តំ

**អនាគាមិមគ្គជ្ឈានចិត្ត ៥ដួង គឺ**

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអនាគាមិមគ្គចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអនាគាមិមគ្គចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអនាគាមិមគ្គចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអនាគាមិមគ្គចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអនាគាមិមគ្គចិត្តំ ។

**អរហត្តមគ្គជ្ឈានចិត្ត ៥ដួង គឺ**

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអរហត្តមគ្គចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអរហមគ្គចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអរហមគ្គចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអរហត្តមគ្គចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអរហត្តមគ្គចិត្តំ ។

## លោកុត្តរផលជ្ឈាន មាន២០ដួង ចែកចេញជា ៤ក្រុម គឺ

១.សោតាបត្តិផលជ្ឈានចិត្ត ៥ដួង
២.សកទាគាមិផលជ្ឈានចិត្ត ៥ដួង
៣.អនាគាមិផលជ្ឈានចិត្ត ៥ដួង
៤.អរហត្តផលជ្ឈានចិត្ត ៥ដួង

### សោតាបត្តិផលជ្ឈានចិត្ត ៥ដួង គឺ

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិផលចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិផលចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសោតាបត្តិផលចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសោតាបត្តិផលចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្តំ

### សកទាគាមិផលជ្ឈានចិត្ត ៥ដួង គឺ

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសកទាគាមិផលចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសកទាគាមិផលចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសកទាគាមិផលចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសកទាគាមិផលចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសកទាគាមិផលចិត្តំ

### អនាគាមិផលជ្ឈានចិត្ត ៥ដួង គឺ

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអនាគាមិផលចិត្តំ
២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអនាគាមិផលចិត្តំ
៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអនាគាមិផលចិត្តំ
៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអនាគាមិផលចិត្តំ
៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអនាគាមិផលចិត្តំ

**អរហត្តផលជ្ឈានចិត្ត ៥ដួង គឺ**

១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអរហត្តផលចិត្តំ

២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអរហត្តផលចិត្តំ

៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអរហត្តផលចិត្តំ

៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអរហត្តផលចិត្តំ

៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអរហត្តផលចិត្តំ ។

# ចេតសិកបរមត្ថ

❖ **ចេតសិកបរមត្ថ មាន ៥២ដួង ចែកចេញជា ៣ក្រុម គឺ**

១.អញ្ញសមានាចេតសិក ១៣ដួង

២.អកុសលចេតសិក ១៤ដួង

៣.សោភណចេតសិក ២៥ដួង

**អញ្ញសមានាចេតសិក ១៣ដួង ចែកចេញជា ២ក្រុម គឺ**

១.សព្វចិត្តសាធារណចេតសិក ៧ដួង គឺ ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា  ជីវិតិន្ទ្រិយំ មនសិការោ ។

២. បកិណ្ណកចេតសិក ៦ដួង គឺ វិតក្កោ វិចារោ អធិមោក្ខោ វីរិយំ បីតិ ឆន្ទោ ។

**អកុសលចេតសិក ១៤ដួង ចែកចេញជា ៥ពួក គឺ**

១.មោចតុក្កៈ ៤ ដួងគឺ មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ

២. លោតិកៈ ៣ ដួងគឺ លោភោ ទិដ្ឋិ មានោ

៣.ទោចតុក្កៈ ៤ ដួងគឺ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ

៤. ថីទុកៈ ២ ដួងគឺ ថីនំ មិទ្ធំ

៥. ឯកវិចិកិច្ឆា ១ ដួង គឺ វិចិកិច្ឆា ។

**សោភណចេតសិក ២៥ដួង ចែកចេញជា ៤ក្រុម គឺ**

១. សោភណសាធារណចេតសិក ១៩ ដួង

២. វិរតិចេតសិក ៣ដួង

៣. អប្បមញ្ញាចេតសិក ២ដួង

៤. បញ្ញិន្ទ្រិយចេតសិក ១ដួង

**១.សោភណសាធារណចេតសិក ១៩ដួង គឺ**

សទ្ធា សតិ ហិរិ ឱត្តប្បំ អលោភោ អទោសោ តត្រមជ្ឈត្តតា កាយបស្សទ្ធិ ចិត្តបស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា ។

**២.វិរតិចេតសិក ៣ដួង គឺ** សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ។

**៣. អប្បមញ្ញាចេតសិក ២ដួង គឺ** ករុណា មុទិតា ។

**៤. បញ្ញិន្ទ្រិយចេតសិក ១ដួង គឺ** បញ្ញិន្ទ្រិយំ ។

# រូបបរមត្ថ

- **រូបបរមត្ថ មាន ២៨ គឺ**

**មហាភូតរូប ៤ និងឧបាទាយរូប២៤**

**ចែកជាពួកមាន ១១ពួក គឺ**

១. មហាភូតរូប ៤គឺ បឋវី១ អាបោ១ តេជោ១ វាយោ១

២. បសាទរូប ៥គឺ ចក្ខុបសាទ១ សោតបសាទ១ ឃានបសាទ១ ជិវ្ហាបសាទ១ កាយបសាទ១

៣. វិសយរូប ៤គឺ វណ្ណរូប១ សទ្ទរូប១ គន្ធ១ រសរូប១

៤. ភាវរូប ២ គឺ ឥត្ថីភាវរូប១ បុរិសភាវរូប១

៥. ហទយរូប ១ គឺ ហទយវត្ថុ

៦. ជីវិតរូប ១ គឺ  ជីវិតរូប

៧. អាហាររូប ១ គឺ  ឱជរូប

៨. បរិច្ឆេទរូប ១ គឺ  អាកាសរូប

៩. វិញ្ញត្តិរូប ២ គឺ  កាយវិញ្ញត្តិរូប១  វចីវិញ្ញត្តិរូប១

១០. វិការរូប ៣ គឺ  រូបស្ស  លហុតា១  រូបស្ស  មុទុតា១ រូបស្ស  កម្មញ្ញតា១

១១. លក្ខណរូប ៤ គឺ  ឧបចយរូប១  សន្តតិរូប១  ជរតារូប១ អនិច្ចតារូប១

**រូប ២៨ចែកជាគូ បាន ១១គូគឺ**

**គូទី១. អជ្ឈត្តិករូប និង ពាហិររូប**

- អជ្ឈត្តិករូប (រូបខាងក្នុង) បានដល់ បសាទរូប៥
- ពាហិររូប(រូបខាងក្រៅ) បានដល់រូប ២៣ដទៃទៀត ។

**គូទី២. វត្ថុរូប និង អវត្ថុរូប**

- វត្ថុរូប (រូបជាទីអាស្រ័យ ឲ្យចិត្ត និងចេតសិកកើតឡើង) បានដល់រូប ៦គឺ បសាទរូប ៥ និងហទយវត្ថុរូប ១
- អវត្ថុរូប (រូបមិនជាទីអាស្រ័យ ឲ្យចិត្ត និងចេតសិកកើតឡើង) បានដល់ រូប ២២ដទៃទៀត ។

**គូទី៣. ទ្វាររូប និង អទ្វាររូប**

- ទ្វាររូប (រូបដែលជាទ្វារ) បានដល់រូប ៧គឺ បសាទរូប៥ និងវិញ្ញត្តិរូប២
- អទ្វាររូប (រូបដែលមិនជាទ្វារ) បានដល់រូប ២១ដទៃទៀត ។

**គូទី៤. ឥន្ទ្រិយរូប និង អនិន្ទ្រិយរូប**

- ឥន្ទ្រិយរូប (រូបដែលជាធំ) បានដល់រូប៨គឺ បសាទរូប ៥ វិញ្ញត្តិ២ និង ជីវិតរូប ១

- អនិន្ទ្រិយរូប (រូបដែលមិនជាធំ) បានដល់រូប ២០ដទៃទៀត ។

**គូទី៥.ឱឡារិករូប និង សុខុមរូប**

- ឱឡារិករូប (រូបគ្រោតគ្រាត) បានដល់រូប ១២ គឺបសាទរូប៥ និង
- គោចររូប៧
- សុខុមរូប (រូបល្អិតសុខុម) បានដល់រូប ១៦ដទៃទៀត ។

**គូទី៦. សន្តិកេរូប និង ទូររេូប**

- សន្តិកេរូប (រូបជិត) បានដល់រូប ១២ គឺបសាទរូប ៥ និងគោចររូប ៧
- ទូររេូប (រូបឆ្ងាយ) បានដល់រូប ១៦ដទៃទៀត ។

**គូទី៧. សប្បដិឃរូប និង អប្បដិឃរូប**

- សប្បដិឃរូប (រូបគួរដល់ការប៉ះខ្ទប់) បានដល់រូប ១២គឺ បសាទរូប ៥ និងគោចររូប ៧
- អប្បដិឃរូប (រូបមិនគួរដល់ការប៉ះខ្ទប់) បានដល់រូប ១៦ដទៃទៀត ។

**គូទី៨. ឧបាទិន្នរូប និង អនុបាទិន្នរូប**

- ឧបាទិន្នរូប (រូបដែលកើតអំពីលោកិយកុសលាកុសលកម្ម) បានដល់រូប ១៨គឺ កម្មជរូប១៨
- អនុបាទិន្នរូប (រូបដែលមិនកើតពីកម្ម) បានដល់រូបដែលកើតពី ចិត្ត ឧតុ និងអាហារ ។

**គូទី៩. សនិទស្សនរូប និង អនិទស្សនរូប**

- សនិទស្សនរូប (រូបគួរដល់ការឃើញដោយភ្នែកបាន) បានដល់ រូប១ គឺវណ្ណរូប
- អនិទស្សនរូប (រូបមិនគួរដល់ការឃើញដោយភ្នែកបាន) បានដល់រូប ២៧ដទៃទៀត ។

**គូទី១០.គោចរគាហិករូប និង អគោចរគាហិករូប**

- គោចរគាហិករូប (រូបដែលទទួលការប៉ះខ្ទប់នឹងបញ្ចារម្មណ៍បាន) បានដល់ រូប៥ គឺបសាទរូប៥
- អគោចរគាហិករូប (រូបដែលទទួលការប៉ះខ្ទប់នឹងបញ្ចារម្មណ៍មិនបាន) បានដល់ រូប២៣ដទៃទៀត ។

**គូទី១១.អវិនិព្ភោគរូប និង វិនិព្ភោគរូប**

- អវិនិព្ភោគរូប (រូបដែលមិនបែកគ្នា) បានដល់រូប៨ គឺ មហាភូតរូប៤ វណ្ណរូប១ គន្ធរូប១ រសរូប១ អាហាររូប១ ។
- វិនិព្ភោគរូប (រូបដែលបែកគ្នា) បានដល់ រូប ២០ដទៃទៀត ។

**រូបចែកតាមសមុដ្ឋានទាំង ៤គឺ**

១.កម្មជរូប ១៨ គឺ បសាទរូប៥ ភាវរូប២ ហទយរូប១ ជីវិតរូប១ មហាភូតរូប៤ គោចររូប៣(វៀរសទ្ទរូប) អាហាររូប១ បរិច្ឆេទរូប១ ។

២.ចិត្តជរូប១៥ គឺ វិញ្ញត្តិរូប២ អវិនិព្ភោគរូប៨ សទ្ទរូប១ បរិច្ឆេទរូប១ វិការរូប៣ ។

៣.ឧតុជរូប ១៣ គឺ អវិនិព្ភោគរូប៨ សទ្ទរូប១ បរិច្ឆេទរូប១ វិការរូប៣ ។

៤.អាហារជរូប១២ គឺ អវិនិព្ភោគរូប៨ បរិច្ឆេទរូប១ វិការរូប៣ ។

## និព្វានបរមត្ថ

ព្រះនិព្វានមាន ១ គឺ **សន្តិលក្ខណំ ។**

ព្រះនិព្វានមាន ២ គឺ **សឧបាទិសេសនិព្វាន ១ , អនុបាទិសេសនិព្វាន ១**

ព្រះនិព្វានមាន ៣ គឺ **សុញ្ញតនិព្វាន ១ , អនិមិត្តនិព្វាន ១ , អប្បណិហិតនិព្វាន ១ ។**

*ចប់គោលបរមត្ថទាំង៤ដោយសង្ខេប*

( ១៤៦ ) **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ៗ**

**១.រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ** ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុ អ្នកដឹងរាត្រី ដែលជាសាវករបស់តថាគតស្រេចនឹង អញ្ញាកោណ្ឌញ្ញៈ ប្រសើរជាងគេ។

**២.មហាបញ្ញានំ យទិទំ សារីបុត្តោៗ** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុ អ្នកមានប្រាជ្ញាច្រើន ស្រេចនឹង សារីបុត្ត

**៣. ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកមានឫទ្ធិ ស្រេចនឹងមហាមោគ្គល្លាន ។

**៤. ធុតវាទានំ យទិទំ មហាកស្សបោ ៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកពោលពាក្យកំចាត់បង់កិលេស ស្រេចនឹងមហាកស្សបៈ ។

**៥. ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកមានទិព្វចក្ខុ ស្រេចនឹង អនុរុទ្ធ ។

៦. **ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោកាឡិគោធាយបុត្តោ ៗ**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកមានត្រកូលខ្ពស់ស្រេចនឹង កាឡិគោធាយបុត្ត។

**៧. មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកមានសំឡេងពីរោះ ស្រេចនឹង លកុណ្ឌកភទ្ទិយៈ។

**៨.សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោៗ**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកបន្លឺសីហនាទ ស្រេចនឹង បិណ្ឌោលភារទ្វាជៈ។

**៩.ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោៗ**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ ជាធម្មកថិក ស្រេចនឹង បុណ្ណមន្តានីបុត្ត។

**១០.សទ្ធិន្តេន តាសិតស្ស ចិត្តាវេន អត្ថំ ចិតដន្តានំ យទិទំ មហាកច្ចានោតិ ៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកចែកសេចក្តីធម៌ ដែលតថាគត សំដែងដោយសង្ខេប ឲ្យពិស្តារបាន ស្រេចនឹង មហាកច្ចានៈ។

**(ចគ្គោ បឋមោ)(ចគ្គទី១ចប់)**

**(១៤៧) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំៗ**

**១. មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ ៗ**ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ អ្នកនិមិត្តកាយសម្រេចចិត្តបាន ដែលជាសាវករបស់តថាគត ស្រេចនឹង ចុល្លបន្តកៈ ។

**២.ចេតោចិវដ្តកុសលានំ យទិទំ ចុល្លបន្ថកោៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនិងចុល្លបន្តកៈ។

**៣.បញ្ញាចិវដ្តកុសលានំ យទិទំ មហាបន្ថកោ ៗ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកឈ្លាសក្នុងការប្រើប្រាជ្ញា ស្រេចនឹងមហាបន្តកៈ ។

**៤.អរណវិហារីនំ យទិទំ សុភូតិ ៗ**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅដោយឥតកិលេស ស្រេចនឹងសុភិតិ

**៥. ទក្ខិណេយ្យានំ យទិទំ សុភូតិ ។**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកគួរដល់ទក្ខិណាទាន ស្រេចនឹងសុភូតិ ។

**៦. អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ។**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកនៅក្នុងព្រៃ ស្រេចនឹង រេវតខទិរវនិយៈ។

**៧. ឈាយីនំ យទិទំ កង្ខារេវតោ ៗ**ម្នាលភិក្ខុទាំឡាយ ពួកភិក្ខុ អ្នកបានឈាន ស្រេចនឹង កង្ខារេវតៈ ។

**៨. អារទ្ធវីរិយានំ យទិទំ សោណោកោឡិវិសោ ៗ**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងសោណកោលិវិសៈ។

**៩. កល្យាណវាក្ករណានំ យទិទំ សោណោកុដិកណ្ណោ ។**ម្នាលភិក្ខុ

ទាំងឡាយ ពួកភិក្ខុ អ្នកពោលពាក្យពិរោះស្រេចនឹង សោណកុដិកណ្ណៈ ។
**១០.លាភីនំ យទិទំ សីវលី ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកមានលាភ ស្រេចនឹង សីវលី ។
**១១. សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ។**ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកមានសទ្ធា ស្រេចនឹង **វក្កលិ** ។

**(វគ្គោ ទុតិយោ) ( វគ្គទី២ចប់)**

**(១៥៨) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ**

**១. សិក្ខាកាមានំ យទិទំ រាហុលោ ។** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នក ស្រឡាញ់សិក្ខា ដែលជាសាវករបស់តថាគត ស្រេចនឹងរាហុលប្រសើរជាងគេ
**២. សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកបួស ដោយសទ្ធា ស្រេចនឹងរដ្ឋបាល ។
**៣. បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។** ម្នាលភិក្ខុទាំង ឡាយ ពួកភិក្ខុអ្នកចាប់ស្លាកមុនដំបូងបង្អស់ ស្រេចនឹង កុណ្ឌធាន ។
**៤. បដិភាណវន្តានំ យទិទំ វង្គីសោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកមាន បដិភាណ ស្រេចនឹង វង្គីសៈ ។
**៥. សមន្តប្បាសាទិកានំ យទិទំ វង្គន្តបុត្តោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នក មានសេចក្ដីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹង ឧបសេនវង្គន្តបុត្ត, ។
**៦. សេនាសនប្បញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកក្រាលសេនាសនៈស្រេចនឹង ទព្វមល្លបុត្ត ។
**៧. ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ ជាទីស្រឡាញ់ជាទីគាប់ចិត្ត របស់ទេវតាទាំងឡាយ ស្រេចនឹង បិលិន្ទវច្ឆៈ ។
**៨.ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ អ្នកត្រាស់ដឹងរហ័សស្រេចនឹង ពាហិយទារុចីរិយៈ ។

**៩. ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកចេះសំដីដ៏វិចិត្ត ស្រេចនឹង កុមារកស្សបៈ ។

**១០. បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោ ។** ម្នាលភិក្ខុទាំងឡាយពួកភិក្ខុ អ្នកបានបដិសម្ភិទា ស្រេចនឹង មហាកោដ្ឋិតៈ ។

**(វគ្គោ តតិយោ) ( វគ្គទី៣ចប់)**

**(១៥៩) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ។,**

**១. ពហុស្សុតានំ យទិទំ អានន្ទោ ។**ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ អ្នកចេះដឹងច្រើនដែលជាសាវករបស់ តថាគតស្រេចនឹងអានន្ទប្រសើរជាងគេ

**២សតិមន្តានំ យទិទំ អានន្ទោ។** ពួកភិក្ខុអ្នកមានស្មារតីស្រេចនឹងអានន្ទ។

**៣).គតិមន្តានំ យទិទំ អានន្ទោ ។** ពួកភិក្ខុ អ្នកមានគតិ ស្រេចនឹងអានន្ទ។

**៤.ធិតិមន្តានំ យទិទំ អានន្ទោ ។** ពួកភិក្ខុ អ្នកមានប្រាជ្ញា ស្រេចនឹងអានន្ទ។

**៥.ឧបដ្ឋាកានំ យទិទំ អានន្ទោ ។** ពួកភិក្ខុ ជាឧបដ្ឋាក ក៏ស្រេចនឹងអានន្ទដែរ។

**៦. មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។** ពួកភិក្ខុ អ្នកមានបរិស័ទច្រើន ស្រេចនឹង ឧរុវេលកស្សបៈ ។

**៧.កុលប្បសាទកានំ យទិទំ កាឡុទាយី ។** ពួកភិក្ខុ អ្នកញុំាងត្រកូលឱ្យជ្រះថ្លា ស្រេចនឹង កាឡុទាយិ ។

**៨.អប្បាពាធានំ យទិទំ ពក្កុលោ។** ពួកភិក្ខុ អ្នកគ្មានអាពាធ ស្រេចនឹងពក្កុលៈ

**៩.បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ ។** ពួកភិក្ខុអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹង សោភិតៈ ។

**១០. វិនយធរានំ យទិទំ ឧបាលិ។**ពួកភិក្ខុ អ្នកទ្រទ្រង់វិន័យស្រេចនឹងឧបាសលិ

**១១. ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។** ពួកភិក្ខុអ្នកឱ្យឱវាទភិក្ខុនីស្រេចនឹងនន្ទកៈ

**១២. ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។**ពួកភិក្ខុ អ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចនឹង នន្ទៈ ។

**១៣.ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ៗ** ពួកភិក្ខុ អ្នកឱ្យឱវាទភិក្ខុស្រេចនឹង មហាកប្បិន ។
**១៤.តេជោធាតុកុសលានំ យទិទំ សាគតោ ៗ** ពួកភិក្ខុ អ្នកឈ្លាសវៃក្នុងតេជោធាតុ ស្រេចនឹង សាគតៈ ។
**១៥.បដិភាណេយ្យកានំ យទិទំ រាធោ ៗ** ពួកភិក្ខុ អ្នកឈ្លាសវៃបដិភាណ ស្រេចនឹង រាធៈ ។
**១៦.លូខចីវរធរានំ យទិទំ មោឃរាជាតិ ។** ពួកភិក្ខុ អ្នកទ្រទ្រង់ចីវរសៅហ្មង ស្រេចនឹង មោឃរាជ ។

**វគ្គោ ចតុត្ថោ (វគ្គទី៤ចប់)**

**(១៥០) ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ ៗ**

**១. រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី ៗ** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុនី អ្នកដឹងរាត្រីដែលជាសាវិការបស់ តថាគត ស្រេចនឹង មហាបជាបតីគោតមី ប្រសើរជាងគេ ។
**២. មហាបញ្ញានំ យទិទំ ខេមា ៗ** ពួកភិក្ខុនី អ្នកមានប្រាជ្ញាច្រើន ស្រេចនឹង ខេមា
**៣. ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា ៗ** ពួកភិក្ខុនី អ្នកមានឫទ្ធិ ស្រេចនឹងនាង ឧប្បលវណ្ណា ។
**៤. វិនយធរានំ យទិទំ បដាចារា ៗ** ពួកភិក្ខុនី អ្នកទ្រទ្រង់វិន័យ ស្រេចនឹង នាង បដាចារា ។
**៥. ធម្មកថិកានំ យទិទំ ធម្មទិន្នា ៗ** ពួកភិក្ខុនី ជាធម្មកថិកា ស្រេចនឹង នាងធម្មទិន្នា ។
**៦. ឈាយីនីនំ យទិទំ នន្ទាៗ** ពួកភិក្ខុនី អ្នកមានឈាន ស្រេចនឹងនាង នន្ទា។
**៧. អារទ្ធវីរិយានំ យទិទំ សោណា ៗ** ពួកភិក្ខុនី អ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងនាង សោណា។

**៨ទិព្វចក្ខុកានំ យទិទំ សកុលា៖**ពួកភិក្ខុនីអ្នកមានទិព្វចក្ខុស្រេចនឹងសកុលា ។
**៩. ខិប្បាភិញ្ញានំ  យទិទំ ភទ្ទា កុណ្ឌលកេសា ។**ពួកភិក្ខុនីបានត្រាស់ដឹងរហ័ស
 ស្រេចនឹងនាង ភទ្ទាកុណ្ឌលកេសា ។
**១០.បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី ៖** ពួកភិក្ខុនីអ្នករឭក
ឃើញបុព្វេនិវាស ស្រេចនឹងនាង ភទ្ទកបិលានី ។
**១១. មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា ៖** ពួកភិក្ខុនី អ្នកបានអភិញ្ញាដ៏ធំ
ស្រេចនឹងនាង  ភទ្ទាកច្ចានា ។
**១២.លូខចីវរធរានំ យទិទំ កិសាគោតមី ៖** ពួកភិក្ខុនី អ្នកទ្រទ្រង់ចីវរដ៏សៅ
ហ្មង ស្រេចនឹងនាង កិសាគោតមី ។
**១៣. សទ្ធាធិមុត្តានំ យទិទំ សិគាលមាតា ៖** ពួកភិក្ខុនី អ្នកមានសទ្ធាស៊ប់ ស្រេច
នឹង នាង សិគាលមាតា ។

**វគ្គោ បញ្ចមោ   (វគ្គទី ៥ ចប់)**

**១.ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសិកានំ  ៖ បឋមំ សរណំ គច្ឆន្តានំ យទិទំ ត ប្បុស្សភល្លិកា វាណិជា ៖** ម្នាលភិក្ខុទាំងឡាយ បណ្ដាឧបាសក អ្នកដល់សរណៈ
ជាបឋម       ដែលជាសាវករបស់ តថាគត ស្រេចនឹង តបុស្សពាណិជ និង
ភល្លិកពាណិជ     ប្រសើរជាងគេ ។
**២. ទាយកានំ យទិទំ សុទត្តោ គហបតិ អានាថបិណ្ឌិកោ ៖** ពួកឧបាសក ជាទាយក
(អ្នកឱ្យទាន) ស្រេចនឹង សុទត្តគហបតី គឺអនាថបិណ្ឌិកសេដ្ឋី ។
**៣. ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ ៖** ពួកឧបាសក ជាធម្មកថិក
ស្រេចនឹង ចិត្តគហបតី ដែលនៅក្នុងស្រុកមច្ឆិកសណ្ឌៈ
**៤.ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោ អាឡវកោ៖**ពួកឧបាសក
អ្នកសង្គ្រោះបរិស័ទ ដោយ សង្គហវត្ថុ ៤ ប្រការស្រេចនឹង ហត្ថកអាឡវកៈ ។
**៥. បណីតទាយកានំ យទិទំ មហានាមោ សក្កោ ៖** ពួកឧបាសក អ្នកឱ្យ

ភោជនមានរសដ៏ឧត្តម ស្រេចនឹង មហានាមសក្កៈ ។
**៦. មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ ។** ពួកឧបាសកអ្នកឱ្យភោជនជាទីគាប់ចិត្ត ស្រេចនឹង ឧគ្គគហបតី អ្នកនៅក្រុងវេសាលី ។
**៧. សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ ។** ពួកឧបាសក អ្នកបំរើសង្ឃ ស្រេចនឹង ឧគ្គតគហបតី។
**៨. អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។** ពួកឧបាសកអ្នកជ្រះថ្លាមិនកម្រើកស្រេចនឹង សូរអម្ពដ្ឋ ។
**៩. បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។** ពួកឧបាសក អ្នកញ៉ាំងបុគ្គលឱ្យជ្រះថ្លា ស្រេចនឹង ជីវកកោមារភច្ចៈ ។
**១០. វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ ។** ពួកឧបាសក អ្នកចេះនិយាយ ឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹង នកុលបិតាគហបតី ។
**វគ្គោ ឆដ្ឋោ (វគ្គទី៦ចប់) ។**
**១. ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ ។ បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា ។** ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសិកាអ្នកដល់នូវសរណៈជាបឋម ដែលជាសាវិការបស់តថាគត ស្រេចនឹង នាងសុជាតាសេនានិធីតា ប្រសើរជាងគេ ។
**២. ទាយិកានំ យទិទំ វិសាខា មិគារមាតា ។**ពួកឧបាសិកាជាទាយិកា (អ្នកឱ្យទាន) ស្រេចនឹងនាងវិសាខាមិគារមាតា ។
**៣. ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។** ពួកឧបាសិកា អ្នកចេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា ។
**៤. មេត្តាវិហារីនីនំ យទិទំ សាមាវតី ។** ពួកឧបាសិកា អ្នកនៅដោយមេត្តា ស្រេចនឹង នាងសាមាវតី ។

**៥. ឈាយីនីនំ យទិទំ ឧត្តរា នន្ទមាតា ៗ** ពួកឧបាសិកា អ្នកមានឈានស្រេចនឹង ឧត្តរានន្ទមាតា ។

**៦. បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា ៗ** ពួកឧបាសិកា អ្នកឱ្យទានផ្ចិតផ្ចង់ ស្រេចនឹង នាងសុប្បវាសាកោលិយធីតា ។

**៧. គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា ៗ** ពួកឧបាសិកា អ្នកបម្រើជំងឺ ស្រេចនឹងនាង សុប្បិយាឧបាសិកា ។

**៨. អវេច្ចប្បសន្នានំ យទិទំ កាតិយានី ៗ** ពួកឧបាសិកា អ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹង កាតិយានី ។

**៩. វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី ៗ** ពួកឧបាសិកា អ្នកចេះធ្វើឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹង នាងនកុលមាតាគហបតានី។

**១០. អនុស្សវប្បសន្នានំ យទិទំ កាលី ឧបាសិកា កុររឃរិកាតិ** ។ពួកឧបាសិកា អ្នកជ្រះថ្លាតាមពាក្យដែលឮតៗគ្នាស្រេចនឹងនាងកា**លីឧបាសិកាកុររឃរិកា**( កុ**លឃរិកា** ) ។

**វគ្គោ សត្តមោ វគ្គទី៧ចប់ ៗ**

# ផ្នែកធម៌បទ សម្រាប់សូត្រ

# អារាធនាព្រះសារីរិកធាតុ

បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ទូលព្រះបង្គំទាំងឡាយ ជាសាវិកាមាន ភិក្ខុសាមណេរ ឧបាសក ឧបាសិកា យុវជន យុវតី កុមារា កុមារី មានចិត្តជ្រះថ្លាណាស់ បានមកប្រជុំគ្នាហើយ ក្នុងទីចំពោះមុខ ព្រះគន្ធកុដិ នៃព្រះដ៏មានព្រះភាគ ដើម្បីអារាធនាយាង ព្រះដ៏មានព្រះភាគ ប្រទក្សិណទីពោធនីយដ្ឋាន និងដើម្បី ខ្ញុំព្រះអង្គទាំងឡាយ វេរនូវផ្កាកម្រង គ្រឿងក្រអូបទាំងឡាយចំពោះព្រះអង្គ បពិត្រព្រះដ៏មានប្រភាគដ៏ចម្រើន សូមព្រះអង្គទ្រង់ព្រះមេត្តាអនុគ្រោះ ដល់ខ្ញុំព្រះអង្គទាំងឡាយដើម្បីសេចក្តីចម្រើនដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះអង្គទាំងឡាយ អស់កាលជា អង្វែងទៅហោង អស់វារៈ២ ដងផង អស់វារៈ ៣ដងផង!!! (ដោយសាមណេរ ស៊ាក់ ស៊ីន)

**ព្រះគាថាធម៌ពោលសសើរគុណព្រះពុទ្ធ**

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**សព្វញ្ញូសិ មហាវីរ លោកជេដ្ឋ នរាសភ។**

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ

បពិត្រព្រះអង្គ ជាបុរសដ៏ឧត្តម ខ្ញុំសូមនស្ការព្រះអង្គ

បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក

ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញូពុទ្ធ។( បិដក៧៤/៧៩ )

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**ពហុជ្ជនំ តារយសិ ទេសេន្តោ អមតំ បទំ។**

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ

បពិត្រព្រះអង្គ ជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ

ព្រះអង្គកាលសម្តែងនូវអមតបទ គឺព្រះនិព្វានញុំាងជនដ៏ច្រើន

ឱ្យឆ្លងវដ្តទុក្ខបាន។ ( បិដក ៧៣/១៨៨ )

**រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ**

**វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ ។**

ព្រះអង្គមិនមានបុគ្គលស្មើក្នុងរូបផង សីលផង សមាធិផង បញ្ញាផង

ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិ

ធម៌និងការញុំាងធម្មចក្កឱ្យប្រព្រឹត្តទៅ។( បិដក ៧៧/១៣ )

**លាភាភេ ន សជ្ជន្តិ សមានេ វិមាននេ**

**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ ក្នុងលាភ និង អលាភ ក្នុងការរាប់អាននិងការមើលងាយ ហេតុនោះបុគ្គលមិនគប្បីឱ្យឆ្គាំឆ្គងនិងព្រះពុទ្ធទាំងនោះឡើយ ៕(បិដក ៧២/១០៨)

## បទសារភញ្ញ

១.សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
ចង្អុលឲ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឲ្យខ្វាយបាត់ អាចកាត់សង្សារទុក្ខបាន ។
២.សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ ។
ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនឹងមានព្រោះធម៌ស្ងប់ ។
៣.ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រៃរ័ត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ ៕

*ព្រះរាជនិពន្ធដោយសម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត***

# ដើមកំណើតរស្មីទាំង៦ពណ៌

១.ពណ៌ខៀវកាលផ្ទៀលព្រះនេត្រា ឲ្យឥន្ទព្រាហ្មណ៍ណាកាលជាស្តេច
នាមស្រីភិរាស្ត្រចង់សម្រេច ឲ្យបានសារពេជ្ជសាស្តាចារ្យ។
២.ពណ៌លឿងកាលអារសាច់ធ្វើមាស បិទលន់អង្គព្រះពុទ្ធបដិមា
ព្រះឥន្ទជាជាងច្នៃរចនា ថ្វាយពរសាធុការពេញផែនដី។
៣.ក្រហមជាពណ៌ឈាមបេះដូង ឆ្កៀលពីដើមទ្រូងដោយខ្នាតខ្មី
បិទពិសពស់ខាំព្រះជនី គង់រស់ជីវីជាស្បើយទៅ។
៤.ពណ៌សឲ្យទានដំរីស មង្គលបវរមាសឆ្អិនឆ្អៅ
ត្រូវរាស្ត្របណ្តេញមិនឲ្យនៅ ព្រមទាំងកូនចៅភរិយាណា។
៥.ហង្សបាទលោហិតសាច់មំសំ អារសាច់ខ្លួនតាំងដូរមាតា
កាលយក្សវាចាប់បរិភោគ្គា ជីវិតមាតារស់រឹងខ្មី។
៦.ផ្លេកពណ្ណរាយកាលជាទន្សាយ ឲ្យទានពុំស្តាយជីវិតអ្វី
លោតចូលភ្នក់ភ្លើងពុំថាអ្វី ឲ្យជាចំណីឥន្ទព្រាហ្មណ៍ណា។
៧.កាលដែលបានត្រាស់ជាព្រះពុទ្ធ ជាមកុដត្រៃភពក្នុងលោកកា
ពណ៌ទាំង៦នេះសោតណា ក្លាយមកកើតជាឆព្វណ្ណរង្សី។
៨.ពេលនេះក្នុងលោកគេសន្មត យកពណ៌នេះកត់ជាសេចក្តី
ហៅទង់សាសនាព្រះជិនស្រី ពាសពេញផែនដីផ្ទៃពសុធា។
៩ .យើងខ្ញុំរាល់គ្នាសូមគោរព វន្ទាចមកពទង់សាសនា
សូមមានមង្គលឈ្នះមារា សត្រូវនានាក្នុងភពបី។
១០ .សូមឲ្យយើងខ្ញុំប្រញាប់ដល់ ដើរកាន់តាមផ្លូវទៅបុរី
ជាឋានបរមសុខសួស្តី ដោយព្រះបារមីនិព្វានហោង៕

# បទលើកទង់ព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក
ប្រទេសតូចធំ បានស្ម័គ្រស្មាគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃព្រះសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឲ្យណាស់គ្រប់ៗគ្នា
សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លាច្រើនសែនលាន
មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ដ៏កល្យា
ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្ដីសុខ ។
យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ ទើបនឹងបានសុខក្សេមក្សាន្តត្រាណ។
ព្រមព្រៀងប្រព្រឹត្ត តាមធម៌សុចរិត ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា
និពន្ធដោយសម្ដេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន.ណាត**

# បទស្លូត្រដាក់ទង់ព្រះពុទ្ធសាសនា

ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរង្គប្រសើរបវរ
ឆ្អៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។
**១.រស្មីពណ៌ខៀវនោះណា** កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់
ឱ្យទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ ។
**២.រស្មីពណ៌លឿងភ្លឺថ្លា** កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទ្រជាងមាសទ្រង់វៃបណ្ឌិត ។
**៣.រស្មីក្រហមនោះណា** កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា។
**៤.រស្មីពណ៌សសុទ្ធសាធ** កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញាណ។
**៥.រស្មីពណ៌ដូចជើងហង្ស** កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឲ្យយក្សសាមាន្យស៊ីប្តូរជីវិត។
**៦.រស្មីពណ៌ផ្លេកពណ្ណរាយ** កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
រស្មីខៀវលឿងក្រហម សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចងចាំទុកអើយ ។
និពន្ធដោយសម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន.ណាត**

# សង្គាលកសូត្រ

(បទព្រហ្មគីតិ)

នេះបទព្រហ្មគីតិ ពីព្រេងប្រឹតទុកទូន្មាន
ដងស្រង់ពីនិទាន សង្គាលសូត្រនៃគាថា
ប្រារព្ធសង្គាលបុត្រ ព្រះចម្កុដអង្គសម្មា
សម្តេចព្រះភគវា ប្រោសទេសនានូវសេចក្តី
ទ្រង់ត្រាស់សួរទៅថា នៃសង្គាលបុត្រគហបតី
ចុះអ្នកនៅធ្វើអ្វី បានជាប្រាណជោគដោយទឹក
សង្គាលបង្គំថ្វាយ ព្រះអង្គអើយបង្គំនឹក
ខ្លួនប្រាណជោគទទឹក ព្រោះរឮកពាក្យបិតា
ឱ្យក្រោកពីព្រលឹម លើកកំបង់ផ្ទង់ហត្ថា
ហើយឱ្យខ្ញុំព្រះករុណា ថ្វាយបង្គំទិស៦
សម្តេចព្រះសាស្តា ត្រាស់សួរថាអ្នកឯងថ្វាយ
បង្គំទិស៦ ព្រោះហេតុអ្វីអ្នកដឹងទេ
សង្គាលមាណពឆ្លើយ បពិត្រអើ្ហយមិនយល់ទេ
ធ្វើនេះតាមពាក្យម៉ែ តាមពាក្យឪមុនគាត់ស្លាប់
មិនដឹងហេតុយ៉ាងណា សូមភគវាមេត្តាប្រាប់
ករុណារង់ចាំស្តាប់ ព្រះទេសនានេះឥឡូវ
រីអង្គព្រះចមត្រៃ ទ្រង់អភ័យទេសតម្រូវ
ប្រោសមនុស្សសត្វតាមផ្លូវ សង្គាលបុត្រយល់ស្តាប់ហើយ
ទ្រង់ជ្រាបយល់សព្វសត្វ រង់ចាំស្តាប់គ្រប់គ្នាអើយ
ទេសនាពុំលង់ឡើយ មានសេចក្តីដូចច្នេះថា

អរិយលោកបង្គំ　　មិនមែនទិសនេះទេណា
លោកអ្នកកម្មវេរា　　អំពើពៀរបិទឱ្យជិត
បណ្ឌិតកាលស្តាប់ហើយ　　មិនឃ្លាតឡើយស៊ូរស់ជិត
សេពគប់កល្យាណមិត្ត　　មិត្តសុចរិតពិតទាំងឡាយ
ម្នាលគហបតីបុត្រ　　ព្រះអរិយបាំងបិទកាយ
ទិស៦ដោយបរិយាយ　　សង្គហៈធម៌ទិសនេះនៃ
ពុកម្តាយទិសខាងកើត　　ទិសសត្តមោត្បូងទិសសី
ទិសលិចភរិយានិងស្វាមី　　ទិសជើងបុត្រីនិងបុត្រា
ទិសក្រោមកម្មករនិងម្ចាស់ផ្ទះ　　ទិសលើជាព្រះពុទ្ធសាសនា
សមណៈកាន់ធម៌អាថ៌　　ក្នុងសាសនាព្រះពុទ្ធអង្គ
កូនត្រូវមានសង្គហៈ　　គោរពជាក់ដោយស្មោះត្រង់
បដិបត្តិឱ្យផូរផង់　　តាមគន្លងម្តាយឪពុក
ត្រូវធ្វើតាមបំណង　　ដែលគាត់ប៉ងនិងគ្រងទុក
ធ្វើឱ្យលោកពេញមុខ　　តាមប្រាថ្នាដែលគាត់ចង់
ពុកម្តាយកាលគាត់ចាស់　　កូនត្រូវកាត់លះរក្សាគ្រង
ចិញ្ចឹមម៉ែផង　　រក្សាឈ្មោះវង្សត្រកូល
ពេលគាត់ឃ្លាតចាកឋាន　　កូនប៉ុន្មានត្រូវបង្សុកូល
បំពេញបុណ្យឱ្យមូល　　ទក្ខិណាទានឧទ្ទិសទៅ
រីអង្គព្រះសម្មា　　ត្រាស់ទេសនាកណ្តាលផ្លូវ
ប្រារព្ធព្រោះហេតុនូវ　　សង្គាលបុត្រយល់ស្តាប់បាន
ព្រះពុទ្ធវិសុទ្ធិពេជ្រ　　ព្រះពុទ្ធត្រាស់កិច្ចអ្នករាល់ប្រាណ
បំពេញមិនបំពាន　　អ្នកនោះថ្កានប្រសើរហោង៕
សូមអនុមោទនា!!!

# មាឃបុណ្ណមី

❖ **មាឃបុណ្ណមី** ថ្ងៃនក្ខត្តឫក្ស ធ្វើបុណ្យរំលឹកហេតុពីរប្រការ
ដែលព្រះសម្ពុទ្ធវិសុទ្ធថ្លៃថ្លា មានករុណាសង្គ្រោះសត្វលោក ។
❖ **មាឃបុណ្ណមី** ប្រជុំសាវ័ក សន្និបាតជាក់ នៃព្រះមានជោគ
ប្រកបដោយអង្គសង្ឃច្រើនគគោក ឆ្លងផុតចាកលោកមិនមានអាល័យ ។
❖ **មាឃបុណ្ណមី** ថ្ងៃព្រះសាស្តា ទ្រង់ត្រាស់វាចាមិនមានទុក្ខភ័យ
ដាក់នូវអាយុសង្ខារនោះនៃ កក្រើកផែនដី មួយម៉ឺនចក្រវាឡ ។
❖ **មាឃបុណ្ណមី** មានហេតុប្លែកៗ អស្ចារ្យចម្លែកមានក្នុងសាសនា
ជាប់ដោយព្រះគុណនៃព្រះសម្មា- សម្ពុទ្ធនោះណាករុណាក្រៃលែង ។
❖ **មាឃបុណ្ណមី** មានចិត្តសទ្ធា ជ្រះថ្លាគ្រប់គ្នាគោរពកោតក្រែង
បូជាព្រះអង្គ និងសង្ឃគម្ដែង មានចិត្តស្ងប់ស្ងែងបូជាដល់គុណ ។
❖ **មាឃបុណ្ណមី** ក្រុមពួកសង្ឃជី បរិស័ទមូលមីរប្រសើរពេកពន់
ប្រព្រឹត្តបូជាឱនកាយបន្ទន់ ទឹកចិត្តទន់ភ្លន់ ដ៏ល្អប្រពៃ ។
❖ **មាឃបុណ្ណមី** ចម្រើនកុសល លះកាត់កង្វល់ ខំប្រឹងលកលៃ
ធ្វើពេលវេលាឱ្យមានតម្លៃ ពីព្រឹកដល់ថ្ងៃ ដោយមិនប្រមាទ ។
❖ **មាឃបុណ្ណមី** មានន័យខ្លាំងណាស់ ព្រះអង្គទ្រង់ត្រាស់នូវព្រះឱវាទ
ប្រាប់បេះដូងធម៌ក្នុងសន្និបាត បរិសុទ្ធស្អាតវិសេសវិសិដ្ឋ ។
❖ **អាសាឍ វិសាខ មាឃបុណ្ណមី** សាវ័កប្រុសស្រី ប្រឹងទូន្មានចិត្ត
ឱ្យបានថ្លាស្អាត ផុតចាកទុច្ចរិត មិនមានវិបរិត នឹងបានសុខស្ងប់ ៕
ដោយភិក្ខុ សុវណ្ណជោតោ ភ.ស.វ.

# វិសាខបុណ្ណមី

▪**វិសាខបុណ្ណមី** គួរឱ្យជ្រះថ្លា ថ្ងៃព្រះសាស្តាសម្មាសម្ពុទ្ធ
ប្រសូតចាកគភ៌ ស្អាតបរិសុទ្ធ វិសេសបំផុតនៅក្នុងលោក។
▪**វិសាខបុណ្ណមី** ថ្ងៃទ្រង់ត្រាស់ដឹង ដែលទ្រង់រំពឹងបច្ចយាការបច្ចូស
សម័យព្រះទ័យស្រស់ថ្លា ត្រាស់ជាសម្មាសម្ពុទ្ធក្នុងលោក។
▪**វិសាខបុណ្ណមី** ថ្ងៃទ្រង់និព្វាន សត្វសែនកោដិលានមកច្រើនគគោកក្រាស់
ក្រៃលត្រៀបត្រាភក្ត្រទទឹកជោក នាំគ្នាសោយសោកស្តាយព្រះសាស្តា។
▪**វិសាខបុណ្ណមី** ថ្ងៃព្រះទ្រង់ត្រាស់ បញ្ជាក់យ៉ាងច្បាស់ បច្ឆិមវាចាថាកុំ
ប្រមាទ រៀលរាល់រូបា ចម្រើនបញ្ញា តាមព្រះមុនី ។
▪**វិសាខបុណ្ណមី** មានន័យខ្លាំងណាស់ បរិស័ទក្មេងចាស់គួរខំសម្តី
ស្រូតរូតស្រុះស្រួលស្តាប់ព្រះធម្មី ក្រុមពួកសង្ឃជីបានពោលសម្តែង
▪**វិសាខបុណ្ណមី** កម្ចាត់ងងឹត ដែលមានក្នុងចិត្តឱ្យភ្លឺចិញ្ចែង
លោភៈទោសៈមោហៈស្តែងៗ ពន្លឺស្វរសែងប្រទីបបញ្ញា ។
▪**វិសាខបុណ្ណមី** បិតក្នុងសីលទាន ឱ្យបានជាយានឆ្លងកាត់សង្សារ
កាត់អបាយភូមិ ទុក្ខច្រើនក្រៃណា ចម្រើនមេត្តាដល់សត្វទាំងឡាយ។
▪**វិសាខបុណ្ណមី** អប់រំវិជ្ជា យល់ដឹងគ្រប់គ្នា មានចិត្តនឿយណាយ
ប្រាជ្ញាយល់ត្រូវ ងងឹតខ្វាត់ខ្វាយ ផុតអន្តរាយកាយចិត្តស្រស់ថ្លា។
▪**ព្រះអង្គប្រសូត** និងបានត្រាស់ដឹង និព្វានថ្ងៃហ្នឹងគួរពិចារណា
សង្ខារទាំងឡាយមិនទៀងឡើយណា គ្រប់រូបអាត្មាកើតចាស់ឈឺស្លាប់ ។
▪**ចូរកុំប្រមាទ**នៅក្នុងទានសីល ដើម្បីផ្តាច់ផ្តិលរូតរះប្រញាប់
សម្មាទិដ្ឋិ ដែលទ្រង់បានប្រាប់ ឆ្ការគាស់កាយកាប់កិលេសតណ្ហា៕

# វិសាខបុណ្ណមី

វិសាខបុណ្ណមីគឺថ្ងៃវិសេស យើងបានចាំចេះថ្ងៃព្រះភគវា
ប្រាំពីរប្រការជ្រះថ្លាវន្ទា វិសាខបូជាឫក្សពារសែនល្អ ។
⭑**ទីមួយ** គឺថ្ងៃសុមេធបណ្ឌិត ពោធិសត្វពិតមានឫទ្ធិបវរ
ចាប់ផ្ដើមទទួលព្រះពុទ្ធព្យាករណ៍ លោកធាតុញាប់ញ័រសាទរពេកក្រៃ។
⭑**ទីពីរ** គឺថ្ងៃក្សត្រថ្លៃប្រសូត អស្ចារ្យរហូតសម្ដោធព្រឹក្សព្រៃ
កំណើតចុងក្រោយជាប់ដោយអត្ថន័យ ផុតចាកភពត្រៃលែងភ័យលែងព្រួយ។
⭑**ទីបី** គឺថ្ងៃព្រះស្រីមហាពោធិ៍ ដុះចេញលេចឆ្ពោះពោធិ៍ពិតមានត្រួយ
ថ្ងៃព្រះប្រសូតស្រួតដុះជាមួយ ជំនួយឱ្យចិត្តបរិស័ទជ្រះថ្លា ។
⭑**ទីបួន** គឺថ្ងៃចមត្រៃត្រាស់ដឹង ថ្ងៃមានទីពឹងពំនឹងលោកា
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ ពួកជនជ្រះថ្លាចិន្តាល្អស្អាត ។
⭑**ទីប្រាំ** គឺថ្ងៃអង្គថ្លៃនិព្វាន ថ្ងៃព្រះទ្រង់ញាណមានពុទ្ធោវាទ
មច្ឆិមវាចាថាកុំប្រមាទ ឱវាទពិសិដ្ឋឋិតនៅជាគ្រូ ។
⭑**ប្រាំមួយ** គឺថ្ងៃប្រល័យព្រះធាតុ ចេតិយលោកនាថនៅទៀតមិនយូរ
ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍ តេជោរំលាយរំលត់ពុទ្ធសាសន៍។
⭑**ប្រាំពីរ** គឺថ្ងៃជោគជ័យពុទ្ធា គ្រប់ព្រះភគវាឈ្នះមារបានត្រាស់
នាំមកនូវសុខវិសេសខ្លាំងណាស់ គ្រប់ព្រះអង្គត្រាស់ព្រះធម៌ទេសនា។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត យើងខ្ញុំមានចិត្តនឹងធឹងជ្រះថ្លា
វន្ទាសំពះអង្គព្រះសាស្ដា សូត្រធម៌ថ្វាយផ្កាបូជាប្រទីប ។

ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

## **អាសាឡ្ហបូជា***(ព្រោះមានហេតុ៥យ៉ាង)*

អាសាឡ្ហបូជា យើងខ្ញុំគ្រប់គ្នា ជ្រះថ្លាកន្លង
ថ្ងៃពេញបូណ៌មី យាយតាប្អូនបង នាំគ្នាត្រសង
មកកាន់អារាម ។

ថ្ងៃនេះអស្ចារ្យ ហេតុប្រាំប្រការ ថ្ងៃចេញចាកកាម
បរិស័ទទាំងអស់ គ្រប់វត្តអារាម នាំគ្នាព្យាយាម
គោរពបូជា ។

**ទីមួយជាថ្ងៃ** ពោធិសត្វថ្លៃ ចាប់ផ្ទៃមាតា
បដិសន្ធិ ក្នុងថ្ងៃនេះណា ដែលផ្ទៃពសុធា
កក្រើកញាប់ញ័រ ។

**ទីពីរជាថ្ងៃ** ព្រះចមម្កុដថ្លៃ និស្ស័យបវរ
ចេញសាងព្រះផ្នួស ឲ្យបានដឹងធម៌ ឆ្លងកាត់នគរ
អស់ចំនួនបី ។

**ទីបីនោះណា** ថ្ងៃមហាអស្ចារ្យ អង្គមានសិរី
ត្រាស់បានពីរខែ ទ្រង់យាងឃ្មាតខ្មី យាងទៅកាន់ព្រៃ
ឥសិមិគទា ។

សម្ដែងធម្មចក្ក ធម៌ល្អឥតអាក់ បឋមទេសនា
ប្រោសបញ្ចវគ្គិយ នឹងពួកទេវតា មានទាំងព្រហ្មា
យ៉ាងច្រើនអនេក ។

**ទីបួនជាថ្ងៃ** សង្ឃលើផែនដី បានកើតជាឯក
កំណើតព្រះសង្ឃ នឹកឃើញគួរត្រេក អរយ៉ាងពន់ពេក

នៅក្នុងសន្តាន ។

**ទីប្រាំជាថ្ងៃ** អង្គព្រះជិនស្រី ព្រះទ័យក្លាហាន
សម្តែងឫទ្ធី គ្មានអ្នកតាំងបាន ឫទ្ធិដ៏ថ្កើងថ្កាន
យមកប្បាដិហារ្យ ។

ផ្ចាញ់ពួកនិគ្រន្ថ ទដ្ឋិទម្រន់ អួតអាងអស្ចារ្យ
ជាអ្នកយល់ខុស មិនមានបញ្ញា ដោយអាងខ្លួនថា
ប្រសើរពេកក្រៃ ។

បន្ទាប់ពីនោះ ព្រះភក្ត្រត្រង់ឆ្ពោះ គិតក្នុងហឫទ័យ
ប្រោសពុទ្ធមាតា នៅស្ថានប្រពៃ តាវត្តិង្សនោះនៃ
ដោយអភិធម្ម ។

យើងខ្ញុំគ្រប់គ្នា គោរពវន្ទា ដោយចិត្តមនោរម្យ
កាយវាចាចិត្ត គិតគន់ឧត្តម ចំពោះបរម
ជាសាស្តាចារ្យ ។

ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃបវរ ខ្ញុំសូមបូជា
នូវទៀននិងធូប ទាំងគ្រឿងសក្ការ មានភ្ញីមានផ្កា
ព្រមទាំងទឹកអប់ ។

បូជាកាយចិត្ត ប្រព្រឹត្តសុចរិត ឲ្យបានគ្រប់សព្វ
បានជាប្រយោជន៍ ដល់ជនគួរគាប់ ទេវតាគន្ធព្វ
គ្រប់ភពគ្រប់ស្ថាន ។

ដោយបុណ្យកុសល ដែលបានតម្កល់ នៅក្នុងសន្តាន
សូមមនុស្សគ្រប់គ្នា បានសុខក្សេមក្សាន្ត សាងល្អគ្រប់ប្រាណ
កុំបីធ្វើបាប ។

បុណ្យនាំឲ្យរស់ បុណ្យនាំឲ្យខ្ពស់ បុណ្យនាំឲ្យជ្រាប

បុណ្យនាំឲ្យល្អ ឲ្យដឹងខ្ពស់ទាប បុណ្យឲ្យសុភាព
បុណ្យឲ្យសុខស្ងប់ ៕

# គោតមប្រវត្តិ

- ❖ ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
- ❖ និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
- ❖ មកចាប់ផ្ទៃមាតា ស្រីស្រីង្គារស្រស់កល្យាណ
- ❖ កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
- ❖ ក្នុងថ្ងៃព្រហស្បតិ៍អា- សាឍមាសាពេញបូណ៌មី
- ❖ រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
- ❖ កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
- ❖ នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
- ❖ កក្រើកផែនពសុធា មានទេវតារាប់រយពាន់
- ❖ ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។
- ❖ ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
- ❖ កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
- ❖ បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
- ❖ នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
- ❖ ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
- ❖ កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី អាសាឍពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។
- ❖ ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លៃ

- គួរឲ្យព្រះរាជា ស្តេចជំពាក់ចិត្តពេកក្រៃ ។
- តែទ្រង់បានកាត់ផ្តាច់ ទ្រង់សម្រេចព្រះហឫទ័យ
- ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។
- បើបិតាបានត្រាស់ រិលរហ័សរកបុត្រា
- មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
- កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
  អាសាឍពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
- កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
- ធ្វើទុក្ករកិរិយា គ្មាននណាធ្វើដូចអី ។
- បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
- ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។
- ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
- ប្រោសបញ្ចវគ្គិយា នាកណ្តាលដងព្រឹក្សព្រៃ ។
- គឺក្នុងឆ្នាំរកា អាសាឍមាសាបុណ្ណមី
- ថ្ងៃសៅរ៍ព្រះជិនស្រី ផ្តើមពោលស្តីធម៌ទេសនា ។
- ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
- សាវ័កព្រះសាស្តា មានរហូតដល់សព្វថ្ងៃ ។
- នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
- គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
- គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
- នៅចំពោះមុខមារ នាបាវាលចេតិយ ។
- បីខែកន្លងទៅ មិនឈប់នៅយឺនយូរអី
- ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។

- ❖ គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា
  គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
- ❖ ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
- ❖ នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា ។
- ❖ សូមឲ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
  អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
- ❖ សូមជួបព្រះសិអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
- ❖ សូមចាក់ផ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕

*និពន្ធដោយ ព្រះភិក្ខុ **វីរបញ្ញោ សាន សុជា***

## គោតមប្រវត្តិ( បុរាណ )

សូមថ្លែងកាលអង្គព្រះលោកនាថ នាមព្រះសិទ្ធត្ថពង្សពុទ្ធា
ជាម្ចាស់នៃយើងទាំងអស់គ្នា កាលគ្រងយរាកបិលភស្តុ ។
សោយសុខសម្បត្តិនិងមហេសី ពិម្ពាក្សត្រីរូបល្អស្រស់
ប្រសើរលើសស្រីស្នំទាំងអស់ ប្រកបដោយយសថ្កើងប្រពៃ ។
តាំងពីប្រសូត្ររហូតសោយរាជ្យ ទ្រង់មានអំណាចឫទ្ធិជោគជ័យ
ឥតហេតុអ្វីមួយនាំឲ្យភ័យ កក្រើកព្រះទ័យនៃក្សត្រា ។
លុះដល់ព្រះជន្ម២៩ ទ្រង់ចេញទតសួនព្រៃព្រឹក្សា
ទ្រង់ទតនិម្មិតដែលទេវតា តំណែងកាយាជាមនុស្សចាស់។
មនុស្សឈឺមនុស្សស្លាប់និងបព្វជិត ទតហើយទ្រង់គិតសង្វេគណាស់
ទ្រង់សួរសារថីឆាប់រហ័ស បញ្ជាក់ឲ្យច្បាស់គ្រប់នាទី ។
សារថីក្រាបទូលព្រះចមភព តាមពិតសព្វគ្រប់តាំងអំពី
រូបមនុស្សជរាមនុស្សព្យាធិ ដរាបដល់ទីភេទព្រះសង្ឃ ។
កាលពោធិវង្សទ្រង់សណ្តាប់ សារថីសាសព្វតាមពិតត្រង់

ទ្រង់ភ្ញាក់ព្រះទ័យឆ្ពោះតម្រង់ ដល់កាយព្រះអង្គនិងពួកសត្វ។
ហើយទ្រង់បន្លឺព្រះឱង្ការ ថាឱ! សង្ខារតែងវិបត្តិ
ជរាព្យាធិចង្រៃក្តាត់ ធ្វើឲ្យសព្វសត្វលំបាកកាយ។
រីឯមរណៈក៏កាចពិត ធ្វើឲ្យជីវិតសត្វអន្តរាយ
អ្នកផងគេស្មានថាសប្បាយ រាល់រូបរាងកាយក្នុងលោកនេះ។
ឱសឱ! រូបប្រាណមិនបានសុខ ទុក្ខអ្វីក៏ទុក្ខច្រើនដល់ម្ល៉េះ
នែសារថីអើយបើដូច្នេះ គួរតែគេចវេះកុំអាល័យ ។
ឃើញតែអ្នកបួសទើបសុខណាស់ ត្រាស់ដឹងធម៌ច្បាស់ពិតពេកក្រៃ
សម្លាប់តណ្ហាឲ្យក្សិណក្ស័យ ដល់សឹកមាល័យព្រះនិព្វានហោង ៕

## ខ្ញុំនឹកព្រះណាស់

ខ្ញុំឈរកណ្តាលទីក្រុងចាស់ ខ្ញុំនឹកព្រះណាស់ពេលព្រលប់
បញ្ជូគិរីនៅឃើញគ្រប់ ចិត្តខ្ញុំប្រារព្ធព្រះសាស្តា ។
ផល្គុនខ្មៅតចាស់ចន្ទភ្លឺហើយ ខ្ញុំពុំឃើញឡើយព្រះបិតា
បាត់ស្ងាត់សូន្យអស់អរហន្តា សល់តែសិលានិងព្រៃភ្នំ ។
ហាក់ដូចថ្មីៗ ឥឡូវសោះ ស្រាប់តែបាត់អស់ចាកចោលខ្ញុំ
ខ្ញុំបានត្រឹមតែថ្វាយបង្គំ ដួងចិត្តស្រែយំនឹកសាស្តា ។
នឹកអើយសែននឹកអង្គព្រះពុទ្ធ ខ្ញុំសូមលំអុតឱនសិរសា
សម្តែងរៀបរាប់ចារអក្ខរា មគធៈសាស្តាធ្លាប់អាស្រ័យ ។
ថ្វីដ្បិតរូបកាយស្តេចយាងបាត់ ធម្មកាយមិនខ្វាត់ឋិតសព្វថ្ងៃ
អារាធនាអង្គព្រះពុទ្ធថ្លៃ គង់ក្នុងហឫទ័យនៃយើងខ្ញុំ ។

*ដោយលោកគ្រូ **អគ្គបណ្ឌិត ប៊ុត សាវង្ស***

# ព្រះអង្គទ្រង់ប្រសូត

កាលព្រះសិទ្ធត្ថអម្ចាស់ថ្លៃ ស្ដេចចុះចាប់ផ្ទៃនៃព្រះមហា
មាយាទេវីពុទ្ធមាតា នៅឆ្នាំរកាពេញបូណ៌មី ។
នាខែអាសាឍថ្ងៃព្រហស្បតិ៍ ជារាជឱរសនៃព្រះស្រី
សុទ្ធោទនៈរាជម្ចាស់ផែនដី កបិលពស្តុបុរីរាជសីមា ។
ស្ដេចទ្រង់ប្រសូតចេញចាកផ្ទៃ មាតានៅថ្ងៃសុក្រថ្លៃថ្លា
នាពេញបូណ៌មីវិសាខា ឆ្នាំច នោះណាមានសួស្ដី ។
នៅពេលដែលព្រះវរមាតា យាត្រាចេញពីរាជបុរី
កបិលពស្តុទៅដើម្បី បង្គំព្រះបិតាមាតា ។
នៅឯទេវទហៈរាជធានី ដល់លុម្ពិនីវ័នថ្លៃថ្លា
ទ្រង់ជ្រកក្រោមម្លប់សាលព្រឹក្សា ទិវាត្រង់ជាក់ទ្រង់ឈឺផ្ទៃ ។
ទ្រង់ឈរតោងមែកព្រឹក្សាសាល អយ្យបុត្តត្រកាលឆោមប្រពៃ
ប្រសូតចាកគភ៌រួសរាន់វៃ វិស័យអ្នកទេសន៍ចាកធម្មា ។
ប្រសូតភ្លាមឈរដើរឈោងឈាន ប្រាំពីរជំហានព្រះបាទា
ទ្រង់បានបន្លឺព្រះវាចា ថាយើងនេះណាជាចម្បង ។
លើលោកទាំងបីឥតនរណា ផ្ទឹមស្មើអាត្មាយើងជាម្ដង
ជាតិនេះជាជាតិបំផុតហោង យើងនឹងចម្លងសត្វទាំងឡាយ។
ឱ្យឆ្លងដល់ទីដ៏ក្សេមក្សាន្ត ដោយធម្មយានអត្ថបរិយាយ
ឱ្យឆ្លងដល់ត្រើយនិព្វាននាយ សូន្យឆ្ងាយចាកទុក្ខសុខមហិមា។
ទីទ្រង់ត្រាស់ដឹងនោះព្រះបាទ អសោកនាថស្ដេចឥណ្ឌា
ទ្រង់សាងគោលថ្មល្អសោភា មួយជាអនុស្សាវរីយ៍ ។
ខ្ញុំសូមក្រាបថ្វាយបង្គំស្មោះ ចំពោះអង្គព្រះមហាមុនី

ស្តេចទ្រង់ប្រសូតនៅត្រង់ទី សួនលុម្ពិនីដោយសទ្ធា ។
សូមឱ្យសិរីជយមង្គល ចូលដល់ខ្ញុំនិងអ្នករាល់គ្នា
ដែលបានសូធ្យស្តាប់សព្វពណ៌នា ពុទ្ធប្បវត្តិនេះកុំបីខានឡើយ ៕

*ចាកជំនួយសតិទាគទី ១៨*

## ព្រះអង្គទ្រង់ត្រាស់ដឹង

កាលព្រះសិទ្ធត្ថដ៏មានបុណ្យ ព្រះជន្មដប់ប្រាំមួយវស្សា
ទ្រង់សោយរាជ្យជួសព្រះបិតា គ្រប់គ្រងរដ្ឋាកបិលពស្តុ ។
ជាមួយព្រះនាងយសោធរា ពិម្ពាក្សត្រីស្រីល្អស្រស់
ប្រសើរលើសស្រីស្នំទាំងអស់ ប្រកបដោយយសថ្កើងណាស់ណា ។
លុះដល់ព្រះជន្មបានគ្រប់ធួន ម្ភៃប្រាំបួនព្រះវស្សា
ទ្រង់បានឱរសមួយថ្លៃថ្លា នាមថារាហុលល្អប្រិមប្រិយ ។
ក្នុងថ្ងៃរាហុលកើតនោះមិញ ទ្រង់ចេញបព្វជ្ជាដោយឃ្មាតខ្មី
បច្ឆិមបដិបត្តិតឹងពេកក្រៃ ដើម្បីឱ្យឆាប់បានត្រាស់ដឹង ។
ក្រោយពេលទ្រង់លះព្រះកិរិយា ទុក្ករៈនោះណាទ្រង់រំពឹង
មជ្ឈិមបដិបត្តិបានត្រាស់ដឹង ធម៌ថ្លៃឥតថ្លឹងដ៏ក្សេមក្សាន្ត ។
នៅនាថ្ងៃពុធពេញបូណ៌មី ពិសាខវង្សីរកាបាន
ជាសព្វញ្ញុពុទ្ធថ្កើងថ្កាន ព្រះញាណប្រាជ្ញប្រោសឆ្លុះលោកា
នៅក្រោមដើមពោធិ៍មានមង្គល នៅត្រង់មណ្ឌលឈ្មោះគយា
ក្បែរឆ្នេរនទីនេរញ្ជរា បានជាគ្រូគ្រប់សព្វភពបី ។
ទីទ្រង់ត្រាស់ដឹងនោះព្រះបាទ អសោកនាថស្តេចផែនដី
ទ្រង់សាងព្រះស្តូបល្អប្រិមប្រិយ សម្គាល់ទីដីទ្រង់ត្រាស់ដឹង ។
ខ្ញុំសូមក្រាបថ្វាយបង្គំវន្ទា ឆ្ពោះព្រះភគវាជាទីពឹង

ព្រះអង្គឈ្នះមារហើយត្រាស់ដឹង សម្លឹងត្រើយនាយនិព្វានពិត។
សូមបុណ្យដែលយើងរួបរួមគ្នា ព្យាយាមពុះពារទាំងឆ្ងាយជិត
ទោះក្តៅ រងា យប់ងងឹត ប្រឹងអស់កាយចិត្តដ្បិតជ្រះថ្លា។
សូមបុណ្យទាំងនេះជួយនាំមុខ ឱ្យឆ្លងផុតទុក្ខដូចប្រាថ្នា
សូមឱ្យបានកើតជាតិណាៗ ជួបទាន់សាសនាព្រះទ្រង់ញាណ។
សូមកុំឱ្យជួបភយន្តរាយ រោគាទាំងឡាយកុំឱ្យមាន
សូមកុំឱ្យជួបការអត់ឃ្លាន រហូតនិព្វានកុំខានឡើយ ៕
ចាកជំនួយសតិភាគទី ១៤

## ទ្រង់ដាក់អាយុសង្ខារ-បរិនិព្វាន

អង្គព្រះទ្រង់ញាណមានតេជះ សម្តែងប្រាប់ព្រះអានន្ទថា
រទេះដែលចាស់បរទៅណា ទៅបានដោយសារអបឫស្សី។
តថាគតចាស់គ្រាំគ្រាហើយ ម្នាលអានន្ទអើយមានមាំអី
ដូចរទេះចាស់អបឫស្សី វស្សាឆ្នាំថ្មីប៉ែតសិបហើយ ។
ក្រោយព្រះអានន្ទទ្រង់ចេញផុត ពីព្រះសម្ពុទ្ធមិនយូរឡើយ
ក្រោយភត្តាហារថ្ងៃត្រង់ហើយ មារមិនកន្តើយគាល់សាស្តា ។
ឆ្នាំម្សាញ់ខែមាឃថ្ងៃអាទិត្យ ពេញបូណ៌មីពិតថ្ងៃនោះណា
ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ចំពោះមុខមារគ្រានោះឯង ។
នៅនាបាវាលចេតិយ ក្បែរវេសាលីក្រៅកំផែង
កក្រើកធរណីគ្រប់កន្លែង ផ្គរលាន់ខ្ទាត់ខ្ទែងខ្ទរអាកាស។
ក្រោយមកភិក្ខុជួបជុំគ្នា អង្គព្រះភគវាទ្រង់បានត្រាស់
សម្តែងគាថាអស្ចារ្យណាស់ រំលឹកយ៉ាងច្បាស់ត្រាស់ឱវាទ។

**ពោល**!

***ទ្រង់បានត្រាស់ថាសង្ខារទាំងឡាយ តែងតែអន្តរាយវិនាសខូចខាត**
**ចូរអ្នកទាំងឡាយកុំបីប្រមាទ ប្រឹងប្រែងសង្វាតឲ្យសម្រេចការ។**
**ភាជន៍ដែលស្មូនឆ្នាំងដំដុតដោយដី តូចក្ដីធំក្ដីនៅឆ្អិនយ៉ាងណា**
**ចុងក្រោយរមែងតែងមានកិរិយា បែកធ្លាយធម្មតានេះជាការពិត ។**
យ៉ាងណាជីវិតសព្វសត្វនិករ ក្មេងចាស់មានក្រពាលឬបណ្ឌិត
ចុងក្រោយរមែងតែងតែស្លាប់ពិត បាត់បង់ជីវិតក៏យ៉ាងនោះដែរ ។
ជីវិតតថាគតមានប្រមាណតិច គោរពពាក្យពេចន៍ឥតគេចកែប្រែ
ពីថ្ងៃនេះទៅនៅត្រឹមបីខែ តថាគតត្រូវតែបរិនិពាន្ទ ។
បីខែកន្លងយ៉ាងរហ័ស សែនសោកស្ដាយណាស់ព្រះទ្រង់ញាណ
វេលាជិតភ្លឺទ្រង់ចូលឈាន ហើយចូលនិព្វានកណ្ដាលព្រៃ។
ក្នុងខែពិសាខថ្ងៃអង្គារ ឆ្នាំម្សាញ់វេលាចុងរាត្រី
ថ្ងៃដប់ប្រាំកើតពេញបូណ៌មី បរិស័ទប្រុសស្រីជុំត្រៀបត្រា ។
ទីទ្រង់និព្វាននោះតាំងនៅ ក្បែរផ្លូវទៅក្រុងកុសិនារា
រាំងភ្នំមួយគូសាលព្រឹក្សា មានផ្ទាំងសិលានៅចន្លោះ ។
កុំថាឡើយមនុស្សសោយសោកា សូម្បីទេវតាស្ថានទាំងអស់
យំសោកបោកប្រាណស្ដាយស្រណោះ លាន់កក្រើកអស់ភពផែនដី ។
ទីទ្រង់និព្វាននោះឥឡូវ មានស្ដូបតាំងនៅល្អប្រិមប្រិយ
សម្គាល់ទីដែលព្រះជិនស្រី និព្វានលើដីកុសិនារា ។
ក្នុងស្ដូបមានព្រះបដិមាថ្ម កសាងយ៉ាងល្អគួរជ្រះថ្លា
តំណាងព្រះសពព្រះសាស្ដា ស្ដុកស្ដឹងកាយាសែនអាសូរ ។
អ្នកទៅដល់ពិតចិត្តដិតជាប់ ឃើញដូចព្រះសពនៅជ្រងោ
មានស្បង់ចីវរថ្វាយផ្លាស់ប្ដូរ ទឹកនេត្រាហូរនឹកព្រះអង្គ ។

នឹកហាក់ដូចជានៅថ្មីៗ នឹកព្រះជិនស្រីប្រោសស្រោចស្រង់
នឹកដល់ព្រះធម៌ល្អផ្ទូរផង់ នឹកទាំងព្រះសង្ឃអង្គសាវ័ក ។
ចាប់តាំងអំពីថ្ងៃនេះទៅ សូមដើរតាមផ្លូវព្រះអរិយៈ
ក្រោមម្លប់ព្រះធម៌ដ៏ត្រជាក់ ផុតពីអន្ទាក់នៃពួកមារ ។
សូមឲ្យលោកអ្នកបានសូធ្យស្តាប់ ប្រវត្តិសារសព្វព្រះភគវា
បានសុខចម្រើនគ្រប់ៗគ្នា កុំបីឃ្លាតឃ្លាគ្រាណាឡើយ ៕

*ដោយឧបាសក គុយ សុធន*

## សម្រស់វេឡុវ័ន មហាវិហារ

គ្រាមួយព្រះបាទពិម្ពិសារ ហឫទ័យមេត្តាឱ្យគេច្រៀង
សរសើរវេឡុវ័នដោយសំនៀង អត្ថន័យសូរសៀងពីរោះក្រៃ។
អ្នកណាមិនឃើញវេឡុវ័ន ដែលព្រះអរហន្តគង់អាស្រ័យ
អ្នកនោះមិនបានឃើញបុរី ឧទ្យានប្រពៃនៃទេវតា។
អ្នកណាបានឃើញវេឡុវ័ន ពិតឥតធុញទ្រាន់បាត់សោកា
អ្នកនោះគឺដូចបានទស្សនា នន្ទវ័នអស្ចារ្យក្នុងទេវលោក។
វត្តវេឡុវ័នកើតឡើងបាន ដោយបុណ្យកល្យាណព្រះមានជោគ
គុណវេឡុវ័នមានក្នុងលោក អ្នកណានឹងមករាប់អស់បាន។
ព្រះនាងខេមាមហេសីស្តេច ស្តាប់ចប់ស្រេចបាច់រឿងឧទ្យាន
ហឫទ័យប៉ងទតមិនអាចខាន ខេមាកល្យាណគាល់រាជា។
រីព្រះរាជាម្ចាស់ផែនដី ត្រាស់ថាមហេសីនាំបរិពារ
ទៅទតឧទ្យានព្រះភគវា គ្រប់គ្នានឹងបានសុខសួស្តី។
គ្រានោះឧទ្យានវេឡុវ័ន មានព្រះអរហន្តជាសិរី

ព្រៃមានពន្លឺឆព្វណ្ណរង្សី ភ្លឺព្រោះសិរីព្រះសាស្តា។
វត្តវេឡុវ័នតាវៅយំ ឮសូររងំឃ្មុំក្រេបផ្កា
ជាភ័ព្វសំណាងព្រះខេមា ជួបព្រះសាស្តាសម្រេចធម៌៕

*ដោយ ប.ស.រ*

## ឋានត្រៃរតនៈ

ក្រុងពារាណសីទឹកដីពោធិសត្វ ក្នុងសង្សារវដ្តបំពេញបារមី
ព្រះបាទព្រហ្មទត្តគ្រងដែនកាសី ព្រះពោធិសត្វថ្លៃបួសជាតាបស។
ឥសិបតនៈព្រៃមិគទាយា ឋានព្រះភគវាគ្រប់អង្គទាំងអស់
សម្តែងធម្មចក្កប្រោសពួកតាបស អរិយមគ្គខ្ពង់ខ្ពស់បឋមទេសនា។
អាសាឍបុណ្ណមីថ្ងៃកំណើតធម៌ ទេសនាបវរមជ្ឈិមាយាត្រា
ថ្ងៃខួបកំណើតព្រះធម៌ទេសនា បរិស័ទជ្រះថ្លាថ្វាយផ្កាចេតិយ។
អាសាឍបុណ្ណមីថ្ងៃកំណើតសង្ឃ សរណៈពេញអង្គគម្រប់បី
ឋានត្រៃរតនៈក្នុងដែនកាសី អាសាឍបុណ្ណមីអាសាឡ្ហបូជា។
ចេតិយព្រះយសខ្ពស់ព្រោះសសរ យសបានស្តាប់ធម៌តលំដាប់គ្នា
ឯហិភិក្ខុដោយព្រះភគវា ព្រះយសបានជាសង្ឃព្រះអរហន្ត។
ហាសិបបួនអង្គសម្លាញ់ព្រះយស មកបួសទាំងអស់ព្រៃមិគទាយវ័ន
ឋានត្រៃរតនៈឋានព្រះភគវ័ន្ត ត្រាស់ប្រាប់អរហន្តចេញផ្សាយសាសនា។
ខ្ញុំសូមបង្គំឋានត្រៃរតនៈ ដោយចិត្តស្មោះស្ម័គ្រនឹកព្រះសាស្តា
នឹកព្រះអរហន្តនឹកធម៌ទេសនា ខ្ញុំសូមប្រាថ្នាផុតកាមលោកីយ៍៕

*ដោយ ប.ស.រ*

## បារមី ៣០

១ ឥតិបិ ទានបារមី សម្បន្នោ សោ ភគវា

ឥតិបិ ទានឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយទានបារមី ទានឧបបារមី ទានបរមត្ថបារមី ដូច្នេះផង ។

២ ឥតិបិ សីលបារមី សម្បន្នោ សោ ភគវា

ឥតិបិ សីលឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយសីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដូច្នេះផង ។

៣ ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយនេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្មបរមត្ថបារមី ដូច្នេះផង ។

៤ ឥតិបិ បញ្ញាបារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយបញ្ញាបារមី បញ្ញាឧបបារមី បញ្ញាបរមត្ថបារមី ដូច្នេះផង ។

៥ ឥតិបិ វីរិយបារមី សម្បន្នោ សោ ភគវា

ឥតិបិ វីរិយឧបបារមី សម្បន្នោ សោ ភគវា

**ឥតិបិ វិរិយបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយវិរិយបារមី វិរិយឧបបារមី វិរិយបរមត្ថបារមី ដូច្នេះផង ។

៦ **ឥតិបិ ខន្តិបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយខន្តិបារមី ខន្តិឧបបារមី ខន្តិបរមត្ថបារមី ដូច្នេះផង ។

៧ **ឥតិបិ សច្ចបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ សច្ចឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយសច្ចបារមី សច្ចឧបបារមី សច្ចបរមត្ថបារមី ដូច្នេះផង ។

៨ **ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ អធិដ្ឋានឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ អធិដ្ឋានបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយអធិដ្ឋានបារមី អធិដ្ឋានឧបបារមី អធិដ្ឋានបរមត្ថបារមី ដូច្នេះផង ។

៩ **ឥតិបិ មេត្តាបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តាឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយមេត្តាបារមី មេត្តាឧបបារមី មេត្តាបរមត្ថបារមី ដូច្នេះផង ។

១០ **ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយឧបេក្ខា បារមី ឧបេក្ខាឧបបារមី ឧបេក្ខាបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ សមត្តឹសបារមី សម្បន្នោ សោ ភគវាតិ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយបារមីទាំង ៣០ ដូច្នេះផង

## ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស

(បិដកលេខ ៦៦, ទំព័រ ២៣៧-២៣៩)

**ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ បត្តោ ។**

ពាក្យថា **ពុទ្ធោ** គឺព្រះដ៏មានព្រះភាគអង្គណា ព្រះដ៏មានព្រះភាគអង្គនោះជាព្រះសយម្ភូ ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងមិនមាននូវ គ្រូអាចារ្យឡើយ ទ្រង់ត្រាស់ដឹងដោយប្រពៃក្រៃលែងនូវសច្ចៈក្នុងធម៌ទាំងនោះដោយព្រះអង្គឯង ពុំបានស្តាប់ពីមុនមកឡើយ ព្រះអង្គទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយផង ទ្រង់ដល់នូវភាពជំនាញក្នុងពលៈទាំងឡាយផង ។

**ពុទ្ធោតិ កេនត្ថេន ពុទ្ធោ** ពាក្យថា **ពុទ្ធោ** តើ **ពុទ្ធោ** ដោយអត្ថដូចម្តេច ?

១. **ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងឡាយ ។

២. **ពោធេតា បជាយាតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គញុំាងពពួកជនឱ្យត្រាស់ដឹងផង ។

៣. **សព្វញ្ញុតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ទាំងពួង ។

៤. **សព្វទស្សាវិតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គឃើញនូវធម៌ទាំងពួងដោយញាណចក្ខុ ។

៥. **អនញ្ញេយ្យតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមានអ្នកដទៃណាដឹកនាំព្រះអង្គឡើយ ។

៦. **វិកសិតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមាននូវស្មារតីដ៏វិសេស ។

៧. **ខីណាសវសង្ខាតេន ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាអស់ទៅនូវអាសវៈ ។

៨. **និរុបក្កិលេសសង្ខាតេន ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាមិនមានឧបក្កិលេស ។

៩. **ឯកន្តវីតរាគោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវរាគៈដោយដាច់ខាត ។

១០. **ឯកន្តវីតទោសោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវទោសៈដោយដាច់ខាត ។

១១. **ឯកន្តវីតមោហោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវមោហៈដោយដាច់ខាត ។

១២. **ឯកន្តនិក្កិលេសោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមាននូវកិលេសដោយដាច់ខាត ។

១៣. **ឯកាយនមគ្គំ គតោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គយាងទៅក្នុងផ្លូវតែមួយ ជាផ្លូវទៅកាន់ព្រះនិព្វានបានដល់សតិប្បដ្ឋាន៤ ។
១៤. **ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសម្មាសម្ពោធិ-ញាណដ៏ប្រសើរមួយ ព្រះអង្គឯង ។

១៥. **អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភត្តា ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គកម្ចាត់បង់នូវការមិនមានបញ្ញាដោយការបាន នូវបញ្ញា ។

**ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។**

ព្រះនាម **ពុទ្ធោ** នេះ មិនមែនជាព្រះនាមដែលព្រះមាតាថ្វាយទេ មិនមែនព្រះបិតាថ្វាយទេ មិនមែនបងប្អូនប្រុសថ្វាយទេ មិនមែនបងប្អូនស្រីថ្វាយទេ មិនមែនមិត្តអាមាត្យថ្វាយទេ មិនមែនញាតិសាលោ ហិតថ្វាយទេ មិនមែនសមណព្រាហ្មណ៍ថ្វាយទេ មិនមែនទេវតាថ្វាយទេ ទ្រង់ព្រះនាម **ពុទ្ធោ** នេះជាវិមោក្ខន្តិកនាម គឺព្រះនាមដែលមានក្នុងទីបំផុត នៃអរហត្តផល របស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគ ជាសច្ឆិកាបញ្ញត្តិ គឺបញ្ញត្តិព្រោះការជាក់ច្បាស់ក្នុងធម៌ទាំងពួង ដែលបានកើត ព្រមជាមួយនឹងសព្វញ្ញុតញ្ញាណ នៅគល់ព្រះពោធិព្រឹក្ស ។

# ធម្មនិយាម ៣០

## របស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ

សូមក្រាបបង្គំប្រណម្យវន្ទា ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា។
**មួយ** រញ្ជួយភពជាតិគ្រប់ចុងក្រោយ បារមីនាំឱ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
**ពីរ** គឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌ ស្មិងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
**បី** ឥរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្តាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្លៃហប្ញទ័យជ្រះថ្លា។
**បួន** សួនឧទ្យានទីឋានប្រសូត ក្នុងព្រៃរហូតឈើស្រូតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ ចក្រវាឡបព្ទតាខ្ទ័រខ្ទារអ៊ូអរ ។
**ប្រាំ** ព្រះប្រសូត ចុះស្រូតយាងឈាន ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្លឺសីហនាទ ។
**ប្រាំមួយ** ប្រមើលទតមើលនិមិត្ត ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាត យាត្រាចាកផ្នួស។
**ប្រាំពីរ** ធីរោផ្តាច់ប្តូរព្យាយាម ឥតមានទាក់ទាមនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង។
**ប្រាំបី** មហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទើបច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា
**ប្រាំបួន** ជូនភ័ព្វទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា ទេពធីតាមារមកគ្រាសាយ័ណ្ហ។

**៩៦** គាប់ហឫទ័យអានាបាណៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវ័នជាន់ឆ្លងកាមា ។
**៩៦មួយ** ជំនួយពីព្រះបារមី ផ្ចាញ់មារអប្រីយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក។
**៩៦ពីរ** មុនីអង្គទ្រង់សម្រេចញាណ ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ ពោធិញ្ញាណខ្ពស់ឯកកក្រើកធរណី។
**៩៦បី** ក្សត្រថ្លៃគង់ក្នុងមហាឋាន វិមុត្តិក្បៀមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកស្ងួយស្ថានទី ចេតិយព្រះមុនីប្រាំពីរកន្លែង។
**៩៦បួន** ជួនព្រហ្មជុំអារាធនា សូមព្រះភគវាយាងត្រាស់សម្តែង
ព្រះធម៌ប្រពៃ វិស័យស្ងូរ្យសែង ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ។
**៩៦ប្រាំ** ចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហបូជា ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ។
**៩៦ប្រាំមួយ** ទ្រង់គង់ត្រាស់ឱវាទ បាតិមោក្ខស្អាងស្អាតឱវាទផូរផង់
បេះដូងព្រះធម៌ពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី។
**៩៦ប្រាំពីរ** ទ្រង់គង់វត្តជេតពន ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណជេតពនសួស្តី ជេតពនជិនស្រីអាស្រ័យជានិច្ច។
**៩៦ប្រាំបី** ទ្រង់សម្តែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា។
**៩៦ប្រាំបួន** ទ្រង់គង់ឋានត្រៃត្រិង្ស ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្តែងអភិធម្មស័ក្តិសមអស្ចារ្យ ថ្វាយព្រះមាតាសុខាអមតៈ។
**១០០** គឺព្រះអង្គទ្រង់ចាកទេវលោក ស្តេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ។
**១០០មួយ** គឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ

អរហត្តផលតម្កល់ប្រក្រតី ឆាប់ក្តីយូរក្តីវិស័យពុទ្ធញ្ញាណ។

**ម្តេពីរ** ប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យសព្វសត្វដែលមាន

ដោយព្រះករុណាសមាបត្តិញ្ញាណ ត្រួតសត្វកោដិលានមានពីរវារៈ។

**ម្តេបី** ទ្រង់លៃវិន័យអាជ្ញា បញ្ញត្តិសិក្ខាតាមការជ្រាបជាក់

មានរឿងកើតមុនខូចគុណសាវ័ក មានហេតុជាក់លាក់ទើបដាក់វិន័យ។

**ម្តេបួន** អង្រួនហឫទ័យករុណា ជាតកទេសនាសាស្តាលកលៃ

ដើមរឿងជាហេតុបង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍។

**ម្តេប្រាំ** ទ្រង់ប្រោសដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្តែងបាដិហារ្យ

កម្ចាត់មានះព្រះញាតិវង្សា ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស។

**ម្តេប្រាំមួយ**ទ្រង់គង់ធូន់ក្នុងធម៌ បរិស័ទណាល្អមានធម៌ទ្រទ្រង់

ស្តេចយាងទទួលស្រុះស្រួលដោយអង្គ គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌។

**ម្តេប្រាំពីរ** ទ្រង់គង់ចាំវស្សា បើមាននរណានិមន្តដោយល្អ

ពេលចេញវស្សាមុនយាងចេញចរ ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ។

**ម្តេប្រាំបី** ទ្រង់គង់យ៉ាងហ្មត់ចត់ មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ

បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់ ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា។

**ម្តេប្រាំបួន** ទ្រង់គង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា

បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា សោយរសមំសាហឫទ័យបរិសុទ្ធ។

**សាមសិប** អវសានទ្រង់បានចូលឈានមុននឹងនិព្វានឈានច្រើនបំផុត

ម្តេប្រាំបួនសែនកោដិសមាបត្តិបរិសុទ្ធ រួចហើយទ្រង់ផុតរលត់សង្ខារ។

**អហំ** វីខ្ញុំ បង្គំវន្ទា ឆ្ពោះព្រះភគវា ព្រះធម៌ថ្លៃថ្លា

ព្រមទាំងព្រះសង្ឃផូរផង់សីលា ចិន្តាលំអុតព្រះពុទ្ធនិយាម ។

សូមឱ្យសព្វសត្វបដិបត្តិតាមធម៌ សាសនាបវរល្អដូចព្រះនាម

អរហំសម្មាគ្មានការទាក់ទាម កិលេសរវាមរវាតសូន្យបង់ ។

សូមឱ្យសាសនាសម្មាសម្ពុទ្ធ បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា។
សូមមនុស្សទេវតាមានការគោរព ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនាសូម
បានសម្រេចដូចក្តីប្រាថ្នា អស់នូវតណ្ហាទុក្ខាចប់ហោង៕

ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

## ឧបមាគុណព្រះរតនត្រៃ ២២ ប្រការ

រីគុណព្រះត្រៃរតន៍ បរិសុទ្ធប្រសើរក្រៃ
លោកបានឧបមេយ្យ មានម្ភៃពីរប្រការ ។
⭑**ទីមួយ**គឺព្រះពុទ្ធ ប្រសើរផុតត្រៃលោកា
ប្រៀបបានព្រះចន្ទ្រា រះនាថ្ងៃពេញបូណ៌មី ។
រីឯព្រះធម្មា ប្រៀបដូចជាកាំរស្មី
នៃដួងព្រះច័ន្ទថ្លៃ ចាំងរស្មីភ្លឺលោកា ។
ព្រះសង្ឃដូចលោកហ្នឹង បានទីពឹងព្រោះចន្ទ្រា
ចែងចាំងរស្មីថ្លា ឱ្យលោកាល្អពេកក្រៃ ។
⭑**ទីពីរ**ព្រះភគវា ប្រៀបដូចជាអាទិត្យថ្លៃ
រះឡើងនៅពេលថ្ងៃ មានរស្មីខ្លាំងមហិមា ។
ព្រះធម៌នៃព្រះអង្គ ផូរផង់ដូចអាភា
ចេញពីអាទិត្យថ្លា ដេញអន្ធការឱ្យខ្ចាត់ទៅ ។
ព្រះសង្ឃអង្គសាវ័ក មានសំវរៈល្អពេកកូវ
ដូចទ្វីបលោកដែលត្រូវ អាទិត្យក្តៅឱ្យភ្លឺថ្លា ។
⭑**ទីបី**ព្រះមុនី ឥតមានពីរក្នុងលោកា
ព្រះអង្គប្រៀបដូចជា អ្នកអុជភ្លើងឆួលដុតព្រៃ ។
រីអង្គព្រះធម្មា ប្រៀបដូចជាភ្លើងក្តៅក្រៃ

ដុតព្រៃស្មៅចង្រៃ ជាសត្រូវនឹងស្រូវស្រែ ។
ព្រះសង្ឃនោះឯងនៃ ឧបមេយ្យដូចដីស្រែ
ដែលម្ចាស់ខិតខំថែ ក្លាយជាស្រែដ៏ឧត្តម ។
⭐**ទីបួន**ព្រះភគវា ប្រៀបដូចជាភ្លៀងយ៉ាងធំ
ប្រយោជន៍ដ៏ឧត្តម តែងកើតមានដល់លោកា ។
ព្រះធម៌ព្រះទ្រង់ញាណ ដែលទ្រង់បានប្រោសទេសនា
ដូចដំណក់ទឹកថ្លា ស្រោចដណ្តប់លើផែនដី ។
សាវ័កអ្នកហ្មត់ចត់ ដូចជនបទពណ៌ខៀវខ្ចី
ដែលភ្លៀងទើបធ្លាក់ថ្មី គួរប្រុសស្រីទាក់នេត្រា ។
⭐**ទីប្រាំ**ព្រះសម្ពុទ្ធ ប្រសើរផុតជននានា
ព្រះអង្គប្រៀបដូចជា សារថីដ៏ចំណាប់ ។
រីឯព្រះធម៌ថ្លៃ ឧបមេយ្យដូចជាច្បាប់
ឧបាយជាគ្រឿងចាប់ បង្ហឹកសេះអាជានេយ្យ ។
ព្រះសង្ឃដ៏សោភា ប្រៀបដូចជាអាជានេយ្យ
ហ្វឹកហាត់ល្អប្រពៃ អាចលៃប្រើទាន់ចិន្តា ។
⭐**ប្រាំមួយ**នោះឯងនៃ ល្អពេកក្រៃព្រះសាស្តា
ព្រះអង្គប្រៀបដូចជា សល្យពេទ្យសម្រាប់ដកសរ ។
ព្រះធម៌នៃព្រះអង្គ មានបែបទ្រង់សែនបវរ
ដូចឧបាយដកសរ គឺទិដ្ឋិសត្វគ្រប់គ្នា ។
សង្ឃសាវ័កកល្យាណ លោកប្រៀបបាននឹងអ្នកណា
ដែលសរមុតកាយា ត្រូវគ្រូពេទ្យដកចេញបាន ។
⭐**ប្រាំពីរ**ព្រះសម្ពុទ្ធ បរិសុទ្ធប្រៀបស្មើបាន
ចក្ខុពេទ្យចំណាន ចេះឧបាយបកនេត្រា ។

ព្រះធម៌វិសេសថ្លៃ ឧបមេយ្យឧបាយា
បកភ្នែកជននានា ឱ្យភ្លឺថ្លាផុតជំងឺ ។
រីឯព្រះសង្ឃា ប្រៀបដូចជាអ្នកភ្នែកឈឺ
ត្រូវពេទ្យបកឱ្យភ្លឺ ចាកងងឹតគឺមោហា ។
✮**ប្រាំបី**ព្រះភគវន្ត អរហន្តជាសាស្តា
ព្រះអង្គប្រៀបដូចជា ពេទ្យមានប្រាជ្ញាឆ្លាតវៃ។
ព្រះធម៌ដ៏កល្យាណ ប្រៀបស្មើបានឱសថថ្លៃ
ដែលពេទ្យមានស្នាដៃ ច្នៃផ្សំត្រូវយ៉ាងចំណាន ។
ព្រះសង្ឃរតន៍ថ្លៃ ឧបមេយ្យអ្នកដែលបាន
សះស្បើយរោគសាមាន្យ គឺកិលេសគ្រប់ប្រការ ។
✮**ប្រាំបួន**ព្រះទ្រង់ញាណ ប្រៀបអ្នកបានស្គាល់មាគ៌ា
បង្ហាញសត្វគ្រប់គ្នា ឱ្យទៅរកទីផុតភ័យ ។
រីឯព្រះធម្មា ដែលសាស្តាទ្រង់លកលៃ
ត្រាស់ទុកដល់សព្វថ្ងៃ ឧបមេយ្យផ្លូវសុខា ។
ចំពោះព្រះសង្ឃរតន៍ បរិសុទ្ធឥតមាយា
ប្រៀបដូចប្រុសស្រីណា ដើរដល់ទីដែលក្សេមក្សាន្ត ។
✮**ទីដប់**ព្រះសាស្តា មានបញ្ញារុងរឿងថ្កាន
ប្រៀបដូចព្រៃហេមពាន្ត ពេញទៅដោយដើមរុក្ខា ។
ព្រះធម៌ដូចដើមថ្នាំ ដុះប្រចាំគ្រប់វេលា
គុណភាពល្អអស្ចារ្យ នៅក្នុងទីព្រៃហេមពាន្ត ។
ព្រះសង្ឃល្អសោភា ប្រៀបដូចជាអ្នកដែលបាន
ឱសថព្រៃហេមពាន្ត ផឹករួចហើយស្បើយរោគា ។
✮**ដប់មួយ**ព្រះមានជោគ ដូចនាយទូកក្នុងជលសា

តែងមានចិត្តករុណា ដល់សព្វសត្វក្នុងភពត្រៃ ។
ព្រះធម៌ពាក្យទូន្មាន ប្រៀបស្មើបានទូកចរណៃ
ចម្លងផុតលោកត្រៃ ឱ្យដល់ត្រើយបានសុខា ។
ព្រះសង្ឃដ៏និមល ដូចអ្នកដល់ត្រើយហើយណា
ត្រើយនោះមានឈ្មោះថា ព្រះនិព្វានសែនសុខក្រៃ ។
☆**ដប់ពីរ**ព្រះភគវា ជាសាស្តាបញ្ញាវៃ
ព្រះអង្គឧបមេយ្យ អ្នកឱ្យទ្រព្យគាប់ចិន្តា
ព្រះធម៌ទាំងប៉ុន្មាន ប្រៀបស្មើបានទ្រព្យនោះណា។
ដែលជនផងនានា តែងប្រាថ្នារៀងរាល់ថ្ងៃ ។
សង្ឃសាវ័កកល្យាណ ដូចអ្នកបានចាយទ្រព្យថ្លៃ
គុណភាពល្អពេកក្រៃ ចាយរួចបានសុខគួរគាប់ ។
☆**ដប់បី**ព្រះនិរភ័យ ឧបមេយ្យអ្នកមានភ័ព្វ
បង្ហាញរណ្តៅទ្រព្យ ឱ្យដល់អ្នកដែលត្រូវការ ។
ព្រះធម៌ពាក្យប្រដៅ ដូចរណ្តៅទ្រព្យនោះណា
ពេញដោយទ្រព្យនានា មានតម្លៃហួសការស្មាន ។
ព្រះសង្ឃអ្នកស្តាប់ទ្រង់ ផ្សរផង់រុងរឿងថ្កាន
ប្រៀបដូចជាអ្នកបាន រណ្តៅទ្រព្យរីករាយក្រៃ ។
☆**ដប់បួន**ព្រះចមភព ល្អសព្វគ្រប់គ្មានទោសពៃរ៍
ព្រះអង្គប្រសើរក្រៃ ដូចជាវីរៈបុរស ។
ព្រះធម៌ពាក្យបង្រៀន ប្រៀបស្មើបានក្តីផុតគ្រោះ
ក្សេមក្សាន្តឥតមានមោះ មានតែសុខគ្រប់ប្រការ ។
ព្រះសង្ឃដ៏សមទ្រង់ វិសុទ្ធិវង្សចិញ្ចែងថ្លា
ដូចអ្នកបានសុខា ដោយសារវីរៈបុរស ។

☆**ដប់ប្រាំ**ព្រះសម្ពុទ្ធ    បរិសុទ្ធសមទាំងអស់
ប្រៀបដូចជាសប្បុរស    អ្នកលួងលោមឱ្យបានស្បើយ។
រីព្រះសទ្ធម្មា    ប្រៀបដូចការលួងនោះហើយ
លួងលោមឱ្យបានល្ហើយ    ស្បើយក្តីសោករោគចង្រៃ ។
ព្រះសង្ឃសាវ័កពុទ្ធ    ដូចអ្នកផុតរួចចាកភ័យ
ឧបទ្រពកំណាចក្រៃ    ព្រោះស្នាដៃនៃព្រះអង្គ ។
☆**ដប់ប្រាំមួយ**នោះណា    ព្រះសាស្តាវិសុទ្ធិវង្ស
ព្រះទ័យស្អាតសោះត្រង់    ប្រៀបប្រដូចនឹងមិត្តល្អ ។
រីឯពាក្យទេសនា    រចនាជាបទធម៌
ដូចពាក្យមិត្តបវរ    ប្រាប់ប្រយោជន៍ដល់មិត្តភ្វា ។
ព្រះសង្ឃឧត្តមពិត    អ្នកនៃបនិត្យព្រះធម្មា
ប្រៀបដូចនឹងអ្នកណា    បានប្រយោជន៍គាប់ហឫទ័យ។
☆**ដប់ប្រាំពីរ**ព្រះនិរទុក្ខ    ល្អគ្រប់មុខហួសវិស័យ
ព្រះអង្គឧបមេយ្យ    បឹងកើតទ្រព្យច្រើនប្រការ ។
ព្រះធម៌ល្អគួរគាប់    ដូចជាទ្រព្យមានខ្លឹមសារ
កើតក្នុងបឹងនោះណា    ជនត្រូវការកើបយកបាន ។
ព្រះសង្ឃស្វាមីភ័ក្តិ    ប្រៀបដូចអ្នកសំណាងមាន
ជួបទ្រព្យបឹងកល្យាណ    រមែងបានក្តីរីករាយ ។
☆**ដប់ប្រាំបី**ព្រះសុគត    ល្អវិសុទ្ធិមិនទន់ជ្រាយ
ប្រៀបធៀបអធិប្បាយ    អ្នកភ្ជួតទឹករាជកុមារ ។
បណ្តាំនៃព្រះអង្គ    សមបែបទ្រង់គ្រប់ប្រការ
ប្រៀបដូចនឹងទឹកថ្លា    សម្រាប់ងូតជម្រះកាយ ។
ព្រះសង្ឃប្រៀបដូចជា    រាជកុមារបានសប្បាយ

ដូតទឹកត្រជាក់សាយ ជ្រះអស់ក្អែលពីកាយា ។
☆ **ដប់ប្រាំបួន** ព្រះជិនស្រី មានសិរីឈ្នះក្រុងមារ
ព្រះអង្គប្រៀបដូចជា អ្នកធ្វើគ្រឿងប្រដាប់កាយ ។
ព្រះធម៌ពាក្យបណ្ដាំ ពីរពាន់ប្រាំរយឆ្នាំថ្លាយ
ដូចគ្រឿងប្រដាប់កាយ ពេញនិយមគ្រប់វេលា ។
សាវ័កព្រះទ្រង់ញាណ ដែលលោកបានស្ដាប់ទេសនា
ដូចអ្នកល្អសោភា ព្រោះអលង្ការធម្មក្ខន្ធ ។
☆ **ទីម្ភៃ** នោះឯងណា ឧបមាព្រះភគវន្ត
ដូចគ្មានឹងដើមចន្ទន៍ ប្រកបក្លិនមានតម្លៃ ។
រីឯព្រះសទ្ធម្ម ដ៏ឧត្ដមសមប្រពៃ
ដូចក្លិនចន្ទន៍ចរណៃ ដែលប្រុសស្រីគួចប្រាថ្នា ។
សាវ័កអ្នកស្មោះត្រង់ អ្នកទ្រទ្រង់សីលសិក្ខា
ដូចជានរណា ស្រង់ក្លិនចន្ទន៍ឈ្ងុយពេកពិត។
☆ **ម្ភៃមួយ** ព្រះបិតា ជាសាស្ដាទ្រង់មានឫទ្ធិ
ដូចផ្ដល់ទឹកអម្រឹត ដល់កូនស្នួនទាំងប្រុសស្រី ។
រីព្រះសទ្ធម្មណា ដែលសាស្ដាពោលស្រដី
ទេសនាយ៉ាងឃ្មាតខ្មី ប្រៀបដូចទឹកអម្រឹតហ្នឹង ។
ព្រះសង្ឃប្រៀបដូចជា អ្នកកំព្រាតតទីពឹង
បានទឹកអម្រឹតហ្នឹង មានពំនឹងរួចមកណា ។
☆ **ម្ភៃពីរ** ព្រះគោតម ដូចបទុមក្នុងជលសា
សូរ្យសែងរះកាលណា រីកសាខាស្រស់ឆើតឆាយ ។
ព្រះធម៌ប្រៀបដូចជា ទឹកដមផ្កាឈូកទាំងឡាយ
គួរស្រូបតតជិននាយ មាននៅក្នុងបទុមផ្កា ។

ព្រះសង្ឃអង្គសាវ័ក អ្នកជឿជាក់ត្រៃសិក្ខា
ប្រដូចនឹងភូមរា បានក្រេបផ្កាក្នុងវារី ។
✯ឧបមាគុណត្រៃរតន៍ មានប្រាកដម្តេពីរ
ដែលខ្ញុំខំសម្តី សូត្រវន្ទីយ៍នមស្ការ ។
សូមឱ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

ដោយភិក្ខុ វជិរប្បញ្ញោ សាន សុជា

## ពុទ្ធកិច្ច ៥ យ៉ាង

គ្រាកាលព្រះសម្ពុទ្ធ ប្រសើរបំផុតដ៏ឧត្តម
បានត្រាស់ជាបឋម សែសិបប្រាំព្រះវស្សា ។
បំពេញពុទ្ធកិច្ច មិនដែលដាច់វេលាណា
សន្មតឈ្មោះហៅថា ពុទ្ធក្រឹត្យាមានប្រាំយ៉ាង ។
**ទី ១** គឺពេលព្រឹក ដ៏ពន្លឹកពន្លឺស្វាង
ព្រះអង្គស្តេចទ្រង់យាង ចេញបិណ្ឌបាតប្រោសសព្វសត្វ ។
**ទី ២** រសៀលជ្រេ ព្រះសុរិយេពេលទៀបស្ងាត់
ទេសនាប្រោសសព្វសត្វ មិនកំណត់ថាសត្វណា ។
**ទី ៣** ពេលព្រលប់ ព្រះចមភពត្រៃលោកា
ប្រទានធម៌ទេសនា ឱ្យឱវាទភិក្ខុសង្ឃ ។
**ទី ៤** ពេលអធ្រាត្រ ព្រះលោកនាថទ្រង់ផ្ចិតផ្ចង់
ព្រះទ័យល្អស្មោះត្រង់ ទ្រង់ដោះស្រាយនូវប្រស្នា ។
ផ្សេងៗកើតឡើងពិត នៅក្នុងចិត្តនៃទេវតា

រឿងឆ្ងល់ធម៌ត្រង់ណា ព្រះសាស្ដាទ្រង់អារកាត់ ។
**ទី ៥** ពេលទៀបភ្លឺ ប្រមើលមើលនិស្ស័យសត្វ
នៅក្នុងសង្សារវដ្ដ ឱ្យប្រាកដគួរសន្ដោស ។
សត្វណាមានសំណាង ព្រះអង្គយាងចេញទៅប្រោស
ប្រទានធម៌ទាបខ្ពស់ ឱ្យទៅតាមឧបនិស្ស័យ ។
ធម៌នេះឈ្មោះហៅថា ពុទ្ធក្រឹត្យាប្រសើរក្រៃ
វិជ្ជាទិវថ្លៃ នៃព្រះពុទ្ធពីបុរាណ ។
បំពេញឥតនឿយណាយ រៀងរាល់ថ្ងៃមិនដែលខាន
លុះចូលព្រះនិព្វាន ទើបឈប់ខានទាំងអស់ហោង ។
ហៃសាធុជនណា អ្នកប្រាថ្នានឹងប៉ុនប៉ង
ចង់ឃ្លាតពីចំណង ត្រៃលោកនេះពិតប្រាកដ ។
ត្រូវខំរៀនសិក្សា នូវធម៌អាថ៌ដែលជាបទ
ពុទ្ធកិច្ចប្រាំប្រាកដ នេះកំណត់គួរយល់ដឹង ។
ជននោះនឹងស្មើបាន នឹងនាឋានជាទីពឹង
ឬនៅនាលោកហ្នឹង នឹងបានខ្លួនជាអ្នកធំ ។
លើសជនផងទាំងឡាយ សុខសប្បាយដ៏ឧត្ដម
ក្សេមក្សាន្តសុខមនោរម្យ រៀងរួចដល់និព្វានហោង ៕

## រក្សាព្រះត្រៃបិដក

សិក្សាបិដកមត៌កព្រះ មានជ័យជំនះឈ្នះមោហា
គឺជាកុសលផ្ដល់បញ្ញា ឆ្លងវដ្ដសង្សារឆ្ពោះនិព្វាន ។
ដូច្នេះយើងត្រូវថែរក្សា បិដកថ្លៃថ្លាជាធម្មទាន
ព្រះធម្មចេតិយប្រាជ្ញាញាណ សាស្ដាត្រូវមានយើងត្រូវប្រឹង ។
រក្សាបិដកមានគុណក្រៃ លកលៃបែងចែកញែកឱ្យដឹង

ប្រាំពីរប្រការគិតសញ្ជឹង　　ល្អម្លឹងប្រឹងថែខ្មែរមានធម៌ ។
**មួយ** គឺ រក្សាព្រះសាសនា　　មរតកអស្ចារ្យជាពុទ្ធពរ
ពាក្យពិតពាក្យពុទ្ធសុទ្ធបវរ　　ចេតិយព្រះធម៌ វិ.សុ.អ.។
**ពីរ** គឺរក្សាព្រះសាស្តា　　វិន័យធម៌អាថ៌ចារទុកដាក់
ឋិតនៅជាគ្រូដ៏សមសក្តិ　　ប្រចក្សធម្មាជាសាស្តា ។
**បី** គឺរក្សាការងារសង្ឃ　　ទ្រទ្រង់តម្រង់ព្រះសាសនា
សង្គាយនាធម៌វិន័យណា　　ត្រាស់អស់វស្សាសែសិបប្រាំ ។
**បួន** គឺរក្សាគុណសម្បត្តិ　　នៃពុទ្ធបរិស័ទចាត់ជាឆ្នាំ
ព្រះធម៌វិន័យព្រះអង្គផ្តាំ　　ឋិតច្រើនពាន់ឆ្នាំព្រោះបរិស័ទ ។
**ប្រាំ** គឺរក្សាត្រៃសទ្ធម្ម　　បរិយត្តិនាំចំបដិបត្តិ
បដិវេធៈជាក់កម្ចាត់　　កិលេសបង់បាត់នៅស្ងាត់សន្តាន ។
**ប្រាំមួយ** រក្សាត្រៃរតនៈ　　ឋិតនៅប្រចក្សសរណដ្ឋាន
ព្រះពុទ្ធព្រះធម៌នាំសុខសាន្ត　　ព្រះសង្ឃកល្យាណមានវិន័យ។
**ប្រាំពីរ** រក្សាត្រៃសិក្ខា　　សាសនាចារជាប់ដួងហឫទ័យ
សីលសមាធិធម៌ប្រពៃ　　ផុតភ័យអាស្រ័យដោយបញ្ញា ។
ព្រះត្រៃបិដកមានប្រវត្តិ　　រឿងរ៉ាវបានកត់ចារអក្ខរា
អរិយធម៌វប្បធម៌មនុស្សទេវតា　　បុព្វេយ៉ាងណាចារឱ្យដឹង ។
បិដកជាច្បាប់ប្រាប់ភពត្រៃ　　អ្នកមាននិស្ស័យលៃលកប្រឹង
សិក្សាបដិបត្តិកម្ចាត់ខឹង　　ជញ្ជឹងសម្លឹងដឹងត្រៃលក្ខណ៍ ។
បិដកច្បាប់ដើមព្រះសាសនា　　បាលីអក្ខរាសាស្តាជាក់
បដិបត្តិបូជាធានាមគ្គ　　កំណត់ត្រៃលក្ខណ៍លាត្រៃលោក។
កសាងចេតិយបិដកខ្មែរ　　យើងនាំគ្នាហែព្រះមានជោគ
សាធុ ! សាធុ ! ផុតចាករោគ　　សាធុផុតលោកអនុមោទនា៕

# ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃ ជាទីពឹងទីរលឹក ។ ខ្ញុំព្រះករុណាសូមក្រាបនមស្ការបូជាព្រះគុណនៃអង្គព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ពេញពោរទៅដោយព្រះមេត្តាករុណារកប្រមាណមិនបាន ។ ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាងក្នុងការសន្សំព្រះបារមីដើម្បីត្រាស់ដឹង ហើយប្រកាសធម៌នាំវេនេយ្យសត្វចេញចាកពី  វដ្តៈ។ ខ្ញុំព្រះករុណាបូជាព្រះពុទ្ធចេតិយដោយសេចក្តីជ្រះថ្លាដ៏ក្រៃលែង សូមតាំងសច្ចាធិដ្ឋាន ដោយផលានិសង្សនៃបុណ្យដែលខ្ញុំព្រះករុណាបានធ្វើក្នុងថ្ងៃនេះ សូមជាបច្ច័យឱ្យបានសម្រេចដូចក្តីប្រាថ្នា ។ អង្គ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ធម៌យ៉ាងណា សូមឱ្យខ្ញុំព្រះករុណាមានចំណែកនៃធម៌របស់ព្រះអង្គក្នុងកាលដ៏សមគួរផងចុះ ។ ទោះបីកើតក្នុងភពជាតិណាៗ សូមកើតនៅក្រោមម្លប់នៃបវរព្រះពុទ្ធសាសនាកណ្តាលកល្យាណមិត្តបានសេពគប់នឹងសប្បុរសដែលជាអ្នកដឹងនូវធម៌ដ៏ប្រសើរ សូមជាបុគ្គលសម្មាទិដ្ឋិ មានឱកាសសិក្សាធម៌ ស្តាប់ធម៌ ប្រព្រឹត្តធម៌ ដែលជាបច្ច័យឱ្យចម្រើនទៅដោយសតិនឹងបញ្ញា បញ្ជូនតទៅគ្រប់ជាតិ រហូតដល់ព្រះនិព្វានហោង ៕

# បណាមគាថា

អរហន្តតថាគត ជ្រាបគ្រប់បទស្វែងគុណធំ
ទ្រង់ជាលោកុត្តម ច្បងជាងសព្វគ្រូលើសលន់ ។
ជាសាស្តានៃលោក ចេះឥតស្មោកទូន្មានជន
ខ្ញុំវន្ទាបន្ទន់ ទ្រង់ដែលជនគួរបូជា ។
ព្រះធម៌នៃសាស្តា ឧបមាដូចពន្លឺ
តែងធ្វើលោកឲ្យភ្លឺ ចាក់ងងឹតឲ្យសូន្យផុត ។
ដែលប្រាជ្ញសម្គាល់អាង ថាតំណាងសព្វញ្ញូពុទ្ធ
ខ្ញុំវន្ទាលំអុត ធម៌នោះសុទ្ធបូជា ។
សាវ័កព្រះសុគត ស្អាតហ្មត់ចត់វិសេសថ្លា
ប្រាជ្ញាត្រៃសិក្ខា លោកសិក្សាធម៌ឧត្តម ។
ជាសង្ឃថ្នាក់ខាងលើ មិនអើពើលោកធម្ម
ខ្ញុំវន្ទាប្រណម្យ សង្ឃឧត្តមជនបូជា ។
ដោយអំណាចវន្ទា ត្រៃរតនាជាអម្ចាស់
សូមឲ្យពុទ្ធសាសន៍ លូតលាស់ក្រាស់ចម្រើនផង។
សូមឲ្យសង្ឃព្រមព្រៀង កុំឲ្យល្មៀងខុសគន្លង
សូមសាធុជនផង កុំមានហ្មងបានសុខសាន្ត ។
ដោយតេជះត្រៃរតន៍ ខ្ញុំប្រតិបត្តិដោយគោរព
សូមឲ្យការរៀនគ្រប់ របស់ខ្ញុំបានវឌ្ឍនា ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទា
សូមឲ្យការសិក្សា របស់ខ្ញុំបានសម្រេចឆាប់ ។
ដោយអំណាចត្រៃរតន៍ មានពុទ្ធរតន៍ជាប្រធាន

ប្រសិនបើកើតមាន អន្តធានចង្រៃរោគ ។
សូមឲ្យវិនាសខ្ចោក កុំសល់រោគតិចតួចឡើយ ។

## សុខាភិយាចនគាថា

ព្រះពុទ្ធដូចអាទិត្យ ឧត្តមពិតជាងពួកជន
កម្ចាត់នូវមោហន្ធ ហើយចេញចាកសព្វកិលេស។
ទ្រង់ស្ថិតនៅលើភ្នំ ដ៏ឧត្តមមគ្គវិសេស
ដាស់សត្វជាប់កិលេស ឲ្យភ្លឺថ្លៃសក្នុងលោកា ។
សូមទ្រង់ប្រោសគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។
ស្វាក្ខាតធម៌ណា ផ្ដូរផងថ្លាគ្មានសៅហ្មង
ជាធម៌ដែលអ្នកផង ឃើញច្បាស់ពិតដោយខ្លួនឯង។
ធ្វើនូវសន្តិភាព ធុរភាពដ៏ចិញ្ចែង
គួរបូជាយ៉ាងស្មែង ធ្វើនិព្វានឲ្យសុខា ។
សូមធម៌នោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។
រីព្រះអរិយសង្ឃ ជាបុត្រអង្គព្រះសម្ពុទ្ធ
លោកស្អាតបរិសុទ្ធ ងាយចិញ្ចឹមរៀងរាល់ផ្ទះ ។
ចិញ្ចឹមដោយអាត្មា កិលេសាលះស្រឡះ
សង្គ្រាមក៏លោកលះ ជ្រះស្រឡះបានក្សេមក្សាន្ត ។
ជាអ្នកស្ដាប់ឱវាទ ដែលលោកនាថទ្រង់ទូន្មាន
ជាសាវ័កកល្យាណ ស្រែបុណ្យទាននៃជននា ។
សូមសង្ឃនោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

**សេចក្តីត្រិះរិះរបស់នាងវិសាខា**

សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានថ្វាយទាន
នូវប្រាសាទថ្មីតាមទ្រព្យដែលមាន ជាវិហារទានចំពោះព្រះសង្ឃ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានឱនអង្គ
ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់ ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានថ្វាយភត្ត
ផ្សំដោយមំសៈធ្វើដោយហ្មត់ចត់ សលាកភត្តជាអាហារទាន ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបព្រះទ្រង់ញាណ
ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន ថ្វាយចីវរទានសំពត់សាច់ល្អ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបសង្ឃបវរ
ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ ទឹកដោះគោល្អនិងទឹកអំពៅ។
មកដល់ឥឡូវខ្ញុំបានសម្រេច គ្រប់មុខស្រេចបាច់ឥតមានសល់នៅ
ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ ក្នុងដំណើរទៅកាន់ព្រះនិព្វាន។៚

# ៦៧,គុណរបស់ទាន

• **ទាន**ចិញ្ចឹមបុត្របរិសុទ្ធក្នុងផ្ទៃ រហូតដល់ថ្ងៃបុត្រថ្លៃចាកគភ៌
**ទាន**ចិញ្ចឹមស្មោះទឹកដោះបបរ កូនរស់បានល្អព្រោះធម៌សប្បុរស។
• **ទាន**ថ្វាយដល់សង្ឃផ្ចង់ឧទ្ទិសទាន ប្រេតរួចពីឃ្លានព្រោះទានរំដោះ
**ទាន**ជាទេវធម៌លម្អសប្បុរស ទានមានចិត្តស្មោះសង្គ្រោះជីវិត។
• **ទាន**គឺជាទ្រព្យជាប់តាមសង្ខារ ជាមិត្តរួមប្រាណឆ្លងភពងងឹត
**ទាន**កាច់បំបាក់មោហៈក្នុងចិត្ត បានត្រាស់ដឹងពិតត្បិតទានបារមី។
• ហៃកូនប្រុសស្រីគប្បីចាំទុក គុណម្តាយឪពុកទានាធិបតី

កូនដឹងមង្គលសាមសិបប្រាំបី ចៀសកម្មអប្រីយ៍ផុតភ័យអបាយ។

*លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស*

## នមស្ការព្រះរតនត្រៃ

សូមឱ្យសាសនាព្រះសម្ពុទ្ធ រុងរឿងបំផុតអស់កាលយូរ
សូមព្រះសទ្ធម្មព្រះបរមគ្រូ ស្ថិតស្ថេរនៅយូរគ្រប់ប្រាំពាន់
សូមឱ្យព្រះពុទ្ធសាសនា រុងរឿងចម្រើន
សូមឱ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសាកលលោក
សូមឱ្យលោកទាំងមូល បានប្រកបដោយសន្តិភាព
ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ**
ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ៕

# កំណាព្យអប់រំផ្សេងៗ

**វត្តស្វាយដង្គុំអ្នកមានគុណខ្ញុំ**

វត្តស្វាយដង្គុំ សង្ឃរស់ជួបជុំ ប្រឹងប្រែងសិក្សា
អប់រំយប់ថ្ងៃ តាមព្រះវាចា ទ្រង់ទូន្មានថា
សិក្សាបដិបត្តិ។

វត្តស្វាយដង្គុំ គ្រូតែងអប់រំ ឱ្យប្រុងប្រយ័ត្ន
មិនត្រូវប្រមាទ ក្នុងការបដិបត្តិ បាបត្រូវលះកាត់
ចម្រើនកុសល។

វត្តស្វាយដង្គុំ បវរសុខុម កន្លែងសិក្សា
សង្គ្រោះអ្នកក្រ បន្តសិក្ខា គ្រប់រូបអាត្មា
នឹងបានភ្លឺស្វាង។

ភិក្ខុសាមណេរ ខំប្រឹងខ្នន់ខ្នេរ ក្រោកព្រឹកស្រាង
ក្រេបយកវិជ្ជា ឱ្យបានភ្លឺស្វាង បរិស័ទសំណាង
សាងបុណ្យកុសល។

វត្តស្វាយដង្គុំ សមណៈអប់រំ លះកាត់កង្វល់
លះអំពើបាប ខំសាងកុសល មិនមានកង្វល់
ចិត្តស្ងប់ជួបសុខ។

បួសហើយត្រូវរៀន មិនត្រូវបំពាន ព្រោះចង់ស្រណុក
ធ្វើអំពើបាប មានភ័យទៅមុខ បើចង់បានសុខ
ត្រូវអប់រំខ្លួន។

សាលាពុទ្ធិកបឋមសិក្សាវត្តស្វាយដង្គំ ខេត្តបាត់ដំបង

| | | |
|---|---|---|
| វត្តស្វាយដង្គំ | ធ្វើឱ្យរូបខ្ញុំ | ដឹងខុសកែខ្លួន |
| កន្លែងអប់រំ | ដ៏ល្អសមសួន | ប្រឹងរៀនកែខ្លួន |

ក្លាយជាមនុស្សល្អ។

| | | |
|---|---|---|
| វត្តស្វាយដង្គំ | បណ្តុះធនធាន | ឱ្យសង្ឃបានរៀន |
| ឱ្យស្គាល់ខ្មៅស | នាយកសាលា | កែសិស្សឱ្យល្អ |

បូជាឈាមជ័រដើម្បីសាសនា។ *ដោយស៊ាក់ស៊ីន*

# ក្មេងវត្ត

ហៃពួកយុវជនអ្នកកម្សត់ បើកុំបានវត្តជ្រកអាស្រ័យ
សមអ្នកនឹងឥតមានតម្លៃ យប់ថ្ងៃហួសទៅឥតមានប្រយោជន៍។
គួរអ្នកកុំភ្លេចវត្តលំនៅ ទោះអ្នកចេញទៅឆ្ងាយស្រទ្បោច
គួរដឹងគុណវត្តកុំបង្ហោច ប្រយោជន៍និងផលផ្តល់ពុំខាន។
បើមានគេសួរពីកាលរៀន ចំណេះរបៀនទាំងប៉ុន្មាន
អ្នកកុំនិយាយបង្វែរដាន ត្រូវប្រាប់ថាបានចេះព្រោះវត្ត។
កុំពោលបង្អួតពួកស្រីៗ ត្រូវស្តីតាមត្រង់កុំបំភ្លាត់
បំផ្លែងបំផ្លើសបំភ្លេចវត្ត ក្រែងទោសទាញទាត់ឲ្យវិនាស។
បាយវត្តជាភោជន៍មានព្រលឹង គួរគិតរំពឹងកុំទីសទាស
នាម៉ឺនមន្ត្រីកើតពីរាស្ត្រ គឺរាស្ត្រឡើងទៅជាមន្ត្រី។
បាយផ្ទះបាយវត្តដូចជាគ្នា ចម្អែតអាត្មាមានជីវី
ឆ្អែតហើយរៀនសូត្រចេះខ្ជួចខ្ជី មុនីកើតមានដោយសារវត្ត
សាធុសូមឱ្យអ្នកបានសុខ និរទុក្ខនិរភ័យសិរីភ័ទ្រ
ជាជនសប្បុរសរបស់រដ្ឋ មានបែបមានបទប្រសើរហោង។

**ព្រះរាជនិពន្ធដោយសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត )៕**

# ឈាមអ្នកម្តាយថ្លៃ

ជីវិតកូនថ្លៃ រស់ដល់សព្វថ្ងៃ ព្រោះបឺតឈាមម៉ែ
កូនបឺជញ្ជក់ ច្រើនថ្ងៃច្រើនខែ បឺឈាមនាក់ម៉ែ
កូនប្រែធំធាត់។

ម៉ែលះបង់ឈាម ដូចធ្វើសង្គ្រាម ឈាមម៉ែហូរខ្សោះ
ឱ្យកូនបានធំ គ្មានស្តាយស្រណោះ បឺឈាមម៉ែចុះ
ណាកូនមាសម្តាយ។

ជីវិតកូនថ្លៃ ទោះម៉ែក្សិណក្ស័យ ក៏ម៉ែមិនណាយ
ឃើញកូនបានសុខ ម៉ែក៏សប្បាយ ទុក្ខសោកទាំងឡាយ
រសាយបាត់អស់។

ឈាមអ្នកម្តាយថ្លៃ សែនមានតម្លៃ ឈាមម្តាយស្រស់ៗ
កូនបឺតពេញពោះ សូមកូនរស់ចុះ កុំបាច់ស្រណោះ
គិតពីម្តាយឡើយ។

ដៃជើងទាំងឡាយ មុខមាត់រាងកាយ ដែលម្តាយឱ្យហើយ
ដែលកើតពីឈាម ម្តាយណាត្រាណត្រើយ កូនបានធំហើយ
កុំធ្វើបាបម៉ែ។

កូនខ្លះចង្រៃ រស់ដល់សព្វថ្ងៃ ព្រោះតែឈាមម៉ែ
យកជើងយកដៃ ដែលម្តាយខំថៃ វាយតប់លើម៉ែ
ឱ្យគាត់ឈឺចាប់។

កូនខ្លះថ្លើមធំ រស់បានសុខុម វាហ៊ានសម្លាប់
នាក់ម្តាយឱ្យក្ស័យ ឱ្យម្តាយឈឺចាប់ កូនហ៊ានសម្លាប់
នាក់ម្តាយខ្លួនឯង។

កូនខ្លះបានធំ ប្រើពាក្យដូចភ្នំ ទៅលើម្តាយឯង

ឱ្យគាត់ឈឺចាប់ ទ្រូងសែនចំបែង មើលងាយម្ដាយឯង
អាងខ្លួនចេះជាង។

អាងម្ដាយមិនចេះ ខ្លួនមានចំណេះ កូនប្រែលំអៀង
សំលុតស្ដីថា អ្នកម្ដាយឱ្យរៀង ម៉ែឯងល្ងង់ជាង
កុំចេះប្រដៅខ្ញុំ។

ប្រើពាក្យអាក្រក់ កូនប្រឹងសម្លក់ ពេលម្ដាយអប់រំ
វាស្រែកសន្ធាប់ គ្មានក្លាចម្ដាយយំ ពាក្យមិនសមរម្យ
ស្ដីថាឱ្យម្ដាយ។

ម្ដាយសែនឈឺ កូនប្រែជាយាប់ ព្រោះកូនសប្បាយ
កូនចេះរកលុយ ភ្លេចអស់គុណម្ដាយ អាងប្រាក់កូនក្លាយ
ហ៊ានមើលងាយម៉ែ។

មាត់កូនប្រុសស្រី ម្ដាយធ្លាប់ប៉ប៊ី អង្វៃលមើលថៃ
កូនយកមាត់នោះ ជេរស្ដីដាក់ម៉ែ ម៉ែយំឥតល្ហែ
ព្រោះតែកូននោះ។

ជាមួយម្ដាយឯង កូនប្រឹងសម្ដែង គ្មានពាក្យល្អសោះ
មិត្តភ័ក្រកូនវិញ ផ្អែមល្ហែមឥតខ្ចោះ សម្ដីពីរោះ
គួរឱ្យសុតា។

មួយជីវិតម៉ែ ទោះទុក្ខឥតល្ហែ នៅតែប្រាថ្នា
សូមកូនបានសុខ ផុតពីទុក្ខា ឱ្យកូនមាតា
ឆាប់ភ្ញាក់ខ្លួនឡើង

ទោះអ្នកចេះដឹង ចេះខ្លាំងដល់ម្ល៉ឹង បានខ្ពស់ថ្កុំថ្កើង
តែបែមើលងាយ លុបគុណម្ដាយយើង ទោសនឹងកើតឡើង
ព្រោះងាយម្ដាយ។ *ដោយលោកគ្រូ ស៊ាក់ ស៊ីន*

# កំណាព្យផ្តើមពេលទេសនា

**សទ្ទហានោ អរហត្តំ ធម្មំ និព្វាន បត្តិយា សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខនោ។**

អ្នកដែលជឿធម៌ព្រះអរហន្តហើយ ធម៌នាំដល់ត្រើយគឺព្រះនិព្វាន
ទាំងមិនប្រមាទឱ្យខាតសីលទាន ធ្វើអ្វីក៏មានការពិចារណា
ជាអ្នកស្តាប់ធម៌គោរពដោយល្អ មិនធ្វើមាត់កមិនពោលចចា
មិនធ្វើរំខានពេលស្តាប់ទេសនា តែងបានបញ្ញាភ្លឺថ្លាដោយពិត
សូមពុទ្ធបរិស័ទអ្នកស្តាត់រកធម៌ ស្តាប់ឱ្យបានល្អយកជាគំនិត
ទុកជាមេរៀនសម្រាប់ជីវិត កុំឱ្យងងឹតលង់លក់មរណា៕

## សុភាសិត

កុំធ្វើជាមនុស្សត្រចៀកស្រាល
មិនត្រូវសប្បាយហើយភ្លេចខ្លួន
ទាំងកុំអំនួតអួតផ្ទួនៗ
កុំគិតថាខ្លួនឯងអស្ចារ្យ
មិនត្រូវមើលងាយអ្នកដទៃ
ពេលធ្វើអ្វីៗពិចារណា
ត្រូវយកខ្លួនឯងជាឧបមា
មនុស្សគ្រប់រូបាប្រាថ្នាសុខ៕

(ដោយសាមណេរ ស៊ាក់ ស៊ីន)

# គ្រូនិងសិស្ស

គ្រូថាសិស្សប្រឹង		គ្រូតឹងសិស្សចេះ
គ្រូណាប្រហែស		សិស្សតែងមន្ទិល
គ្រូជេរប្រដៅ		សិស្សបែរមិល
គ្រូកែសិស្សខ្ជិល		ឫកដូចដុំថ្ម។
ពេលសិស្សពូកែ		ថាមកពីពូជ
ដល់សិស្សប្រែខូច		ថាគ្រូមិនល្អ
ទំនើងគ្រូស្ទើរ		លើកដៃអង្វរ
គ្រូទ្រាំដល់ក		ចាប់ប្រើធម៌ក្តៅ

## ក្រមសីលធម៌គ្រូបង្រៀន

គោរពពេលវេលា		សម្លៀកបំពាក់សមរម្យ
មានអាកប្បកិរិយាសមរម្យ		មានយុត្តិធម៌មិនលំអៀង
មានវិធីសាស្ត្រល្អក្នុងការបង្រៀន		មានចំណេះដឹងទូលំទូលាយ
មានមនសិការវិជ្ជាជីវៈនិងការងារ		មានព្រហ្មវិហារធម៌
វៀរចាកអំពើអបាយមុខ		ធ្វើគំរូល្អសម្រាប់មហាជនទូទៅ

## អារាមធាត់វត្តស្គម

១, អារាមរីកធំជុំរបង		វិហារកុដិផងចងសួនច្បារ
ក្លោងទ្វារសង់ថ្មីច្នៃរចនា		ក្បូរក្បាច់លាយផ្កាសង្ហាគន់ ។
២មហាកុដិថ្មីលៃឲ្យអស់		កុឲ្យចាញ់ឈ្មោះផ្កាយបីបួន
រាប់ជាន់ឡើងលើធ្វើសមសួន		ពួនពាក់សង្ហារិមថ្មី ៗ ។
៣,មើលពីខាងក្រៅហៅគាប់ចិត្ត		អារាមដូចផ្សិតរីកស្គីមស្ដែ
វិហារថ្មធំល្អឥតបី		បរិស័ទចាស់ថ្មីកើតជ្រះថ្លា ។

៤,ចាយប្រាក់រាប់កោដិផ្តោតតែសង់ ឥដ្ឋក្បឿងស៊ីម៉ង់ត៍កុដិសាលា
សួនច្បារខ្លោងទ្វារគាប់នេត្រា ចោលវត្តសិក្ខាគ្មានអ្នកខ្វល់ ។
៥, បរិស័ទក្រៅក្នុងលង់គំនិត លែងព្រួយឈប់គិតមិនខ្វីយល់
សាងវត្តយកឈ្មោះមិនអែកអល់ តម្កល់ទុកកេរ្តិ៍ឲ្យគេស្ញើច ។
៦, អារាមគ្រប់វត្តធាត់ស្ទើរប្រេះ ឯរឿងចំណេះបែរស្គមខើច
ពោលរឿងរៀនសូត្រគេលួចសើច ស្ញើចតែរឿងធ្វើកុដិសាលា ។
៧,ហែមចៀវហួតតាតជូនណាតសម័យ អ្នកប្រាជ្ញពេញដីដែនខមរា
ព្រោះគេខ្វល់ខ្វាយរឿងសិក្សា ជាងកុដិសាលាវិហារថ្ម ។
៨, ធមធានសម្បត្តិទ្រព្យវិជ្ជា គួរជនគ្រប់គ្នាជួយបន្ត
កុំគិតតែកុដិវិហារល្អ ចោលវត្តបរវចោលសិក្សា ៕

**រស់ព្រោះរៀនសូត្រ**

**ក** កាន់សៀវភៅទៅសាលា **ខ** ខំសិក្សាគ្រប់មេរៀន
**គ** គួរជៀសវាងអំពើព្រាន **ឃ** ឃើញគឿងញៀនដូចលាមក
**ង** ងាកមុខចេញពីវង់ល្បែង **ច** ចេះចាត់ចែងកុំទ្រមក់
**ឆ** ឆាប់រួសរាន់កុំទាន់ងក់ **ជ** ជៀសកុំភ្លក្សជក់គ្រឿញៀន
**ឈ** ឈានចេញដើរឲ្យប្រញាប់ **ញ** ញាប់ឲ្យឆាប់គ្រប់វិញ្ញាណ
**ដ** ដុះចំណេះមកពីរៀន **ឋ** ឋិតប្រិតប្រៀនទើបបានគាប់
**ឌ** ឌុកជក់ចិត្តខិតខំរៀន **ឍ** ឍោជាស្ពានរៀនជាទ្រព្យ
**ណ** ណេះចេះដឹងនឹងជាភ័ព្វ **ត** តបគុណជាប់ទ្រព្យវិជ្ជា ។
**ថ** ថាចំណេះជាឃ្លាំងទ្រព្យ **ទ** ទាក់ខ្ជាប់ភ័ព្វមានមុខងារ
**ធ** ធានាមានទ្រព្យគ្រាប់វិជ្ជា **ន** នាំពូជធាឲ្យសព្វគ្រប់ ។
**ប** បុណ្យកើតមានព្រោះតែសាង **ផ** ផ្លូវសំណាងកើតមិនឈប់

**ជ** ជួយខ្លួនឯងគេគោរព　　**ភ** ភ័ណ្ឌកើតគ្រប់ព្រោះគិនិត ។
**ម** មានទ្រព្យធនកុំឆ្មើងញាតិ　　**យ** យើងយោងជាតិដូចជីវិត
**រ** រំដោះ ជាតិ ពី ងងឹត　　**ល** លើកគំនិត ស្នេហាជាតិ
**វ** វឌ្ឍន៍សាងជាតិខ្មែរប្រុសស្រី　　**ស** សា ទឹក ដី កុំ វិវាទ
**ហ** ហ្លួងហែងចិត្ត ស្មោះត្រង់ជាតិ　　**ឡ អ** សាងមាតុភូមិយើង៕

# យើងកូនខ្មែរថែអក្សរជាតិ

១/យើងកូនខ្មែរស្នេហ៍អក្សរជាតិ　　ពុំរវាតយកចិត្តទុកដាក់
សរសេរខ្មែរដោយចិត្តមោទនៈ　　ចាំជាក់ច្បាស់ស្រឡាញ់អក្ខរា។
២/ព្យញ្ជនៈខ្មែរមាន៣៣　　ស្រៈ២៣ផ្សំជាអក្ខរា
ស្រៈពេញតួ១៥ទៀតណា　　វណ្ណយុត្តាច្រើនសម្បូរបែប។
៣/សញ្ញារបាទ(៌)ទណ្ឌឃាតអស្តា(៏)　　សំយោគ(័)ណាលេខទោ(ៗ)ត្រីសព្ទ(៊)
មូសិកទន្តធ្មេញកណ្តុរសម្លាប់(៉)　　រស្សៈឆាប់អានលឿនបន្តក់(់)
៤/ស្នាមចុច២យុគលពិន្ទុ(ះ)　　ភ្ជាប់រជ្ជុឬសហសញ្ញា(-)
កាកបាទបូកជើងក្អែក(៎)ទៀតណាខណ្ឌសញ្ញា(។)សួរ(?)ក្បៀស(,)ឧទាន(!)
៥/វង់ក្រចក( )　　មច្ឆណ្ឌពងត្រី(...)
អញ្ញប្រកាសន័យ(...)　　អព្ភន្តរៈ វង់តង្កៀប([])
៦/ទ្វិពិន្ទុ(៖)　　កុក្កុដនេត( )ឃ្នាប{}
លៈ(។ល។)　　អាទិសង្កេត(.)
គោមូត្រ( )　　ខណ្ឌចប់(៕)

# បំពុលសង្គម

មនុស្សខ្លះសព្វថ្ងៃ មិនសូវសំចៃ ប្រឹងជេរផ្ដាសា
មានរឿងតិចតួច មិនចេះលាក់ការ ប្រឹងវាយប្រហារ
យកឈ្នះរៀងខ្លួន។

ជំងឺចម្លែក ជំងឺតួឯក និយាយលើកខ្លួន
ខំប្រឹងខ្លាំងណាស់ ប្រឹងអួតផ្ទួនៗ ផុសអួតលើកខ្លួន
ថាឯងគ្រាន់បើ។

ខ្លះចាស់សក់ស្កូវ តែតាមមើលទៅ ចរិតក្មេងតើ
ផុសជេរឪដង ប៉ងគេសរសើរ ចង់បានគ្រាន់បើ
ចរិតមិនថ្លៃ។

ផុសហើយផុសទៀត មើលចុះមារយាទ ឥតមានតម្លៃ
ផុសវាយប្រហារ ជេរឥតសំចៃ មនុស្សនេះរាល់ថ្ងៃ
ជារោគសង្គម។

រឿងផ្ទាល់ខ្លួនសោះ ម្ដេចធ្វើឡេះឡោះ ធ្វើឥតសមរម្យ
ដើម្បីលើកខ្លួន តែពុលសង្គម ប្រឹងចងគំនុំ
មិនអប់រំចិត្ត។

មនុស្សដែលចាស់ពិត គេមានគំនិត មិនគិតប្រហារ
ស្វររកហេតុផល គិតដោះបញ្ហា ប្រឹងវាយប្រហារ
ពេលណាចប់រឿង។ ដោយ ស៊ាក់ ស៊ីន

## កំណាព្យ

ធ្វើបុណ្យឱ្យទាន់ខែភ្លឺ កុំចាំគាត់ឈឺស្លាប់មរណា
ទើបនាំបងប្អូនមកវេជា ដល់គុណរូបាអាត្មាគាត់
ធ្វើបុណ្យយ៉ាងនេះហៅខែងងឹត កាលនៅជីវិតមិនមានមាត់
ដល់ពេលស្លាប់ហើយទើបនឹកគាត់ យកធាតុដាក់វត្តឱ្យស្តាប់ធម៌
ខ្លួនម្តាយឪពុកនៅស៊ីបាន កូនចៅប៉ុន្មានមិននឹកនា
យកបាយឬទឹកម្ហូបសម្ល មិនមានត្រេកអរបូជាឡើយ
កូនអើយខ្ញុំផ្ដាំជាសតំនិត ដែលអ្នកបានគិតនៅខាងក្រោយ
បើអ្នកមានគុណនៅរស់ឡើយ កុំឱ្យស្តាយក្រោយខានបូជា

## ពុកម្តាយប្រាថ្នាប្រយោជន៍៣យ៉ាង

ឪពុកម្តាយយកកូនមកផ្ញើនឹងលោកគ្រូ គឺចង់បានប្រយោជន៍បីយ៉ាងពីលោកគ្រូដើម្បីផ្តល់ទៅកូនទៅរបស់គាត់ ៖

-ប្រយោជន៍ ទី១: ចង់ឱ្យកូនគាត់ដឹងក្តីខុសត្រូវ ទាបខ្ពស់ ល្អអាក្រក់ ។

-ប្រយោជន៍ ទី២: ចង់ឱ្យកូនគាត់មានបញ្ញា ដើម្បីបំបាត់ភាពអប្រិយថោកទាប ។

-ប្រយោជន៍ ទី៣: ចង់ឱ្យកូនចេះដឹង ដើម្បីឱ្យជួយពន្យល់ញាតិបរិស័ទ ឱ្យឆ្លងផុតពីភាពក្រីក្រ លំបាក វេទនា ក្នុងជីវិត ។

ប្រយោជន៍ បីយ៉ាងនេះហើយ លោកគ្រូៗខិតខំយកចិត្ត ទាំងយប់ថ្ងៃដើម្បីបំពេញឱ្យបានចំពោះសមណសិស្សគ្រប់ៗអង្គ។ ដោយសារការខិតខំបំពេញរហូតដល់ខ្លួនព្រះអង្គផ្ទាល់ អ្នកផងទាំងឡាយបានហៅថាជាមនុស្សគ្រោះថ្នាក់(កាច) ...។

# ពុទ្ធប្បវត្តិសង្ខេប

## មេរៀនទន្ទេញចាំមិនងាយភ្លេច និងចំណាយពេលតិច

| | | ថ្ងៃ | ខែ | ឆ្នាំ | |
|---|---|---|---|---|---|
| ១ | ចាប់ ចាប់បដិសន្ធិ | ព្រ. | អា. | រ. | |
| ២ | ប្រ. ប្រសូត្រ | សុក្រ | ពិ. | ច | |
| ៣ | កា. រៀបអភិសេក | ទិត្យ | អា. | ឆ្លូវ | |
| ៤ | គ្រង. គ្រងរាជសម្បត្តិ | សៅរ៍ | កត្តិក | ឆ្លូវ | |
| ៥ | បួស. សាងផ្នួស | ព្រ. | អា. | ថោះ | ១៥កើត |
| ៦ | ត្រាស់. ត្រាស់ជាព្រះពុទ្ធ | ពុធ | ពិ. | រ. | |
| ៧ | សង្ខារ. ដាក់អាយុសង្ខារ | អា. | មាឃ | ម្សាញ់ | |
| ៨ | និព្វាន. ចូលបរិនិព្វាន | អង្គារ | ពិ. | ម្សាញ់ | |
| ៩ | ាប់ពុទ្ធសករាជ | ពុធ១រោជ | ពិ. | ម្សាញ់ | |
| ១០ | ថ្វាយព្រះភ្លើង | ពុធ ៨រោជ | ពិ. | ម្សាញ់ | |
| *សង្ខេបដោយលោកគ្រូ ស៊ាក់ ស៊ីន វត្តស្វាយដង្គុំ ២៣/០៥/២០១៨* | | | | | |

## តារាងរាប់ទ្វារមគ្គទាំង៣០

| ភេទ | ប្រភេទ | ចំនួនទ្វារ | សរុប |
|---|---|---|---|
| ឥត្ថី | មនុស្សស្រី | ៣ | ៩ |
| | អមនុស្សស្រី | ៣ | |
| | តិរច្ឆានញី | ៣ | |
| ឧភតោព្យញ្ជនក | មនុស្ស | ៣ | ៩ |
| | អមនុស្ស | ៣ | |
| | តិរច្ឆាន | ៣ | |
| បណ្ឌក | មនុស្ស | ២ | ៦ |
| | អមនុស្ស | ២ | |
| | តិរច្ឆាន | ២ | |
| បុរិស | មនុស្សប្រុស | ២ | ៦ |
| | អមនុស្សប្រុស | ២ | |
| | តិរច្ឆានឈ្មោល | ២ | |

# ខ្នាតចីវរខណ្ឌ៥




## គំរូស្បង់

